# ការសិក្សាវាយតម្លៃលើផលប៉ះពាល់នៃសម្បទានដីសង្គមកិច្ច មកលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅតាមទីជនបទក្នុងប្រទេសកម្ពុជា




អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

សហភាពអឺរ៉ុប

*00000000145*


ចែកជូនដោយឥតគិតថ្លៃ

# ការសិក្សាវាយតម្លៃលើផលប៉ះពាល់នៃសម្បទានដីសង្គមកិច្ច
# មកលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
# នៅតាមទីជនបទក្នុងប្រទេសកម្ពុជា

# សេចក្តីថ្លែងអំណរគុណ

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅចំពោះ មន្ត្រីរដ្ឋាភិបាល បុគ្គលិកអង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធដទៃទៀត ដែលបានផ្តល់នូវព័ត៌មាន ទស្សនយោបល់សំខាន់ៗ និងសំណូមពរនានា។

សូមថ្លែងអំណរគុណជាពិសេសចំពោះប្រជាពលរដ្ឋរស់នៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំងប្រាំមួយដែលត្រូវបានស្រាវជ្រាវ ហើយដែលពួកគាត់បានព្រមព្រៀងផ្តល់បទសម្ភាសន៍សម្រាប់របាយការណ៍នេះ។

ការិយាល័យOHCHR សូមថ្លែងអំណរគុណផងដែរចំពោះ លោក Benjamin Rutledge ដែលបានរៀបចំសរសេរនូវសេចក្តីព្រាងបឋមនៃរបាយការណ៍នេះដោយផ្អែកលើការស្រាវជ្រាវដែលរៀបចំនិងដឹកនាំធ្វើឡើងដោយក្រុមហ៊ុន Angkor Research។

សៀវភៅនេះ ត្រូវបានរៀបរៀង និង បោះពុម្ពផ្សព្វផ្សាយក្រោមជំនួយឧបត្ថម្ភរបស់សហភាពអឺរ៉ុប។ ទស្សនៈ និងបទបង្ហាញនានាក្នុងអត្ថបទនេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា គឺវាមិនមែនជាការឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ ។

រូបថតក្របមុខ៖ គ្រួសារដែលទទួលបានដីនៅទីតាំងដីសម្បទានសង្គមកិច្ច ក្នុងភូមិ ស្រែលើ សែនជ័យ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ
ស្នាដៃ៖ ការិយាល័យOHCHR

រក្សាសិទ្ធិការបោះពុម្ព ឆ្នាំ ២០១៨

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំប្រទេសកម្ពុជា
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# មាតិកា


សន្ទានុក្រម ........................................................................................................ 4

ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌគតិយុត្តិជុំវិញសម្បទានដីសង្គមកិច្ច .................................................... 11

ហេតុផលដែលនាំឲ្យការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ធ្វើការសិក្សាវាយតម្លៃនេះ ........ 16

កំណត់សម្គាល់អំពីវិធីសាស្ត្រ ........................................................................................ 23

អនុសាសន៍ចំពោះតួអង្គពាក់ព័ន្ធ ................................................................................... 28

សង្ខេបលទ្ធផលរកឃើញជារួមនៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦ ........................................ 35

ឧបសម្ព័ន្ធទី ១៖ ទិន្នន័យអង្កេតពីសម្បទានដីសង្គមកិច្ចក្នុងឃុំរស្មីសាមគ្គី ស្រុក ឱរ៉ាល់ ខេត្តកំពង់ស្ពឺ ..................... 72

ឧបសម្ព័ន្ធទី ២៖ ទិន្នន័យអង្កេតពីសម្បទានដីសង្គមកិច្ច ក្នុងឃុំបឹងប្រាំ ស្រុកបវេល ខេត្តបាត់ដំបង...................... 92

ឧបសម្ព័ន្ធទី ៣៖ ទិន្នន័យអង្កេតពីសម្បទានដីសង្គមកិច្ចក្នុងភូមិស្រែលើសែនជ័យ ឃុំដាក្រញ៉ុំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ
............................................................................................................ 115

ឧបសម្ព័ន្ធទី ៤៖ ទិន្នន័យអង្កេតពីសម្បទានដីសង្គមកិច្ចភូមិបឹងខ្នុរ ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ.................. 137

ឧបសម្ព័ន្ធទី ៥៖ ទិន្នន័យអង្កេតពីសម្បទានដីសង្គមកិច្ចក្នុងភូមិពូលុ  ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ......... 155

ឧបសម្ព័ន្ធទី ៦៖ ទិន្នន័យអង្កេតពីសម្បទានដីសង្គមកិច្ចនៅឃុំត្រពាំងធ្លាំង ស្រុកឈូក ខេត្តកំពត ....................... 175

## សន្ទានុក្រម

**លំនៅឋានសមរម្យ (Adequate Housing)** – គណៈកម្មាធិការសហប្រជាជាតិទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានកំណត់ថា សិទ្ធិមានលំនៅឋានសមរម្យមិនគួរត្រូវបានគេបកស្រាយតាមន័យចង្អៀត ឬន័យរិតត្បិត ជាឧទាហរណ៍ ស្មើនឹងទីជម្រកដែលគ្រាន់តែមានដំបូលប្រក់ពីលើក្បាលរបស់មនុស្សម្នាក់ ឬចាត់ទុកគ្រាន់តែជាទំនិញដោះដូរនោះទេ។ ផ្ទុយទៅវិញ សិទ្ធិនេះគួរត្រូវបានគេចាត់ទុកថាជាសិទ្ធិរស់នៅកន្លែងណាមួយប្រកបដោយសន្តិសុខ សន្តិភាព និងសេចក្តីថ្លៃថ្នូរ។ ខណៈពេលដែលពាក្យថាសមរម្យ ត្រូវបានកំណត់មួយផ្នែកដោយកត្តាសង្គម សេដ្ឋកិច្ច វប្បធម៌ អាកាសធាតុ បរិស្ថាន និងកត្តាផ្សេងទៀត គណៈកម្មាធិការនេះបានកំណត់នូវទិដ្ឋភាពមួយចំនួននៃសិទ្ធិនេះ ដែលគេត្រូវយកមកពិចារណាសម្រាប់គោលបំណងនេះ ទោះជាក្នុងកាលៈទេសៈណាក៏ដោយ។ ទិដ្ឋភាពទាំងនេះមាន៖ (ក) សុវត្ថិភាពក្នុងការកាន់កាប់ស្របច្បាប់ (ខ) ភាពអាចទទួលបាននូវសេវាកម្ម សម្ភារៈ បរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ (គ) ភាពអាចលៃលកបាន (ឃ) ភាពអាចរស់នៅបាន (ង) ភាពអាចទៅប្រើប្រាស់បាន (ច) ទីតាំង (ឆ) ភាពសមរម្យខាងវប្បធម៌។[1]

**កម្រិតជីវភាពសមរម្យ (Adequate standard of living)** - មាត្រា ១១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ចែងថា មនុស្សគ្រប់រូបមានសិទ្ធិ "មានកម្រិតជីវភាពសមរម្យសម្រាប់ខ្លួនឯង និងក្រុមគ្រួសាររបស់ខ្លួន" រាប់បញ្ចូលទាំងការមាន ចំណីអាហារ សម្លៀកបំពាក់ លំនៅឋានសមរម្យ និងការកែលំអលក្ខខណ្ឌនៃការរស់នៅជាបន្តបន្ទាប់។ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានចេញនូវសេចក្តីពន្យល់ទូទៅជាច្រើនអំពីធាតុផ្សំនៃសិទ្ធិនេះ ដូចជា សិទ្ធិមានលំនៅឋានសមរម្យ (សេចក្តីពន្យល់ទូទៅលេខ ៤ និង ៧) សិទ្ធិទទួលបានចំណីអាហារ (សេចក្តីពន្យល់ទូទៅលេខ ១២) សិទ្ធិទទួលបានទឹកស្អាត (សេចក្តីពន្យល់ទូទៅលេខ ១៥) ក៏ដូចជាសិទ្ធិទទួលបានសន្តិសុខ

[1] យោបល់លេខ ៤ នៃគណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ៖ សិទ្ធិមានលំនៅឋានសមរម្យ (មាត្រា ១១ (១) នៃកតិកាសញ្ញានេះ) អនុម័តក្នុងសម័យប្រជុំលើកទី ៦ របស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កាលពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩១។

សង្គម (សេចក្ដីពន្យល់ទូទៅលេខ ១៩)។ សិទ្ធិមានកម្រិតជីវភាពសមរម្យ ត្រូវបានដាក់បញ្ចូលក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើនផ្សេងទៀត។

**សេវាជាមូលដ្ឋាន (Basic services)** – ពាក្យនេះសំដៅលើសេវាជាមូលដ្ឋាន (ដូចជា អគ្គិសនី ទឹក សេវាអនាម័យ សុខភាព និងអប់រំ) ដែលគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះត្រូវការ ដើម្បីអាចអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនបាន។ ក្នុងអនុក្រឹត្យស្ដីពី សម្បទានដីសង្គមកិច្ច (២០០៣) ការវាយតម្លៃលើហេដ្ឋារចនាសម្ព័ន្ធដែលមានចាំបាច់សម្រាប់អនុវត្តផែនការសម្បទានដីសង្គមកិច្ច គួរមានដូចជា "ផ្លូវ ទឹក អគ្គិសនី សាលារៀន ផ្សារ មណ្ឌលសុខភាព ឧបករណ៍ និងបរិក្ខារផ្សេងៗ សម្រាប់អភិវឌ្ឍន៍ដី និងសេវាផ្សេងទៀត"។

CDHS - ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា។

ELC –សម្បទានដីសេដ្ឋកិច្ច - យោងតាមច្បាប់ភូមិបាល (២០០១) សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច អាចត្រូវបានផ្ដល់ ដើម្បីអនុញ្ញាតឲ្យ "អ្នកទទួលផលកាប់ឆ្ការ ទាញយកផលដោយធ្វើអាជីវកម្មកសិឧស្សាហកម្មលើដីនៃព្រះរាជាណាចក្រកម្ពុជា"។

FAO - អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។

**សន្តិសុខស្បៀង (Food Security)** – សិទ្ធិទទួលបានអាហារ មានចែងក្នុងកតិកាសញ្ញាស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឆ្នាំ ១៩៦៦។ បើតាមអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (ហៅកាត់ថា FAO) សន្តិសុខស្បៀងកើតមាន "នៅពេលដែលមនុស្សគ្រប់រូប នៅគ្រប់ពេលទាំងអស់ មានលទ្ធភាពខាងផ្នែករូបវន្តសង្គម និងសេដ្ឋកិច្ច ដើម្បីទទួលបានអាហារក្នុងបរិមាណគ្រប់គ្រាន់ ប្រកបដោយសុវត្ថិភាព និងមានសារធាតុចិញ្ចឹម ដែលបំពេញនូវតម្រូវការអាហារ និងចំណង់ចំណូលចិត្តក្នុងការបរិភោគរបស់ពួកគេ ដើម្បីមានជីវិតរស់នៅពោរពេញដោយភាពរស់រវើក និងសុខភាពរឹងមាំ។"[2] សន្តិសុខស្បៀងគឺជាលក្ខខណ្ឌជាមុនដើម្បីសម្រេចបានដោយពេញលេញនូវសិទ្ធិទទួលបានចំណីអាហារ។

[2] អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ (FAO), ស្ថានភាពអសន្តិសុខស្បៀងនៅលើពិភពលោក ឆ្នាំ ២០០១ (ទីក្រុងរ៉ូម ឆ្នាំ២០០១)

តាមច្បាប់សិទ្ធិមនុស្ស មនុស្សគ្រប់រូប មិនថាពួកគេមានសាវតា ស្ថានភាព យេនឌ័រ ឬជាតិពន្ធុបែបណានោះទេ សុទ្ធតែមានសិទ្ធិទទួលបានអាហារគ្រប់គ្រាន់ និងសិទ្ធិរួចផុតពីគ្រោះអត់ឃ្លាន។

GTZ - Deutsche Gesellschaft für Technische Zusammenarbeit GmbH (ភាសាអាល្លឺម៉ង់៖ ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស) បច្ចុប្បន្ន ហៅថា GIZ - Deutsche Gesellschaft für Internationale Zusammenarbeit

ICCPR - កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ICESCR – កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ID Poor Programme) - កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដឹកនាំដោយក្រសួងផែនការនៃរាជរដ្ឋាភិបាលកម្ពុជា

OHCHR – ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស

**អ្នកគ្មានដីធ្លី (Landlessness)** - សំដៅលើអ្នកដែលពុំមានដីជាកម្មសិទ្ធិ សម្រាប់ធ្វើស្រែចម្ការ ឬអ្នកដែលត្រូវបានរារាំងមិនឲ្យធ្វើជាម្ចាស់កម្មសិទ្ធិលើដីដែលពួកគេប្រើប្រាស់ជាបណ្តោះអាសន្ន។ អ្នកគ្មានដីធ្លី អាចជាបុគ្គល ឬគ្រួសារដែលត្រូវបានបណ្តេញចេញពីដីធ្លី ឬអ្នកដែលបានបាត់បង់ដីធ្លី ដោយសារគ្រោះមហន្តរាយធម្មជាតិ ។

**ការចុះបញ្ជីដីធ្លី (Land registration)** – ការកត់ត្រាសិទ្ធិលើដីធ្លី ក្នុងទម្រង់ជាការចុះបញ្ជីជាសាធារណៈ ដូចជា ក្នុងប្រព័ន្ធទិន្នន័យសុរិយោដី ដែលអាចបែងចែកជាប័ណ្ណកម្មសិទ្ធិ។ នេះអាចជាឯកសារដែលចេញដោយស្ថាប័នណាមួយរបស់រដ្ឋាភិបាល ដែលមានបញ្ចូលព័ត៌មានស្តីពី សិទ្ធិលើដីធ្លី ទីតាំងដី និងអ្នកកាន់កាប់ដី។ ការចុះបញ្ជីដីអាចធ្វើតាមក្បាលដី ឬធ្វើផ្អែកទៅតាមអ្នកកាន់កាប់ ឬឯកសារផ្ទេរកម្មសិទ្ធិ។

LMAP - គម្រោងគ្រប់គ្រង និងរដ្ឋបាលដីធ្លី

(LASED)- គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

អាជ្ញាធរមូលដ្ឋាន (Local Authorities) - ជាពាក្យប្រើក្នុងរបាយការណ៍នេះ ដើម្បីសំដៅលើមេភូមិ មេឃុំ និងមន្ត្រីនៅថ្នាក់មូលដ្ឋានផ្សេងៗទៀត។ គេមិនគួរសន្មត់ថា បុគ្គលទាំងនេះគឺជាមន្ត្រីនៅថ្នាក់ស្រុក ថ្នាក់ខេត្ត ឬមន្ត្រីផ្សេងទៀត ដែលទទួលខុសត្រូវអនុវត្តដំណើរការសម្បទានដីសង្គមកិច្ចឡើយ។ ឈ្មោះ និងមុខតំណែងជាក់លាក់ ត្រូវបានលុបចោល ដើម្បីការពារអត្តសញ្ញាណរបស់អ្នកឆ្លើយតបចំពោះការអង្កេតនេះ។

MLMUPC - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

NGO – អង្គការមិនមែនរដ្ឋាភិបាល

NSDP - ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

គ្រួសារក្រីក្រ (Poor families/households) – អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដូចដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (២០១១) សំដៅលើការកំណត់គ្រួសារក្រីក្រ កម្រិតនៃភាពក្រីក្ររបស់គ្រួសារទាំងនេះ និងអត្រានៃភាពក្រីក្រតាមតំបន់។ បើតាមអនុក្រឹត្យនេះ អត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវបានធ្វើឡើង ដោយផ្អែកជាចម្បងលើការសម្ភាសន៍ប្រជាពលរដ្ឋតាមគ្រួសារ (រៀបចំដោយក្រសួងផែនការ)។ កម្រងសំណួរមានបញ្ចូលសូចនាករស្តីពីភាពក្រីក្រជាច្រើន ដូចជា ស្ថានភាពលំនៅឋាន ទំហំដីលំនៅឋាន និងដីប្រើប្រាស់សម្រាប់ផលិតកម្មកសិកម្ម ប្រភពចំណូល សន្តិសុខស្បៀង ចំនួនសមាជិកគ្រួសារដែលមិនអាចរកចំណូលបាន ធៀបជាមួយនឹងចំនួនសមាជិកសរុបក្នុងផ្ទះ ទំនិញនិងបរិក្ខារសំខាន់ៗ មធ្យោបាយធ្វើដំណើរ ចំនួនកុមារអាយុពី ៦ ដល់ ១១ ឆ្នាំ ដែលមិនបានទៅរៀន និងកត្តាពាក់ព័ន្ធផ្សេងទៀតជាច្រើន។ គួរមានការរៀបចំកិច្ចពិគ្រោះយោបល់ជាមួយនឹងសមាជិកសហគមន៍ និងអាជ្ញាធរមូលដ្ឋានផងដែរ។

ប្រកាស (Prakas) - បញ្ញារដ្ឋបាល ឬប្រកាស - ប្រកាសគឺជាសេចក្តីសម្រេចថ្នាក់ក្រសួង ឬអន្តរក្រសួង ដែលចុះហត្ថលេខាដោយក្រសួងណាមួយ។ បើតាមឋានានុក្រមនៃក្របខណ្ឌច្បាប់ និងគោលនយោបាយរបស់កម្ពុជា ប្រកាសកើតចេញពីច្បាប់ ឬអនុក្រឹត្យ ហើយត្រូវអនុលោមទៅតាមច្បាប់ ឬអនុក្រឹត្យនោះ។

**PSIA** - ការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គមនៃកម្មវិធីសម្បទានដីសង្គមកិច្ចដែលមានក្នុងផែនការរបស់ប្រទេសកម្ពុជា។

**ដីលំនៅឋាន (Residential land)** – បើតាមអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (២០០៣) អ្នកសុំដីសម្បទានសង្គមកិច្ច ត្រូវកំណត់ថាតើការស្នើសុំដី ធ្វើឡើង សម្រាប់ធ្វើជាដីលំនៅឋាន ឬសម្រាប់បង្កបង្កើនផលជាលក្ខណៈគ្រួសារ ឬសម្រាប់គោលបំណងទាំងពីរ។ អនុក្រឹត្យនេះកំណត់ថា ប្រសិនបើពុំមានសំណង់លំនៅឋានលើដីសម្បទានសង្គមកិច្ចសម្រាប់សង់លំនៅឋាន មុខសញ្ញាទទួលដីត្រូវសង់យ៉ាងហោចណាស់ផ្នែកណាមួយនៃទីជម្រកអចិន្ត្រៃយ៍មិនឲ្យហួសពី ៣ ខែ ក្រោយពេលទទួលបានដីរួច ហើយសមាជិកគ្រួសារណាម្នាក់ត្រូវរស់នៅជាក់ស្តែង និងជាអចិន្ត្រៃយ៍លើដីនេះឲ្យបានយ៉ាងហោចណាស់ ៦ ខែក្នុងឆ្នាំនីមួយៗ”។ នេះគឺជាលក្ខខណ្ឌមួយ ដែលត្រូវបំពេញឲ្យបាន ដើម្បីរក្សាសិទ្ធិភោគៈលើ “ដីលំនៅឋាន” និងដើម្បីអាចទទួលបានប័ណ្ណកម្មសិទ្ធិ។ ដីលំនៅឋាន អាចត្រូវបានគេឲ្យនិយមន័យទូលំទូលាយថាជាក្បាលដីដែលមានគ្រួសារមួយ ឬច្រើនរស់នៅ ឬក្បាលដីទំនេរដែលត្រូវបានបែងចែកជាតំបន់ ឬបែងចែកសម្រាប់គោលបំណងសង់លំនៅឋាន ក្នុងអនុក្រឹត្យ ឬដំណើរការរៀបចំផែនការណាមួយ ដូចមានចែងក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចជាដើម។

**SLC** – សម្បទានដីសង្គមកិច្ច - យោងតាមច្បាប់ភូមិបាល (២០០១) សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សង្គម អនុញ្ញាតឲ្យអ្នកទទួលប្រយោជន៍រៀបចំដី ដើម្បីសង់លំនៅឋាន និង/ឬដាំដំណាំលើដី ដែលជាកម្មសិទ្ធិរបស់រដ្ឋ ដើម្បីធានាការចិញ្ចឹមជីវិត។

**ការវាយតម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថាន (Social and Environmental Impact Assessments)** –ការវាយតម្លៃផ្តោតលើហានិភ័យបង្កឡើងដោយគម្រោងអភិវឌ្ឍន៍ និងកំណត់ថាតើគេគួរគ្រប់គ្រងហានិភ័យទាំងនេះយ៉ាងដូចម្តេច ដើម្បីសម្រេចនូវលទ្ធផលរំពឹងទុក ហើយក្នុងពេលជាមួយគ្នាអាចកាត់បន្ថយផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថានឬសង្គម។ យោងតាមក្របខ័ណ្ឌច្បាប់របស់កម្ពុជា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គឺជា

លក្ខខណ្ឌជាមុនដ៏សំខាន់ និងចាំបាច់សម្រាប់ផ្តល់សម្បទានដី។[3] ឧទាហរណ៍៖ មាត្រា ៩ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចចែងថា នេះគឺជាផ្នែកដែលចាំបាច់ត្រូវតែមានក្នុងដំណើរការរៀបចំផ្តល់សម្បទានដីសង្គមកិច្ច។

**ដីសាធារណៈរបស់រដ្ឋ (State public land)** - យោងតាមច្បាប់ភូមិបាល (២០០១) ដីរដ្ឋបែងចែកជាពីរប្រភេទ៖ ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ យោងតាមមាត្រា ១៥ នៃច្បាប់ភូមិបាល (២០០១) និងអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ ២០០៥ ដីសាធារណៈរបស់រដ្ឋជាដីដែលប្រើប្រាស់សម្រាប់ប្រយោជន៍សាធារណៈ ហើយរាប់បញ្ចូលធនធានធម្មជាតិនានាដូចជា ព្រៃឈើ ទន្លេ បឹងធម្មជាតិ ដែនបម្រុងធម្មជាតិការពារដោយច្បាប់ បេតិកភ័ណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ។ ដីសាធារណៈរបស់រដ្ឋមិនអាចលក់ ឬផ្ទេរបានឡើយ ហើយមិនអាចជាកម្មវត្ថុនៃដីសម្បទានសេដ្ឋកិច្ច ឬសង្គមកិច្ចឡើយ។[4]

**ដីឯកជនរបស់រដ្ឋ (State Private Land)** - ប្រសិនបើដីសាធារណៈរបស់រដ្ឋបាត់បង់តម្លៃប្រើប្រាស់សម្រាប់ប្រយោជន៍សាធារណៈ វាអាចក្លាយជាដីឯកជនរបស់រដ្ឋ ដែលអាចប្រើសម្រាប់គោលបំណងផ្សេងទៀត ដូចជា សម្រាប់ជាសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ចជាដើម ហើយអាចជួលរយៈពេលវែងផងដែរ។ យោងតាមមាត្រា ១៦ នៃច្បាប់ភូមិបាល ដីសាធារណៈរបស់រដ្ឋ អាចក្លាយជាដីឯកជនរបស់រដ្ឋបានតែតាមរយៈការធ្វើអនុបយោគផ្លូវការ ស្របតាមច្បាប់ស្តីពីការផ្ទេរទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋប៉ុណ្ណោះ។[5]

**អនុក្រឹត្យ (Sub Decree)** - អនុក្រឹត្យ ត្រូវបានប្រើដើម្បីបញ្ជាក់ឲ្យបានច្បាស់ពីបញ្ញត្តិក្នុងច្បាប់ដែលកំពុងចូលជាធរមាន និងអាចកំណត់ពីមុខងារ និងភារកិច្ចរបស់ស្ថាប័នរដ្ឋ តែងតាំងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ឬធ្វើអនុបយោគដីជាដើម។ ការព្រាងអនុក្រឹត្យធ្វើឡើងតាមក្រសួង

[3]ការវិភាគផ្អែកលើសិទ្ធិមនុស្សអំពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានគោលដៅផ្សេងទៀតនៅព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាសិទ្ធិមនុស្ស A/HRC/21/63/Add.1. 2012.

[4] ដូចគ្នានឹងប្រភពខាងលើ

[5]ដូចគ្នានឹងប្រភពខាងលើ

ពាក់ព័ន្ធ និងអនុម័តដោយគណៈរដ្ឋមន្ត្រី។ អនុក្រឹត្យក៏គួរទទួលបានការឯកភាពពីនាយករដ្ឋមន្ត្រីផងដែរ។

**សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី (Tenure Security)** – ការកាន់កាប់ដីធ្លី គឺជាទំនាក់ទំនងរវាងមនុស្ស ក្នុងនាមជាបុគ្គល ឬក្រុម ពាក់ព័ន្ធជាមួយនឹងដីធ្លី មិនថាកំណត់ដោយច្បាប់ ឬដោយប្រពៃណីនោះទេ។ សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី គឺជាភាពប្រាកដប្រជានៃសិទ្ធិលើដីរបស់បុគ្គលណាម្នាក់ ដែលនឹងត្រូវបានអ្នកផ្សេងទៀតទទួលស្គាល់ និងត្រូវបានការពារ ក្នុងករណីជួបនឹងបញ្ហាប្រឈមណាមួយ។ បុគ្គលដែលមិនមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីប្រឈមនឹងហានិភ័យនៃការគំរាមកំហែងចំពោះសិទ្ធិលើដីធ្លីរបស់ពួកគេ ពីការទាមទារប្រជែងយកដីនោះ ហើយអាចនឹងបាត់បង់ដីធ្លី ដោយសារតែការបណ្តេញចេញ។[6]

**UNICEF** - មូលនិធិសហប្រជាជាតិដើម្បីកុមារ

**WHO** - អង្គការសុខភាពពិភពលោកនៃសហប្រជាជាតិ

[6] ការកាន់កាប់ដីធ្លី និងការអភិវឌ្ឍជនបទ។ ការសិក្សាពីការកាន់កាប់ដីធ្លី អង្គការ FAO។ ឆ្នាំ ២០០២។

## និន្នាការទូទៅនៃក្របខ័ណ្ឌគតិយុត្តិជុំវិញសម្បទានដីសង្គមកិច្ច

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣) ធានាសិទ្ធិលើទ្រព្យសម្បត្តិឯកជន ដោយរាប់បញ្ចូលការផ្តល់កម្មសិទ្ធិពេញលេញលើដី/ទ្រព្យសម្បត្តិដល់ពលរដ្ឋខ្មែរ។ ច្បាប់ភូមិបាលកម្ពុជា (២០០១) ជាច្បាប់ដែលចែង និងគ្រប់គ្រងលើដំណើរការរដ្ឋបាល និងគ្រប់គ្រងដីធ្លី។ ច្បាប់ភូមិបាលចែងថា សម្បទានដីអាចត្រូវបានផ្តល់ ដើម្បីប្រយោជន៍សង្គមកិច្ច ដែលជាយន្តការច្បាប់ អនុញ្ញាតឲ្យមានការផ្ទេរដីឯកជនរបស់រដ្ឋដល់បុគ្គលឯកជន ឬក្រុម ដើម្បីបម្រើប្រយោជន៍សង្គម សម្រាប់សង់លំនៅឋាន និងបង្កបង្កើនផលជាលក្ខណៈគ្រួសារ។ សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សង្គម*អនុញ្ញាតឲ្យអ្នកទទួលប្រយោជន៍រៀបចំដី ដើម្បីសង់លំនៅឋាន ឬ/និងដាំដំណាំលើដី ដែលជាកម្មសិទ្ធិរបស់រដ្ឋ ដើម្បីធានាការចិញ្ចឹមជីវិត។*[7]

រដ្ឋាភិបាលបានបោះជំហានទៅមុខដ៏សំខាន់មួយ ក្នុងការឆ្លើយតបចំពោះបញ្ហានៃអ្នកគ្មានដីធ្លី និងបញ្ហាភាពក្រីក្រនៅតំបន់ជនបទ ក្នុងប្រទេសកម្ពុជា តាមរយៈបទប្បញ្ញត្តិទាំងនេះ ក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ និងតាមរយៈការអនុម័តលើអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចដែលត្រូវបានចេញក្នុងខែមីនា ឆ្នាំ២០០៣។ អនុក្រឹត្យនេះដាក់ចេញនូវមូលដ្ឋានសម្រាប់បែងចែកដីឯកជនរបស់រដ្ឋ ដល់គ្រួសារគ្មានដី និងគ្រួសារខ្វះខាតដី និងក្រុមផ្សេងទៀត។ មាត្រា ២ នៃអនុក្រឹត្យនេះគូសបញ្ជាក់ថា សម្បទានដីសង្គមកិច្ច គឺជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋសម្រាប់ប្រយោជន៍សង្គមកិច្ចដល់ជនក្រីក្រដែលខ្វះខាតដី សម្រាប់សង់លំនៅឋាន និង/ឬធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

យោងតាមអនុក្រឹត្យនេះ សម្បទានដីសង្គមកិច្ច អាចប្រើសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋដល់អតីតយុទ្ធជន ផ្តល់ដីសម្រាប់គ្រួសារដែលបាត់បង់ទីលំនៅដោយសារគ្រោះមហន្តរាយធម្មជាតិ ឬគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬសម្រួលដល់ការអភិវឌ្ឍសម្បទានដីសេដ្ឋកិច្ច តាមរយៈការផ្តល់ដីដល់កម្មករ។[8] ផ្ទុយទៅវិញ ការផ្តល់សម្បទានដី

[7] ច្បាប់ភូមិបាល ២០០១ មាត្រា ៥៩។

[8] អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣) មាត្រា ៣។

សេដ្ឋកិច្ចធ្វើឡើងសម្រាប់កាប់ឆ្ការដី ដើម្បីអភិវឌ្ឍកសិឧស្សាហកម្ម។ អនុក្រឹត្យនេះដាក់ចេញនូវលក្ខខណ្ឌ សម្រាប់រៀបចំផែនការសម្បទានដីសង្គមកិច្ច ការបង្កើតនិងការអភិវឌ្ឍ ហើយប្រកាសស្តីពីគោលការណ៍ណែនាំសម្រាប់អនុវត្តអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (២០០៣) [9] ចែងលំអិតពីជំហានដែលចាំបាច់ សម្រាប់អនុវត្ត។ អនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ (២០០៥) ចែងពីការចុះបញ្ជី ប្រភេទ និងអនុបយោគដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។

ច្បាប់ភូមិបាលឆ្នាំ២០០១ កំណត់ថា៖ អនុក្រឹត្យដោយឡែកសម្រាប់សម្បទានដីសង្គមកិច្ចនីមួយៗត្រូវតែបានចេញនៅមុនការចូលកាន់កាប់ ឬដាំដុះលើដីនោះ។ សម្បទានដីនេះត្រូវតែចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីកំណត់ជាដីសម្បទានសង្គមកិច្ចបាន។[10] ច្បាប់ភូមិបាល និងអនុក្រឹត្យនេះចែងថា សម្បទានដីសង្គមកិច្ចអាចផ្តល់បានតែលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋប៉ុណ្ណោះ និងបានចែងផងដែរថា ការកាន់កាប់ដីរដ្ឋជាក់ស្តែងមិនអាចនាំឲ្យមានការផ្តល់ដីសម្បទានបានឡើយ។[11] ការទទួលខុសត្រូវលើការអនុវត្ត ត្រូវបានចែករំលែករវាងអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៃក្រសួងមហាផ្ទៃ។

យោងតាមអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច សម្បទានដីសង្គមកិច្ចអាចជាកម្មវិធីនៅថ្នាក់មូលដ្ឋាន ឬកម្មវិធីថ្នាក់ជាតិ។ ប្រជាពលរដ្ឋម្នាក់ ឬច្រើននាក់ ឬអង្គការមួយ ឬច្រើនដែលធ្វើការងារជាមួយ ឬតំណាងឲ្យប្រជាពលរដ្ឋក្នុងឃុំណាមួយ អាចផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចនៅមូលដ្ឋាន តាមរយៈក្រុមប្រឹក្សាឃុំសង្កាត់ នៃឃុំសង្កាត់ ដែលដីសម្បទានសង្គមកិច្ចនោះឋិតនៅ។ ដោយឡែក កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចត្រូវបានផ្តួចផ្តើមឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធមួយ ឬច្រើន ក្នុងករណីដូចតទៅ i)

[9] ប្រកាសស្តីពីគោលការណ៍ណែនាំស្តីពីការអនុវត្តអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច លេខ ២០០ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៣។

[10] ច្បាប់ភូមិបាល ២០០១ មាត្រា ៥៣។

[11] អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣) ជំពូកទី ២ និងទី ៣។

កន្លែងដែលមានកម្មវិធីអភិវឌ្ឍន៍ដីនៅតំបន់ដាច់ស្រយាល ដែលពុំទាន់មានប្រជាជនមូលដ្ឋានគ្រប់គ្រាន់ដើម្បីអភិវឌ្ឍដីនោះ ii) កន្លែងដែលមានកម្មវិធីតាំងទីលំនៅថ្មីសម្រាប់គ្រួសារច្រើន ដូចជា អ្នកតាំងទីលំនៅតាមសំណង់បណ្ដោះអាសន្នតាមទីប្រជុំជន ឬគ្រួសារដែលត្រូវផ្លាស់ប្ដូរទីកន្លែង iii) កន្លែងដែលមានកម្មវិធីសម្បទានដីសង្គមកិច្ច អាចផ្សារភ្ជាប់ទៅនឹងសម្បទានដីសេដ្ឋកិច្ច ដើម្បីអភិវឌ្ឍកសិឧស្សាហកម្ម ឬ iv) កន្លែងដែលមានកម្មវិធីអភិវឌ្ឍន៍ថ្មី ឬមានកម្មវិធីអភិវឌ្ឍន៍ស្រាប់។

គណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់ខេត្ត/ក្រុងអាចផ្ដល់ការសម្រេចយល់ព្រមលើផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ប្រសិនបើផែនការសម្បទានដីសង្គមកិច្ចនោះត្រឹមត្រូវតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ដោយអនុក្រឹត្យស្ដីពីសម្បទានដីសង្គមកិច្ច និងប្រសិនបើគេសម្រេចថា ដីនោះជាដីឯកជនរបស់រដ្ឋដែលនៅទំនេរ ហើយសមស្របសម្រាប់ផែនការសម្បទានដីសង្គមកិច្ច។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/ក្រុង ត្រូវជូនដំណឹងដល់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិអំពីផែនការនីមួយៗ ដែលបានសម្រេចយល់ព្រម។ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិអាចពិនិត្យកែសម្រួលផែនការ ឬលុបចោលសេចក្ដីសម្រេចយល់ព្រម ប្រសិនបើ (ក) ផែនការសម្បទានដីសង្គមកិច្ចនោះមិនស្របនឹងអាទិភាពនៃការប្រើប្រាស់ដីថ្នាក់ជាតិ មានកំហុសបច្ចេកទេស ឬរំលោភបទប្បញ្ញត្តិទាំងឡាយនៃអនុក្រឹត្យនេះ ឬច្បាប់ផ្សេងទៀត ឬ (ខ) ប្រសិនបើផែនការនេះមិនស្របនឹងលក្ខខណ្ឌចាំបាច់ នៃកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ។[12]

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដែលមានក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ជាប្រធាន អាចផ្ដល់ការយល់ព្រមលើផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិដែលបានស្នើឡើងឬពិគ្រោះយោបល់ជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធទៅតាមការចាំបាច់។ ក្រសួងនេះក៏អាចពិនិត្យកែសម្រួលផែនការនេះផងដែរ។ កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដែលបានទទួលការសម្រេចយល់ព្រមរួចហើយ ត្រូវអនុវត្ត

[12]អនុក្រឹត្យស្ដីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣) មាត្រា ៥ និង ៦។

ដោយក្រសួងស្ថាប័ន តាមការកំណត់ក្នុងផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដោយមានការសម្របសម្រួលជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង ក្រុមប្រឹក្សាឃុំសង្កាត់ និងប្រជាពលរដ្ឋនៅក្នុងតំបន់ពាក់ព័ន្ធ លើកលែងតែកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិចែងផ្សេងពីនេះ។[13]

អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចកំណត់ពីទំហំអតិបរមានៃដីសម្បទានដែលផ្តល់សម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ មានទំហំធំបំផុត ២ ហិកតា ប៉ុន្តែអាចដំឡើងរហូតដល់ ៥ ហិកតា "អាស្រ័យតាមលក្ខណៈដី សក្តានុពលដី ឬប្រភេទដំណាំ និងកម្លាំងពលកម្មរបស់គ្រួសារអ្នកសុំដី"។[14] អនុក្រឹត្យនេះក៏បានចែងផងដែរថា អ្នកទទួលដីត្រូវបំពេញទៅតាមលក្ខណៈវិនិច្ឆ័យផ្អែកហិរញ្ញវត្ថុដែលកំណត់ក្នុងប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។ គោលការណ៍ណែនាំស្តីពីចំណូលត្រូវគិតគូរពីទំហំគ្រួសារ អាយុ និងសុខភាពរបស់សមាជិកគ្រួសារ។

ក្នុងឆ្នាំ ២០០៥ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ក្រសួងផែនការបានរៀបចំនូវកម្រងសំណួរ និងនីតិវិធីស្តង់ដាដើម្បីធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅតំបន់ជនបទ។ ការជ្រើសរើសគ្រួសារទទួលបានសម្បទានដីសង្គមកិច្ច ត្រូវបានធ្វើឡើងដោយប្រើប្រាស់យន្តការដែលមានតម្លាភាព និងដំណើរការជ្រើសរើសដោយមានការចូលរួមដែលមានបញ្ចូល "ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ" និងកម្មសិទ្ធិដីបច្ចុប្បន្នរបស់គ្រួសារទាំងនោះ។[15] ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានដាក់ឲ្យអនុវត្តជាផ្លូវការ តាមរយៈអនុក្រឹត្យលេខ ២៩១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលបានចេញដោយក្រសួងផែនការ ក្នុងឆ្នាំ ២០១១។ អនុក្រឹត្យនេះ ដាក់ចេញនូវនីតិវិធី និងចែងពីរបៀបការធ្វើ

[13]អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣) មាត្រា ៧ និង ៨។

[14]អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣) មាត្រា ១៧។

[15] មេរៀនដែលទទួលបាន បទពិសោធន៍នៃការអនុវត្តសម្បទានដីសង្គមកិច្ច ក្នុងប្រទេសកម្ពុជា ដោយ Iris Richter ខែ មករា ឆ្នាំ ២០១៦។

អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងរបៀបប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ។[16] មាត្រា១៧ ចែងថា ស្ថាប័ន/ក្រសួងរដ្ឋាភិបាលដែលពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ដែលមានបំណងផ្តល់សេវា ឬជំនួយទៅដល់គ្រួសារក្រីក្រ ឬបុគ្គលក្រីក្រ រាប់ទាំងកិច្ចអន្តរាគមន៍សង្គ្រោះបន្ទាន់សមស្របណាមួយ ត្រូវតែប្រើប្រាស់ជាបឋមនូវទិន្នន័យគ្រួសារក្រីក្រថ្នាក់ជាតិដែលមានសុពលភាពនេះ។ បើទោះបីជាអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចពុំបានចែងច្បាស់ថា ត្រូវតែប្រើប្រាស់ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីកំណត់មុខសញ្ញាទទួលសម្បទានដីសង្គមកិច្ចក៏ដោយ (អនុក្រឹត្យនេះត្រូវបានចេញក្នុងឆ្នាំ២០០៣ មុនពេលមានគម្រោងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ) ប្រព័ន្ធនេះត្រូវបានប្រើប្រាស់ជាបន្តបន្ទាប់ ជាមធ្យោបាយចម្បងសម្រាប់កំណត់រកគ្រួសារក្រីក្រ ដោយប្រើប្រាស់ដំណើរការដែលមានការចូលរួម និងតម្លាភាព ហើយចាប់តាំងពីពេលនោះមកដល់បច្ចុប្បន្ន រដ្ឋាភិបាលបានប្រកាសថា អត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាវិធីសាស្ត្រកំណត់មុខសញ្ញាជាចម្បង ដែលត្រូវប្រើប្រាស់ក្នុងកម្មវិធីគាំពារសង្គម។[17] ដូច្នេះ វាជាសមាសភាពមួយសំខាន់នៃកម្មវិធីសម្បទានដីសង្គមកិច្ច។

---

[16] អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រលេខ ២៩១ អនក្រ.បក ទទួលបានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ កាលពីថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១១។

[17] សូមមើលយុទ្ធសាស្ត្រជាតិគាំពារសង្គម ២០១១-២០១៥ អនុម័តដោយគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១។ យុទ្ធសាស្ត្រជាតិគាំពារសង្គមចែងថា "រាជរដ្ឋាភិបាលមានបំណងយកអត្តសញ្ញាណកម្មគ្រួសារក្រីក្រមកប្រើប្រាស់ជាវិធីសាស្ត្រកំណត់មុខសញ្ញាអ្នកទទួលផលជាចម្បង ក្នុងគ្រប់កម្មវិធីគាំពារសង្គមទាំងអស់ ហើយក្នុងពេលជាមួយគ្នា នៅបើកចំហឲ្យមានការប្រើប្រាស់វិធីសាស្ត្របំពេញបន្ថែម ក្នុងករណីដែលមានហេតុផល
សមស្រប។"

## ហេតុផលដែលនាំឲ្យការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ធ្វើការសិក្សាវាយតម្លៃនេះ

ការបែងចែកដីរដ្ឋដ៏គំហុក ក្នុងអំឡុងពេលនៃការបើកចំហរសេដ្ឋកិច្ចទីផ្សារសេរីរបស់ប្រទេសកម្ពុជា ជាលទ្ធផលមានសេចក្តីរាយការណ៍ថាមានប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះជាច្រើនគ្រួសារត្រូវបានផាត់ចេញពីដំណើរការនៃការបែងចែកដីធ្លី។[18] ខណៈដែលដីរាប់លានហិកតាត្រូវបានផ្ទេរទៅឲ្យវិនិយោគិនដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភមួយក្រុមតូចតាមរយៈកម្មវិធីសម្បទានដីសេដ្ឋកិច្ចដែលត្រូវបានរៀបចំឡើងដើម្បីជម្រុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងអំឡុងពេល ២៥ឆ្នាំចុងក្រោយនេះ ការបែងចែកដីរដ្ឋដោយស្របច្បាប់ដល់គ្រួសារដែលគ្មានដីនិងគ្រួសារក្រីក្រនៅមិនទាន់សម្រេចបានតាមគោលដៅនៅឡើយ។[19]

ការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម (PSIA) ត្រូវបានផលិតឡើងក្នុងឆ្នាំ ២០០៣-២០០៤ សម្រាប់ផែនការកម្មវិធីសម្បទានដីសង្គមកិច្ចរបស់កម្ពុជា ហើយត្រូវបានធ្វើឡើងជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរួមគ្នារវាងធនាគារពិភពលោក អង្គការ Oxfam GB ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងកម្មវិធី GTZ-LMAP[20]។ ទិន្នន័យការ

[18] ការវិភាគផ្នែកលើសិទ្ធិមនុស្សអំពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានគោលដៅដទៃទៀតនៅព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាសិទ្ធិមនុស្ស A/HRC/21/63/Add.1. 2012.

[19] Muller, Franz-Volker ការបែងចែកដីធ្លីនៅថ្នាក់ឃុំ ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ភាពជោគជ័យ និងបទពិសោធន៍ដែលរៀន ស្ទូត្របានពីគម្រោង: ការបែងចែកដីធ្លីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ ឯកសារបង្ហាញនៅឯសន្និសីទប្រចាំឆ្នាំរបស់ ធនាគារពិភពលោក ស្តីពីដីធ្លី និងភាពក្រីក្រ ឆ្នាំ២០១២ ទំព័រ ៥។

[20] ការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម (PSIA) លើផែនការកម្មវិធីសម្បទានដីសង្គមកិច្ច ត្រូវបានធ្វើឡើងចន្លោះពីខែ ឧសភា ឆ្នាំ ២០០៣ និងខែ ឧសភា ឆ្នាំ ២០០៥។ នេះ គឺជាការវិភាគដែលធ្វើឡើងរួមគ្នារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ GTZ, Oxfam GB, វិទ្យាស្ថានកសិពាណិជ្ជកម្មកម្ពុជា (ABiC) និងធនាគារពិភពលោក។ សូមមើលផលប៉ះពាល់លើភាពក្រីក្រី និងសង្គមដែលអាចកើតមានឡើងពីកម្មវិធីសម្បទានដីសង្គមកិច្ចដែលត្រូវបានស្នើឡើង។ បទបង្ហាញ និងការពិភាក្សាពីលទ្ធផល និងអនុសាសន៍ ដែលបានពីការវិភាគ PSIA។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច GTZ-LMAP គម្រោងគ្រប់គ្រង និងរដ្ឋបាលដីធ្លី អង្គការ Oxfam GB ធនាគារពិភពលោក EASRD ខែ ឧសភា ឆ្នាំ ២០០៥។ ការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម បានឲ្យនិយមន័យ "ភាពគ្មានដី" គឺការគ្មានកម្មសិទ្ធិលើដីកសិកម្ម និងការគ្មានមធ្យោបាយ ដើម្បីទិញវា។ ភាពខ្វះដីត្រូវបានគេឲ្យនិយមន័យថា គឺការគ្មានដីគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ដល់គ្រួសារ (ប្រហែលមួយភាគប្រាំមួយនៃមួយហិកតាសម្រាប់

អង្កេតអំពីភាពគ្មានដី និងភាពខ្វះខាតដីនៅកម្ពុជា បានបង្ហាញនៅពេលនោះ បញ្ជាក់ថា មានគ្រួសារ ១២% នៃគ្រួសារខ្មែរ គ្មានដី គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ១៩% ជាគ្រួសារគ្មានដី ហើយមានគ្រួសារ ៥% បន្ថែមទៀត ត្រូវបានចាត់ទុកថាជាគ្រួសារដែលខ្វះខាតដី។ អត្រាអ្នកគ្មានដីត្រូវបានរកឃើញថា មានការប្រែប្រួលខ្ពស់ពីឃុំមួយ ទៅឃុំមួយទៀត។ ក្នុងចំណោមអ្នកដែលគ្មានដីសរុប មាន ៨០% ដែលមិនធ្លាប់មានដីជាកម្មសិទ្ធិផ្ទាល់ខ្លួនទាល់តែសោះក្នុងសហគមន៍ដែលពួកគេកំពុងរស់នៅបច្ចុប្បន្ន ខណៈពេលដែលនៅសល់ ២០% ទៀត បានបាត់បង់កម្មសិទ្ធិរបស់ខ្លួន។[21] មូលហេតុ ដែលត្រូវបានលើកឡើងញឹកញាប់ជាងគេថានាំឲ្យគ្រួសារបាត់បង់ដី គឺចំណាយពាក់ព័ន្ធនឹងការថែទាំសុខភាព។[22] ការវិភាគនេះក៏ចែងផងដែរថា ការទទួលបានដី ត្រូវបាន គេពិចារណា គឺជាសំណាញ់សុវត្ថិភាពសង្គមដែលសំខាន់បំផុតជាងគេតែមួយគត់ នៅតំបន់ជនបទ។ ការស្រាវជ្រាវ និងការវិភាគនេះ បានផ្តល់នូវភស្តុតាងជាមូលដ្ឋាន និងបរិបទ សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ដែលទើបនឹងបង្កើតថ្មី។

កម្មវិធីសម្បទានដីសង្គមកិច្ចបង្កើតក្រោយមកទៀត មានគោលបំណងបង្កើតនូវគំរូដែលចំណាយអស់តិច មានប្រសិទ្ធភាព និងយកទៅអនុវត្តនៅកន្លែងផ្សេងទៀតបានសម្រាប់ធ្វើការបែងចែកដីរដ្ឋដល់គ្រួសារក្រីក្រទូទាំងប្រទេស តាមរយៈសម្បទានដី។ ក្នុងន័យនេះ កម្មវិធីសម្បទានដីសង្គមកិច្ច គឺជាការខិតខំប្រឹងប្រែងគួរឲ្យកោតសរសើររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសហការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំនូវកម្មវិធីមួយ សម្រាប់លើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋនៅជនបទ និងធានាឲ្យមានការបំពេញលក្ខខណ្ឌ

---

សមាជិកគ្រួសារម្នាក់ ត្រូវបានគេប្រើប្រាស់ ហើយបន្ទាប់មកកែសម្រួលទៅតាមគុណភាពដីកសិកម្ម តាមភូមិនិមួយៗ ក្នុងការគណនាក្រោយមកទៀត)។

[21] ខណៈពេលដែលរបាយការណ៍ផ្សេងទៀតផ្តល់ស្ថិតិខុសៗគ្នាអំពីភាពគ្មានដី ទិន្នន័យនេះត្រូវបានរកឃើញថាមានសង្គតិភាពជាមួយនឹងព័ត៌មានដែលមានក្នុងប្រព័ន្ធទិន្នន័យធំៗ និងគម្រោងស្រាវជ្រាវផ្សេងទៀត។

[22] ការវិភាគផលប៉ះពាល់លើភាពក្រីក្រ និងសង្គម ។ សូមមើល ផលប៉ះពាល់លើភាពក្រីក្រ និងសង្គមដែលអាចកើតមានឡើងពីកម្មវិធីសម្បទានដីសង្គមកិច្ចដែលត្រូវបានស្នើឡើង។ បទបង្ហាញ និងការពិភាក្សាពីលទ្ធផល និងអនុសាសន៍ ដែលបានពីការវិភាគ PSIA។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច GTZ-LMAP គម្រោងគ្រប់គ្រង និងរដ្ឋបាលដីធ្លី អង្គការ Oxfam GB ធនាគារពិភពលោក EASRD ខែឧសភា ឆ្នាំ ២០០៤។

ចាំបាច់ សម្រាប់ការមានកម្រិតជីវភាពរស់នៅសមរម្យ សម្រាប់ប្រជាពលរដ្ឋក្រខ្សត់ និងងាយរងគ្រោះជាងគេក្នុងប្រទេសនេះ។ ក្រុមមុខសញ្ញា មានដូចជា គ្រួសារដែលមានជំនាញកសិកម្មតិចតួច ឬគ្មានជំនាញកសិកម្មសោះ គ្រួសារដែលជាប់បំណុលធ្ងន់ធ្ងរ គ្រួសារដែលមានកម្រិតវប្បធម៌ទាប និងមានសុខភាពមិនល្អ ដូច្នេះការអនុវត្តកម្មវិធីនេះកន្លងមកជួបប្រទះនឹងការលំបាក ហើយនៅបន្តជួបការលំបាករហូតដល់បច្ចុប្បន្ននេះ។

កាលពីឆ្នាំ ២០១២ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបញ្ជាក់ថា ដីសរុបដែលបែងចែកដល់ប្រជាពលរដ្ឋក្រីក្រ តាមគ្រប់រូបភាពទាំងអស់ គឺ ១៩៩.៨២០ ហិកតា សម្រាប់ប្រជាពលរដ្ឋ ៣០.៥៨៨ គ្រួសារ និងមានការផ្តល់ផ្ទះចំនួន ៣.៩៦៥ ខ្នង។[23] ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០១៤-២០១៨ រដ្ឋាភិបាលបានប្រកាសថា រដ្ឋាភិបាលបានផ្តល់ដីដល់ប្រជាពលរដ្ឋ ("ក្រីក្រ") ប្រមាណជា ១៥.០០០ គ្រួសារ ប្រកបដោយជោគជ័យ ក្នុងទម្រង់ជា "ការធ្វើប្រទានកម្មដី" គិតត្រឹមចុងឆ្នាំ ២០១៣ តាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចដែលអនុវត្តទូទាំងប្រទេស។ ក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) ជាគម្រោងសាកល្បង អនុវត្តដោយសហការជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក៏មានការបែងចែកដីដល់ប្រជាពលរដ្ឋក្រីក្រ និងគ្មានដី ៥.០០០ គ្រួសារបន្ថែមទៀតផងដែរ។ ក្នុងក្របខ័ណ្ឌកម្មវិធីរដ្ឋបាល គ្រប់គ្រង និងបែងចែកដី របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋាភិបាលបានអនុវត្តកម្មវិធី LASED សាកល្បង ជាមួយនឹងការគាំទ្របច្ចេកទេសពី GIZ និងការឧបត្ថម្ភហិរញ្ញវត្ថុពីធនាគារពិភពលោក។ "គោលបំណងអភិវឌ្ឍន៍" មួយរបស់កម្មវិធីLASED គឺកែលំអ*ដំណើរការ*កំណត់អត្តសញ្ញាណដីរដ្ឋ ដែលត្រូវផ្ទេរទៅគ្រួសារក្រីក្រ ដែលបំពេញបានតាមលក្ខណៈវិនិច្ឆ័យ។ ការសាកល្បងកម្មវិធី LASED បានបញ្ចប់កាលពីខែ ធ្នូ ឆ្នាំ ២០១៤ ដូច្នេះ បើតាមទ្រឹស្តី ដំណើរការដែលត្រូវបានកែលំអទាំងនេះគួរតែត្រូវបានអនុវត្តនៅទីតាំងសម្បទានដីសង្គមកិច្ច ដែលមិនស្ថិតក្រោមកម្មវិធី LASED ប្រសិនបើ

[23] ការវិភាគផ្អែកលើសិទ្ធិមនុស្សអំពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានគោលដៅដទៃទៀតនៅព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាសិទ្ធិមនុស្ស A/HRC/21/63/Add.1. 2012.

សមាសភាគមួយនេះនៃគម្រោង LASED បានទទួលជោគជ័យ។ ជំហានទី២ នៃគម្រោងឈ្មោះថា LASED II ត្រូវបានអនុម័តក្នុងឆ្នាំ២០១៦ ហើយនឹងបន្តរហូតដល់២០២១។[24]

ក្រៅពីការស្រាវជ្រាវវាយតម្លៃលើភាពជោគជ័យនៃគម្រោង LASED ក្រោមហិរញ្ញប្បទានរបស់ធនាគារពិភពលោក មានព័ត៌មានស្តួចស្តើងបំផុតដែលរៀបរាប់លំអិតអំពីអ្វីដែលជាផលប៉ះពាល់ជាក់លាក់នៃកម្មវិធីសម្បទានដីសង្គមកិច្ចនៅទូទាំងប្រទេសរបស់រដ្ឋាភិបាល មិនថាទៅលើអ្នកទទួលផល ឬក៏ទៅលើសហគមន៍មូលដ្ឋានបានរងផលប៉ះពាល់ពីកម្មវិធីសម្បទានដីសង្គមកិច្ចទាំងនោះទេ។ ការវាយតម្លៃបឋមលើព័ត៌មាន ដែលអាចរកបានជាសាធារណៈ បានបង្ហាញថា មានការសិក្សាតិចតួចប៉ុណ្ណោះ ដែលរាយការណ៍ពីដំណើរការ និងលទ្ធផលនៃការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច។ ឥឡូវនេះ រដ្ឋាភិបាលកំពុងពង្រីក និងអភិវឌ្ឍកម្មវិធីសម្បទានដីសង្គមកិច្ចរបស់ខ្លួនបន្ថែមទៀត។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ លើកឡើងថា រដ្ឋាភិបាលនឹង "បន្តអនុវត្តកាន់តែសកម្ម និងស៊ីជម្រៅថែមទៀតនូវកំណែទម្រង់ដីធ្លី ដោយផ្តោតលើការពង្រឹងការគ្រប់គ្រង ការរៀបចំ ការប្រើប្រាស់ និងការបែងចែកដីធ្លី ដើម្បីរួមចំណែកធ្វើឲ្យសម្រេចគោលដៅជាតិក្នុងការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាន និងធនធានធម្មជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារ។" នេះរួមមាន "ការបន្តបែងចែក និងប្រើប្រាស់ដីរដ្ឋ ជាពិសេស ដីសម្បទានសេដ្ឋកិច្ច ដែលត្រូវបានដកហូតមកវិញ និងផ្ទៃដី ដែលត្រូវបានបោសសំអាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីបម្រើប្រយោជន៍នៃការអភិវឌ្ឍប្រកបដោយតម្លាភាពនិងសមធម៌ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជនក្រីក្រ យោធិនពិការ គ្រួសារយោធិនពលីនិងមរណៈ និងអតីតកងកម្លាំងប្រដាប់អាវុធដែលគ្មាន ឬខ្វះដីពិតប្រាកដ តាមរយៈការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច និងការធ្វើប្រទានកម្ម។"[25] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានកំណត់

[24] គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ជំហានII។ សូមមើល http://projects.worldbank.org/P150631/?lang=en&tab=overview

[25] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០១៤-២០១៨ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០១៤។

គោលដៅក្នុងការផ្តល់ដល់ "ប្រជាជនក្រីក្រ ៤៣.០០០ គ្រួសារ" ទទួលបានដី តាមរយៈសម្បទានដីសង្គមកិច្ច ត្រឹមឆ្នាំ ២០១៨ ដែលបានឯកភាពដាក់ក្នុងសូចនាករស្នូលនៃការពិនិត្យតាមដានអំពីសម្បទានដីសង្គមកិច្ច សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។[26]

ប៉ុន្តែ បើតាមការលើកឡើងរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ការផ្តល់ និងការគ្រប់គ្រងសម្បទានដី ក្នុងប្រទេសកម្ពុជា នៅខ្វះតម្លាភាព និងខ្វះភាពអនុលោមតាមតាមច្បាប់ដែលមានជាធរមាន។[27] អង្គការ GIZ ក៏បានរាយការណ៍ផងដែរថា ការអនុវត្ត និងការពង្រឹងការអនុវត្តនីតិរដ្ឋ ក្នុងការបែងចែកសម្បទានដីសង្គមកិច្ច ជួបប្រទះនឹងបញ្ហា ដោយសារតែមានករណីទន្ទ្រាន និងដណ្តើមយកដី ពីសំណាក់បុគ្គល និងស្ថាប័នរដ្ឋ។[28]

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅកម្ពុជា បានទទួលពាក្យបណ្តឹងជាច្រើន និងការអំពាវនាវសុំជំនួយពីគ្រួសារដែលរស់នៅតំបន់សម្បទានដីសង្គមកិច្ច ក៏ដូចជាពីអ្នកដែលអះអាងថាត្រូវបានគេបណ្តេញចេញពីតំបន់សម្បទានដីសង្គមកិច្ចដែលបង្កើតថ្មី។ ដោយសារតែបញ្ហា ដែលរាយការណ៍ដោយក្រុមសង្គមស៊ីវិល និងការរកឃើញដោយ OHCHR អំឡុងពេលចុះដល់ទីតាំងជាក់ស្តែង និងជាការឆ្លើយតបចំពោះបណ្តឹងដែល OHCHR បានទទួលដោយផ្ទាល់នោះ ទើបOHCHR បានរៀបចំឲ្យមានការស្រាវជ្រាវទូលំទូលាយមួយ ដើម្បីវាយតម្លៃលើផលប៉ះពាល់ដែលសម្បទានដីសង្គមកិច្ចមានលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទ។

---

[26] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០១៤-២០១៨ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០១៤ ទំព័រ ២២៨ ជាភាសាអង់គ្លេស។

[27] ការវិភាគផ្នែកលើសិទ្ធិមនុស្សអំពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានគោលដៅផ្សេងទៀតនៅព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាសិទ្ធិមនុស្ស A/HRC/21/63/Add.1. 2012.

[28] Muller, Franz-Volker ការបែងចែកដីធ្លីនៅថ្នាក់ឃុំ ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ភាពជោគជ័យ និងបទពិសោធន៍ដែល រៀនសូត្របានពីគម្រោង: ការបែងចែកដីធ្លីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ ឯកសារបង្ហាញនៅឯសន្និសីទប្រចាំឆ្នាំរបស់ ធនាគារពិភពលោក ស្តីពីដីធ្លី និងភាពក្រីក្រ ឆ្នាំ២០១២ ទំព័រ៥។

OHCHR បានវាយតម្លៃលើផលប៉ះពាល់នៃសម្បទានដីសង្គមកិច្ចចំនួន ៦ ទីតាំង ក្នុងខេត្តចំនួន ៦ (ត្បូងឃ្មុំ កំពង់ស្ពឺ បាត់ដំបង កំពង់ធំ មណ្ឌលគិរី និងកំពត) ។ ការសិក្សានេះផ្តោតជាចម្បងលើអ្នកទទួលផលដែលទទួលបានដីក្នុងតំបន់សម្បទានដីសង្គមកិច្ចទាំង៦។ ការអង្កេត និងការពិគ្រោះយោបល់ក៏ត្រូវបានធ្វើឡើងជាមួយនឹងក្រុមដែលរស់នៅជុំវិញទីតាំងសម្បទានដីសង្គមកិច្ច អាជ្ញាធរមូលដ្ឋាន និងតំណាងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ គោលបំណងចម្បងនៃការស្រាវជ្រាវនេះ គឺដើម្បីវាយតម្លៃលើផលប៉ះពាល់ ដែលសម្បទានដីសង្គមកិច្ចមានលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទ ក្នុងប្រទេសកម្ពុជា រាប់បញ្ចូលទាំងអ្នកទទួលផល និងគ្រួសារផ្សេងទៀត ដែលទទួលរងផលប៉ះពាល់ដោយសារកម្មវិធីសម្បទាននេះផងដែរ។

ការអង្កេតនេះធ្វើការវាយតម្លៃលើកម្រិតតម្លាភាព ក្នុងដំណើរការនៃការកំណត់ ការបែងចែក និងការផ្តល់ដី ពោលគឺ ថាតើ ការផ្តល់ដីធ្វើឡើងដោយសមធម៌ដែរឬទេ និងថាតើដំណើរការទាំងនេះផ្តល់នូវលទ្ធផលអ្វីខ្លះ។ ការវិភាគនេះ មានគោលបំណងផ្តល់ឲ្យអ្នកតាក់តែងគោលនយោបាយ អ្នកផ្តល់សេវា និងអ្នកពាក់ព័ន្ធផ្សេងទៀតនូវគំនិតកាន់តែស៊ីជម្រៅអំពីទស្សនៈយល់ឃើញ និងតម្រូវការរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានទាំងមូល។ ព័ត៌មាននេះគួរប្រើជាជំនួយស្មារតី សម្រាប់ការរៀបចំផែនការ និងការសម្រេចចិត្តនាពេលអនាគតអំពីការបែងចែកធនធាន ក៏ដូចជាការផ្តួចផ្តើមឲ្យមានអន្តរាគមន៍ នៅកន្លែងដែលបញ្ហាលេចចេញមកបន្ទាន់បំផុត ដែលទាមទារឲ្យមានការយកចិត្តទុកដាក់។

គោលបំណងមួយទៀតនៃការស្រាវជ្រាវនេះ គឺដើម្បីវាយតម្លៃលើកម្រិតដែលកម្មវិធីសម្បទានដីសង្គមកិច្ចកំពុងត្រូវបានប្រើប្រាស់ ដើម្បីផ្លាស់ប្តូរទីលំនៅរបស់ជនរងគ្រោះដោយសារការបណ្តេញចេញ ទប់ទល់ជាមួយនឹងការធ្វើឯកជនភាវូបនីយកម្ម និងការធ្វើអនុបយោគដីដែលធ្លាប់តែកាន់កាប់កន្លងមកដោយគ្រួសារ ឬកាត់បន្ថយផលប៉ះពាល់នៃដំណើរការផ្តល់សម្បទានដីសេដ្ឋកិច្ចដែលរៀបចំមិនបានល្អ ដែលពុំបានផ្តោតការយកចិត្តទុកដាក់គ្រប់គ្រាន់លើសិទ្ធិជាកម្មសិទ្ធិ និងសិទ្ធិភោគៈ របស់សហគមន៍មូលដ្ឋាន។ ខណៈពេលដែលមូលហេតុ ដែលនាំឲ្យមានការបង្កើតកម្មវិធីសម្បទានដីសង្គមកិច្ច ផ្តោតជុំវិញការ

កាត់បន្ថយភាពក្រីក្រ និងការផ្តល់នូវសន្តិសុខសង្គមតាមរូបភាពមួយ ដល់ក្រុមជួបការលំបាក មានការចោទប្រកាន់ពីប្រជាជនមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលនានាថា កម្មវិធីសម្បទានដីសង្គមកិច្ចអនុវត្តដោយមានពាក់ព័ន្ធនឹងអំពើពុករលួយ ដែលធ្វើឲ្យការអនុវត្តគោលនយោបាយចែកប័ណ្ណកម្មសិទ្ធិដីធ្លីពុំមានសមធម៌។

ការអង្កេតនេះក៏វាយតម្លៃផងដែរ ថាតើ កម្មវិធីសម្បទានដីសង្គមកិច្ចត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងកំពុងផ្តល់លំនៅឋានសមរម្យ លទ្ធភាពទទួលបានសេវាជាមូលដ្ឋាន និងដីសមស្របសម្រាប់ការធ្វើកសិកម្មដល់អ្នកទទួលផលដែរឬទេ។ ក្នុងការសិក្សាមួយដែលធ្វើឡើងកាលពីឆ្នាំ ២០១៥ ដោយ LICADHO អង្គការនេះបានប៉ាន់ប្រមាណថា ក្នុងចំណោមគ្រួសារដែលបានទទួលដីលំនៅឋាន តាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) មានគ្រួសារតិចជាង ៥០% ប៉ុណ្ណោះ ដែលបានមករស់នៅ និងបន្តរស់នៅជាក់ស្តែង ដោយពួកគេលើកឡើងថាទីតាំងដីសម្បទានសង្គមកិច្ចពាក់កណ្តាលមិនទាន់អាចដំណើរការទៅបាន ហើយត្រូវការការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសយ៉ាងច្រើន ដើម្បីអាចមាននិរន្តរភាពក្នុងកម្រិតអប្បបរមាទៅមុខទៀត។[29] ក្រុមដែលធ្វើការងារខាងសិទ្ធិដីធ្លី និងសហគមន៍ ក៏បានលើកឡើងផងដែរថា សម្បទានដីសង្គមកិច្ចបានបង្កើតឲ្យមានករណីជម្លោះដីធ្លីថ្មីៗ និងបានបង្កើនការបំផ្លាញព្រៃឈើ។ រដ្ឋាភិបាលពុំបានផ្តល់ឲ្យមានជាសាធារណៈនូវប្រព័ន្ធទិន្នន័យដែលមានព័ត៌មានអំពីការបែងចែកដី ការបង្កើតសម្បទានដី ឬលទ្ធផល និងផលប៉ះពាល់នៃកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រដ្ឋាភិបាលនោះទេ។ របាយការណ៍នៃការស្រាវជ្រាវនេះបង្ហាញដោយសង្ខេបពីផលប៉ះពាល់ទាំងនោះ និងធ្វើការឆ្លុះបញ្ចាំងថា តើទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀតកំពុងបំពេញទៅតាមតម្រូវការរបស់ក្រុមអ្នកទទួលផលផ្សេងៗបានកម្រិតណា។

[29] ដីដែលមិនអាចដាំដំណាំបាន៖ ការពិនិត្យទៅលើសម្បទានដីសង្គមកិច្ច អង្គការលីកាដូ ឆ្នាំ ២០១៥ ។

## កំណត់សម្គាល់អំពីវិធីសាស្ត្រ

ការសម្ភាសស៊ីជម្រៅត្រូវបានធ្វើឡើងជាមួយនឹងប្រជាពលរដ្ឋ ៦៨០ ខ្នងផ្ទះដោយឡែកៗពីគ្នា នៅតាមទីតាំងសម្បទានដីសង្គមកិច្ច ក្នុងខេត្តទាំង ៦ នៅចុងឆ្នាំ២០១៥ ហើយ និងដំណើរទស្សនកិច្ចដល់ទីតាំង បានធ្វើឡើងដោយ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងឆ្នាំ ២០១៥ និង ២០១៦។ ។វិធីសាស្ត្រនេះត្រូវបានរៀបចំឡើង ដោយប្រើប្រាស់បច្ចេកទេសសម្ភាសបែបបរិមាណវិស័យ និងគុណវិស័យបញ្ចូលគ្នា។ បច្ចេកទេសទាំងនេះមានដាក់បញ្ចូលសំណួរបែបគុណវិស័យជុំវិញការទទួលបានសេវាសាធារណៈ និងថាតើគ្រួសារគិតថាកម្រិតជីវភាពរស់នៅ ឬស្ថានភាពលំនៅឋានរបស់ពួកគេបានប្រសើរជាងមុនដែរឬទេ។ បច្ចេកទេសនេះក៏មានបញ្ចូលការប្រមូលទិន្នន័យបែបបរិមាណវិស័យអំពីទំហំផ្ទះ កម្រិតប្រាក់ចំណូល និងបំណុលតាមខ្នងផ្ទះផងដែរ។ ការពិភាក្សាជាក្រុមគោលដៅ ជាមួយសហគមន៍ជិតខាង និងការសម្ភាសមួយទល់មួយដោយចំហ និងប្រើពេលយូរជាមួយនឹងតំណាងអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន បានជួយផ្តល់នូវរូបភាពកាន់តែពេញលេញអំពីផលប៉ះពាល់នៃសម្បទានដីសង្គមកិច្ចមកលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទ។

ការអង្កេតទាំងនេះត្រូវបានរៀបចំឡើង ដើម្បីប្រមូលព័ត៌មាន និងភស្តុតាងអំពីការគោរព និងការការពារសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច ដែលសិទ្ធិទាំងនេះភាគច្រើនពាក់ព័ន្ធជាមួយនឹងសិទ្ធិមានកម្រិតជីវភាពសមរម្យ ដូចជា ការមានលំនៅឋានសមរម្យ ដែលរាប់បញ្ចូលភាពជាប់លាប់នៃការកាន់កាប់ លទ្ធភាពទទួលបានសេវាជាមូលដ្ឋាន ដូចជា សេវាអប់រំ និងសុខភាព ទឹក និងអនាម័យ និងសន្តិសុខស្បៀង ជាដើម។ ការអង្កេតនេះក៏បញ្ចូលផងដែរនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមួយចំនួន ដូចជា សិទ្ធិបោះឆ្នោត សិទ្ធិទទួលបានព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិ ជាដើម។

អ្នកឆ្លើយតប ត្រូវបានស្នើផងដែរឲ្យធ្វើការវាយតម្លៃដោយខ្លួនឯងផ្ទាល់ និងដាក់ពិន្ទុលើលទ្ធភាពនៃការទទួលបានសេវា និងដំណើរការដែលមានការចូលរួម ដូច្នេះសំណួរនានាត្រូវបានរៀបចំឡើង ដើម្បីវាស់វែងគំនិតយល់ឃើញ ជាជាងការវាស់វែងដែលមាន

លក្ខណៈវិទ្យាសាស្ត្រ។ ការធ្វើបែបនេះផ្តល់នូវព័ត៌មានអំពីកម្រិតជីវភាពរស់នៅ ក៏ដូចជាអំពីការយល់ដឹងរបស់ប្រជាពលរដ្ឋលើសិទ្ធិជាក់លាក់មួយចំនួន និងទស្សនៈរបស់ពួកគេលើអាជ្ញាធរមូលដ្ឋាន និងការទំនាក់ទំនងរបស់ពួកគេជាមួយនឹងអាជ្ញាធរមូលដ្ឋាន។ ចំណុចសំខាន់ដែលត្រូវកត់សម្គាល់ពាក់ព័ន្ធនឹងការឲ្យប្រជាពលរដ្ឋដាក់ពិន្ទុលើលទ្ធភាពទទួលបានសេវា មិនគួរត្រូវបានគេយកទៅបកស្រាយថាជាការកំណត់ពីប្រភេទសេវាដែលអាចរកបាននោះទេ។ អាចថា ប្រជាជនម្នាក់ពុំបានដឹងពីនីតិវិធីជាក់លាក់ ដែលអនុវត្តដោយអាជ្ញាធរមូលដ្ឋាន ឬទីកន្លែងរបស់អ្នកផ្តល់សេវានៅមូលដ្ឋានជាដើម។ ការវាយតម្លៃដោយខ្លួនឯងអំពីសន្តិសុខស្បៀងអាចបង្ហាញពីកម្រិតដ៏ខ្ពស់នៃកង្វះអាហារូបត្ថម្ភ ក្នុងសហគមន៍ ប៉ុន្តែចាំបាច់ត្រូវមានការវាយតម្លៃបែបវេជ្ជសាស្ត្រលើកម្រិតអាហារូបត្ថម្ភ ទើបអាចកំណត់ដឹងបានជាក់លាក់។ ស្រដៀងគ្នានេះដែរ ប្រជាជនត្រូវបានសួរថាតើ ពួកគេត្រូវបានគេឲ្យចូលរួមក្នុងដំណើរការផ្សេងៗនៃការរៀបចំផែនការសម្បទានដីសង្គមកិច្ចដែរឬទេ ឧទាហរណ៍ ថាតើពួកគេត្រូវបានគេពិគ្រោះយោបល់ជាមុន ឬ ក្នុងអំឡុងពេលការអភិវឌ្ឍន៍ទីតាំងនេះដែរឬទេ។ ការយល់ដឹង និងការរំពឹងទុករបស់អ្នកឆ្លើយតបពាក់ព័ន្ធនឹងការពិគ្រោះយោបល់អាចមានលក្ខណៈផ្សេងពីគ្នា ហើយការចូលរួមអាចមិនមែនជាការបង្ហាញពីការអនុវត្តល្អនោះទេ។ ប៉ុន្តែ ប្រសិនបើចម្លើយដែលផ្តល់នឹងត្រូវរក្សាជាការសំងាត់វិញនោះវា គឺជា ការផ្តល់ឱកាសឲ្យប្រជាជនរំលេចឲ្យឃើញថាពួកគេត្រូវបានគេផាត់ចេញពីការពិគ្រោះយោបល់នេះដែរឬទេ។

ជាងនេះទៀត លទ្ធផលនៃការអង្កេតនេះគួរផ្តល់បានជារូបភាពដ៏មានតម្លៃមួយចំពោះសេវាអ្វីខ្លះដែលអាចរកបាននាពេលបច្ចុប្បន្ននៅតាមទីតាំងសម្បទានដីសង្គមកិច្ចនានា និងដែលគេកំពុងប្រើប្រាស់ជាក់ស្តែង។ ឧទាហរណ៍ ប្រសិនបើមណ្ឌលសុខភាពមួយពុំមានបុគ្គលិក ហើយតែងបិទទ្វារជាប្រចាំ អ្នកឆ្លើយតបអាច*មិន*លើកឡើងពីមណ្ឌលសុខភាពនេះឡើយ នៅពេលដែលពួកគេត្រូវបានសួរថាតើត្រូវការចំណាយពេលប៉ុន្មាន ដើម្បីទៅដល់មណ្ឌលសុខភាពដែលនៅជិតបំផុត ខណៈពេលដែលអាជ្ញាធរមូលដ្ឋានអាចលើកឡើងថាមានសេវាបែបនេះក្នុងសហគមន៍ ដូច្នេះចម្លើយរបស់ពួកគេអាចខុសគ្នា។ គោល

បំណងនៃការសាកសួរសមាជិកសហគមន៍អំពីសេវាសង្គម គឺដើម្បីវាយតម្លៃថាតើ បច្ចុប្បន្ននេះមានសេវាអ្វីខ្លះដែលកំពុងផ្តល់ សេវាណាខ្លះដែលអាចរកបាន និងសេវាណាខ្លះដែលកំពុងត្រូវបានប្រើប្រាស់។ ដូច្នេះ ការអង្កេតនេះត្រូវបានតាក់តែងឡើងដើម្បីរំលេច ចេញនូវការព្រួយបារម្ភរបស់គ្រួសារដែលងាយរងគ្រោះ និងជំរុញឲ្យមានការវិភាគបន្ថែមអំពីការបែងចែកធនធាន និងអំពី ការអភិវឌ្ឍ និងតាក់តែងឡើងនូវកម្មវិធីសម្បទានដីសង្គមកិច្ច។

អាជ្ញាធរមូលដ្ឋាន ដែលត្រូវបានសម្ភាស មានដូចជា មេភូមិ មេឃុំ ឬមន្ត្រីថ្នាក់ឃុំផ្សេងទៀត។ ពួកគេមានតួនាទីផ្សេងៗគ្នា ក្នុងការរៀបចំផែនការ និងការអនុវត្តសម្បទានដីសង្គមកិច្ច ហើយចំណេះដឹងរបស់ពួកគេអំពីដំណើរការ និងគោលនយោបាយនានា ក៏មានលក្ខណៈខុសៗគ្នាផងដែរ។ ការអង្កេតត្រូវបានធ្វើឡើង ដើម្បីស្វែងយល់ពីចំណេះដឹង និងការយល់ដឹងរបស់ពួកគេ ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ក្នុងការពិនិត្យតាមដានជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ឈ្មោះទាំងអស់របស់អ្នកឆ្លើយតបចំពោះការអង្កេតត្រូវបានលុបចោល ក្នុងរបាយការណ៍នេះ។

ការអង្កេតបែបបរិមាណវិស័យអំពីកម្រិតជីវភាពរស់នៅ មិនត្រូវបានធ្វើឡើងក្នុងសហគមន៍ដែលពុំមានសម្បទានដីសង្គមកិច្ចឡើយ ដូច្នេះការអង្កេតនេះពុំបានធ្វើការប្រៀបធៀបកម្រិតជីវភាពរស់នៅបច្ចុប្បន្នរវាងអ្នកដែលរស់នៅក្នុង និងក្រៅតំបន់សម្បទានដីសង្គមកិច្ចដោយផ្ទាល់ឡើយ និងកន្លែងផ្សេងៗទៀតដែល ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ផ្តល់ជាស្ថិតិថ្នាក់ជាតិដោយមានការប្រៀបធៀបនោះទេ[30]។ ការទទួលបានទឹកស្អាតបរិភោគអនាម័យ និងបញ្ហាអាហារូបត្ថម្ភ គឺជាបញ្ហាគួរឲ្យកត់សម្គាល់នៅតាមសហគមន៍នានាក្នុងប្រទេសកម្ពុជា ហើយចាំបាច់ត្រូវមានការពិនិត្យមើលស្ថិតិទូទាំងប្រទេស និងស្ថិតិមូលដ្ឋានសិន មុននឹងធ្វើការកំណត់ឲ្យបានពេញលេញពីផលប៉ះពាល់ដែលសម្បទានដីសង្គមកិច្ចមានលើជីវភាពរស់នៅជនបទ។ ទិន្នន័យអង្កេតនេះគួរបង្កលក្ខណៈងាយស្រួលឲ្យគេអាចវិភាគបានកាន់តែប្រសើរពីផលប៉ះពាល់នៃសម្បទានដី

---

[30] វិទ្យាស្ថានស្ថិតិជាតិ/កម្ពុជា, អគ្គនាយកដ្ឋានសំរាប់សុខភាព/កម្ពុជា, និង ICF international 2015។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ2014 https://dhsprogram.com/publications/publication-FR312-DHS-Final-Reports.com

សង្គមកិច្ចនៅតាមសហគមន៍ជនបទ និន្នាការនៅតាមទីតាំងសម្បទានដីសង្គមកិច្ចផ្សេងៗ ក៏ដូចជាធ្វើការប្រៀបធៀបជាមួយនឹងសហគមន៍ក្បែរខាងផ្សេងទៀត។

ព័ត៌មានដែលបានពីការអង្កេត ត្រូវបានបំពេញបន្ថែមដោយការចុះដល់ទីតាំងសម្បទានដីសង្គមកិច្ចផ្ទាល់របស់ OHCHR ក៏ដូចជាការពិនិត្យមើលច្បាប់ គោលនយោបាយ និងឯកសារពាក់ព័ន្ធបន្ថែមទៀត។

លទ្ធផលរកឃើញនៃការអង្កេត ដែលត្រូវបានឆ្លុះបញ្ចាំងក្នុងរបាយការណ៍នេះមានគោលបំណងផ្តល់ជាជំនួយស្មារតី ដើម្បីធ្វើឲ្យការអនុវត្តអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចកាន់តែមានលក្ខណៈល្អប្រសើរ។ អ្នកផ្តល់ជំនួយ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលកំពុងធ្វើការងារក្នុងវិស័យដីធ្លីរបស់រដ្ឋាភិបាលនៅកម្ពុជា អាចយកព័ត៌មាននេះទៅប្រើប្រាស់ដើម្បីស្វែងយល់ឲ្យបានកាន់តែស៊ីជម្រៅអំពីដំណើរការនានាដែលត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងការបង្កើតសម្បទានដីសង្គមកិច្ច ផលប៉ះពាល់នៃកម្មវិធីសម្បទានដីសង្គមកិច្ច ក៏ដូចជាតម្រូវការ និងភាពងាយរងគ្រោះបច្ចុប្បន្នរបស់គ្រួសារទទួលផល។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានប្រាស្រ័យទាក់ទងពិគ្រោះយោបល់ជាមួយធនាគារពិភពលោក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ ក្នុងឆ្នាំ២០១៥ ខណៈពេលដែលផ្តួចផ្តើមរៀបចំផែនការស្រាវជ្រាវនេះ។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានផ្ញើរទៅក្រុមនេះនូវបញ្ជីទីតាំងដែលបានស្នើរឡើង និងវិធីសាស្រ្តការអង្កេត ហើយនិងបានអញ្ជើញ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចូលរួមកិច្ចពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋានទៀត។ ការស្រាវជ្រាវនេះខ្លួនវាភាគច្រើនមានលើ ការសម្ភាសជាមួយគ្រួសារតាមផ្ទះច្រើន ហើយត្រូវបានបំពេញបន្ថែមដោយការសម្ភាសជាមួយមន្ត្រីមូលដ្ឋាន និងបុគ្គលិក អង្គការទៀត។ នេះរួមមាន ការសម្ភាសជាមួយអង្គការ ADHOC Wathanakpheap Vigilance DCA LWD LICADHO និង CLEC។ មានការរៀបចំសិក្ខាសាលាផ្តល់សុពលភាពការសិក្សាស្រាវជ្រាវនេះនៅរាជធានីភ្នំពេញ ក្នុងខែកុម្ភៈ ឆ្នាំ ២០១៧ ដើម្បីប្រមូលមតិយោបល់លើសេចក្តីព្រាង

ចុងក្រោយ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអាជ្ញាធររដ្ឋាភិបាលដែលកំពុងធ្វើការងារលើកិច្ចការទាក់ទងនឹងសម្បទានដីសង្គមកិច្ច។

## អនុសាសន៍ចំពោះតួអង្គពាក់ព័ន្ធ

### ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖

- ផែនការសម្បទានដីសង្គមកិច្ច មិនគួរត្រូវបានអនុញ្ញាតយល់ព្រមនៅលើទីតាំងដែលមានក្បាលដីត្រួតលើ ឬពាក់ព័ន្ធនឹងដីដែលមានទំនាស់។ យន្តការដោះស្រាយជម្លោះដីធ្លីដែលមានស្រាប់ មានសមត្ថភាពនៅមានកម្រិតនៅឡើយ ហើយជម្លោះដីធ្លីរ៉ាំរ៉ៃមួយចំនួន ដែលលើកមកបង្ហាញក្នុងរបាយការណ៍នេះដែលពាក់ព័ន្ធជាមួយនឹងសម្បទានដីសង្គមកិច្ចដែលមានស្រាប់ មិនទាន់បានដោះស្រាយនៅឡើយទេ។[31]
- សម្បទានដីសង្គមកិច្ចមិនគួរប្រើប្រាស់ជាមធ្យោបាយ សម្រាប់ដោះស្រាយជម្លោះដីធ្លី ឬសម្រាប់ផ្តល់ជាភោគៈនូវដីដែលមានការកាន់កាប់រួចហើយនោះឡើយ។ គួរមានការប្រើប្រាស់វិធីសាស្ត្រដែលច្បាស់លាស់ និងមានតម្លាភាព ដើម្បីកំណត់ដីថ្មីដែលមាន និងទំនេរ សម្រាប់បម្លែងជាសម្បទានដីសង្គមកិច្ច។
- ដីសម្បទានសង្គមកិច្ច មិនគួរត្រូវបានបង្កើតនៅលើទីតាំងដែលមានព្រំប្រទល់ជាប់ជាមួយដីដែលប្រើប្រាស់ដោយ សហគមន៍ជនជាតិដើមភាគតិច លុះត្រាតែការទាមទារនានាអំពីកម្មសិទ្ធិសមូហភាព ឬបុគ្គលរបស់ជនជាតិដើមភាគ តិចត្រូវបានពិនិត្យ និងវាយតម្លៃពេញលេញរួចរាល់ ដោយអនុញ្ញាតឲ្យមានការតវ៉ា ឬការស្នើសុំសម្រាប់ការវិនិច្ឆ័យឡើងវិញតាមដំណើរការដែលមានលក្ខណៈសមធម៌ និងយុត្តិធម៌។
- ការវាយតម្លៃលើហេតុប៉ះពាល់សង្គម និងបរិស្ថាន ត្រូវធ្វើឡើងមុនពេលមានការសម្រេចយល់ព្រមលើសម្បទានដីសង្គមកិច្ច ស្របតាមមាត្រា៩នៃអនុក្រឹត្យស្តីពី

[31] សូមមើលឧទាហរណ៍ដូចជា ឯកសារស្តីពីកិច្ចសហប្រតិបត្តិការជាមួយប្រទេសកម្ពុជា និងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) ដំណាក់កាលទី ២ គោលជំហាររបស់សហរដ្ឋអាមេរិច ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦។ ចំណុចនេះធ្វើឲ្យមានមន្ទិលជុំវិញឯករាជ្យភាពនៃប្រព័ន្ធតុលាការកម្ពុជា និងសមត្ថភាពរបស់ប្រព័ន្ធតុលាការក្នុងការបំពេញតួនាទីសំខាន់ ក្នុងការធានាឲ្យការអនុវត្តគម្រោងអភិវឌ្ឍន៍នានាអាចប្រព្រឹត្តទៅប្រកបដោយសមធម៌ និងតម្លាភាព។

សម្បទានដីសង្គមកិច្ច និងត្រូវទុកពេលសម្រាប់ពិគ្រោះយោបល់ជាសាធារណៈ។ លទ្ធផលនៃការវាយតម្លៃហេតុប៉ះពាល់នេះ គួរដាក់ឲ្យមានជា សាធារណៈ។[32]

- ការជ្រើសរើសមុខសញ្ញាទទួលបានសម្បទានដីសង្គមកិច្ច ដែលជាជនក្រីក្រ និងជនគ្មានដីធ្លី គួរធ្វើឡើងដោយប្រើប្រាស់ដំណើរការបើកចំហ ប្រកបដោយតម្លាភាព សមធម៌ និងមានការចូលរួមពីសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងតួអង្គឯករាជ្យនានា ដូចជា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងស្របតាមអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច និងអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ នីតិវិធីនៃប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បច្ចុប្បន្ននេះ ត្រូវបានប្រើប្រាស់ជាប្រព័ន្ធស្តង់ដារបស់ជាតិ សម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ គួរប្រើប្រាស់ នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ដើម្បីកំណត់រកមុខសញ្ញាជាជនក្រីក្រ និងជនគ្មានដីធ្លី ដើម្បីទទួលបាន សម្បទានដីសង្គមកិច្ច។
- បទប្បញ្ញត្តិក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ដែលកំណត់អំពីការបង្ការមិនឲ្យអ្នកទទួលផលសម្បទានដីសង្គមកិច្ច ធ្វើការផ្ទេរដីមុនពេលកំណត់ ត្រូវតែជំរុញឲ្យមានការអនុវត្តឡើងវិញ។ ចំណុចនេះគួរបញ្ចូលបទប្បញ្ញត្តិនៃការណែនាំឲ្យបានច្បាស់លាស់ដល់អ្នកទទួលផលសម្បទានដីសង្គមកិច្ច ថ្មីៗថា រាល់ការផ្ទេរសិទ្ធិធ្វើឡើង *វេាង* បុគ្គលឬគ្រួសារទាំងឡាយ រស់នៅឯទីតាំងសម្បទានដីសង្គមកិច្ច ត្រូវបានហាមឃាត់។ អាជ្ញាធរមូលដ្ឋានគួរត្រូវបានស្នើឲ្យពង្រឹងការអនុវត្តបទប្បញ្ញត្តិទាំងនេះ ដើម្បីធានាថាដីដែលផ្តល់ជាសម្បទានដីសង្គមកិច្ច មិនត្រូវបានផ្ទេរ ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចព្រមព្រៀងសម្បទានដីសង្គមកិច្ចនេះឡើយ។

**អគ្គនាយដ្ឋានលំនៅឋាន គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/ក្រុង៖**

***<u>ចំពោះដីសម្បទានសង្គមកិច្ចនាពេលអនាគត៖</u>***

[32] ការធ្វើបែបនេះនឹងជួយធានាថាសម្បទានដីសង្គមកិច្ចនឹងមិនបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានលើបរិស្ថានឬសហគមន៍មូលដ្ឋានឡើយ ហើយវិធានការកាត់បន្ថយផលប៉ះពាល់ដែលចាំបាច់ អាចត្រូវបានដាក់ឲ្យអនុវត្ត មុនពេលការខូចខាតនានាកើតមានឡើង។

- ផែនការសម្រាប់សម្បទានដីសង្គមកិច្ចថ្មី តាមដែលអាចធ្វើទៅបាន គួរតែដាក់បញ្ចូលឲ្យបានពេញលេញទៅក្នុងផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត មុនពេលមានការបែងចែកក្បាលដី។
- ការទទួលបានសេវាសុខភាព អប់រំ និងសេវាជាមូលដ្ឋានផ្សេងទៀត រាប់ទាំងការទទួលបានទឹក គួររៀបចំជាផែនការជាស្រេច ដោយគណៈកម្មាធិការសម្បទានដីសង្គមកិច្ចដែលមានសមាសភាពពហុជំនាញ ដោយសហការជាមួយនឹងដៃគូអភិវឌ្ឍន៍ និងរៀបចំឲ្យរួចជាស្រេចមុន គ្រួសារទាំងនេះ ផ្លាស់ទៅនៅលើទីតាំងសម្បទានដីសង្គមកិច្ចថ្មី។
- គួរមានការសម្របសម្រួលលើកកម្ពស់ការសហការគ្នារវាងក្រសួង ភ្នាក់ងារ និងដៃគូអភិវឌ្ឍន៍ ដែលចូលរួមក្នុងការរៀបចំផែនការប្រើប្រាស់ដី និងការផ្តល់សេវា។ គួរធ្វើការសិក្សាវាយតម្លៃឡើងវិញជាទៀងទាត់នូវការគាំទ្រ និងធនធានចាំបាច់ៗដើម្បីធានាឲ្យសម្បទានដីសង្គមកិច្ចមាននិរន្តរភាព ហើយអាចរកបាននូវឋវិកាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍ។
- កម្មវិធីសម្បទានដីសង្គមកិច្ចពេលអនាគត គួរសំលឹងមើលការបញ្ចូលនូវបញ្ញត្តិការគាំទ្របន្ថែម (សម្ភារៈ ហិរញ្ញប្បទាន និង/ឬជំនួយដល់ការសាងសង់ ជំនួយជាអាទិភាពទៅដល់មេគ្រួសារដែលងាយរងគ្រោះ) ទៅដល់គ្រួសារ ក្រីក្រ គ្មានផ្ទះ ដើម្បីធានាថា លំនៅឋានសម្បទានដីសង្គមកិច្ចបំពេញបាននូវកំរិតស្តង់ដាអប្បរមា បានចែងក្នុងច្បាប់ សិទ្ធិមនុស្ស។[33] ការណ៍នេះនឹងផ្តល់លទ្ធភាពឲ្យគ្រួសារទាំងនោះផ្លាស់ទៅនៅលើទីតាំងសម្បទានដីសង្គមកិច្ចនោះកាន់តែបានឆាប់រហ័ស និងគួរតែអនុញ្ញាតឲ្យគ្រួសារក្រី

[33] គណៈកម្មាធិការអង្គការសហប្រជាជាតិ ស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានចែងថា សិទ្ធិមានលំនៅឋានសមរម្យ គួរត្រូវបានមើលឃើញ ដូចជាសិទ្ធិរស់រានមានជីវិតនៅកន្លែងណាក៏ដោយក្នុងសន្តិសុខ សន្តិភាព និងថ្លៃថ្នូរ។ ខណៈនេះ ភាពសមរម្យ ត្រូវបានកំណត់ក្នុងផ្នែកមួយដោយកត្តាសង្គម សេដ្ឋកិច្ច វប្បធម៌ បរិយាកាស អេកូឡូស៊ី និងកត្តាផ្សេងៗ ហើយគណៈកម្មាធិការនេះ បានចែងពីទិដ្ឋភាពជាក់លាក់មួយចំនួននៃសិទ្ធិដែល ត្រូវតែ ត្រូវមានការទទួលខុសត្រូវចំពោះគោលបំណងនេះ ក្នុងបរិបទពិសេសណាមួយ។ ទិដ្ឋភាពសិទ្ធិទាំងនេះ រួមមាន៖(a) សុវត្ថិភាពការកាន់កាប់ស្របច្បាប់ (b)ការរកប្រើប្រាស់បាននូវសេវា សម្ភារៈ បរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ (c) ការអាចលៃលកបាន (d) ភាពអាចរស់នៅបាន (e) ការអាចចូលទៅដល់ (f) ភាពសមស្របនៃទីតាំង និង ភាពគ្រប់គ្រាន់ខាងវប្បធម៌។ សូមមើល សេចក្តីពន្យល់ទូទៅនៃ CESCR លេខ៤៖ សិទ្ធិមានលំនៅឋានសមរម្យ (មាត្រា ១១ (១) នៃកតិកាសញ្ញា) ដែលបានអនុម័តរួចនៅសម័យប្រជុំទី៦ នៃគណៈកម្មាធិការស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩១។

ក្រទាំងនោះ ប្រើប្រាស់ធនធានកម្រដើម្បីអភិវឌ្ឍដីកសិកម្ម ប្រកបមុខជំនួញខ្នាតតូច ឬក៏គាំទ្រដល់ក្រុមគ្រួសាររបស់ពួកគេ។

- គួរផ្តល់ការគាំទ្របន្ថែមដល់គ្រួសារដែលបានផ្លាស់មករស់នៅលើទីតាំងដីសម្បទានសង្គមកិច្ច ដើម្បីធានាដល់ការចំណាយដំបូងលើការសាងសង់ផ្ទះ អភិវឌ្ឍការផ្គត់ផ្គង់ទឹកដែលមានស្ថេរភាព និងបង្កើតនូវបរិយាកាសរស់នៅដែលមានសុវត្ថិភាពដែលមិនបណ្តោយឲ្យគ្រួសារទាំងអស់នោះធ្លាក់ទៅក្នុងភាពក្រីក្រ ហើយទុកដីសម្បទានសង្គមកិច្ច ចោលគ្មាននិរន្តរភាព។

***<u>ចំពោះដីសម្បទានសង្គមកិច្ចដែលមានស្រាប់៖</u>***

- គួរមានការបង្កើតប្រភពទឹកស្អាតបរិភោគបន្ថែមទៀតជាបន្ទាន់ នៅតាមទីតាំងសម្បទានដីសង្គមកិច្ចនិមួយៗ ។ ការទទួលបានប្រភពទឹកសម្រាប់ប្រើប្រាស់នេះ មិនគួរពឹងផ្អែកលើលទ្ធភាព គ្រួសារទទួលផលឲ្យជាអ្នកជីកអណ្តូង ឬចំណាយប្រាក់ទិញទឹកស្អាតបរិភោគនោះទេ។
- តាមដែលអាចធ្វើទៅបាន គួរមានកិច្ចខិតខំប្រឹងប្រែងបង្កើនឱកាសការងារ និងធានាឲ្យមានការវិនិយោគវិស័យឯកជន នៅតាមតំបន់សម្បទានដីសង្គមកិច្ច ដើម្បីជម្រុញឲ្យមានការបង្កើតការងារ។ ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន គួរត្រូវបានបង្កើតឡើង នៅពេលដែលអាចធ្វើបាន។ គួរផ្តល់លទ្ធភាពទទួលបានឥណទានដល់គ្រួសារទទួលផលដែលមានស្រាប់ ប៉ុន្តែ មិនគួរដាក់កម្មសិទ្ធិដីធ្លីឲ្យមានហានិភ័យនោះទេ។ កំរិតបំណុល ចាំបាច់គេត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្ន។ ចាំបាច់ត្រូវមានការវិនិយោគបន្ថែម ដើម្បីជម្រុញពន្លឿនសេដ្ឋកិច្ចមូលដ្ឋាន នៅតាមតំបន់សម្បទានដីសង្គមកិច្ចដែលមានស្រាប់ ដើម្បីធានាឲ្យទីតាំងទាំងនេះមាននិរន្តរភាព។ នេះគឺជាចំណុចសំខាន់ពិសេស នៅតាមទីតាំងសម្បទានដីសង្គមកិច្ច ដែលផ្តល់តែដីលំនៅឋាន ដោយពុំមានក្បាលដីដោយឡែកសម្រាប់ការអភិវឌ្ឍផ្នែកកសិកម្ម។
- ការទទួលបានសេវាថែទាំសុខភាព និងជំនួយវេជ្ជសាស្ត្រដែលអាចលៃលកបានគួរផ្តល់ឲ្យមានសម្រាប់គ្រួសារទទួលបានដីទាំងអស់។ ស្ត្រី និងកុមារដែលងាយរងគ្រោះប្រឈមនឹងឧបសគ្គធ្ងន់ធ្ងរមួយចំនួនជាពិសេស ក្នុងការទទួលបានសេវាថែទាំសុខភាព

ដូច្នេះគួរមានការផ្តត់ផ្គង់ដល់កន្លែងនូវបរិក្ខារពេទ្យនិងការព្យាបាលសម្រាប់ក្រុមទាំងនេះ។

- វិធានការជាបន្ទាន់គួរចាត់ឡើង ដើម្បីធានាឲ្យសាលារៀន នៅតាមទីតាំងសម្បទានដីសង្គមកិច្ច មានធនធានគ្រប់គ្រាន់។ ថវិកាសម្រាប់គាំទ្រការអប់រំគួរមានកាន់តែប្រសើរឡើង ដើម្បីបញ្ចៀសបាននូវ ការធាក់ចេញ និងវិសមភាពដែលកំពុងមាន ហើយធនធានកាន់តែច្រើនបន្ថែមទៀតគួរតែត្រូវបានផ្តល់ឲ្យសម្រាប់ការអប់រំដល់គ្រួសារដែលរស់នៅតាមទីតាំងសម្បទានដីសង្គមកិច្ច ដែលពួកគេស្ថិតក្នុងចំណោមគ្រួសារក្រីក្រជាងគេក្នុងប្រទេសនេះ។ គួរមានការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីគុណតម្លៃ និងសារៈសំខាន់នៃការអប់រំក្នុងសាលារៀន ហើយចាំបាច់ត្រូវមានការវាយតម្លៃ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងវិសមភាពចំណូល។
- គ្រួសារទទួលផលគួរទទួលបានការបណ្តុះបណ្តាលជំនាញកសិកម្ម របៀបដាំដំណាំឧស្សាហកម្ម ការដាំបន្លែ ការអភិវឌ្ឍអាជីវកម្ម និងការស្វែងរកទីផ្សារសម្រាប់ដំណាំរបស់ពួកគេ។ ការកែលំអរការដាំដុះលើដីកសិកម្ម គឺជាការសំខាន់ចាំបាច់ សម្រាប់ប្រយុទ្ធប្រឆាំងនឹងបញ្ហាកង្វះអាហារូបត្ថម្ភ សន្តិសុខស្បៀង ក៏ដូចជាបង្កើនចំណូលគ្រួសារ។ ស្របតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ប្រជាជនរស់នៅលើសម្បទានដីសង្គមកិច្ច គួរអាចអនុវត្តសិទ្ធិរបស់ខ្លួនខាងសេរីភាពសម្តែងគំនិត មនសិការ ជំនឿសាសនា ការគោរពបូជា ឬប្រមូលផ្តុំដែលផ្សារភ្ជាប់ទៅនឹងជំនឿ ឬសាសនាណាមួយ ក៏ដូចជាបង្កើត និងរក្សាទីកន្លែង សម្រាប់គោលបំណងទាំងនេះ។[34] ការរៀបចំផែនការសម្បទានដីសង្គមកិច្ច គួរបញ្ចូលការពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋដែលនឹងមករស់នៅលើទីតាំងនេះ និងប្រជាពលរដ្ឋដែលកំពុងរស់នៅលើដីទីតាំងនេះស្រាប់អំពីសារៈសំខាន់នៃការផ្សាភ្ជាប់ពួកគេទៅនឹងការបង្កើត ឬការរក្សាទីកន្លែងសក្ការៈបូជា។ ប្រជាពលរដ្ឋ ដែលមានបំណងអនុវត្តសិទ្ធិខាងជំនឿសាសនា គួរទទួលបានការគាំទ្រ ដែលអាចធ្វើឡើង តាមរយៈការផ្តល់ក្បាលដី/ដីក្នុង

[34]សេចក្តីប្រកាសរបស់មហាសន្និបាតស្តីពីការលុបបំបាត់រាល់ទម្រង់នៃការមិនអធ្យាស្រ័យ និងការរើសអើងផ្អែកជំនឿ ឬសាសនា សេចក្តីសម្រេចលេខ ៣៦/៥៥ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៨១។

សម្បទានដីសង្គមកិច្ច និងធនធានផ្សេងទៀត ដែលចាំបាច់ សម្រាប់បង្កើតទីកន្លែងសក្ការៈបូជា។

- អាជ្ញាធរមូលដ្ឋានគួរធ្វើការងារជាមួយនឹងដៃគូអភិវឌ្ឍន៍ ដើម្បីផ្តល់ការគាំទ្រដល់ស្ត្រី និងក្មេងស្រី ដែលរងគ្រោះដោយសារអំពើហិង្សា។ ការគាំទ្រនេះគួរមានដូចជាការបង្កលក្ខណៈងាយស្រួលឲ្យពួកគេទៅប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ និងប្រាស្រ័យទាក់ទងជាមួយនគរបាល ការផ្តល់សេវាថែទាំសុខភាព និងសេវាគាំទ្រផ្សេងទៀត ក៏ដូចជាការការពារដើម្បីកុំឲ្យពួកគេទទួលរងអំពើហិង្សាបន្តទៀត។ អ្នកទទួលបានដីសម្បទានសង្គមកិច្ចមានដូចជាក្រុមងាយរងគ្រោះ ដូចជា ស្ត្រីក្រីក្រ ដែលរស់នៅតំបន់ដាច់ស្រយាលជាដើម ដែលទំនងជាមានជម្រើសតិចតួច ហើយជារឿយៗ ខ្វះលទ្ធភាពទទួលបានសេវាជាមូលដ្ឋាន ដូចប្រជាជនកម្ពុជាទូទៅ។
- មានសេចក្តីត្រូវការនូវការវិភាគបន្ថែមទៀត ដើម្បីរកមូលហេតុការកើនឡើងបំណុលនៃគ្រួសារក្នុងតំបន់សម្បទានដីសង្គមកិច្ច។

**ព្រះរាជអាជ្ញា និងក្រសួងយុត្តិធម៌៖**

- គ្រួសារទទួលផលក្នុងចំនួនដ៏ច្រើនអះអាងថា ពួកគេត្រូវបង់លុយ ដើម្បីឲ្យគេជ្រើសរើសបែងចែកដីឲ្យ។ គួរមានការស៊ើបអង្កេតឲ្យបានពេញលេញលើការចោទប្រកាន់ថាមានអំពើពុករលួយកើតឡើង។ មន្ត្រីមូលដ្ឋានដែលត្រូវបានរកឃើញថា បានជម្រិតប្រាក់ពីគ្រួសារទទួលផល ឬអ្នកពាក់ព័ន្ធផ្សេងទៀត គួរទទួលបានការផ្តន្ទាទោស។
- ចាំបាច់ត្រូវបង្កើតយន្តការដោះស្រាយជម្លោះដីធ្លីថ្មី ឬពង្រឹងយន្តការដែលមានស្រាប់ ដើម្បីផ្តល់លទ្ធភាពឲ្យបុគ្គល និងសហគមន៍ ដែលជឿថា ពួកគេត្រូវបានបណ្តេញចេញ ឬទទួលរងការលំបាកដោយភាពអយុត្តិធម៌ ដោយសារការបង្កើតសម្បទានដីសង្គមកិច្ច អាចទទួលបានដំណោះស្រាយ។ គួរផ្តល់ជំនួយផ្លូវច្បាប់ ដើម្បីគាំទ្រដល់ជនរងគ្រោះដោយសារការដណ្តើមយកដីឬការទន្ទ្រានយកដីពីក្រុមហ៊ុនឯកជនឬតួអង្គផ្សេងទៀត។

- គួរមានការបង្កើតស្ថាប័នបច្ចេកទេសឯករាជ្យមួយសម្រាប់ទទួល និងដោះស្រាយរាល់ការកើតទុក្ខមិនសុខចិត្ត និងពាក្យបណ្តឹងទាំងអស់ដែលទទួលបានពីទីតាំងសម្បទានដីសង្គមកិច្ចនៅទូទាំងប្រទេស។
- គួរមានការស៊ើបអង្កេតឲ្យបានពេញលេញលើការគំរាមកំហែងដល់គ្រួសារទទួលផលសម្បទានដីសង្គមកិច្ច ឲ្យលក់ដីរបស់ខ្លួន។ បុគ្គលដែលត្រូវបានគេបង្ខំឲ្យលក់ដី គួរទទួលបានដំណោះស្រាយ។

**ទីភ្នាក់ងារសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍៖**

- អង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងារអង្គការសហប្រជាជាតិ គួរបំពេញតួនាទីឲ្យកាន់តែសកម្មបន្ថែមទៀតនៅតាមទីតាំងសម្បទានដីសង្គមកិច្ច តាមរយៈការពិនិត្យមើល និងវាយតម្លៃលើកម្រិតជីវភាពរស់នៅ និងការធ្វើឲ្យអាជ្ញាធរមូលដ្ឋានមានគណនេយ្យភាពចំពោះការផ្ទៀងផ្ទាត់ជាលក្ខណៈឯករាជ្យលើដំណើរការនៃការបែងចែកដី និងដំណើរការផ្សេងទៀត។
- ដៃគូអភិវឌ្ឍន៍ដែលផ្តល់ហិរញ្ញប្បទានដល់ការបង្កើតសម្បទានដីសង្គមកិច្ចគួរផ្តល់ការគាំទ្រដ៏សមស្របដល់ការតាំងលំនៅជាលក្ខណៈឯកជន។ ឧទាហរណ៍ របាយការណ៍របស់ធនាគារពិភពលោកស្តីពីទិន្នន័យអនុវត្តគម្រោង របស់ LASED បញ្ជាក់ថា ១០០% នៃគ្រួសារដែលបំពេញតាមលក្ខខណ្ឌតម្រូវរបស់ LASED បានទទួលការគាំទ្រសមស្របសម្រាប់ការតាំងទីលំនៅជាលក្ខណៈឯកជន។[35] ការគាំទ្រការតាំងទីលំនៅ គួរពង្រីកដល់គ្រួសារទទួលបានសម្បទានដីសង្គមកិច្ចដែលមិនស្ថិតក្រោមគម្រោង LASED ផងដែរ។ គួរមានការពិនិត្យឡើងវិញលើកម្រិត និងប្រភេទនៃការគាំទ្រផងដែរ។

[35]ស្ថានភាព និងលទ្ធផលនៃការអនុវត្ត - ការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច នៅកម្ពុជា (P084787) - របាយការណ៍ធនាគារពិភពលោកលេខ ISR11681

## សង្ខេបលទ្ធផលរកឃើញជារួមនៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦

### ប្រជាសាស្ត្រ៖

ការអង្កេតត្រូវបានធ្វើឡើងជាមួយប្រជាពលរដ្ឋចំនួន ៦៨០ ខ្នងផ្ទះ ដោយឡែកៗពីគ្នា ដែលប្រព្រឹត្តិទៅនៅក្នុងខេត្តត្បូងឃ្មុំ កំពង់ស្ពឺ បាត់ដំបង កំពង់ធំ មណ្ឌលគិរី និងកំពត។ តាមខេត្តនីមួយៗ ក៏មានការសម្ភាសជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងតំណាងអង្គការមិនមែនរដ្ឋាភិបាលផងដែរ[36]។

៦៦% នៃអ្នកឆ្លើយតបចំពោះការសម្ភាសដែលជាអ្នកទទួលផលសម្បទានដីសង្គមកិច្ច គឺជាស្ត្រី ទោះបីជាយ៉ាងណានេះក៏ដោយ មានតែ ២៨% ប៉ុណ្ណោះនៃអ្នកឆ្លើយតបដែលជាមេគ្រួសារ គឺជាស្ត្រី។ នេះ គឺជានិន្នាការដែលមានដូចគ្នានៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់។ អ្នកឆ្លើយតប ៨២% លើកឡើងថា ពួកគេបានរៀបការហើយ ឬកំពុងរស់នៅជាមួយអ្នកដែលពួកគេមានទំនាក់ទំនងជាមួយ ហើយ ១៣% គឺស្ត្រីមេម៉ាយ/បុរសពោះម៉ាយ ឬលែងលះ។ ការជ្រើសរើសអ្នកឆ្លើយតបចំពោះការសម្ភាស ឆ្លុះបញ្ចាំងពីការបែងចែកអ្នកទទួលផលសម្បទានដីសង្គមកិច្ចតាមយេនឌ័រនៅលើទីតាំងសម្បទានដីសង្គមកិច្ចចំនួន ៣ កន្លែង ដោយមានតែខេត្តកំពតប៉ុណ្ណោះ ដែលមានអ្នកទទួលផលជាបុរស ពេញវ័យក្នុងចំនួនច្រើនជាងស្ត្រី។ អាជ្ញាធរមូលដ្ឋាន ដែលត្រូវបានសម្ភាសក្នុងខេត្តមណ្ឌលគិរី និងកំពង់ធំ មិនអាចផ្តល់ព័ត៌មានលំអិតអំពីអ្នកទទួលផលដែលបែងចែកតាមយេនឌ័រនោះទេ។ ការរើសអើងយេនឌ័រក្នុងការបែងចែកផ្តល់ដី ហាក់បីដូចជាមិនមានបញ្ហានោះទេ បើទោះបីជាការពិនិត្យតាមដាន និងការប្រមូលទិន្នន័យ ហាក់បីដូចជាមិនបានធ្វើឲ្យដូចៗគ្នាក្នុងទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦ ក៏ដោយ។ ការរើសអើងយេនឌ័រ ហាក់បីដូចជាបញ្ហាដែលកើតមានជាប់ជុំវិញការទទួលបានការអប់រំ។ បញ្ហានេះ ត្រូវបានលើកយកមកពិភាក្សាខាងក្រោម (សូមមើលទំព័រ៤៥)។

---

[36] ការសម្ភាសត្រូវបានធ្វើនៅចុងឆ្នាំ២០១៥ និងដើម២០១៦។ អង្គការមិនមែនរដ្ឋាភិបាល បានសម្ភាសរួមមាន ADHOC Wathanakpheap អង្គការVigilance DCA LWD LICADHO និង CLEC។ អាជ្ញាធរមូលដ្ឋាន បានសម្ភាសរួមមាន មេឃុំ មេភូមិ និងសមាជិកក្រុមប្រឹក្សាឃុំ។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ក៏ពិគ្រោះយោបល់ផងដែរ។

អាយុមធ្យមរបស់អ្នកឆ្លើយតបគឺ ៤៦ ឆ្នាំ។ ជាមធ្យមទំហំគ្រួសារមួយ រស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់មានសមាជិក ៤,៧៥ នាក់ (ក្នុងមួយខ្នងផ្ទះ) និងមានកូនជាមធ្យម ២,៣ នាក់។ មិនមែនពួកគេទាំងអស់ រស់នៅលើទីតាំងទាំងនេះជាប្រចាំនោះទេ។ ក្នុងករណីមួយចំនួន គ្រួសារអ្នកទទួលផលដំបូងដែលបន្តរស់នៅលើទីតាំងទាំងនេះមានត្រឹមតែ ១០% ប៉ុណ្ណោះ។[37] ចំណុចនេះត្រូវបានលើកយកមកវិភាគបន្តទៀត ក្នុងរបាយការណ៍ស្តីពីសម្បទានដីសង្គមកិច្ចនីមួយៗដូចខាងក្រោម។ អ្នកឆ្លើយតបភាគច្រើនលើសលុប (៩៨%) បានពិពណ៌នាខ្លួនឯងថា ជាជនជាតិខ្មែរ ហើយអ្នកដែលនៅសេសសល់ប្រកាសខ្លួនឯងថា ជាជនជាតិភាគតិចចាម។ ខេត្តមណ្ឌលគិរី គឺជាទីតាំងសម្បទានដីសង្គមកិច្ចតែមួយគត់ដែលអ្នកតាំងទីលំនៅលើកឡើងថាពួកគេជាជនជាតិភាគតិចចាម។

រយៈពេលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចជាមធ្យម គឺ ៨២ ខែ (ស្មើនឹង ៦,៨ ឆ្នាំ)។ រយៈពេលកំណត់សម្រាប់ស្នើសុំប័ណ្ណកម្មសិទ្ធិដីជាផ្លូវការដូចដែលមានចែងក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច គឺរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចឲ្យបានយ៉ាងតិចបំផុត ៦០ ខែ ឬស្មើនឹង ៥ ឆ្នាំ។ មានតែអ្នកឆ្លើយតបដែលរស់នៅក្នុងខេត្តបាត់ដំបង និងត្បូងឃ្មុំប៉ុណ្ណោះ ដែលជាមធ្យម រស់នៅលើសពីរយៈពេលកំណត់ ៦០ ខែ ហើយអ្នកតាំងទីលំនៅ អាចថា ទាំងអស់ដែលត្រូវបានអង្កេតនៅទីតាំងសម្បទានដីសង្គមកិច្ចទាំងពីរ បានទទួលប័ណ្ណកម្មសិទ្ធិ។ ជារួម មានខ្នងផ្ទះ ៥៦% ក្នុងទីតាំងទាំងអស់បានទទួលប័ណ្ណកម្មសិទ្ធិដី។ ស្ទើរតែពុំមានអ្នកតាំងទីលំនៅណាម្នាក់ ក្នុងខេត្តកំពត មណ្ឌលគិរី កំពង់ស្ពឺ ឬកំពង់ធំ បានទទួលប័ណ្ណកម្មសិទ្ធិដីឡើយ។ លក្ខខណ្ឌតម្រូវ ផ្តល់ចំពោះអ្នកទទួលផលដែលស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ និងគោរពតាមលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសម្បទានដីសង្គមកិច្ច រួមមានការរស់នៅទីនោះឲ្យបាន ៥ ឆ្នាំសិន ហាក់បីដូចជាត្រូវបានបំពេញក្នុងករណីភាគច្រើន។

[37] ចំនួនប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ច មានការឡើងចុះ ដោយគ្រួសារដែលត្រូវបានអង្កេតស្ទើរតែទាំងអស់លើកឡើងថា សមាជិកគ្រួសាររបស់ពួកគេធ្វើចំណាកស្រុកទៅរកការងារធ្វើ និងស្វែងរកការអប់រំ។

ទោះជាយ៉ាងណាក៏ដោយ ក៏តួលេខសរុបបែបនេះមិនអាចឲ្យគេពិនិត្យដឹងពីគ្រួសារដែលអាចនឹងមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិ ប៉ុន្តែនៅមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិនោះទេ។ ជីវភាពរស់នៅក្រីក្រ និងបញ្ហាប្រឈមមួយចំនួន ដូចជា កង្វះសេវាជាមូលដ្ឋាន និងឱកាសការងារតិចតួច កំពុងបង្កផលប៉ះពាល់ដល់លទ្ធភាពរបស់គ្រួសារទទួលបានដីក្នុងការបំពេញទៅតាមលក្ខណៈវិនិច្ឆ័យ បានចែងក្នុងអនុក្រឹត្យនេះដែលស្តីពីការតម្រូវឲ្យមានជាចាំបាច់នូវការកាន់កាប់ជាបន្តបន្ទាប់រយៈពេល ៥ ឆ្នាំ ទើបទាមទារសិទ្ធិមានកម្មសិទ្ធិបាន។

| ខេត្ត | បាត់ដំបង | ត្បូងឃ្មុំ | កំពង់ស្ពឺ | កំពង់ធំ | កំពត | មណ្ឌលគិរី |
|---|---|---|---|---|---|---|
| ចំនួនខែ ការរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចជាមធ្យម | ១៣១ | ៧២ | ៣៧ | ៣៥ | ៥៧ | ៤៧ |

**ការបែងចែកដី៖**

នៅពេលសួរពីមូលហេតុដែលពួកគេបានទទួលដីក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះ អ្នកទទួលផលដែលបានសាកសួរ ៨១% ឆ្លើយថា ដោយសារតែពួកគេគ្មានដី ហើយ ៥៩% លើកឡើងពីភាពក្រីក្រ។ មានគ្រួសារតែ ១% ប៉ុណ្ណោះ ដែលអះអាងថា ពួកគេត្រូវបានគេផ្លាស់ប្តូរទីលំនៅ ដើម្បីផ្តល់ទីតាំងសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ ១១% លើកឡើងថា ពួកគេផ្លាស់ទីលំនៅ ដោយសារតែឱកាសការងារនៅតាមចំការនៃសម្បទានដីសេដ្ឋកិច្ច។ គ្រួសារដែលលើកឡើងបែបនេះ មានតែអ្នកមកពីខេត្តមណ្ឌលគិរី និងត្បូងឃ្មុំតែប៉ុណ្ណោះ។ មានចំណុចត្រួតគ្នាត្រង់នេះដោយអ្នកឆ្លើយតបបានផ្តល់នូវចម្លើយជាច្រើនដែលជាហេតុផលនាំឲ្យពួកគេទទួលបានដី។ ស្របពេលដែលការលើកទឹកចិត្ត និងតម្រូវការមានលក្ខណៈផ្សេងគ្នាទៅតាមខេត្ត -អ្នកទទួលផលភាគច្រើនក្នុងខេត្តកំពង់ធំលើកឡើងថា ពួកគេផ្លាស់ប្តូរទីកន្លែងរស់នៅ ដោយសារតែគ្រោះមហន្តរាយធម្មជាតិ អ្នក

ទទួលផលក្នុងចំនួនច្រើនដ៏លើសលុប ហាក់បីដូចជាគ្រួសារក្រីក្រ គ្មានដីដែលត្រូវការ ជំនួយ។ នៅពេលសាកសួរថា ហេតុអ្វីបានជាគ្រួសារផ្សេងទៀតដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះទទួលបានដី ចម្លើយគឺដូចគ្នានឹងករណីខាងលើដែរ - ការគ្មានដី និងភាពក្រីក្រ។ ប៉ុន្តែ មូលហេតុដំបូងដែលនាំឲ្យគ្រួសារទាំងនេះគ្មានដីមិនត្រូវបានដឹងច្បាស់នោះទេ។

មាត្រា ៧ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ចែងថា កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចត្រូវបានផ្តួចផ្តើមឡើងនៅ "កន្លែងដែលមានកម្មវិធីតាំងទីលំនៅថ្មីសម្រាប់គ្រួសារច្រើន ដូចជាករណីអ្នករស់នៅដែលជាអ្នកតាំងលំនៅឋានមិនផ្លូវការ ឬគ្រួសារដែលត្រូវផ្លាស់ប្តូរទីកន្លែងជាដើម" ឬ "កន្លែងដែលមានកម្មវិធីសម្បទានដីសង្គមកិច្ចអាចផ្សារភ្ជាប់ទៅនឹងសម្បទានដីសេដ្ឋកិច្ច ដើម្បីអភិវឌ្ឍកសិឧស្សាហកម្ម"។ បើទោះបីជាការបង្កើតសម្បទានដីសេដ្ឋកិច្ច សម្រាប់គោលបំណងអភិវឌ្ឍកសិឧស្សាហកម្ម មានសារៈសំខាន់ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងណាក៏ដោយ វាមិនគួរប្រើជាហេតុផលសម្រាប់បណ្តេញប្រជាជនចេញពីដី ហើយមិនគួរធ្វើឲ្យប្រជាពលរដ្ឋលែងមានដី ឬត្រូវការដីបន្ថែមសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេនោះឡើយ។ គួរឲ្យចាប់អារម្មណ៍ មានតែមួយគ្រួសារទេ ក្នុងចំណោម៦៨០ខ្នងផ្ទះ បានសម្ភាស បានអះអាងថា ត្រូវបានបណ្តេញ ចេញពីផ្ទះពីមុនរបស់គាត់។ ក្នុងសម្បទានដីសង្គមកិច្ច ៣ កន្លែង គ្រួសារ និងសហគមន៍ជនជាតិដើមភាគតិចរស់នៅជុំវិញទីតាំងសម្បទានដីសង្គមកិច្ច ពិតជាបានលើកឡើងថា ពួកគេត្រូវបានបណ្តេញចេញ ដើម្បីយកដីប្រើសម្រាប់ផ្តល់សម្បទានដីសង្គមកិច្ច។ ករណីនីមួយៗត្រូវបានបង្ហាញដោយសង្ខេប ដូចខាងក្រោម។

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់រដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៥-២០០៦ ដោយក្រសួងផែនការ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ទូទាំងប្រទេស។ ក្នុងឆ្នាំ ២០០៥ ក្រសួងផែនការបានរៀបចំនីតិវិធី និងឧបករណ៍ ជាបទដ្ឋានមួយសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដែលរស់នៅតំបន់ជនបទ ក្រោមការគាំទ្រពី GIZ

និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដូចជា រដ្ឋាភិបាលអូស្ត្រាលី គណៈកម្មការអឺរ៉ុប និងយូនីសេហ្វ ជាដើម។[38] គ្រួសារ ដែលត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារក្រីក្រ តាមរយៈដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រនេះ ទទួលបាន "ប័ណ្ណសមធម៌" ឬប័ណ្ណសម្គាល់អត្តសញ្ញាណគ្រួសារក្រីក្រ។[39] គ្រួសារក្រីក្រអាចប្រើប្រាស់ប័ណ្ណសមធម៌ទាំងនេះ ដើម្បីទទួលបានសេវាជាច្រើន ដែលផ្តល់ដោយរដ្ឋាភិបាល និងអង្គការផ្សេងទៀត។

| ខេត្ត | បាត់ដំបង | ត្បូងឃ្មុំ | កំពង់ស្ពឺ | កំពង់ធំ | កំពត | មណ្ឌលគិរី | មធ្យម |
|---|---|---|---|---|---|---|---|
| ភាគរយនៃគ្រួសារទទួលផលសម្បទានដីសង្គម ដែលកាន់ប័ណ្ណអត្តសញ្ញាណកម្មក្រីក្រ | ៨៤% | ៥២% | ៧០% | ៥០% | ៨៩% | ១៩% | ៧២% |

បច្ចុប្បន្ននេះ ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្ត្រជាតិគាំពារសង្គមរបស់រដ្ឋាភិបាល[40] ដែលបានដាក់ចេញនូវដំណើរការដែលមានលក្ខណៈបរិយាប័ន្ន តម្លាភាព (ស្ថិតិថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ អាចរកបាន តាមរយៈគេហទំព័រនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

[38] សូមមើលកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការ រាជរដ្ឋាភិបាលកម្ពុជា អាចរកបានតាមរយៈគេហទំព័រៈ http://www.mop.gov.kh/Projects/IDPoor/tabid/154/Default.aspx

[39] ប័ណ្ណនេះមានដាក់រូបថតសមាជិកគ្រួសារ លេខកូដគ្រួសារ កម្រិតនៃភាពក្រីក្ររបស់គ្រួសារ រយៈពេលសុពលភាពរបស់ប័ណ្ណនេះ និងព័ត៌មានទូទៅអំពីរបៀបប្រើប្រាស់ប័ណ្ណ។

[40] សូមមើលយុទ្ធសាស្ត្រជាតិគាំពារសង្គម ២០១១-២០១៥ អនុម័តដោយគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១។ យុទ្ធសាស្ត្រជាតិគាំពារ សង្គម លើកឡើងថា "រាជរដ្ឋាភិបាលកម្ពុជាមានបំណងយកវិធីសាស្ត្រអត្តសញ្ញាណកម្មគ្រួសារក្រីក្រនេះ មកធ្វើជាវិធីសាស្ត្រកំណត់មុខសញ្ញាក្រុមគោលដៅបឋម សម្រាប់គ្រប់គម្រោងគាំពារសង្គមទាំងអស់ ហើយក្នុងពេលជាមួយគ្នា ផ្តល់អនុសញ្ញាឲ្យមានការប្រើប្រាស់វិធីសាស្ត្របំពេញបន្ថែម ក្នុងករណីដែលមានហេតុផលប្រើប្រាស់វិធីសាស្ត្រនេះ។"

របស់ក្រសួងផែនការ)[41] និងស្របច្បាប់ដើម្បីកំណត់រកគ្រួសារដែលត្រូវការជំនួយជាងគេ។ ការដាក់ឲ្យអនុវត្តនូវអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងឆ្នាំ២០១១ បានបង្កើនប្រសិទ្ធភាពតាមរយៈការដាក់ចេញនូវមូលដ្ឋានច្បាប់ សម្រាប់ប្រព័ន្ធកំណត់អត្តសញ្ញាណកម្មបែបនេះ និងមិនធ្វើឲ្យមានការត្រួតគ្នា។ ចាប់តាំងពីពេលនោះមក ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រនេះត្រូវបានប្រើប្រាស់ជានីតិវិធីស្តង់ដា សម្រាប់កម្មវិធីដែលកំណត់រកគ្រួសារក្រីក្រ និងតំបន់ក្រីក្រធ្វើជាមុខសញ្ញាទទួលផល[42] ហើយបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់ដោយអាជ្ញាធរមូលដ្ឋានភាគច្រើនដែលបានចូលរួមក្នុងការអង្កេតនេះ ដើម្បីជួយជ្រើសរើសមុខសញ្ញាទទួលបានដីសម្បទានសង្គមកិច្ច។

តួលេខចំនួនប្រជាជនដែលកាន់ប័ណ្ណសម្គាល់អត្តសញ្ញាណគ្រួសារក្រីក្រ មានការប្រែប្រួលគួរឲ្យកត់សម្គាល់។ ជាសរុប មានអ្នកឆ្លើយតប ប្រហាក់ប្រហែល ៧២% ដែលមានប័ណ្ណសម្គាល់អត្តសញ្ញាណគ្រួសារក្រីក្រ ប៉ុន្តែ នៅតាមទីតាំងសម្បទានដីសង្គមកិច្ចមួយចំនួន ដូចជា ខេត្តមណ្ឌលគិរី ជាដើម មានគ្រួសារតែ ១៩% ប៉ុណ្ណោះ ដែលមានប័ណ្ណនេះ។ ប័ណ្ណអត្តសញ្ញាណកម្មក្រីក្រ មានសុពលភាពប្រើប្រាស់បានតែ៣ឆ្នាំប៉ុណ្ណោះ ដូច្នេះហើយ ប័ណ្ណដែលហួសពេលកំណត់ និងបោះបង់ចោល ក៏ជារឿងបញ្ហាមួយដែរ។ គ្រួសារ ៧៧% អះអាងថា ភាពក្រីក្រ គឺជាកត្តាមួយដែលនាំឲ្យពួកគេទទួលបានដី ប៉ុន្តែ ច្រើនជាងមួយភាគបីនៃគ្រួសារទាំងនេះ ពុំមានឯកសារត្រឹមត្រូវដើម្បីបញ្ជាក់ចំណុចនេះក្នុងដំណើការជ្រើសរើសជាផ្លូវការនោះឡើយ។ ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គួរត្រូវបានប្រើប្រាស់ដើម្បីកំណត់ពីលក្ខណៈសម្បត្តិសមស្របរបស់អ្នកដាក់ពាក្យសុំដី ដែលត្រូវជ្រើសរើស - បច្ចុប្បន្ននេះ ទិន្នន័យនេះគឺជាមធ្យោបាយចម្បង សម្រាប់វាយតម្លៃកម្រិតនៃភាពក្រីក្រ និងអ្នកសុំដីដែលបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្រប។[43]

[41] សូមមើលកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ប្រព័ន្ធទិន្នន័យនៃមជ្ឈមណ្ឌលព័ត៌មានអត្តសញ្ញាណគ្រួសារក្រីក្រ ក្រសួងផែនការ អាចរកបានតាមរយៈគេហទំព័រ៖ www.idpoor.gov.kh/en/reports/2/2

[42] សូមមើលកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការ រាជរដ្ឋាភិបាលកម្ពុជា អាចរកបានតាមរយៈគេហទំព័រ៖ http://www.mop.gov.kh/Projects/IDPoor/tabid/154/Default.aspx

[43] មាត្រា ១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣) ចែងថា អ្នកស្នើសុំដីសម្បទាន សង្គមកិច្ច គួរបំពេញលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុ ដែលកំណត់ដោយក្រសួងសង្គមកិច្ច ការងារ

អនុក្រឹត្យលេខ ២៩១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (នីតិវិធី និងវិធានទើបតែត្រូវបានដាក់ឲ្យអនុវត្តជាផ្លូវការក្នុងឆ្នាំ២០១១ប៉ុណ្ណោះ) ចែង អំពីរបៀបគួរកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ។[44] នីតិវិធីទាំងនេះតម្រូវឲ្យមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមតំណាងភូមិដែលត្រូវបានជ្រើសរើសដោយអ្នកភូមិ ស្របទៅតាមគោលការណ៍ប្រជាធិបតេយ្យ។ ការចាត់ចំណាត់ថ្នាក់ភាពក្រីក្ររបស់គ្រួសារ ត្រូវគណនាដោយបូកសរុបពិន្ទុ ផ្អែកតាមការឆ្លើយតបដែលបានពីការសម្ភាស និងតាមរយៈការពិភាក្សាពីស្ថានភាពជាក់ស្តែងរបស់គ្រួសារនីមួយៗ។[45]

នៅកន្លែងដែលគ្រួសារភាគច្រើនខ្វះខាតប័ណ្ណគ្រួសារក្រីក្រ គេមានមន្ទិលសង្ស័យពីសុពលភាពនៃដំណើរការជ្រើសរើសនេះ។ អ្នកទទួលបានដីសម្បទានសង្គមកិច្ចទាំងអស់បានបែងចែកដីឲ្យ ក្រោយអនុក្រឹត្យ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឆ្នាំ២០១១ គួរមានប័ណ្ណគ្រួសារក្រីក្រទាំងនេះ ដែលនេះជាមធ្យោបាយស្នូល សម្រាប់វាយតម្លៃកម្រិតភាពក្រីក្រ ហើយដើម្បីកំណត់ អត្តសញ្ញាណអ្នកដាក់ពាក្យសុំដែលមានលក្ខណៈសម្បត្តិអាចទទួលបាន និងអ្នកទទួលដីទាំងនេះ។ កង្វះប័ណ្ណគ្រួសារក្រីក្រ អាចដោយសារតែប័ណ្ណទាំងនេះហួសរយៈពេលកំណត់ (មានសុពលភាពរយៈពេលតែ៣ឆ្នាំប៉ុណ្ណោះ) គ្រួសារទាំងនេះលែងត្រូវបានគេចាត់ទុកថារស់នៅក្នុងភាពក្រីក្រទៀត ឬដោយសារតែកាលពីដំបូង មានការប្រើប្រាស់មធ្យោបាយផ្សេងទៀត ដើម្បីវាយតម្លៃកម្រិតនៃភាពក្រីក្រ នៅពេលដែលសម្បទានដីសង្គមកិច្ចត្រូវបានបង្កើតដំបូង។ ប័ណ្ណទាំងនេះអាចមិនត្រូវបានអាជ្ញាធរមូលដ្ឋានចេញឲ្យ។ បើទោះបីជាអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ដែលត្រូវបាន

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយផ្អែកលើយោបល់របស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ។ គោលការណ៍ណែនាំអំពីការវាយតម្លៃប្រាក់ចំណូលត្រូវពិចារណាដោយផ្អែកលើទំហំគ្រួសារ និងលក្ខខណ្ឌ អាយុ និងសុខភាពនៃសមាជិកគ្រួសារ។ គោលការណ៍ណែនាំនេះអាចប្រែប្រួលទៅតាមតំបន់ ទៅតាមពេលវេលា ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច និងជីវភាពរស់នៅ។

[44] អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ លេខ ២៩១ អនក្រ.បក ឯកភាពដោយគណៈរដ្ឋមន្ត្រី ក្នុងកំឡុងកិច្ចប្រជុំពេញអង្គ កាលពីថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១១។

[45] អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ លេខ ២៩១ អនក្រ.បក មាត្រា ១១ និង ១២។

ចេញមុនអនុក្រឹត្យអត្តសញ្ញាណកម្មគ្រួសារក្រីក្រក៏ដោយ ក៏ពុំបានតម្រូវឲ្យមានការប្រើប្រាស់ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែរ ហើយអនុក្រឹត្យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក៏បានចែងយ៉ាងច្បាស់ថា ទិន្នន័យគ្រួសារក្រីក្រថ្នាក់ជាតិដែលមានសុពលភាពនេះគួរត្រូវបានប្រើប្រាស់នៅកន្លែងដែលពុំមានទិន្នន័យទាំងនេះត្រូវបានប្រើប្រាស់។ ចំណុចនេះគួរចាត់ទុកថាជាការអនុវត្តមិនទាន់បានល្អ។ គ្មានជម្រើសផ្សេងៗណាដែលមានលក្ខណៈស្របច្បាប់ មានតម្លាភាព មានបរិយាប័ន្ន និងមានគណនេយ្យភាព ត្រូវបានគេរកឃើញឡើយ មកដល់បច្ចុប្បន្ននេះ។ នៅទីតាំងសម្បទានដីសង្គមកិច្ចក្នុងខេត្តមណ្ឌលគិរី ពុំមានមេភូមិ មេឃុំ ឬបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា អាចបញ្ជាក់ថាតើលក្ខណៈវិនិច្ឆ័យណាខ្លះដែលត្រូវបានគេយកមកប្រើប្រាស់ ក្នុងដំណើរការជ្រើសរើសឡើយ ដោយពួកគេបានលើកឡើងថា ពួកគេពុំបានចូលរួមក្នុងដំណើរការជ្រើសរើសនេះឡើយ។ ការជ្រើសរើសមុខសញ្ញាទទួលដីដោយពុំមានសមធម៌ អាចធ្វើឲ្យប៉ះពាល់ដល់នីតិវិធីផ្តល់សម្បទានដីសង្គមកិច្ចទាំងមូល និងធ្វើឲ្យមានមន្ទិលសង្ស័យដល់សុពលភាពរបស់កម្មវិធីនេះ។

គ្រួសារតាមផ្ទះភាគច្រើន (៨៣%) បានលើកឡើងថា ពួកគេ បានចូលរួមក្នុង<u>ដំណើរការកំណត់ និងរៀបចំផែនការនៅតាមទីតាំងសម្បទានដីសង្គមកិច្ចដែរ</u> ដោយមានអ្នកតាំងទីលំនៅ ៨៣% បានបញ្ជាក់ថា អាជ្ញាធរមូលដ្ឋានបានពន្យល់ពីមូលហេតុដែលពួកគេត្រូវបានជ្រើសរើសឲ្យទទួលដី។ ប៉ុន្តែ តួលេខមានការប្រែប្រួលគួរឲ្យកត់សម្គាល់ ដោយក្នុងខេត្តមណ្ឌលគិរី និងកំពង់ធំ មានអ្នកតាំងទីលំនៅត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ ដែលបានចូលរួមយ៉ាងសកម្ម។ អ្នកតាំងទីលំនៅក្នុងភាគរយតិចជាងនេះ (៦៩%) បានលើកឡើងថា អាជ្ញាធរបានពន្យល់ពីដំណើរការជ្រើសរើស និងបែងចែកដី និងប្រើប្រាស់ប្រព័ន្ធចាប់ឆ្នោតដើម្បីបែងចែកដី។ បរិមាណ និងគុណភាពនៃការពិគ្រោះយោបល់រវាងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានក៏មានការប្រែប្រួលខុសគ្នាគួរឲ្យកត់សម្គាល់ផងដែរ។

របកគំហើញនៃការអង្កេតទាំងនេះបង្ហាញពី<u>ការចូលរួមសហការពីអាជ្ញាធរមូលដ្ឋានជាមួយនឹងគ្រួសារទទួលផលភាគច្រើន</u> ក្នុងការរៀបចំផែនការ និងអភិវឌ្ឍទីតាំងដីតាំងពី

ដំបូងៗ ក្នុងខេត្តកំពង់ស្ពឺ ត្បូងឃ្មុំ និងកំពត។ ការចូលរួម សហការបែបនេះហាក់បីដូចជាធ្វើឡើងតែជាមួយនឹងគ្រួសារមួយចំនួនតូច ដែលបច្ចុប្បន្នកំពុងរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចក្នុងខេត្តកំពង់ធំ ហើយមានការចូលរួមសហការដោយមានកំរិតណាស់នៅទីតាំងសម្បទានដីសង្គមកិច្ច ក្នុងខេត្តមណ្ឌលគិរី និងបាត់ដំបង។ នៅកន្លែងដែលមានកិច្ចពិគ្រោះយោបល់ វាមិនបង្ហាញភស្តុតាងជាក់ច្បាស់ថា វាជាការអនុវត្តល្អនោះឡើយ ផ្ទុយទៅវិញ វាគឺជាការឆ្លុះបញ្ចាំងពីការយល់ឃើញរបស់ប្រជាពលរដ្ឋថាតើពួកគេគិតថាពួកគេបានចូលរួមក្នុងដំណើរការរៀបចំផែនការ ឬអត់។

កម្រិតនៃកិច្ចពិគ្រោះយោបល់ និងការចូលរួមក្នុងការរៀបចំផែនការ និងការអភិវឌ្ឍមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងការយល់ឃើញរបស់អ្នកទទួលផល ថាតើការបែងចែកដីធ្វើឡើងប្រកបដោយសមធម៌ និងយុត្តិធម៌ដែរឬទេ។ ប្រជាជនដែលរស់នៅលើដីសម្បទានសង្គមកិច្ចចាត់ទុកដំណើការនេះ ថាមានភាពយុត្តិធម៌ នៅពេលដែលមានកិច្ចពិគ្រោះយោបល់សមស្របត្រូវបានធ្វើឡើង នៅពេលដែលពួកគេបានទទួលឯកសារចាំបាច់នានា និងនៅពេលដែលអាជ្ញាធរបានអញ្ជើញពួកគេឲ្យចូលរួម។ ការយល់ឃើញបែបនេះមានកម្រិតខ្ពស់បំផុត ក្នុងខេត្តកំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ ដែលមានប្រជាជនជាង ៩៥% ជឿថា <u>ដំណើរការបានអនុវត្តបែងចែកដីធ្វើឡើងប្រកបដោយយុត្តិធម៌</u>។ ផ្ទុយទៅវិញក្នុងខេត្តបាត់ដំបងវិញ តួលេខនេះមានត្រឹមតែ ២៧% ប៉ុណ្ណោះ ដែលបង្ហាញពីការមិនពេញចិត្តខ្លាំងជាមួយនឹងដំណើរការនេះ។ នេះអាចទំនងជាកើតឡើងចេញពីលទ្ធផលនៃការពិតមួយដែលសម្បទានដីសង្គមកិច្ច ត្រូវបានបង្កើតឡើងនៅ លើដីមានជម្លោះ ហើយគ្រួសារទទួលផលសម្បទានដីសង្គមកិច្ចនោះ មិនទាន់បានកាន់កាប់ក្បាលដីកសិកម្មនៃដីដែលគេ បានសន្យាផ្តល់ឲ្យនៅឡើយ។

| ខេត្ត | បាត់ដំបង | ត្បូងឃ្មុំ | កំពង់ស្ពឺ | កំពង់ធំ | កំពត | មណ្ឌលគិរី | មណ្ឌលគិរី |
|---|---|---|---|---|---|---|---|
| ភាគរយនៃគ្រួសារទទួលផលសម្បទានដីសង្គម ដែលបានថែងថា ការចែកចាយដីសម្បទានសង្គមកិច្ចប្រកបដោយ "សមធម៌ និងត្រឹមត្រូវ" | ២៧% | ៩៦% | ៩៨% | ៨៦% | ៨៩% | ៥៥% | ៦៧% |

៧៩គ្រួសារ ឬ១២%នៃអ្នកឆ្លើយតប(ជាបឋមនៅក្នុងខេត្តបាត់ដំបង និងមណ្ឌលគិរី) បានលើកឡើងថា ពួកគេបានបង់លុយទៅឲ្យអាជ្ញាធរមូលដ្ឋាន (ឬម្ចាស់គម្រោង ដែលជាអ្នកដាក់ពាក្យសុំសម្បទានដីសង្គមកិច្ច) ក្នុងអំឡុងដំណើរការដាក់ពាក្យសុំ។ ក្នុងខេត្តមណ្ឌលគិរី បុគ្គលដែលផ្តើមគំនិតសុំដីសម្បទានសដីង្គមកិច្ច បានលើកឡើងថា គាត់បានបង់ប្រាក់ដើម្បីឲ្យពាក្យសុំរបស់គាត់ដំណើរការទៅមុខ ហើយបន្ទាប់មក ប្រជាជនដែលសុំដីត្រូវបង់ប្រាក់ ដើម្បីបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីអ្នកសុំដីដែលបំពេញតាមលក្ខណៈសម្បត្តិសមស្រប។ ពុំមានការតម្រូវឲ្យបង់ថ្លៃសេវាទេ នៅក្នុងអនុក្រឹត្យពាក់ព័ន្ធ ឬលិខិតបទដ្ឋាន គតិយុត្តិផ្សេងទៀត។ នេះបង្ហាញថា អាចមានការប្រព្រឹត្តអំពើពុករលួយ ក្នុងដំណើរការបែងចែកដី។ នេះគឺជាបញ្ហាយ៉ាងពិសេស ដោយសារតែក្រុម មុខសញ្ញាទទួលដីជាទូទៅ គឺជាគ្រួសារក្រីក្រ និងគ្មានដី ហើយ ដោយហេតុថាគ្រួសារមួយភាគធំកំពុងជាប់ផុងក្នុងបំណុល។

មាត្រា ១៨ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ចែងថា "មុខសញ្ញាអ្នកទទួលដីត្រូវធ្វើកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ ជាមួយអាជ្ញាធរមានសមត្ថកិច្ចផ្តល់ដី ដែលបញ្ជាក់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់មុខសញ្ញាអ្នកទទួលដី អនុលោមតាមកម្មវិធីសម្បទាន

ដីសង្គមកិច្ចនោះ និងចែងពីករណីលើកលែង ដូចជា ករណីប្រធានសក្តិ ឬមានជំងឺធ្ងន់ធ្ងរ ដែលរារាំងដល់ការបំពេញកាតព្វកិច្ចទទួលខុសត្រូវនោះ។" នៅក្នុងទីតាំងទាំង ៦ មានអ្នកឆ្លើយតបត្រឹមតែ ៥៨% ប៉ុណ្ណោះ ដែលលើកឡើងថា បានចុះហត្ថលេខាលើកិច្ចសន្យាបែបនេះ។

មានអ្នកឆ្លើយតបត្រឹមតែ ៦០% ប៉ុណ្ណោះ ដែល<u>បានទទួលផែនការសម្បទានដីសង្គមកិច្ច</u>។ ក្រុមប្រឹក្សាឃុំគួរផ្តួចផ្តើមរៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់មូលដ្ឋាន ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមលក្ខខណ្ឌដែលត្រូវបានដាក់ចេញក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។ មាត្រា ៦ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចចែងថា ផែនការដែលបានយល់ព្រម ត្រូវបើកចំហរជាសាធារណៈក្នុងសង្កាត់/ឃុំពាក់ព័ន្ធ។ អ្នករស់នៅលើដី អាចមិនបានយល់ដឹង អំពីផែនការទាំងនេះពីមុនរហូតមក ជាជាងការត្រូវបានគេបដិសេធនូវការទទួលនេះ។ អ្នកទទួលដីត្រូវតែ "បានត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ស្របតាមផែនការសម្បទានដីសង្គមកិច្ច ដែលបានយល់ព្រម"។[46]

ប្រជាជនតាំងទីលំនៅលើទីតាំងសម្បទានដីសង្គមកិច្ចភាគច្រើន (៦៦%) បានលើកឡើងថា ពួកគេត្រូវបានស្នើឲ្យចូលរួមកែលំអរសម្បទានដីសង្គមកិច្ច។ ដូចករណីខាងដើមដែរ <u>មានការរៀបចំផែនការ និងជម្រុញគ្រួសារភាគច្រើនតាមសហគមន៍ឲ្យចូលរួមក្នុងកម្រិតខ្ពស់ពីសំណាក់អាជ្ញាធរមូលដ្ឋាន</u> ក្នុងខេត្តកំពង់ស្ពឺ ប៉ុន្តែមានការជម្រុញឲ្យចូលរួមបែបនេះតិចតួចប៉ុណ្ណោះ ក្នុងខេត្តមណ្ឌលគិរី និងកំពង់ធំ ក្នុងការអភិវឌ្ឍទីតាំងសម្បទានដីសង្គមកិច្ច។

<u>ការជម្រុញឲ្យមានការចូលរួមសកម្ម ហាក់បីដូចជាធាតុផ្សំ ដើម្បីឲ្យទីតាំងសម្បទានដីសង្គមកិច្ចទទួលបានជោគជ័យ។ សេរីភាពនៃការទទួលបានព័ត៌មាន សិទ្ធិទទួលបានព័ត៌មាន</u> ការចែករំលែកគំនិតយោបល់ និងការផ្តល់ឱកាសឲ្យបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត គឺជាផ្នែកមួយដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ និងអាចឲ្យប្រជាពលរដ្ឋធ្វើការ

[46] មាត្រា ១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣)

សម្រេចចិត្តបានត្រឹមត្រូវពីជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។ មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ចែងពីសិទ្ធិមានសេរីភាពបញ្ចេញមតិយោបល់ដែលរាប់បញ្ចូលសិទ្ធិស្វែងរក ទទួល និងផ្តល់ព័ត៌មាន។ មាត្រា ៥ នៃកតិកាសញ្ញា ICCPR ចែងពីសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាងដែលត្រូវបានជ្រើសរើសដោយសេរី។ ការរំពឹងទុករបស់ប្រជាពលរដ្ឋខ្មែរ លែងកំហិតត្រឹមតែជាការមានអាហារ និងទឹកគ្រប់គ្រាន់ទៀតហើយ។ ពួកគេចាប់ផ្តើមទាមទារចង់បាននូវសេវាមូលដ្ឋានដែលល្អប្រសើរជាងមុន មានទាំង នីតិរដ្ឋ តម្លាភាពពីមន្ត្រីដែលពួកគេបោះឆ្នោតជ្រើសរើស និងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីជាដើម។[47]

ការចូលរួមក្នុងដំណើរការរៀបចំផែនការ ការផ្តល់ឯកសារ និងការទទួលបានព័ត៌មាន គួរផ្តល់ភាពអង់អាចដល់សហគមន៍ ជម្រុញឲ្យមានការចូលរួមជាមួយអាជ្ញាធរ ពង្រឹងដំណើរការប្រជាធិបតេយ្យ និងនាំឲ្យសម្រេចលទ្ធផលកាន់តែល្អប្រសើរ សម្រាប់គ្រប់ភាគីទាំងអស់ ក្នុងការអភិវឌ្ឍទីតាំងសម្បទានដីសង្គមកិច្ច។ នេះគឺជាចំណុចដែលមានសារៈសំខាន់ ជាពិសេស នៅពេលបែងចែកធនធានដែលមានកម្រិតដល់គ្រួសារក្រីក្រ និងងាយរងគ្រោះខ្លាំង ដែលកំពុងរស់នៅលើ ឬកៀកនឹងបន្ទាត់នៃភាពក្រីក្រ។ លទ្ធផលដែលទទួលបានពីការអង្កេតនេះ បង្ហាញឲ្យឃើញពីលទ្ធផលជាច្រើន មានទាំងវិជ្ជមាន ទាំងអវិជ្ជមាន នៅតាមទីតាំងសម្បទានដីសង្គមកិច្ចផ្សេងៗ ហើយមានការបង្ហាញច្បាស់ថាអាជ្ញាធរមូលដ្ឋាន ប្រើប្រាស់ស្តង់ដាខុសៗគ្នា ក្នុងការរៀបចំផែនការពិគ្រោះយោបល់ និងជម្រុញឲ្យមានការចូលរួមពីប្រជាជន។ ឧទាហរណ៍៖ អាជ្ញាធរក្នុងខេត្តកំពង់ស្ពឺ ហាក់បីដូចជាមានជោគជ័យ និងការគាំទ្រយ៉ាងសកម្មកាន់តែខ្លាំងក្លា បន្ថែមទៀតក្នុងការធ្វើការងារដោយផ្ទាល់ជាមួយអ្នកទទួលដី ដែលនាំឲ្យការបែងចែកដីធ្វើទៅបានប្រកបដោយសមធម៌ និងធ្វើឲ្យប្រជាពលរដ្ឋយល់ថាការបែងចែកដីនេះធ្វើឡើងប្រកបដោយយុត្តិធម៌។

[47] ធនាគារពិភពលោក ឆ្នាំ ២០១៣។ តើជនក្រីក្របាត់អស់ទៅណា? ការវាយតម្លៃភាពក្រីក្រប្រទេសកម្ពុជា ឆ្នាំ ២០១៣ វ៉ាស៊ីនតោន ឌីស៊ី ធានាគារពិភពលោក។ https://openknowledge.worldbank.org/handle/10986/17546 License: CC BY 3.0 IGO.

ស្ថានភាពរស់នៅ៖

ប្រជាជនតាំងទីលំនៅក្នុងទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦ ស្ទើរតែទាំងអស់ (៩៨%) បានលើកឡើងថា ពួកគេបានជម្រាបដល់អាជ្ញាធរពីស្ថានភាពរស់នៅមិនល្អ នៅទីតាំងរបស់ពួកគេ។ ការត្អូញត្អែរញឹកញាប់ជាងគេ គឺពាក់ព័ន្ធនឹងកង្វះទឹក (៦៨%) និងកង្វះអាហារ (៦៤%) បើទោះបីជាមានការលើកឡើងពីបញ្ហាផ្សេងទៀត ដូចជា ឱកាសការងារតិចតួច គុណភាពផ្លូវ កង្វះអគ្គិសនី និងកង្វះសេវាអនាម័យ ជាដើម។ ចំណុចទាំងនេះត្រូវបានលើកយកមកបង្ហាញលំអិតដូចខាងក្រោម។ ជាងពាក់កណ្តាលនៃករណីទាំងអស់ដែលមានការតវ៉ាទាំងនេះ មានការលើកឡើងថា អាជ្ញាធរពុំបានឆ្លើយតបឡើយ។

បញ្ហានេះកើតឡើង បើទោះបីជានៅតាមទីតាំងសម្បទានដីសង្គមកិច្ចភាគច្រើន អាជ្ញាធរមូលដ្ឋាន ហាក់បីដូចជាបានពិនិត្យតាមដានស្ថានភាព ដោយហេតុថាកន្លងមកពួកគេ បានចុះតាមផ្ទះជាប្រចាំ និង/ឬបានរៀបចំកិច្ចប្រជុំតាមភូមិ ដែលពួកគេបានសួរនាំប្រជាជនអំពីស្ថានភាពនៃការរស់នៅ និងបញ្ហាបច្ចុប្បន្ន។ អ្នកឆ្លើយតបបានលើកឡើងថា កិច្ចប្រជុំភូមិ (៧៥%) គឺជាមធ្យោបាយចម្បង សម្រាប់លើកឡើងពីបញ្ហានានា ហើយមានគ្រួសារ ៣៣% ទៀត ត្រូវបានអាជ្ញាធរចុះសួរនាំតាមផ្ទះ។ អាជ្ញាធរមូលដ្ឋាន បានដឹងយ៉ាងច្បាស់ពីស្ថានភាពទាំងនេះ ក្រោយពេល បានទទួលបណ្តឹងពីប្រជាជន និងបានធ្វើការពិនិត្យតាមដាន និងចុះផ្តល់ព័ត៌មានដល់មូលដ្ឋាន ប៉ុន្តែពួកគេនៅខ្វះសមត្ថភាព ឆន្ទៈ ឬធនធាន សម្រាប់ដោះស្រាយបញ្ហា និងឆ្លើយតបចំពោះពាក្យបណ្តឹងទាំងនេះ។

ក្នុងខេត្តកំពង់ស្ពឺ គ្រួសារតាមផ្ទះ ៨៥% បានលើកឡើងថា អាជ្ញាធរមូលដ្ឋានបាធ្វើការពិនិត្យតាមដានស្ថានភាពនៃការរស់នៅ ដោយមានគ្រួសារប្រមាណជាពាក់កណ្តាល បានទទួលការវាយតម្លៃជាប្រចាំខែ និងមាន ៣៥% ទៀត និយាយថា ពួកគេអាចផ្តល់ព័ត៌មានត្រលប់ដល់អាជ្ញាធរមូលដ្ឋានយ៉ាងហោចណាស់រៀងរាល់ ៣ ខែ ម្តង។ អាជ្ញាធរបានសាកសួរពីកម្រិតចំណូល សន្តិសុខស្បៀង ផលិតកម្មកសិកម្ម និងបញ្ហាពាក់ព័ន្ធផ្សេងទៀត។ អាជ្ញាធរ ហាក់បីដូចជាបានប្រើប្រាស់វិធីសាស្ត្រសកម្មដែលសម នឹងទទួលបានការកោតសរសើរក្នុងការពិនិត្យតាមដាន និងវាយតម្លៃកម្រិតជីវភាព និងកំណត់ពីកន្លែង

ដែលអាចមានបញ្ហាកើតមានឡើង បើទោះបីជាពួកគេមិនអាចដោះស្រាយគ្រប់ការព្រួយបារម្ភទាំងអស់ក៏ដោយ។

ជំនួយដែលអង្គការមិនមែនរដ្ឋាភិបាលផ្តល់ដល់សហគមន៍ហាក់បីដូចជាមានកម្រិតនៅឡើយ នៅក្នុងគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់។ ជាមធ្យម ក្នុងចំណោមគ្រួសារដែលបានសាកសួរទាំងអស់ មានតែ ៣៧% ប៉ុណ្ណោះ ដែលបានលើកឡើងថាពួកគេបានទទួលការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល។ តួលេខនេះមានប្រមាណជា ៥០% ក្នុងខេត្តកំពង់ស្ពឺ និងត្បូងឃ្មុំ និង ២៦% ក្នុងខេត្តបាត់ដំបង។ ហាក់បីដូចជាពុំមានផ្តល់ការគាំទ្រដល់អ្នកឆ្លើយតប នៅតាមទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀតឡើយ។ អង្គការមិនមែនរដ្ឋាភិបាលមានសក្តានុពលក្នុងការបំពេញតួនាទីកាន់តែសកម្ម ក្នុងគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ក្នុងការ ពិនិត្យតាមដាន និងវាយតម្លៃកម្រិតជីវភាពរស់នៅ និងធ្វើឲ្យអាជ្ញាធរមូលដ្ឋានមានគណនេយ្យភាពតាមរយៈការផ្ទៀងផ្ទាត់ជាលក្ខណៈឯករាជ្យលើដំណើរការបែងចែកដី និងដំណើរការផ្សេងទៀត។

**ភាពសមស្របនៃដី៖**

អ្នកទទួលផលទាំងនោះ បានទទួលដីលំនៅឋាន ឬក៏បានទទួលទាំងដីលំនៅឋាន និងដីកសិកម្ម។ ប្រជាជនភាគច្រើន ដែលតាំងទីលំនៅក្នុងសម្បទានដីសង្គមកិច្ចក្នុងខេត្តបាត់ដំបង មកដល់ពេលនេះ បានទទួលតែដីលំនៅឋានប៉ុណ្ណោះ ខណៈពេលដែលប្រជាជនភាគច្រើន នៅទីតាំងសម្បទានដីសង្គមកិច្ច ៥ កន្លែង ផ្សេងទៀត បានទទួលទាំងដីលំនៅឋាន និងដីកសិកម្ម។ ដីសម្រាប់ធ្វើកសិកម្ម ជាធម្មតា មិនទាន់បាន "កាប់ឆ្ការ" និងមិនទាន់អាចប្រើប្រាស់សម្រាប់ធ្វើកសិកម្មបានឡើយ នៅពេលដែលប្រជាជនទទួលបានដីពីដំបូង - ក្នុងចំណោមអ្នកឆ្លើយតបទាំងអស់ មាន ៧៣% បានលើកឡើងថា ដីរបស់ពួកគេមិនទាន់អាចយកមកធ្វើកសិកម្មបានឡើយ ហើយ ២១% ទៀត បានលើកឡើងថា មានតែដីកន្លែងខ្លះប៉ុណ្ណោះ ដែលអាចប្រើប្រាស់សម្រាប់ធ្វើកសិកម្មបាន។ ប្រជាជនដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចបានលើកឡើងថា ពួកគេពុំមានលទ្ធភាពចំណាយជួលគេកាប់ឆ្ការដី ខ្វះឧបករណ៍សម្ភារសម្រាប់កាប់ឆ្ការដី ឬពុំមានពេលវេលាសម្រាប់ធ្វើការងារ

នេះ។ អង្គការមិនមែនរដ្ឋាភិបាល ដែលចុះអង្កេតតាមទីតាំងសម្បទានដីសង្គមកិច្ច ធ្លាប់ទទួលបានការត្អូញត្អែរពីប្រជាពលរដ្ឋថា ដីមិនមានជីជាតិ ហើយដីដែលបែងចែកតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច គឺមិនសមស្របសម្រាប់ការធ្វើកសិកម្មឡើយ។ នេះហាក់បីដូចជាមិនមែនជាបញ្ហាធំដុំ នៅទីតាំងភាគច្រើន ក្នុងចំណោមទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦ ដែលត្រូវបានអង្កេតនោះឡើយ ដោយមានតែអ្នកទទួលដីក្នុងខេត្តកំពង់ស្ពឺប៉ុណ្ណោះ ដែលបានលើកឡើងថា នេះជាបញ្ហាធំដុំ។ ដីសម្បទានសង្គមកិច្ចភាគច្រើនមិនទាន់បានកាប់ឆ្ការ ឬដាំដុះនៅឡើយ ដោយសារតែប្រជាពលរដ្ឋ ពុំមានលទ្ធភាពធ្វើការអភិវឌ្ឍដីទាំងនេះ ហើយក្បាលដីទាំងនេះអាចជាក្បាលដីដែលពុំមានជីជាតិ។

<u>ក្បាលដីសម្រាប់សង់លំនៅឋាន ជាមធ្យមមានទំហំ</u> ១៩២០ ម៉ែត្រការ៉េ ពោលគឺមានចាប់ពី ១០០០ ម៉ែត្រការ៉េ រហូតដល់ ១៧៥២ ម៉ែត្រការ៉េ។ អ្នកឆ្លើយតបភាគច្រើនលើសលុបបានលើកឡើងថា ពួកគេបានទទួលដីដែលមានទំហំប៉ុនគ្នានឹងអ្នកជិតខាងរបស់ពួកគេដែរ ដែលនេះបង្ហាញពី<u>ការបែងចែកប្រកបដោយសមធម៌</u> នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ជាទូទៅ។ គ្រួសារ ៣% បានលើកឡើងថា ពួកគេបានទទួលដីក្នុងទំហំតូចជាងអ្នកជិតខាងរបស់ពួកគេ។

<u>ផ្ទះមានទំហំជាមធ្យម គឺ</u> ២៨ ម៉ែត្រការ៉េ។ ទំហំផ្ទះជាមធ្យមនេះ ត្រូវបានគេចំណាត់ចន្លោះចាប់ពីទំហំ២០ដល់ ៥២ ម៉ែត្រការ៉េ ក្នុងខេត្តមណ្ឌលគីរី ដែលទំហំផ្ទះជាមធ្យមនេះមានទំហំធំជាងគេត្រូវបានគេកំណត់ត្រាទុក។ ផ្ទះស្ទើរតែទាំងអស់ត្រូវបានសាងសង់ដោយគ្រួសារខ្លួនឯង ហើយក្នុងករណីមួយចំនួន សាងសង់ដោយមានជំនួយពីអ្នកជិតខាង។ គ្រួសារអាចសង់ផ្ទះ ជាមធ្យម ៨ ខែ ក្រោយពេលបានទទួលដីសម្បទានសង្គមកិច្ចរួច។

បើតាមអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច "ប្រសិនបើគ្មានរចនាសម្ព័ន្ធលំនៅឋានលើដីលំនៅឋាននៃសម្បទានដីសង្គមកិច្ចនោះទេ <u>មុខសញ្ញាអ្នកទទួលដីត្រូវសាងសង់យ៉ាងហោចណាស់នូវចំណែកណាមួយ នៃជម្រកស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងរយៈពេលបីខែ បន្ទាប់ពីទទួលបានដី</u> ហើយសមាជិកនៃគ្រួសារនោះត្រូវរស់នៅពិតប្រាកដ និងជាអចិន្ត្រៃយ៍លើដីនោះឲ្យបានលើសពីប្រាំមួយខែក្នុងមួយឆ្នាំ។ មុខសញ្ញាអ្នកទទួលដីនៃសម្បទានដីសង្គម

កិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ត្រូវធ្វើកសិកម្មជាក់ស្តែងលើដីនោះ ក្នុងរយៈពេលដប់ពីរខែ បន្ទាប់ពីបានទទួលដី ហើយបន្តប្រើប្រាស់ដីនេះ ស្របតាមលក្ខខណ្ឌចាំបាច់នៃកម្មវិធីសម្បទាន។[48] ប្រសិនបើអ្នកទទួលផលខកខានមិនបានបំពេញតាមលក្ខខណ្ឌនៃការកាន់កាប់ និងប្រើប្រាស់ដីសម្បទាននោះ ដីនេះនឹងត្រូវវិលមកជាដីរបស់រដ្ឋវិញ ដើម្បីធ្វើការបែងចែកសារជាថ្មី។ ចំណុចនេះហាក់បីដូចជាមិនត្រូវបានអនុវត្តឲ្យបានតឹងរ៉ឹង ក្នុងករណីភាគច្រើនឡើយ។ ឧទាហរណ៍ ប្រជាជនរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ច ក្នុងខេត្តមណ្ឌលគិរី បានសាងសង់ផ្ទះ ជាមធ្យម ១៧ ខែ ក្រោយពីបានទទួលដីសម្បទានសង្គមកិច្ច។ ក្នុងខេត្តបាត់ដំបង រយៈពេលមធ្យមគឺ ១២ ខែ។ ដោយសារតែគ្រួសារទទួលដីភាគច្រើន គឺជាគ្រួសារក្រីក្រ មានធនធានតិចតួច គោលការណ៍នេះមិនគួរអនុវត្តតឹងរ៉ឹងនោះទេ ប្រសិនបើគេចង់ទទួលបានជោគជ័យ នៅទីតាំងសម្បទានដីសង្គមកិច្ចនាពេលអនាគត លើកលែងតែមានការផ្តល់ធនធានបន្ថែមឲ្យបានច្រើនដល់គ្រួសារទាំងនោះ នៅពេលដែលពួកគេធ្វើការផ្លាស់ទៅទីតាំងសម្បទានដីសង្គមកិច្ចទាំងនោះ។

អ្នកឆ្លើយតបភាគច្រើន (៦៧%) លើកឡើងថា លំនៅឋានថ្មីរបស់ពួកគេ*ល្អជាង ឬល្អឆ្ងាយជាង* ផ្ទះមុនៗរបស់ពួកគេ។ ប៉ុន្តែ ពួកគេ ១៣% បានលើកឡើងថា លំនៅឋានថ្មី*អន់*ជាងផ្ទះមុនរបស់ពួកគេ ហើយភាគរយដែលនៅសល់លើកឡើងថា ស្ថានភាពប្រហាក់ប្រហែលគ្នា។ បើទោះបីជាមួយផ្នែកនៃចម្លើយនេះអាចដោយសារការយល់ឃើញរបស់ម្ចាស់ផ្ទះក៏ដោយ វាគឺជាសញ្ញាបញ្ជាក់ច្បាស់ពីជោគជ័យនៃគម្រោងសម្បទានដី សង្គមកិច្ចពោលគឺថាតើគ្រួសារក្រីក្រ ឬគ្រួសារគ្មានដីបានទទួលដី និងលំនៅឋានសមរម្យ ដែលបំពេញតម្រូវការជាមូលដ្ឋានរបស់ពួកគេបានដែរឬទេ? ក្នុងករណីនេះ ទីតាំងសម្បទានដីសង្គមកិច្ចហាក់បីដូចជាបានបង្កលក្ខណៈឲ្យមានការលើកកម្ពស់កម្រិតជីវភាព តាមរយៈការផ្តល់ដី ហើយស្ថានភាពលំនៅឋានមានភាពល្អប្រសើរជាងមុន សម្រាប់គ្រួសារមួយភាគធំ។ នេះមិនមែនមានន័យថា លំនៅឋានលើទីតាំងសម្បទានដីសង្គមកិច្ចបានបំពេញទៅតាមស្តង់ដាអប្បរមា ដូចមានចែងក្នុងសេចក្តីពន្យល់ទូទៅលេខ ៤ ស្តីពី លំនៅឋានសមរម្យ

[48] អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (២០០៣) មាត្រា ១៨។

របស់គណៈកម្មាធិការទទួលបន្ទុកកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នោះទេ ហើយកង្វះការទទួលបានប្រភពទឹកស្អាតបរិភោគនេះ ស្មើឡើងថា បញ្ហានេះអាចមិនមានក្នុងករណីច្រើន។ វាក៏មិនមែនជាការបង្ហាញថា ការគាំទ្ររបស់រដ្ឋាភិបាល ឬអ្នកផ្តល់ជំនួយបានផ្តល់លំនៅឋានសមរម្យជាក់ស្តែងនោះដែរ។ មានអ្នកទទួលដីត្រឹមតែ ២% ប៉ុណ្ណោះ ដែលបានទទួលផ្ទះ ដែលត្រូវបានសាងសង់ជាផ្នែកមួយនៃដំណើរការសម្បទានដីសង្គមកិច្ច។ ប៉ុន្តែ ចំណុចនេះពិតជាបានបង្ហាញថា មានការសម្រេចបានសិទ្ធិលំនៅឋានជាបន្តបន្ទាប់ តាមរយៈការផ្តល់ជាធនធាន ក្នុងករណីនេះ សម្រាប់គោលបំណងលំនៅឋាន និងធ្វើកសិកម្មដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅសម្រាប់ក្រុមងាយរងគ្រោះ។

ដីកសិកម្មមានទំហំមធ្យម ១,១៧ ហិចតា។ តួលេខនេះមានការប្រែប្រួលខុសគ្នាឆ្ងាយ ឧទាហរណ៍ ក្នុងខេត្តមណ្ឌលគិរី ទំហំដីជាមធ្យមគឺ ៤,៣៦ ហិចតា។ ប្រជាជនដែលរស់នៅលើដីសម្បទានសង្គមកិច្ច ៨% បានលើកឡើងថា អ្នកជិតខាងរបស់ពួកគេបានទទួលដីក្នុងទំហំធំជាងដីដែលពួកគេបានទទួល ដែលនេះបង្ហាញថា ការបែងចែកដីធ្វើឡើងដោយសមធម៌ នៅតាមតំបន់ភាគច្រើន ប៉ុន្តែមិនមែនក្បាលដីទាំងអស់សុទ្ធតែមានទំហំស្មើគ្នានោះទេ។ មន្ត្រីមូលដ្ឋានលើកឡើងថា ពេលខ្លះ គ្រួសារដែលមានសមាជិកច្រើនបានទទួលដីធំជាងគ្រួសារដែលមានសមាជិកតិច។

ការផ្តល់សម្បទានដីសង្គមកិច្ចជាច្រើនកន្លែង ធ្វើឡើងនៅតំបន់ដែលមានព្រៃក្រាស់ ដែលតម្រូវឲ្យមានការកាប់ឆ្ការព្រៃលើទីតាំងសម្បទានដីសង្គមកិច្ចនេះ សម្រាប់ធ្វើកសិកម្ម និងសង់លំនៅឋាន (សូមមើលទំព័រ៣២ ជាឧទាហរណ៍) ។ កង្វះឱកាសការងារអាចជាសក្តានុពលរួមចំណែកនាំឲ្យមានការកាប់បំផ្លាញព្រៃឈើបន្ថែមទៀត (បើទោះបីជាលទ្ធផលនៃការអង្កេត ពុំបានរកឃើញចំណុចនេះឲ្យបានជាក់លាក់យ៉ាងណាក៏ដោយ ហើយប្រជាពលរដ្ឋប្រហែលជាមិនចង់សារភាពថាខ្លួនបានកាប់ឈើខុសច្បាប់នោះដែរ)។ មានអ្នកឆ្លើយតបត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ (៤៤%) ដែលរកចំណូលពីការធ្វើកសិកម្មលើទីតាំងសម្បទានដីសង្គមកិច្ចដែលខ្លួនទើបទទួលបានថ្មីៗ។ ចំណូលប្រចាំឆ្នាំជាមធ្យមដែលបានពីការធ្វើកសិកម្មគឺ ៦៨៧ ដុល្លារ បើទោះបីជាតួលេខនេះមានការប្រែប្រួលខុសគ្នា

ឆ្ងាយរវាងតំបន់សម្បទានដីសង្គមកិច្ចផ្សេងៗគ្នាក៏ដោយ។ ក្នុងខេត្តកំពត ដោយសារតែដីមានទំហំតូច គ្រួសាររកចំណូលជាមធ្យមត្រឹមតែ ៨៩ ដុល្លារ ក្នុងមួយឆ្នាំប៉ុណ្ណោះ។ ក្នុងខេត្តកំពង់ស្ពឺ បើទោះបីជាដំណើរការរៀបចំផែនការ និងអភិវឌ្ឍន៍ធ្វើឡើងដោយមានការពិគ្រោះយោបល់កម្រិតខ្ពស់យ៉ាងណាក៏ដោយ ការទទួលបានចំណូលពីរបរកសិកម្ម ជាមធ្យម បានត្រឹមតែ ២៤២ ដុល្លារ ក្នុងមួយឆ្នាំតែប៉ុណ្ណោះ។ តួលេខនេះមានកម្រិតទាបជាចំណូលជាមធ្យម ក្នុងប្រទេសកម្ពុជាទាំងមូល។ អ្នកធ្វើការដោយទទួលបានប្រាក់ឈ្នួលក្នុងប្រទេសកម្ពុជា ជាធម្មតា ទទួលបានចំណូល ១២១ ដុល្លារ *ក្នុងមួយខែ* (២០១២)។[49] ប្រាក់ឈ្នួលមធ្យមក្នុងវិស័យកាត់ដេរ នៅពេលធ្វើការប្រៀបធៀបនេះ ត្រូវបានកំណត់ថាមានចំនួន ១៩៥ ដុល្លារ ក្នុងមួយខែ (ហើយបច្ចុប្បន្ននេះ កំពុងកែសម្រួលបង្កើនថែមទៀត)។ នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ចំណូលពីរបរកសិកម្ម ត្រូវបានបំពេញបន្ថែមដោយប្រភពចំណូលផ្សេងទៀត ដូចបង្ហាញខាងក្រោម។

អ្នកដែលមិនអាចរកចំណូលបាន លើកឡើងថា ទិន្នផលកសិកម្មមានបរិមាណតិចតួច ហើយដំណាំដែលដាំ គឺសម្រាប់តែបរិភោគក្នុងគ្រួសារតែប៉ុណ្ណោះ។ កម្រិតចំណូលទំនងជាការឆ្លុះបញ្ចាំងពីទំហំដី - ចំណូលមានកម្រិតខ្ពស់ជាងគេ នៅខេត្តមណ្ឌលគិរី និងត្បូងឃ្មុំ ជាទីដែលមានការបែងចែកដីទំហំធំៗ។ កត្តាផ្សេងទៀត ក៏នឹងមានផលប៉ះពាល់ផងដែរ - អ្នកឆ្លើយតប ៨៤% ក្នុងខេត្តត្បូងឃ្មុំបានទទួលជំនួយពីអង្គការមិនមែនរដ្ឋាភិបាលមួយ សម្រាប់ដាំដុះលើដីរបស់ពួកគេ (ផ្ទុយទៅវិញ អ្នកឆ្លើយតបក្នុងខេត្តមណ្ឌលគិរីពុំបានទទួលជំនួយបែបនេះនោះទេ)។ អ្នកទទួលដីជាច្រើនខ្វះទុនវិនិយោគ សម្រាប់កាប់ឆ្ការដី រៀបចំ និងដាំដុះលើដីរបស់ពួកគេ។ ដំណើរការជ្រើសរើសតម្រូវឲ្យអ្នកទទួលដីជាជនក្រីក្រ ដែលមានន័យថាពួកគេពុំមានដើមទុន ឬមានដើមទុនតិចតួច។ វាក៏មានន័យផងដែរថា ប្រជាពលរដ្ឋដែលរស់លើសម្បទានដី សង្គមកិច្ចច្រើនតែរវល់ពេកមិនអាចអភិវឌ្ឍដីរបស់ពួកគេបាន ដោយហេតុថាពួកគេត្រូវទៅធ្វើការងារពេញម៉ោងនៅកន្លែងផ្សេង ដើម្បី

[49] សូមមើល ILO: Global Wage Report 2012/13, op. cit., p. 40.

ទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគេ។ លទ្ធផលនៃការអង្កេតលើការងារ ការកាប់ឆ្ការដី និងការជាប់បំណុល គាំទ្រដល់របកគំហើញនេះ។

សកម្មភាពសេដ្ឋកិច្ច និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ នៅតំបន់ជនបទក្នុងប្រទេសកម្ពុជា ពឹងអាស្រ័យខ្លាំងលើសកម្មភាពកសិកម្ម។ ដំណាំកសិកម្មត្រូវបានគេលើកឡើងថាជាកត្តារួមចំណែកចម្បងជាងគេ ដែលនាំឲ្យមានការកើនឡើងយ៉ាងគំហ៊ុកនូវចំណូលសរុបរបស់គ្រួសារ ទូទាំងប្រទេសកម្ពុជា។[50] ការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ ត្រូវបានជម្រុញមួយផ្នែកដោយសារតែការកើនឡើងខ្លាំងនៃតម្លៃស្រូវអង្ករ ការបង្កើនផលិតកម្មស្រូវ ការកើនឡើងនូវប្រាក់ឈ្នួលនៅជនបទ និងការកើនឡើងនូវចំណូលពីការប្រកបមុខរបរដោយខ្លួនឯង ក្រៅតែពីការធ្វើកសិកម្ម។[51] ចាំបាច់ត្រូវ មានបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការគាំទ្រផ្សេងទៀត នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ដើម្បីធានាយ៉ាងណាឲ្យដីកសិកម្មត្រូវបានគេយកមកប្រើប្រាស់ ហើយជីវភាពរស់នៅដែលពឹងផ្អែកលើការធ្វើកសិកម្មលើដីសម្បទានសង្គមកិច្ចនេះ មាននិរន្តរភាព។

**ការរកប្រាក់ចំណូល៖**

គេ អាចពន្យល់ពីការប្រែប្រួលកម្រិតជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្រតាមទីតាំងសម្បទានដីសង្គមកិច្ច តាមរយៈការពិនិត្យមិនត្រឹមតែលើកម្រិតចំណូលរួមរបស់គ្រួសារប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវពិនិត្យមើលប្រភពផ្សេងៗគ្នានៃចំណូលទាំងនេះផងដែរ។ នៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦ ដែលត្រូវបានអង្កេត ចំណូលដែលបានពីការធ្វើកសិកម្ម ត្រូវបានបំពេញបន្ថែមដោយការងារក្នុងទម្រង់ផ្សេងទៀត ដូចជា ការងារក្នុងរោងចក្រ ការងារនៅលើទីតាំងសម្បទានដីសេដ្ឋកិច្ច និងតាមរយៈការប្រកបមុខរបរដោយខ្លួនឯងក្នុងទម្រង់ផ្សេងទៀត។ អ្វីដែលសំខាន់ ដើម្បីសម្រេចជោគជ័យជាសក្តានុពលនៅ

---

[50]Sobrado, Carlos; Neak, Samsen; Ly, Sodeth; Aldaz-Carroll, Enrique; Gamberoni, Elisa; Arias-Vazquez, Francisco; Fukao, Tsuyoshi; Beng, Simeth; Johnston, Timothy; Joaquin, Miguel San; Bruni, Lucilla; de Groot, Richard. ឆ្នាំ ២០១៤ តើជនក្រីក្របាត់អស់ទៅណា? ការវាយតម្លៃភាពក្រីក្រប្រទេសកម្ពុជា ឆ្នាំ ២០១៣ វ៉ាស៊ីនតោន ឌីស៊ី ក្រុមធានាគារពិភពលោក។

[51] ដូចគ្នានឹងប្រភពខាងលើ

តាមទីតាំងសម្បទានដីសង្គមកិច្ច និងសុខុមាលភាពគ្រួសារដែលរស់នៅតាមទីតាំងទាំងនោះ គឺគ្រួសារទទួលបានដី ត្រូវតែមានឱកាសការងារ និងប្រភពចំណូលប្រកបដោយនិរន្តភាពឲ្យបានច្រើន និងអាចរកចំណូលបន្ថែមសម្រាប់គ្រួសារពីការធ្វើកសិកម្ម នៅក្នុងករណីដែលចាំបាច់។ នេះ មិនមែនជាអ្វីដែលមាននៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ឡើយ។

គ្រួសារតាមផ្ទះស្ទើរតែទាំងអស់ (៩៨%) ដែលត្រូវបានសាកសួរ មានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់មានការងារធ្វើ និងមានគ្រួសារតាមផ្ទះប្រមាណជា ៧៨% មានសមាជិកមានការងារធ្វើចាប់ពីពីរនាក់ឡើងទៅ ដោយគ្រួសារមួយចំនួនមានសមាជិករហូតដល់ ៨ នាក់ ដែលមានការងារធ្វើ។ ជាការឆ្លើយតបចំពោះការសាកសួរពីប្រភេទការងារដែលពួកគេធ្វើ ៤៨% បានលើកឡើងថាធ្វើជាអ្នកស៊ីឈ្នួលតាមស្រែចម្ការ ៧២% ធ្វើការងារប្រភេទប្រើកម្លាំងផ្សេងទៀត ៦% ធ្វើការតាមរោងចក្រកាត់ដេរ ៧% ធ្វើការងារក្នុងសេវាសាធារណៈ និង ២២% មានមុខរបរខ្លួនឯង។ <u>ចំណូលរបស់គ្រួសារប្រចាំខែបញ្ចូលគ្នា</u> ជាមធ្យមពីការងារគឺ ២៣០ ដុល្លារ ក្នុងមួយខែ។ ប៉ុន្តែ តួលេខនេះមានការប្រែប្រួលខុសៗគ្នារវាងទីតាំងសម្បទានដីសង្គមកិច្ចផ្សេងៗគ្នា។ ឧទាហរណ៍ ក្នុងខេត្តបាត់ដំបង ចំណូលជាមធ្យមមានត្រឹមតែ ១៦៧ ដុល្លារតែប៉ុណ្ណោះក្នុងមួយខែ បើទោះបីជាមានសមាជិកគ្រួសារច្រើនធ្វើការងារក៏ដោយ។ ចំណូលភាគច្រើនបានពីការធ្វើកសិកម្ម ការងារស៊ីឈ្នួលគេ/ការងារតាមរោងចក្រ និងពីមុខរបរខ្លួនឯង ដូចជា លក់ផលិតផលផ្ទាល់ជាដើម។

មុននឹងផ្លាស់មករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ចំណូលប្រចាំខែជាមធ្យមរបស់អ្នកឆ្លើយតបគឺតិចជាង ២១៣ដុល្លារ ក្នុងមួយខ្នងផ្ទះ ដែលបង្ហាញថា តាមរយៈការធ្វើកសិកម្ម រួមនឹងការងារ/មុខរបរផ្សេងទៀត <u>ចំណូលជាមធ្យមមានការកើនឡើង នៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦</u>។ តួលេខនេះក៏មានការប្រែប្រួលខុសៗគ្នាគួរឲ្យកត់សម្គាល់ផងដែរ។ ឧទាហរណ៍ នៅខេត្តកំពង់ធំ ចំណូលប្រចាំខែកន្លងមកគឺប្រមាណជា ៥៩៦ ដុល្លារជាមធ្យម។ អ្នកទទួលផល ធ្លាប់រស់នៅតាមដងទន្លេមេគង្គ និងរកចំណូល តាមរយៈការធ្វើនេសាទ និងមធ្យោបាយផ្សេងទៀត។ ការបាក់ច្រាំងទន្លេធ្វើឲ្យគ្រួសារទាំងនេះ

បាត់បង់ទីលំនៅ និងដាក់ពាក្យសុំដីសម្បទានសង្គមកិច្ច។ ដូច្នេះ ចំណូលប្រចាំខែមានការថយចុះ ប៉ុន្តែនេះក៏មិនមែនជាខ្នាតដែលល្អបំផុត ដើម្បីវាយតម្លៃឲ្យដឹងថាតើសម្បទានដីសង្គមកិច្ចមានផលប៉ះពាល់ជាវិជ្ជមានលើជីវិតរស់នៅរបស់គ្រួសារ ក្នុងករណីនេះដែរ។ ទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦ មានលក្ខណៈខុសៗគ្នា។ គ្រួសារទទួលផលមកពីខេត្តផ្សេងៗគ្នា មានសាវតាខុសគ្នា ទទួលបានកម្រិតនៃការគាំទ្រផ្សេងៗគ្នានៅពេលដែលពួកគេផ្លាស់មករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ និងហាក់បីដូចជាទទួលរងផលប៉ះពាល់ដោយសារតែកត្តាផ្សេងៗគ្នា នៅពេលដែលពួកគេមកកសាងជីវិតលើសម្បទានដីសង្គមកិច្ចទាំងនេះ។ ដូច្នេះ តួលេខចំណូល និងចំណាយ ជាមធ្យម នៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦ គួរតែត្រូវបានយល់ដឹងទៅតាមស្ថានភាពដែលលើកឡើងនេះ។

<u>ការចំណាយជាមធ្យមបច្ចុប្បន្នរបស់ខ្នងផ្ទះនិមួយៗ</u> បានកើនឡើងគួរឲ្យកត់សម្គាល់នៅតាមទីតាំងសម្បទានដី សង្គមកិច្ចទាំង ៦ ហើយបច្ចុប្បន្ននេះគឺ ១៩៩ ដុល្លារ ក្នុងមួយខែពោលគឺកើនឡើងពី ១៥៤ ដុល្លារ មុនពេលផ្លាស់មករស់នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ការកើនឡើងនូវចំណាយខ្ពស់បំផុត គឺដោយសារតែចំណាយលើម្ហូបអាហារ និងសេវាថែទាំសុខភាព បើទោះបីជានៅតាមទីតាំងសម្បទានដីសង្គមកិច្ចមួយចំនួន ការកើនឡើងខ្លាំងនូវការចំណាយគឺដោយសារតែការរៀបចំពិធីសាសនាផងដែរ។ ការចំណាយប្រចាំខែជាមធ្យម ហាក់បីដូចជាកើនឡើងលឿនជាងចំណូលមធ្យមប្រចាំខែរបស់គ្រួសារនីមួយៗ នៅតាមទីតាំងសម្បទានដីសង្គមកិច្ចភាគច្រើន។

អ្នកឆ្លើយតប ៧៩% និយាយថា ពួកគេដឹងពី<u>កុមារដែលធ្វើការងារ ដើម្បីរកចំណូលបន្ថែមសម្រាប់គ្រួសារ</u> (កុមារត្រូវបានគេឲ្យនិយមន័យថាជាមនុស្សអាយុក្រោម ១៥ ឆ្នាំ ក្នុងការអង្កេតនេះ)។ នេះ គឺជាលទ្ធផលរកឃើញដូចៗគ្នា នៅតាមគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់។ ការងារភាគច្រើន ជាការងារកសិកម្ម និងជាប្រភេទការងារប្រើកម្លាំងពលកម្មផ្សេងទៀត បើទោះបីជាមានកុមារធ្វើការជាង ១០% ត្រូវបានគេរាយការណ៍ថាកំពុងធ្វើការតាមរោងចក្រយ៉ាងណាក៏ដោយ។ សូមសម្គាល់ថា សំណួរនេះសួរថាតើអ្នក

ឆ្លើយតប*ដឹង* ពីកុមាររស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចណាខ្លះដែលកំពុងធ្វើការងារ ពោលគឺមិនមែនសួរថាតើកូនៗរបស់ពួកគេខ្លួនឯងកំពុងធ្វើការងារឬអត់នោះទេ។

២៥%នៃគ្រួសារទាំងនោះ ជឿថា ការទទួលបានសេវាអប់រំ រឹតតែអន់ ចាប់តាំងពីផ្លាស់មកនៅលើសម្បទានដីសង្គមកិច្ចនេះ ហើយ ២០%ទៀត បានថា បច្ចុប្បន្ន មានក្មេងតិចតួចរស់នៅក្នុងផ្ទះសម្បែង បានចូលរៀន។ ៤២%នៃ អ្នកឆ្លើយតប បាននិយាយថា ការទទួលបានការអប់រំ មានការប្រសើរឡើង បន្ទាប់ពីបានផ្លាស់មកនៅលើសម្បទានដីសង្គមកិច្ចនេះ។

| ខេត្ត | បាត់ដំបង | ត្បូងឃ្មុំ | កំពង់ស្ពឺ | កំពង់ធំ | កំពត | មណ្ឌលគិរី | មធ្យម |
|---|---|---|---|---|---|---|---|
| ភាគរយនៃគ្រួសារទទួលផលសម្បទានដីសង្គម ដែលបានដាក់ពិន្ទុលើការទទួលបានការអប់រំរបស់ពួកគេ ដោយសារមានភាពប្រសើរឡើងនៅទីតាំងសម្បទានដីសង្គមកិច្ច | ៤០% | ៥៤% | ៥៥% | ០% | ១៧% | ៣% | ៤២% |

មានគ្រួសារតែ ២៨% ប៉ុណ្ណោះ ដែលមានប្រាក់សន្សំសម្រាប់គ្រួសារ បើទោះបីជាប្រាក់សន្សំជាមធ្យម មានការកើនឡើង ចាប់ពីពេលដែលពួកគេផ្លាស់មកនៅតំបន់សម្បទានដីសង្គមកិច្ចនេះក៏ដោយ ហើយបច្ចុប្បន្ននេះ ប្រាក់សន្សំជាមធ្យមគឺ ១៧៦,៨១ ដុល្លារនៃ គ្រួសារច្រើន មានជាប់បំណុល ហើយកម្រិតមធ្យមនៃបំណុលមានការកើនឡើងខ្លាំង ចាប់តាំងពីពេលដែលពួកគេ ផ្លាស់មកនៅតំបន់សម្បទានដីសង្គមកិច្ចនេះមក។ គ្រួសារទទួលផលជាប់បំណុលបន្ថែមច្រើន ក្រោយពីផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ច ៥ កន្លែង ក្នុងចំណោមសម្បទានដីសង្គមកិច្ចទាំង ៦ កន្លែង លើកលែងតែខេត្ត

មណ្ឌលគិរីចេញ។ បច្ចុប្បន្ននេះ គ្រួសារតាមផ្ទះច្រើនជំពាក់បំណុលគេជាមធ្យម ៩៣៩ ដុល្លារ ក្នុងមួយខ្នងផ្ទះ កើនឡើងពី ១១៣ ដុល្លារ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ នេះមានន័យថា គ្រួសារតាមផ្ទះទាំងនោះ ខ្ចីបុលគេបន្ថែមច្រើន នៅពេលផ្លាស់មក ឬក្រោយពេលផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ និង/ឬការកើនឡើងនូវចំណាយរបស់គ្រួសារធ្វើឲ្យគ្រួសារត្រូវជាប់បំណុលគេ។ នេះគឺជាការព្រួយបារម្ភមួយ ដោយសារតែចំណូលប្រចាំខែរបស់គ្រួសារមានកម្រិតទាប និងពុំមានស្ថិរភាព។

ក្នុងចំណោមគ្រួសារតាមផ្ទះទាំងអស់ដែលត្រូវបានសាកសួរ មានប្រមាណជាពាក់កណ្តាល (៤៥%) ដែលមានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់រស់នៅឆ្ងាយពីទីតាំងសម្បទានដីសង្គមកិច្ចនេះ ជាអចិន្ត្រៃយ៍។ សមាជិកគ្រួសារភាគច្រើនលើសលុប ដែលរស់នៅឆ្ងាយពីទីតាំងនេះគឺជាកូនរបស់អ្នកឆ្លើយតបចំពោះការអង្កេតនេះដែលធ្វើចំណាកស្រុកដើម្បីរកការងារធ្វើ។ នេះបង្ហាញថា ការងារសមរម្យពុំអាចរកបាននៅតាមទីតាំងសម្បទានដីសង្គមកិច្ចជាច្រើន ហើយចាំបាច់ត្រូវមានការវាយតម្លៃលើនិរន្តរភាពរបស់សម្បទានដីសង្គមកិច្ចឡើងវិញ ប្រសិនបើកូនៗជំនាន់ក្រោយរបស់អ្នករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចបច្ចុប្បន្ននេះ សម្រេចចិត្តមិនរស់នៅ ឬមិនអាចរស់នៅទីតាំងនេះបាន។

ចំណូលតាមគ្រួសារ មានការកើនឡើងក្នុងចំណោមអ្នកទទួលផលភាគច្រើន ដែលភាគច្រើនជាគ្រួសារក្រីក្រ។ ប៉ុន្តែ កម្មវិធីសម្បទានដីសង្គមកិច្ចត្រូវបានរៀបចំឡើង ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងសម្រួលដល់ការលើកកម្ពស់ជីវភាពរស់នៅ និងការធ្វើកសិកម្មរបស់គ្រួសារគ្មានដី។ អ្នកទទួលផលគួរអាចរកចំណូល សម្រាប់គ្រួសាររបស់ពួកគេនៅនឹងទីតាំងផ្ទាល់ និងមិនគួរបង្ខំចិត្តធ្វើចំណាកស្រុកទៅឆ្ងាយ ដើម្បីរកការងារធ្វើនោះទេ។ ពាក់ព័ន្ធជាមួយនឹងចំណុចនេះ កម្មវិធីសម្បទានដីសង្គមកិច្ចបង្ហាញឲ្យឃើញថា កំពុងទទួលបានជោគជ័យតែមួយផ្នែកប៉ុណ្ណោះ។

**ការទទួលបាន ទឹក និងអនាម័យ៖**

ការទទួលបានទឹកស្អាតប្រើប្រាស់ គឺជាបញ្ហាចោទមួយដ៏ខ្លាំងនៅក្នុងទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦ ដែលត្រូវបានអង្កេត។ ក្នុងចំណោមគ្រួសារទាំងអស់ដែលត្រូវបានសម្ភាស មានតែ ២៦% ប៉ុណ្ណោះ ដែលអះអាងថាអាចទទួលបានទឹកស្អាតសម្រាប់បរិភោគបានជាប់លាប់។ ប្រភពទឹករបស់ប្រជាពលរដ្ឋ រួមមាន អណ្តូងដៃ (៣១%) អណ្តូងស្នប់សាធារណៈ (១៣%) បឹងបួរ អូរ ឬស្រះ (២៣%) ទិញទឹកដបបរិភោគ (១១%) ឬត្រង់ទឹកភ្លៀងទុក (៩%)។ ៧៥% នៃអ្នករស់នៅទីតាំងនោះ បានរាយការណ៍ថា ធ្វើប្រព្រឹត្តកម្មទឹកមុនពេលបរិភោគ តាមរយៈការដាំឲ្យពុះ (៩០%) ឬការប្រើប្រាស់ជើងចម្រោះ (១០%)។ អ្នកឆ្លើយតប ៣៨% រាយការណ៍ពី ពណ៌ រសជាតិ និង/ឬ ក្លិនប្លែករបស់ទឹកដែលពួកគេបរិភោគ និងមានគ្រួសារតែ ២% ប៉ុណ្ណោះ ដែលលើកឡើងថា ទឹករបស់ពួកគេត្រូវបានសំអាតដោយប្រើប្រាស់សារធាតុក្លរ។ អ្នកឆ្លើយតបសម្ភាស ៤៧% ដាក់ពិន្ទុឲ្យការទទួលបានទឹកស្អាតរបស់ពួកគេ*ថាអន់ ឬអន់ខ្លាំង* ជាងកន្លែងដែលពួកគេរស់នៅកន្លងមក។ មានតែ ២៧% ប៉ុណ្ណោះ ដែលលើកឡើងថា ការទទួលបានទឹកប្រើប្រាស់មានភាពល្អប្រសើរជាងមុន។ នេះមានន័យថា បញ្ហាជុំវិញការមានទឹកស្អាតប្រើប្រាស់គឺមានភាពស្រួចស្រាវ នៅតាមគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ហើយទំនងជានឹងមានផលប៉ះពាល់លើសុខភាព ចំណូលរបស់គ្រួសារ ការអប់រំ និងការទទួលបានសិទ្ធិជាមូលដ្ឋានផ្សេងទៀត។

| ខេត្ត | បាត់ដំបង | ត្បូងឃ្មុំ | កំពង់ស្ពឺ | កំពង់ធំ | កំពត | មណ្ឌលគិរី | មធ្យម |
|---|---|---|---|---|---|---|---|
| ភាគរយនៃគ្រួសារទទួលផលសម្បទានដីសង្គម ដែលបានដាក់ពិន្ទុលើការទទួលបានទឹករបស់ពួកគេ ដោយសារមានលក្ខណៈអន់ជាង ប្រៀបទៅនឹងកន្លែងលំនៅឋានពីមុន | ៤៣% | ១៦% | ៤៦% | ៩១% | ៥៥% | ៦៨% | ៤៧% |

បើធ្វើការប្រៀបធៀប ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS)[52] ឆ្នាំ ២០១៤ លើកឡើងថា នៅរដូវប្រាំង គ្រួសារ ៣៥% នៅកម្ពុជា ផឹកទឹកដែលបានពីប្រភពដែលទំនងជា "ពុំមានគុណភាពសមស្រប" (ដែលឆ្លុះបញ្ចាំងពីប្រភេទដែលស្នើឡើងដោយអង្គការសុខភាពពិភពលោក (WHO) និងមូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF)។ ភាគរយនេះថយចុះមកនៅ ១៦% នៅរដូវវស្សា នៅពេលដែលមានគ្រួសារតាមផ្ទះកាន់តែច្រើនប្រើប្រាស់ទឹកភ្លៀង សម្រាប់បរិភោគ។ ប្រភពចម្បងនៃទឹកបរិភោគ នៅរដូវវស្សា គឺទឹកភ្លៀង សម្រាប់ជិតពីរគ្រួសារ ក្នុងរៀងរាល់ ៤ គ្រួសារ ហើយទឹកភ្លៀង គឺជាប្រភពទឹកបរិភោគដែលប្រើប្រាស់ញឹកញាប់ជាងគេ នៅរដូវវស្សា សម្រាប់គ្រួសារ ដែលតាំងនៅតំបន់ជនបទ។ នៅរដូវប្រាំង ភាគរយគ្រួសារ ដែលប្រភពទឹកផឹកនៅក្នុងបរិវេណផ្ទះរបស់ខ្លួនថយចុះមកនៅ ៦៩% សម្រាប់គ្រួសារនៅទីប្រជុំជន និង ៥១% សម្រាប់គ្រួសារនៅតំបន់ជនបទ។ ប្រភពទឹកបរិភោគគឺតែមួយ សម្រាប់រដូវប្រាំង និងរដូវវស្សា សម្រាប់ ៩២% នៃគ្រួសារតាមផ្ទះនៅទីប្រជុំជន និង ៦៧% នៃគ្រួសារតាមផ្ទះនៅជនបទ។[53] ការចាត់ប្រភេទរបស់ WHO និងUNICEF ចាត់ទុកទឹកអណ្តូងស្អុះ និងទឹកភ្លៀងថា ទំនងជាមានគុណភាពសមស្រប ហើយអ្នកឆ្លើយតបប្រហែលជាចាត់ទុកទឹករបស់ខ្លួនថាគ្មានសុវត្ថិភាពសម្រាប់បរិភោគទេ បើទោះបីជាទឹកចេញពី ប្រភពទាំងនេះក៏ដោយ ប្រសិនបើទឹកមានគុណភាពអន់ ឬអាចដោយសារតែពួកគេមិនដឹងច្បាស់ពីគុណភាពទឹក។

ទឹកស្អាតសម្រាប់បរិភោគ និងសេវាអនាម័យ មានភាពចាំបាច់បំផុត ដើម្បីធានានិរន្តរភាពជីវិតរស់នៅ និងសុខភាព និងជាមូលដ្ឋាន សម្រាប់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ សិទ្ធិទទួលបានទឹកស្អាត ក្នុងច្បាប់ សិទ្ធិមនុស្សអន្តរជាតិ តម្រូវឲ្យរដ្ឋនានាធានាយ៉ាងណាឲ្យប្រជាពលរដ្ឋគ្រប់រូប អាចទទួលបានទឹកស្អាតសម្រាប់បរិភោគក្នុងបរិមាណគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងប្រើប្រាស់ក្នុងគ្រួសារ ដែលត្រូវបានគេឲ្យនិយមន័យថាជា

[52] វិទ្យាស្ថានស្ថិតិជាតិ/កម្ពុជា, អគ្គនាយកដ្ឋានសំរាប់សុខភាព/កម្ពុជា, និង ICF international 2015។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ2014 https://dhsprogram.com/publications/publication-FR312-DHS-Final-Reports.com

[53] វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយដ្ឋានសុខភាព និង ICF អន្តរជាតិ ឆ្នាំ២០១៥។ អង្កេតស្ថិតិប្រជាសាស្ត្រ និងសុខភាព កម្ពុជា ឆ្នាំ២០១៤។ ភ្នំពេញ ប្រទេសកម្ពុជា និង រ៉ុកវីល ម៉ារីលែន សហរដ្ឋអាមេរិក៖ វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយដ្ឋានសុខភាព និង ICF អន្តរជាតិ។ ទំព័រ ១៨

ទឹកសម្រាប់បរិភោគ រក្សាអនាម័យផ្ទាល់ខ្លួន បោកសំអាតសម្លៀកបំពាក់ រៀបចំអាហារ និងអនាម័យផ្ទាល់ខ្លួន និងសម្រាប់ក្រុមគ្រួសារ។ កាតព្វកិច្ចទាំងនេះ ក៏តម្រូវឲ្យរដ្ឋធានាជាបណ្ដើរៗឲ្យប្រជាពលរដ្ឋ ទទួលបានសេវាអនាម័យឲ្យបានគ្រប់គ្រាន់ ដែលនេះជាសមាសភាគជាមូលដ្ឋានមួយសម្រាប់សេចក្តីថ្លៃថ្នូរ និងការរក្សាភាពជាឯកជនសម្រាប់មនុស្ស ក៏ដូចជាត្រូវការពារគុណភាពនៃការផ្គត់ផ្គង់ និងធនធានទឹកបរិភោគផងដែរ។[54] ដោយហេតុថាមានអ្នកឆ្លើយតបជិតពាក់កណ្ដាលអះអាងថាការទទួលបានទឹកមានការថមថយជាងមុននេះបង្ហាញថា <u>សិទ្ធិទទួលបានទឹកជាបណ្ដើរៗមិនត្រូវបានសម្រេចនៅតាមទីតាំងសម្បទានដីសង្គមកិច្ចក្នុងប្រទេសកម្ពុជាឡើយ។</u>

៩៨% ក្នុងចំណោមអ្នករស់នៅ ទីតាំងទាំងនោះ ត្រូវបានសាកសួរ បាននិយាយថានៅសម្បទានដីសង្គមកិច្ចនេះ ពុំមានប្រព័ន្ធបញ្ចេញចោលទឹកស្អុយដែលកំពុងដំណើរការនោះទេ។ មានគ្រួសារតែ ៤២% ប៉ុណ្ណោះ ទទួលបានប្រយោជន៍<u>បរិក្ខារអនាម័យក្នុងផ្ទះ</u>[55]។ មួយភាគបីនៃគ្រួសារដែលមានបង្គន់ក្នុងផ្ទះ លើកឡើងថា ពួកគេ ពុំមានទឹកគ្រប់គ្រាន់ដើម្បីប្រើប្រាស់បង្គន់នេះឲ្យបានត្រឹមត្រូវឡើយ។ ប្រជាជនផ្សេងទៀត បន្ទោរបង់ក្នុងព្រៃ ឬជីករណ្ដៅនៅកន្លែងណាមួយ ដើម្បីបន្ទោរបង់។ មានភាពខុសគ្នាខ្លាំង រវាងគ្រួសារតាមផ្ទះដែលរស់នៅទីក្រុង និងទីជនបទចំពោះលទ្ធភាពប្រើប្រាស់សម្ភារៈអនាម័យនៅទូទាំងប្រទេសកម្ពុជា។ ការអង្កេតរបស់ CDHS រាយការណ៍ថា គ្រួសារភាគច្រើននៅតំបន់ជនបទពុំមានបង្គន់ប្រើប្រាស់ឡើយ ដោយគ្រួសារពាក់កណ្ដាល (៥០%) រាយការណ៍មកថាគ្មានបង្គន់ ហើយត្រូវប្រើទីវាល ឬគុម្ពោតព្រៃសម្រាប់បន្ទោរបង់។ តួលេខនេះ ត្រូវបាន

[54] សិទ្ធិទទួលបានទឹកស្អាត ។ បណ្ណព័ត៌មាន OHCHR លេខ ៣៥, OHCHR, WHO និង UN Habitat ឆ្នាំ ២០១២។

[55] ស្របគ្នានេះដែរ និយមន័យនៃអនាម័យ ដូចបានស្នើរឡើងដោយអ្នកជំនាញឯករាជ្យ ស្តីពី ទឹក និងអនាម័យ ជា ប្រព័ន្ធមួយសម្រាប់ការប្រមូល ដឹកជញ្ជូន ការធ្វើប្រព្រឹត្តិកម្ម និងការបោះចោល ឬការប្រើប្រាស់ឡើងវិញនូវមលមោចនា (មានលាមក ទឹកនោម ញើស) របស់មនុស្ស និងអនាម័យភាពជាប់ពាក់ព័ន្ធ" ។ រដ្ឋ ត្រូវតែធានាឲ្យបានថា មនុស្សគ្រប់រូប ដោយគ្មានការរើសអើង មានសិទ្ធិជារូបវ័ន្ត និងគ្រប់គ្រាន់ ដើម្បីទទួលបាននូវអនាម័យ ក្នុងគ្រប់ទិដ្ឋភាពនៃជីវិត ដែលមានសុវត្ថិភាព ប្រកបដោយអនាម័យភាព សន្តិសុខ និងដែលអាចទទួលយកបានតាមលក្ខណៈវប្បធម៌ និងសង្គមកិច្ច ហើយដែលផ្តល់នូវ ភាពឯកជន និង ធានាឲ្យបាននូវសេចក្តីថ្លៃថ្នូរ" ។ សេចក្តីថ្លែងការណ៍ ស្តីពីសិទ្ធិមានអនាម័យ ឆ្នាំ២០១០ E/C ១២/២០១០/១

រាយការណ៍ដែរថាមាន ៧% ប៉ុណ្ណោះ ក្នុងចំនោមគ្រួសារតាមផ្ទះនៅតំបន់ទីប្រជុំជន ។ ការទទួលបានបរិក្ខារអនាម័យមានការកើនឡើងខ្លាំង ខណៈពេលដែលភាគរយនៃគ្រួសារតាមផ្ទះដែលពុំមានបរិក្ខារអនាម័យប្រើប្រាស់ថយចុះពី ៥៧% ក្នុងឆ្នាំ ២០១០ មកនៅត្រឹមតែ ៥៤% ក្នុងឆ្នាំ ២០១៤។[56] <u>ទីតាំងសម្បទានដីសង្គមកិច្ចដែលត្រូវបានអង្កេតទទួលបានពិន្ទុក្រោមមធ្យមភាគថ្នាក់ជាតិ សម្រាប់អនាម័យនៅតំបន់ជនបទ។</u>

ការទទួលបានទឹកប្រើប្រាស់ជាប្រចាំក្នុងផ្ទះ នឹងធ្វើឲ្យស្ត្រី និងកុមារលែងចាំបាច់ចំណាយពេលទៅរកទឹកពីប្រភពឆ្ងាយៗ ក៏ដូចជាកាត់បន្ថយហានិភ័យ ដែលពាក់ព័ន្ធនឹងការទៅដងទឹកតាមបឹង ទន្លេ និងស្រះជាដើម។ មានការរាយការណ៍អំពីករណីស្លាប់របស់កុមារជាច្រើនករណី ដោយសារផលវិបាកនៃការទទួលទឹកប្រើប្រាស់ខ្សត់ខ្សោយ នៅតាមកន្លែងតាំងទីលំនៅថ្មី។[57] UNICEF ក៏បានធ្វើរបាយការណ៍ផងដែរ ថា កង្វះខាតទឹក និងអនាម័យ គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាដ៏ធំបំផុត កំពុងមានផលប៉ះពាល់ដល់សុខភាពរបស់កុមារទូទាំងប្រទេសកម្ពុជា ជាពិសេស អ្នកដែលរស់នៅតាមទីជនបទ។ ផលវិបាកច្រើនចំពោះកុមារ ដែលមានលក្ខណៈធ្ងន់ធ្ងរជាពិសេសនោះ ដោយសារតែការកើតឡើងខ្ពស់នៃការរាគរុះ ជំងឺស្បែក ជំងឺផ្លូវដង្ហើម ដូចជា រោគរលាកសួត ពោះវៀន និងជំងឺផ្សេងដែលកើតពីទឹក និងជំងឺដែលទាក់ទងនឹង មលមោចនា(មានលាមក ទឹកនោម ញើស) សាយភាយទៅលើសុខភាពកុមារ ហើយនិងនៅក្នុងករណីជាច្រើនទៀត ផ្តល់លទ្ធផលដល់ការស្លាប់។[58] ចាំបាច់ត្រូវមានការធ្វើសកម្មភាពបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងកង្វះលទ្ធភាពទទួល បានទឹកស្អាតប្រើប្រាស់ នៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់។

---

[56] វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយដ្ឋានសុខភាព និង ICF អន្តរជាតិ ឆ្នាំ២០១៥។ អង្កេតស្ថិតិប្រជាសាស្ត្រ និងសុខភាព កម្ពុជា ឆ្នាំ២០១៤។ ភ្នំពេញ ប្រទេសកម្ពុជា និង រ៉ុកវីល ម៉ារីលែន សហរដ្ឋអាមេរិក៖ វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយដ្ឋានសុខភាព និង ICF អន្តរជាតិ។ ទំព័រ ៤២

[57] សូមមើល មរណភាពរបស់កុមារ២នាក់ ដែលទាក់ទងទៅនឹងគម្រោង AusAID នៅកម្ពុជា ដោយ Richard Baker និង Nick McKenzie ឆ្នាំ២០១០ អាចរកមើលបាននៅ http://www.smh.com.au/national/two-child-deaths-linked-to-ausaid-cambodia-project-20101031-178w7.html

[58] ឯកសារស្តីពី ទឹក អនាម័យ និងអនាម័យភាព របស់UNICEF កម្ពុជា។ អាចរកមើលបាននៅលើគេហទំព័រ https://www.unicef.org/cambodia/8.WASH.pdf

## សន្តិសុខស្បៀង៖

ការប្រយុទ្ធប្រឆាំងនឹងភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ គឺជាកាតព្វកិច្ចសិទ្ធិមនុស្សតាមផ្លូវច្បាប់។[59] បើតាមអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (ហៅកាត់ថា FAO) សន្តិសុខស្បៀងកើតមាន "នៅពេលដែលមនុស្សគ្រប់រូប មានលទ្ធភាពផ្នែករូបវន្ត សង្គម និងសេដ្ឋកិច្ច នៅគ្រប់ពេល ដើម្បីទទួលបានអាហារប្រកបដោយសុវត្ថិភាព និងសារជាតិចិញ្ចឹមនៅគ្រប់ពេល សម្រាប់បំពេញតម្រូវការអាហារ និងចំណង់ចំណូលចិត្តអាហាររបស់ពួកគេ ដើម្បីអាចរស់នៅបានប្រកបដោយភាពសកម្ម និងមានសុខភាពល្អ។"[60]

៩៨% នៃអ្នកឆ្លើយតប បាននិយាយថា យ៉ាងហោចណាស់មានម្តងក្នុងខែកន្លងទៅនេះ ពួកគេភ័យខ្លាចថាពួកគេនឹងពុំមានអាហារគ្រប់គ្រាន់ សម្រាប់គ្រួសាររបស់ពួកគេ ដោយ ៦១% លើកឡើងថា នេះគឺជាការភ័យខ្លាច ដែលពួកគេមានជាប្រចាំ។ <u>មានគ្រួសារ ៨៣% បានលើកឡើងថា ពួកគេមានរបបអាហារដោយមានកំណត់ និងត្បិតត្បៀត</u> (ដូចជាគ្មានសាច់ ឬត្រីបរិភោគជាដើម) នៅពេលណាមួយ ក្នុងខែកន្លងទៅនេះ ដោយសារតែខ្វះលុយ ហើយ ៨៨% ត្រូវរកគាស់កាយមើមរុក្ខជាតិពីក្នុងព្រៃ ឬរកសាច់ដែលមានគុណភាពអន់ខ្លាំងមកបរិភោគ ដោយសារតែមូលហេតុដូចគ្នានេះ។ អ្នកឆ្លើយតប ៦២% បានលើកឡើងថា ពួកគេធ្លាប់ដាច់អាហារ កាលពីខែមុននេះ ហើយអ្នកឆ្លើយតប ៥៥% អះអាងថាមានថ្ងៃខ្លះ ក្នុងខែកន្លងទៅនេះ ដែលពួកគេពុំមានអ្វីបរិភោគទាល់តែសោះ ដោយសារតែពុំមានលទ្ធភាពទិញអាហារ ឬដោយសារតែពុំមានអាហារ។ គ្រួសារតាមផ្ទះចំនួន ២៣% លើកឡើងថា លទ្ធភាពទទួលបានអាហារបរិភោគបានថមថយ ចាប់តាំងពីពេលដែលពួកគេ ផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ បើទោះបីជាសម្រាប់គ្រួសារចំនួន ៣៧% ស្ថានភាពនេះបានល្អប្រសើរជាងមុនក៏ដោយ។ មានតែ ១៦% ប៉ុណ្ណោះ ដែលលើកឡើងថា ស្ថានភាពនេះបានល្អប្រសើរជាងមុនក្នុងកម្រិតគួរឲ្យកត់សម្គាល់។ លទ្ធផលទាំងនេះរំលេចឲ្យឃើញថាតាមរយៈការធ្វើស្វ័យវាយតម្លៃ សន្តិសុខស្បៀង ដែលនៅតែជាបញ្ហា

---

[59] សិទ្ធិទទួលបានអាហារគ្រប់គ្រាន់។ បណ្ណព័ត៌មាន OHCHR លេខ ៣៥, OHCHR និង FAO ឆ្នាំ ២០១០។

[60] អង្គការ FAO, ស្ថានភាពអសន្តិសុខស្បៀងលើពិភពលោក ឆ្នាំ២០០១ (ទីក្រុងរ៉ូម ឆ្នាំ២០០១)

ប្រឈមធំមួយ សម្រាប់គ្រួសារភាគច្រើន។ លទ្ធផលដែលសម្រេចបានក្នុងផ្នែកនេះនៅមានស្តួចស្តើងនៅឡើយ។ ក្នុងទីតាំងសម្បទានដីសង្គមកិច្ចពាក់កណ្តាលដែលត្រូវបានវាយតម្លៃ លទ្ធភាពទទួលបានអាហារកាន់តែក្លាយទៅជាបញ្ហាធំ នៅពេលដែលប្រជាពលរដ្ឋមករស់នៅក្នុងទីតាំងសម្បទាន ដីសង្គមកិច្ច។ បញ្ហានេះទំនងជាកាន់តែរីកធំឡើងៗដោយសារតែគ្រួសារទទួលផលភាគច្រើន បានលើកឡើងថាពុំមានបទពិសោធន៍ ឬជំនាញខាងការធ្វើកសិកម្មឡើយ (អាចដោយសារតែគ្រួសារជាច្រើនធ្លាប់គ្មានដី)។ ដូច្នេះ អាហារូបត្ថម្ភទំនងជាបញ្ហាធំមួយ សម្រាប់គ្រួសារជាច្រើន ដែលរស់នៅក្នុងទីតាំងសម្បទានដីសង្គមកិច្ច ជាពិសេសសម្រាប់កុមារដែលខ្វះលទ្ធភាពទទួលបានចំណីអាហារជាមូលដ្ឋាន ដែលមានផ្ទុកប្រូតេអ៊ីន ហើយដែលគ្រួសារពុំមានលទ្ធភាពកាប់ឆ្ការដីសម្រាប់ធ្វើកសិកម្មបាន។

| ខេត្ត | បាត់ដំបង | ត្បូងឃ្មុំ | កំពង់ស្ពឺ | កំពង់ធំ | កំពត | មណ្ឌលគិរី | មធ្យម |
|---|---|---|---|---|---|---|---|
| ភាគរយនៃគ្រួសារទទួលផលសម្បទានដីសង្គម ដែលបានដាក់ពិន្ទុលើសន្តិសុខស្បៀងរបស់ពួកគេ ដោយសារមានភាពប្រសើរឡើងនៅទីតាំងសម្បទានដីសង្គមកិច្ច | ៣៣% | ៦០% | ៣៥% | ៩% | ៤១% | ១៦% | ៣៧% |

ប្រទេសកម្ពុជា បានសម្រេចវឌ្ឍនភាពតិចតួចប៉ុណ្ណោះ ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាអាហារូបត្ថម្ភជាទូទៅ។ បញ្ហាក្រិន ក្នុងចំណោមកុមារអាយុក្រោម ៥ ឆ្នាំនៅកម្ពុជា បានថយចុះពី ៤៥% ក្នុងឆ្នាំ ២០១០ មកនៅ ៣២% ក្នុងឆ្នាំ ២០១៤ ប៉ុន្តែបញ្ហាអាហារូបត្ថម្ភនៅតែត្រូវបានគេចាត់ទុកថាបានរួមចំណែកធ្វើឲ្យមានករណីកុមារស្លាប់ប្រមាណជា ៤៥% ក្នុងប្រទេសកម្ពុជា។[61] បញ្ហាក្រិនកើតមានច្រើនក្នុងចំណោមកុមារក្រីក្រ កុមារដែលម្តាយមាន

[61] Chhoun, P., et al. លក្ខខណ្ឌរស់នៅនិងការងារនៃមាតានិងកុមារដែលកង្វះអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា៖ ការពិនិត្យមើលជាប្រព័ន្ធ (ឆ្នាំ២០១៦) ៣ (៤):១-៧

កម្រិតវប្បធម៌ទាប និងក្នុងចំណោមសហគមន៍ដែលមានគ្រួសារតាមផ្ទះជាងពាក់កណ្តាល បន្ទោរបង់ពាសវាលពាសកាល។[62] នៅគ្រប់ទីតាំងសម្បទានដី សង្គមកិច្ចទាំងអស់ដែលបានចុះទៅ សុទ្ធតែខ្វះទឹកស្អាតប្រើប្រាស់ សេវាអនាម័យ ប្រជាជនបន្ទោរបង់ពាសវាលពាសកាល និងជួបប្រទះបញ្ហាសន្តិសុខស្បៀង។ ធនាគារពិភពលោក បានកំណត់ថា ដំណោះស្រាយចំពោះបញ្ហាអាហារូបត្ថម្ភត្រូវតែបញ្ចូលសកម្មភាពរួមគ្នាជាច្រើនដែលផ្តោតលើបញ្ហាលើសពីបរិមាណអាហារសម្រាប់បរិភោគ។ ដំណោះស្រាយនេះ គួរបញ្ចូលសកម្មភាពដែលផ្តោតលើគុណភាពអាហារ បរិស្ថាន (ការបន្ទោរបង់ពាសវាលពាសកាល) និងទម្លាប់អនាម័យ (លាងសំអាតដៃ និងអាហារ និងការអនុវត្តអនាម័យល្អប្រសើរផ្សេងទៀត)[63]។

របាយការណ៍អង្គការលីកាដូ ឆ្នាំ ២០១៥ ដែលវាយតម្លៃលើកម្មវិធីសម្បទានដីសង្គមកិច្ចក្រោមគម្រោង LASED បានរំលេចឲ្យឃើញពីបញ្ហាដីកសិកម្ម ពុំមានទំហំគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការធ្វើកសិកម្ម ដែលនាំឲ្យប្រជាពលរដ្ឋត្រូវបន្តជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង។[64] ខណៈពេលដែលអ្នកឆ្លើយតបចំពោះការអង្កេតភាគច្រើន ក្នុងការសិក្សាដែលធ្វើឡើងដោយ OHCHR ពុំបានលើកពីគុណភាពអន់នៃដី និងដីគ្មានជីជាតិ ថាជាបញ្ហាដែលនាំមកនូវ អសន្តិសុខស្បៀង តែវាហាក់បីដូចជាបញ្ហាដ៏ធំ នៅទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦ ដែលបានអង្កេត។ បញ្ហាចំណូលទាប ការជាប់បំណុលខ្ពស់ អនាម័យទាប កង្វះបរិក្ខារកសិកម្ម និងកង្វះឱកាសការងារសមរម្យ សុទ្ធតែរួមចំណែកនាំឲ្យមានបញ្ហាអសន្តិសុខស្បៀង និងបញ្ហាអាហារូបត្ថម្ភ នៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំង ៦ កន្លែង។

---

[62] Sobrado, Carlos; Neak, Samsen; Ly, Sodeth; Aldaz-Carroll, Enrique; Gamberoni, Elisa; Arias-Vazquez, Francisco; Fukao, Tsuyoshi; Beng, Simeth; Johnston, Timothy; Joaquin, Miguel San; Bruni, Lucilla; de Groot, Richard. ឆ្នាំ២០១៤ តើជនក្រីក្របាត់អស់ទៅណា? ការវាយតម្លៃភាពក្រីក្រប្រទេសកម្ពុជា ឆ្នាំ ២០១៣ វ៉ាស៊ីនតោន ឌីស៊ី ក្រុមធនាគារពិភពលោក។

[63] Ibid.World Bank Group 2013

[64] ដីដែលមិនអាចដាំដំណាំបាន៖ ការពិនិត្យទៅលើសម្បទានដីសង្គមកិច្ច អង្គការលីកាដូ ឆ្នាំ ២០១៥ ។

ស្ថានភាពនៅតាមទីតាំងសម្បទានដីសង្គមកិច្ចជាច្រើនកន្លែង ធ្វើឲ្យគ្រួសារទទួលផលមិនចង់ផ្លាស់ទៅនៅទីនោះជាអចិន្ត្រៃយ៍ឡើយ។ នេះ ធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពរបស់កម្មវិធីនេះ។ ប្រសិនបើ ពុំមានអ្នកតាំងទីលំនៅឲ្យបានច្រើនគ្រប់គ្រាន់ ដើម្បីជម្រុញសកម្មភាពសេដ្ឋកិច្ចនៅមូលដ្ឋាននោះទេ នោះកម្រិតចំណូល និងឱកាសការងារអាចនៅទ្រឹង ឬធ្លាក់ចុះជាមិនខាន។

**ជម្លោះដីធ្លី៖**

មានគ្រួសារទទួលផលចំនួន ២៦ គ្រួសារ (៩% នៃគ្រួសារតាមផ្ទះដែលត្រូវបានអង្កេត) បានលើកឡើងថា បច្ចុប្បន្ននេះ ពួកគេកំពុងជាប់ពាក់ព័ន្ធក្នុងជម្លោះដីធ្លី ជាមួយអ្នកតាំងទីលំនៅមុន ជាមួយអាជ្ញាធរមូលដ្ឋាន ឬក្រុមហ៊ុនឯកជន។ បើទោះបីជាភាគរយនេះជាចំនួនតិចតួច បើធៀបនឹងចំនួនគ្រួសារសរុបដែលបានអង្កេតក៏ដោយ វាគឺជាចំណុចគួរឲ្យព្រួយបារម្ភ ដោយសារតែកម្មវិធីសម្បទានដីសង្គមកិច្ចត្រូវបានរៀបចំឡើង ដើម្បីផ្តល់សិទ្ធិកាន់កាប់ឲ្យបានជាប់លាប់ និងផ្តល់លំនៅឋានសមរម្យដល់ប្រជាជនក្រីក្រ និងងាយរងគ្រោះ។ អ្នកឆ្លើយតប ២៩% ជួបប្រទះនឹងការទន្ទ្រានលើដីរបស់ខ្លួន ហើយមានគ្រួសារ ១៦% លើកឡើងថាបានទទួលរងការបៀតបៀន ឬការគំរាមកំហែង ពាក់ព័ន្ធជាមួយនឹងដីរបស់ពួកគេ ភាគច្រើនពីសំណាក់អ្នកដែលមកតាំងទីលំនៅមុនៗ ក៏ដូចជាពីក្រុមហ៊ុនឯកជន យោធា និងស្ថាប័នរដ្ឋ។ ការកើតឡើងខ្ពស់នូវការគំរាមកំហែង និងការយាយីដែលបានចោទប្រកាន់ច្រើនករណីពីស្ថាប័នរដ្ឋ និងយោធា គឺជាបញ្ហាចោទយ៉ាងពិសេសមួយ ដោយសារតែភាពងាយរងគ្រោះរបស់គ្រួសារក្រីក្រ និងដោយសារតែជាទូទៅ គ្រួសារតាមផ្ទះទាំងនេះពឹងអាស្រ័យលើស្ថាប័នរដ្ឋឲ្យដោះស្រាយបញ្ហាជម្លោះដីធ្លីឲ្យខ្លួន។ ការជាប់ពាក់ព័ន្ធរបស់ស្ថាប័នរដ្ឋ គឺជាឧបសគ្គមួយ ដែលរាំងដល់ការទទួលបានយុត្តិធម៌ និងដំណោះស្រាយជម្លោះដីធ្លីប្រកបដោយសមធម៌។ ចំណុចនេះ នឹងរួមចំណែកធំធេងដល់បញ្ហាសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ដែលផ្ទុយគ្នាទៅនឹងគោលដៅមួយ ក្នុងចំណោមគោលដៅនានានៃកម្មវិធីសម្បទានដីសង្គមកិច្ច។

មានបញ្ហាមួយចំនួន ត្រូវបានកំណត់ជាប់ពាក់ព័ន្ធទៅនឹងសម្បទានដីសង្គមកិច្ចជាក់លាក់ខ្លះ។ ឧទាហរណ៍៖ សហគមន៍ជនជាតិដើមភាគតិចមួយចំនួន ត្រូវបានគេបណ្តេញចេញដោយបង្ខំពីដី ដែលពួកគេ អះអាងថាជាដីដូនតារបស់ពួកគេ ដើម្បីប្រើជាសម្បទានដីសង្គមកិច្ចនៅក្នុងខេត្តមណ្ឌលគិរី។ បើតាមការលើកឡើងរបស់មន្ត្រីមូលដ្ឋានបច្ចុប្បន្ននេះ ដីមួយចំនួននៃសម្បទានដីសង្គមកិច្ចកំពុងអភិវឌ្ឍដោយក្រុមហ៊ុនឯកជន។ សេចក្តីប្រកាសរបស់សហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ដែលអនុម័តដោយមហាសន្និបាតសហប្រជាជាតិក្នុងឆ្នាំ ២០០៧ និងបានទទួលការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់សិទ្ធិរបស់ជនជាតិដើម ភាគតិចលើដីដែនដី និងធនធានរបស់ពួកគេរាប់បញ្ចូលទាំងដី ដែលធ្លាប់កាន់កាប់បែបប្រពៃណីដោយពួកគេ ប៉ុន្តែ បច្ចុប្បន្ននេះ កំពុងកាន់កាប់ដោយអ្នកផ្សេងទៀត ជាបញ្ហាអង្គហេតុ និងអង្គច្បាប់។[65] ដីដូនតា ពុំមែនជាពាក្យដែលត្រូវបានទទួលស្គាល់ក្នុងច្បាប់របស់ប្រទេសកម្ពុជាឡើយ ប៉ុន្តែច្បាប់ភូមិបាលឆ្នាំ ២០០១ មានបញ្ចូលជំពូកមួយស្តីពី "អចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច" និងបានផ្តល់និយមន័យដល់សហគមន៍ជនជាតិដើមភាគតិចថាជា "ក្រុមមនុស្សដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដី ដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។" [66] សម្រាប់ជនជាតិដើមភាគតិចជាច្រើន ក្នុងប្រទេសកម្ពុជាទំនាក់ទំនងរបស់ពួកគេជាមួយនឹងដី ដែនដី និងធនធានរបស់ពួកគេ គឺជាលក្ខណៈសំខាន់ដែលកំណត់ពីអត្តសញ្ញាណរបស់ពួកគេ។ និយមន័យសហគមន៍ជនជាតិដើមភាគតិចដែលចែងក្នុងច្បាប់ គឺផ្អែកទៅតាមការប្រើប្រាស់ដីតាមទំនៀមទម្លាប់ និងបែបផែនរស់នៅជាប្រពៃណី ប៉ុន្តែភស្តុតាងដែលបង្ហាញពីការរស់នៅតាមក្បួនខ្នាតទំនៀមទម្លាប់ និងបែបផែននៃការរស់នៅបែបប្រពៃណី អាចមិនងាយស្រួលផ្តល់គ្រប់ពេលនោះទេ ដោយហេតុថាប្រពៃណីតែងមានការប្រែប្រួល ហើយការប្រើប្រាស់ដីតាមបែបទំនៀមទម្លាប់ទៀតសោតតែងប្រែប្រួលជាបន្តបន្ទាប់ ទៅតាមការផ្លាស់ប្តូរស្ថានភាពជាក់ស្តែង ដែលកើតឡើង

[65]សេចក្តីប្រកាសរបស់សហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (២០០៧)

[66] ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ២៣

ដោយសាររបបគាបសង្កត់រាប់ទសវត្សរ៍ និងការបាត់បង់លំនៅឋានជាទូទៅ។[67] របកគំហើញមួយចំនួន ក្នុងការស្រាវជ្រាវនេះ បង្ហាញពីប្រភេទនៃបញ្ហាប្រឈម ដែលសហគមន៍ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជាជួបប្រទះ ក្នុងការការពារសិទ្ធិដីធ្លីរបស់ពួកគេ ដោយសារតែពួកគេត្រូវបានផាត់ចេញពីការពិគ្រោះយោបល់ និងពុំមានការអង្កេតពីផលប៉ះពាល់សង្គម។

សម្បទានដីសង្គមកិច្ចនៅក្នុងខេត្តបាត់ដំបង ត្រូវបានគេចេញលើដីដែលបានកាន់កាប់ដោយគ្រួសារផ្សេងៗ និងបន្សល់ទុកនូវជម្លោះលើដីនេះ។ លើសពីនេះទៀត កម្មវិធីធ្វើប័ណ្ណកម្មសិទ្ធិ និងការចែកចាយដីទាំងពីរនេះ (សម្បទានដីសង្គមកិច្ច និងយុទ្ធនាការបទបញ្ជា ០០១)[68] ត្រូវបានគេអនុវត្តក្នុងពេលជាមួយគ្នា ហើយវិធានរដ្ឋបាល បង្ហាញឲ្យឃើញថា ត្រូវបានគេប្រើប្រាស់ដោយអាចផ្លាស់ប្តូរគ្នាបាន។ កម្មវិធីសម្បទានដីសង្គមកិច្ចនេះ មានចេតនាផ្តល់ឲ្យគ្រួសារ អ្នកទទួលផលជាមួយប័ណ្ណកម្មសិទ្ធិលើក្បាលដីកសិកម្ម បានកាន់កាប់ដោយគ្រួសារផ្សេងៗ។ បន្ទាប់មក គ្រួសារទទួលផលសម្បទានដីសង្គមកិច្ច បានដាក់ពាក្យស្នើសុំ និងទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីក្រោមយុទ្ធនាការ ធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីតាមបទបញ្ជា ០០១ ថ្វីត្បិតតែយ៉ាងនេះ ក៏ជម្លោះដីធ្លីនេះ មិនទាន់ត្រូវបានគេដោះស្រាយនៅឡើយ រហូតដល់ពេលនេះ។ ឥឡូវនេះ គ្រួសារទទួលផលសម្បទានដីសង្គមកិច្ច កាន់កាប់ក្បាលដីលំនៅឋាន តែមិន កាន់កាប់ក្បាលដីកសិកម្មទេ។

---

[67] ធនាគារអភិវឌ្ឍអាស៊ី។ ដី និងការបន្តវប្បធម៌៖ សិទ្ធិលើដីសហគមន៍របស់ជនជាតិដើមភាគតិច នៅក្នុងតំបន់អាស៊ី។ ទីក្រុង Mandaluyong ប្រទេសពីលីពីន៖ ធនាគារអភិវឌ្ឍអាស៊ី ឆ្នាំ ២០០៩។

[68] ក្នុងខែឧសភាឆ្នាំ២០១២ បទបញ្ជាលេខ ០០១ ត្រូវបានចេញដោយនាយករដ្ឋមន្ត្រី ស្តីពីការប្រកាស ការបញ្ឈប់ជាបន្ទាន់បណ្តោះអាសន្ន នូវការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងការអនុវត្តគោលនយោបាយ "ស្បែកខ្លា" ចំពោះព្រំប្រទល់ដីរបស់សហគមន៍ដែលមានស្រាប់ និងព្រំប្រទល់ដី ប័ណ្ណកម្មសិទ្ធិឯកជន បានមាននៅក្នុងដីដែលបានយល់ព្រម នឹងត្រូវបានគេវាស់វែង និងផាត់ចេញពីសម្បទាន ហើយប័ណ្ណកម្ម សិទ្ធិដីនៅលើដីទាំងនោះ នឹងត្រូវបានផ្តល់ជូន។ បទបញ្ជា ០០១ មានចេតនាកាត់បន្ថយចំនួនដីជម្លោះក្នុងតំបន់ជនបទ និងផ្តល់សុវត្ថិភាពសិទ្ធិកាន់កាប់ សម្រាប់គ្រួសារ មានហានិភ័យនៃការបណ្តេញចេញជា សក្តានុពល ជាពិសេស ក្នុងតំបន់ជនបទ នៅលើ និងជុំវិញសម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀត។ យោងទៅតាម តួលេខរបស់រដ្ឋាភិបាល មកដល់ខែឧសភា ឆ្នាំ២០១៣ ចំនួន ២២៦,២៥២ប័ណ្ណកម្មសិទ្ធិ បានចេញរួចហើយទៅឲ្យគ្រួសារទាំងនោះ។ សូមមើលពី តួនាទី និងសមិទ្ធិផលរបស់ការិយាល័យ ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយដល់ប្រជាជន និងរដ្ឋាភិបាលកម្ពុជាក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្ស។ របាយការណ៍របស់អគ្គលេខាធិការ(A/HRC/24/32)។

អ្នកចុះសម្ភាស បានទទួលបណ្ដឹងជាច្រើនពីប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ជិតទីតាំងសម្បទានដីសង្គមកិច្ច ដោយពួកគេមួយចំនួនបានអះអាងថាត្រូវបានគេបណ្ដេញចេញពីសម្បទានដីសង្គមកិច្ច។ ប្រជាពលរដ្ឋផ្សេងទៀតបានលើកឡើងថា ដីព្រៃក្នុងមូលដ្ឋានដែលមានតម្លៃ ដែលគ្រួសារពឹងអាស្រ័យសម្រាប់ប្រមូលអនុផលព្រៃឈើ (ជាពិសេសសម្រាប់ធ្វើជាអាហារ បានទទួលរងការបំផ្លិចបំផ្លាញ)។ គ្រួសារទទួលផលមួយចំនួនអះអាងថាបានបង់ប្រាក់ជាច្រើន ដើម្បីឲ្យគេជ្រើសរើសផ្ដល់ដីឲ្យ។ អ្នកទទួលផលមួយចំនួន ហាក់បីដូចជាបានទទួលក្បាលដី ដែលធ្លាប់ប្រើ ឬកាន់កាប់ដោយអ្នកផ្សេងទៀតកន្លងមក។ ដូច្នេះ តួលេខ ៤% ខាងលើ មិនមែនជាការឆ្លុះបញ្ចាំងពិតប្រាកដពីចំនួនជម្លោះដីធ្លី ដែល បានកើត ឡើងដោយសារកម្មវិធីសម្បទានដីសង្គមកិច្ចឡើយ។

ខណៈពេលដែលមានកិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីធានាយ៉ាងណាឲ្យសម្បទានដីសង្គមកិច្ច ក្លាយជាដីដែលប្រជាពលរដ្ឋអាចរស់នៅបាន ការវាយតម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថាន ដែលតម្រូវដោយអនុក្រឹត្យស្ដីពីសម្បទានដីសង្គមកិច្ច ហាក់បីដូចជាមិនបានធ្វើ ឬធ្វើមិនបានគ្រប់ជ្រុងជ្រោយ ដើម្បីអាចកំណត់ដឹង និងកាត់បន្ថយហានិភ័យដែលអាចកើតឡើង និងហានិភ័យជាក់ស្ដែង ដែលកើតមានចំពោះសហគមន៍ជិតខាង។ ធនធានទឹក គឺជាធនធានកម្រនៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ហើយការហូរចូលយ៉ាងគំហ៊ុកភ្លាមៗរបស់ប្រជាពលរដ្ឋជាច្រើនគ្រួសារ ត្រូវតែបង្កការលំបាកបន្ថែមដែលមិនអាចចៀសរួចដល់គ្រួសារ ដែលរស់នៅតំបន់នេះ លើកលែងតែមានការវិនិយោគធំៗដើម្បីបង្កើតប្រភពផ្គត់ផ្គង់ទឹកស្អាត។

### អំពើហិង្សាលើស្ត្រី និងក្មេងស្រីៈ

អំពើហិង្សាលើស្ត្រី និងក្មេងស្រី បង្ហាញឲ្យឃើញថា គឺជាការព្រួយបារម្ភធំមួយសម្រាប់គ្រួសារ នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ (បើទោះបីជាមិនសូវជាកើតមានច្រើនករណី ក្នុងខេត្តកំពង់ធំ និងមណ្ឌលគិរី ក៏ដោយ នេះបើតាមការផ្ដល់ព័ត៌មានពីគ្រួសារ)។ ជារួម អ្នកឆ្លើយតប ៥៣% បានលើកឡើងថា ពួកគេបានដឹងពីករណីអំពើហិង្សាលើស្ត្រី និង/ឬក្មេងស្រី ហើយមានអ្នកឆ្លើយតបជាងមួយភាគបីជឿថាបញ្ហានេះបានកើន

ឡើង ចាប់តាំងពីពេលដែលពួកគេផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ការរកឃើញទាំងនេះ មិនផ្តល់នូវការគណនាច្បាស់លាស់នៃអត្រា ទូទៅនៃហិង្សាផ្លូវភេទនោះទេ។ ក្រុមចុះអង្កេត បានប្រើសំនួរលើប្រធានបទនេះដើម្បីវាស់គំនិតយោបល់សហគមន៍តែប៉ុណ្ណោះ។

ស្ថិតិជាតិ ដែលផ្សាយក្នុងការអង្កេត CDHS ឆ្នាំ ២០១៤ បង្ហាញថា ក្នុងចំណោមស្ត្រី ៥ នាក់ ដែលមានអាយុពី ១៥ ទៅ ៤៩ ឆ្នាំ មាន ១ នាក់ ធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយយ៉ាងហោចណាស់ម្តង ចាប់តាំងពីអាយុ១៥ ឆ្នាំមក និងមាន ៩% ទទួលរងអំពើហិង្សាផ្លូវកាយ ក្នុងកំឡុង ១២ ខែ មុនពេលមានការអង្កេតនេះ។ ស្ត្រីអាយុពី ១៥ ដល់ ៤៩ ឆ្នាំ ចំនួន ៦% រាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទយ៉ាងហោចណាស់ម្តង ក្នុងជីវិតរបស់ពួកគេ។[69] ការប្រមូលទិន្នន័យដែលសុក្រិត និងអាចជឿទុកចិត្តបានអំពីករណីអំពើហិង្សាក្នុងគ្រួសារ គឺជាការលំបាកមួយ ដោយសារតែករណីដែលចាត់ទុកថាជាអំពើហិង្សា ឬការរំលោភបំពានមានការប្រែប្រួលខុសៗគ្នាពីវប្បធម៌មួយ ទៅវប្បធម៌មួយទៀត និងពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ហើយជារឿយៗ វប្បធម៌នៃការរក្សាភាពស្ងៀមស្ងាត់ មានផលប៉ះពាល់លើកម្រិតនៃការរាយការណ៍។ ដូច្នេះ បើទោះបីរបកគំហើញនៃការអង្កេតនេះមិនអាចផ្តល់ស្ថិតិឲ្យបានសុក្រិតយ៉ាងណាក៏ដោយ ក៏ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី នៅតាមទីតាំងសម្បទានដីសង្គមកិច្ច គឺពិតជាឧស្សាហ៍កើតមានឡើង ហើយបញ្ហានេះទំនងជាមិនត្រូវបានគេរាយការណ៍គ្រប់ករណីឡើយ។

**និរន្តរភាព៖**

ថ្វីត្បិតតែអ្នកទទួលផល និងអាជ្ញាធរមូលដ្ឋានជួបប្រទះនឹងបញ្ហាប្រឈម ដូចបានពន្លេចឡើងខាងលើ ដូចជា ការទទួលបានទឹកដោយមានកំណត់ អសន្តិសុខស្បៀង និងឱកាសការងារ មានកំណត់នៅទីតាំងសម្បទានដីសង្គមកិច្ចក៏ដោយ ក្នុងចំណោមប្រជាជន

[69] វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយដ្ឋានសុខភាព និង ICF អន្តរជាតិ ឆ្នាំ២០១៥។ អង្កេតស្ថិតិប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១៤។ ភ្នំពេញ ប្រទេសកម្ពុជា និង រ៉ុកវិល ម៉ារីលែន សហរដ្ឋអាមេរិក៖ វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយដ្ឋានសុខភាព និង ICF អន្តរជាតិ។ ទំព័រ ២៥៧។

ដែលរស់នៅលើសម្បទានដីសង្គមកិច្ចទាំងអស់ដែលត្រូវបានអង្កេត មានតែ ១១% ប៉ុណ្ណោះ ដែលពិចារណាចាកចេញពីទីតាំងសម្បទានដីសង្គមកិច្ច។ នេះមិនមែនមានន័យថា កម្រិតជីវភាពរស់នៅសមរម្យទេ ឬមិនមានន័យថាសិទ្ធិទាំងនេះកំពុងត្រូវបានការពារ ឬលើកកម្ពស់ដោយសមរម្យទេ ឬក៏មិនមានន័យថាអ្នករស់នៅទីតាំងនោះពេញចិត្តជាមួយនឹងកម្មវិធី សម្បទានដីសង្គមកិច្ចនោះទេ។ ប៉ុន្តែ វាពិតជាបង្ហាញថា ជម្រើសផ្សេងក្រៅតែពីការរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ច ទំនងជារឹតតែយ៉ាប់យ៉ឺនជាងនេះ ហើយអ្នកទទួលផលជឿថា ពួកគេមានកម្រិតជីវភាពរស់នៅល្អប្រសើរជាងនៅលើទីតាំងសម្បទានដីសង្គមកិច្ច ជាជាងករណីដែលពួកគេផ្លាស់ទៅរស់នៅទីកន្លែងផ្សេង។ វាក៏អាចជាការឆ្លុះបញ្ចាំងផងដែរ ថា មានប្រជាជនជាច្រើនគ្រួសារនៅមិនទាន់បានទទួលប័ណ្ណកម្មសិទ្ធិដីដែលជាកត្តារារាំងមិនឲ្យពួកគេលក់ដីបាន។ គួរមានការពិនិត្យតាមដាន និងរាយការណ៍បន្ថែមទៀតពីការកាន់កាប់ដីរបស់គ្រួសារ ក្រោយពេលដែលគ្រួសារភាគច្រើនបានមកតាំងទីលំនៅលើទីតាំងសម្បទានដីសង្គមកិច្ចបានយ៉ាងហោចណាស់ ៥ ឆ្នាំ ដើម្បីកំណត់ពីនិរន្តរភាពពិតប្រាកដរបស់កម្មវិធីសម្បទានដីសង្គមកិច្ច។

ធនាគារពិភពលោកបានបង្ហាញថា សេដ្ឋកិច្ចរបស់កម្ពុជាមានកំណើនរឹងមាំ ក្នុងរយៈពេលមួយទសវត្សរ៍ ដោយទទួលបានចំណាត់ថ្នាក់ក្នុងចំណោមចំណាត់ថ្នាក់ល្អបំផុតក្នុងពិភពលោក ហើយការប្រើប្រាស់តាមគ្រួសារមានការកើនឡើងគួរឲ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ កំណើននេះគឺជាកំណើនដែលគាំទ្រដល់ជនក្រីក្រ ដោយមិនត្រឹមតែកាត់បន្ថយវិសមភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្កើនការប្រើប្រាស់របស់ប្រជាពលរដ្ឋក្រីក្របន្ថែមទៀត ពោលគឺលឿនជាងការប្រើប្រាស់របស់ប្រជាពលរដ្ឋដែលមិនមែនជាជនក្រីក្រទៅទៀត។ ជាលទ្ធផល អត្រានៃភាពក្រីក្រទូទាំងប្រទេសបានថយចុះគួរឲ្យកត់សម្គាល់ "លើសពីការរំពឹងទុក"។ ប៉ុន្តែ ប្រជាពលរដ្ឋភាគច្រើន ក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ បានគេចផុតពីភាពក្រីក្រតែបន្តិចបន្តួចប៉ុណ្ណោះ៖ ពួកគេនៅតែងាយរងគ្រោះខ្លាំង ដោយសូម្បីតែវិបត្តិបន្តិចបន្តួចក៏អាចរុញច្រានពួកគេឲ្យធ្លាក់ចូលទៅក្នុងភាព

ក្រីក្រវិញដែរ។[70] លទ្ធផលនៃការអង្កេតទាំងនេះបញ្ជាក់ថា គ្រួសារដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចគិតថា ខ្លួនងាយរងគ្រោះខ្លាំង ហើយបើទោះបីជាគ្រួសារជាច្រើនលែងត្រូវបានចាត់ទុកថាជាគ្រួសារក្រីក្រជាផ្លូវការ ដោយសារតែចំណូលរបស់ពួកគេកើនឡើងបន្តិចក៏ដោយ ក៏ពួកគេភាគច្រើន ស្ថិតនៅលើបន្ទាត់នៃភាពក្រីក្រតែបន្តិចបន្តួចប៉ុណ្ណោះ។ ដើម្បីឲ្យកម្មវិធីសម្បទានដីសង្គមកិច្ចទទួលបានផលដល់កម្រិតអតិបរមា គោលនយោបាយរបស់រដ្ឋាភិបាលគួរផ្តោតលើផលិតភាពនៃធនធានដែលប្រជាពលរដ្ឋក្រីក្រ រស់នៅតំបន់ជនបទមាន ពោលគឺកម្លាំងពលកម្ម និងដីរបស់ពួកគេ។ អាជ្ញាធរមូលដ្ឋាន គួរផ្តោតការយកចិត្តទុកដាក់លើការកសាងបន្ថែមលើអត្ថប្រយោជន៍ដែលបានកន្លងមកនៅលើទីតាំងសម្បទានដីសង្គមកិច្ច និងចៀសវាងការគិតថា ការផ្តល់ដី នឹងធានាជាស្វ័យប្រវត្តិឲ្យគ្រួសារទទួលផល អាចទទួលបានចំណូលបានជាប់លាប់ មានកម្រិតជីវភាពសមរម្យមានសិទ្ធិកាន់កាប់ដីជាប់លាប់ មានសុវត្ថិភាព និងអនាគតប្រកបដោយចីរភាពនោះ។

---

[70]Sobrado, Carlos; Neak, Samsen; Ly, Sodeth; Aldaz-Carroll, Enrique; Gamberoni, Elisa; Arias-Vazquez, Francisco; Fukao, Tsuyoshi; Beng, Simeth; Johnston, Timothy; Joaquin, Miguel San; Bruni, Lucilla; de Groot, Richard. ឆ្នាំ២០១៤ តើជនក្រីក្របាត់អស់ទៅណា? ការវាយតម្លៃភាពក្រីក្រប្រទេសកម្ពុជា ឆ្នាំ ២០១៣ វ៉ាស៊ីនតោន ឌីស៊ី ក្រុមធនាគារពិភពលោក។

## ឧបសម្ព័ន្ធទី ១៖ ទិន្នន័យអង្កេតពីសម្បទានដីសង្គមកិច្ចក្នុងឃុំស្រែសាមគ្គី ស្រុក ឱរ៉ាល់ ខេត្តកំពង់ស្ពឺ

*របកគំហើញសំខាន់ៗ*

- *អ្នកទទួលផលដែលឆ្លើយតបចំពោះការអង្កេតនេះភាគច្រើនលើសលុប បានលើកឡើងថា ខ្លួនបានចូលរួមក្នុងការកំណត់ និងរៀបចំផែនការនៅទីតាំងសម្បទានដីសង្គមកិច្ច ហើយអ្នកទទួលដីស្ទើរតែទាំងអស់ជឿថា ការបែងចែកដីធ្វើឡើងដោយយុត្តិធម៌។*
- *សហគមន៍ជិតខាងបានលើកឡើងពីការមិនសប្បាយចិត្តអំពីការបាត់បង់ដីព្រៃដែលគ្រួសារពឹងអាស្រ័យ សម្រាប់ប្រមូលអនុផលព្រៃឈើ។ ប្រភពដែលផ្តល់អាហារដ៏មានតម្លៃត្រូវទទួលរងការបំផ្លិចបំផ្លាញ ដើម្បីបង្កើតជាដីកសិកម្មសម្រាប់កម្មវិធីសម្បទានដីសង្គមកិច្ច ដោយអ្នកទទួលផលមិនមែនជាគ្រួសារដែលរស់នៅក្នុងមូលដ្ឋានឡើយ។ អ្នកឆ្លើយតបមកពីសហគមន៍ជិតខាងក៏បានអះអាងថាបានបាត់បង់ដី ដោយសារតែកម្មវិធីសម្បទានដីសង្គមកិច្ចនេះដែរ។ ដីដែលបាត់បង់នេះហាក់បីដូចជាអំពី ការចូលទៅ ដីព្រៃ ជាជាងដីលំនៅឋាន ។*
- *មិនទាន់មានគ្រួសារណាបានទទួលប័ណ្ណកម្មសិទ្ធិដីនៅឡើយទេ (ដោយសារតែពួកគេមិនបានរស់នៅក្នុងតំបន់នេះឲ្យបាន ៥ ឆ្នាំ ទៅតាមលក្ខខណ្ឌតម្រូវនោះឡើយ)។ ប៉ុន្តែ ពុំមានគ្រួសារតាមផ្ទះណា បានទទួលឯកសារពាក់ព័ន្ធនឹងការបែងចែកដីឡើយ។ គ្រួសារចំនួនបីភាគបួន បានចុះហត្ថលេខាលើកិច្ចសន្យាជាមួយអាជ្ញាធរទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ច ចំពោះសម្បទានដីសង្គមកិច្ចនេះ។*
- *អ្នកឆ្លើយតបប្រមាណជា ១៦% បានលើកឡើងថា ពួកគេទទួលបានចំណូលតិចតួចពីការធ្វើកសិកម្ម ដោយសារតែដីមានគុណភាពទាប។*
- *គ្រួសារពីរភាគបីដែលត្រូវបានសម្ភាសពុំបានទទួលទឹកស្អាតសម្រាប់ផឹកឡើយ។ ពួកគេជិតពាក់កណ្តាលដាក់ពិន្ទុឲ្យលទ្ធភាពទទួលបានទឹករបស់ពួកគេថាអន់ ឬអន់*

*ខ្លាំង ជាងនៅកន្លែងពួកគេរស់នៅមុនៗ។ លទ្ធភាពទទួលបានទឹក គឺជាបញ្ហាស្រួចស្រាវមួយក្នុងខេត្តកំពង់ស្ពឺ ហើយពុំមានការបែងចែកធនធានឲ្យបានគ្រប់គ្រាន់ដើម្បីផ្តល់ទឹកស្អាតសម្រាប់បរិភោគនោះឡើយ។ ពុំមានប្រព័ន្ធលូសម្រាប់បញ្ចេញទឹកស្អុយដាក់នៅទីតាំងសម្បទានដីសង្គមកិច្ចឡើយ បើទោះបីជាមានគ្រួសារតាមផ្ទះ ៧៥% មានបរិក្ខារអនាម័យក្នុងទម្រង់មួយចំនួនក៏ដោយ (ភាគច្រើនជាបង្គន់ចាក់ផេះ)។*

- *ការទទួលបានសេវាជាមូលដ្ឋានផ្សេងទៀត ដូចជា សុខភាព និងការអប់រំ នៅមានកម្រិតនៅឡើយ ( ជាមធ្យម ប្រជាពលរដ្ឋត្រូវចំណាយពេល ៦៥ នាទី ដើម្បីធ្វើដំណើរទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុត) ហើយហាក់បីដូច កំពុងកើតមាននូវតំរូវការយ៉ាងខ្លាំងក្លា អាស្រ័យលើថវិការបស់ខ្លួងផ្ទះក្រីក្រ ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះពុំទទួលបានការផ្គត់ផ្គង់អគ្គិសនីជាស្ថេរភាពឡើយ។ អសន្តិសុខស្បៀង គឺជាបញ្ហាមួយ សម្រាប់គ្រួសារភាគច្រើន។*
- *ចំណូលប្រចាំខែរបស់គ្រួសារជាមធ្យម មានការកើនឡើង ដូចគ្នានឹងចំណាយប្រចាំខែ និងបំណុលរបស់គ្រួសារផងដែរ។*

មានគ្រួសារតាមផ្ទះចំនួន ១៨១ ត្រូវបានសម្ភាសនៅទីតាំងសម្បទានដីសង្គមកិច្ចខេត្តកំពង់ស្ពឺនេះ។ មន្ត្រីមូលដ្ឋាន បានលើកឡើងថា គ្រួសារទទួលផលសរុបមានចំនួន ៥២៥ គ្រួសារ និងមានប្រជាពលរដ្ឋចំនួន ២០១៨ នាក់រស់នៅលើទីតាំងនេះ។ ដីនេះកន្លងមកធ្លាប់ចុះបញ្ជីជាដីសម្បទានសង្គមកិច្ច កាលពីខែ មិថុនា ឆ្នាំ ២០១២ នេះបើតាមការលើកឡើងរបស់អាជ្ញាធរមូលដ្ឋាន។ សម្បទានដីសង្គមកិច្ចនេះ ជាកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន បានបង្កើតឡើងតាមការស្នើសុំរបស់មន្ត្រីឃុំ និងក្រុមការងារថ្នាក់ស្រុក ដែលធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលជីវិតថ្លៃថ្នូរ (LWD) ដើម្បីអភិវឌ្ឍក្បាលដី។ ឥឡូវនេះ វា ជាផ្នែកមួយនៃកម្មវិធីបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន២ (LASED II) គាំទ្រពីក្រោយដោយធនាគារពិភពលោក(បានបញ្ចូលក្នុងជំហាន ២ របស់កម្មវិធីបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ប៉ុន្តែមិនមាននៅក្នុងជំហាន១ទេ)។

អ្នកឆ្លើយតប ៦៩% គឺជាស្ត្រី បើទោះបីជាមានអ្នកឆ្លើយតបត្រឹមតែ ៣០% ប៉ុណ្ណោះ ដែលបានប្រកាសថាមេគ្រួសារជាស្ត្រី។ ៨២% លើកឡើងថា ពួកគេរៀបការរួច ឬកំពុងរស់នៅជាមួយអ្នកដែលពួកគេមានទំនាក់ទំនងជាមួយ។ ១៥% គឺជាស្ត្រីមេម៉ាយ/បុរសពោះម៉ាយ ឬលែងលះ។ អាយុមធ្យមរបស់អ្នកឆ្លើយតបគឺ ៤៣ ឆ្នាំ។ អ្នកឆ្លើយតបទាំងអស់លើកឡើងថា ពួកគេជាជនជាតិខ្មែរ។

នៅពេលសាកសួរពីមូលហេតុដែលពួកគេបានទទួលដីសម្បទានសង្គមកិច្ច អ្នកឆ្លើយតប ៩៣% បានឆ្លើយថា ដោយសារតែពួកគេគ្មានដី ហើយ ៦៧% ឆ្លើយថាដោយសារតែពួកគេមានជីវភាពក្រីក្រ។ ចម្លើយនៅទីនេះមានលក្ខណៈត្រួតគ្នា ដោយសារតែអ្នកឆ្លើយតបផ្តល់ចម្លើយជាច្រើន ដើម្បីបញ្ជាក់ពីហេតុផលនៃការទទួលបានដី។ មានប្រជាពលរដ្ឋតែពីរគ្រួសារប៉ុណ្ណោះ ដែលបានលើកឡើងថា ពួកគេផ្លាស់មកទីនេះ ដោយសារតែគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ មាន ៣ គ្រួសារជាគ្រួសារយោធិនចូលនិវត្តន៍ និងមួយគ្រួសារលើកឡើងថា ពួកគេបានទទួលដី ដោយសារតែពួកគេធ្វើការងារក្នុងចំការសម្បទានដីសេដ្ឋកិច្ច។ ប្រជាពលរដ្ឋមួយគ្រួសារបានលើកឡើងថា ពួកគេត្រូវបានបណ្តេញចេញដោយបង្ខំពីដីមុនរបស់ពួកគេ ទីបំផុតក្លាយជាគ្រួសារដែលគ្មានដី និងបានទទួលដីមួយកន្លែងលើទីតាំងសម្បទានដី សង្គមកិច្ចនេះ។

នៅពេលសាកសួរពីមូលហេតុដែលគ្រួសារផ្សេងទៀតបានទទួលក្បាលដី ក្នុងទីតាំងសម្បទានដីសង្គមកិច្ច អ្នកឆ្លើយតបបានលើកឡើងពីភាពគ្មានដី (៨៦%) និងភាពក្រីក្រ (៦១%) ថាជាហេតុផលចម្បង។ ពុំមានអ្នកឆ្លើយតបជាច្រើន លើកឡើងថា ការបែងចែកដីមានទំនាក់ទំនងផ្ទាល់ជាមួយនឹងការងារសម្បទានដីសេដ្ឋកិច្ចឡើយ។ នេះបង្ហាញថា ក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចក្នុងខេត្តកំពង់ស្ពឺនេះ អ្នកទទួលផលមានមន្ទិលសង្ស័យតិចតួចប៉ុណ្ណោះអំពីការបែងចែកក្បាលដីមិនត្រឹមត្រូវ យកពីគ្រួសារក្រីក្រ ឬគ្មានដី ទៅឲ្យអ្នកដែលផ្លាស់មកនៅតំបន់នេះ ដើម្បីធ្វើការងារលើសម្បទានដីសេដ្ឋកិច្ច។

មានអ្នកទទួលផលតែ ៧០% ប៉ុណ្ណោះ ដែលមានប័ណ្ណសម្គាល់គ្រួសារក្រីក្រ (តាមរយៈកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ) ខណៈពេលដែលអ្នកឆ្លើយតប ៣០% ទៀត ពុំ

មានប័ណ្ណនេះឡើយ។ បើតាមទ្រឹស្តី អ្នកទទួលផលសម្បទានដីសង្គមកិច្ច ក្រៅតែពីយោធិនរំសាយ ឬជនរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ គួរទទួលបានប័ណ្ណអត្តសញ្ញាណគ្រួសារក្រីក្រ ដោយសារតែប័ណ្ណនេះគឺជាមធ្យោបាយចម្បង សម្រាប់វាយតម្លៃកម្រិតនៃភាពក្រីក្រ និងកំណត់អត្តសញ្ញាណអ្នកសុំដី និងអ្នកទទួលបានដីដែលបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្រប។[71] កង្វះប័ណ្ណគ្រួសារក្រីក្រ មានន័យថា មានការប្រើប្រាស់មធ្យោបាយផ្សេងទៀត ដើម្បីវាយតម្លៃកម្រិតនៃភាពក្រីក្រ និងកំណត់អត្តសញ្ញាណអ្នកដែលបំពេញតាមលក្ខណៈសម្បត្តិសមស្រប ដើម្បីទទួលបានដី។ អាជ្ញាធរមូលដ្ឋានដែលបានសាកសួរ បានលើកឡើងថា ការជ្រើសរើសត្រូវបានធ្វើឡើង ដោយផ្អែកទៅតាមភាពគ្មានដី និងភាពក្រីក្រ ប៉ុន្តែពុំបានផ្តល់ព័ត៌មានលំអិតបន្ថែមអំពីរបៀបវាយតម្លៃ ឬបញ្ជាក់លើការជ្រើសរើសនេះទេ។ ពុំមានការបង្ហាញថាមានការលំអៀងទៅរកក្រុមណាមួយនោះទេ ហើយពុំមានប្រជាពលរដ្ឋដែលរស់នៅជាប់នឹងសម្បទានដីសង្គមកិច្ចណាបានទទួលក្បាលដី នៅទីតាំង សម្បទានដីសង្គមកិច្ចនេះទេ។

អ្នកទទួលដីដែលឆ្លើយតបភាគច្រើនលើសលុប (៩៥%) អះអាងថាបានចូលរួមក្នុង <u>ការកំណត់ និងការរៀបចំផែនការនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ</u>។ នេះគឺជាភាគរយខ្ពស់បំផុតនៃការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការនេះ ក្នុងចំណោមទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ដែលត្រូវបានអង្កេត។ នេះបង្ហាញថា ដំណើរការពិគ្រោះយោបល់ក្នុងខេត្តកំពង់ស្ពឺមានបរិយាប័ន្នជាងនៅទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀត។ លើសពីនេះ ប្រជាពលរដ្ឋ ៩៨% បានលើកឡើងថា អាជ្ញាធរមូលដ្ឋានបានពន្យល់ពីដំណើរការជ្រើសរើស និងបែងចែកដីនេះដែរ។ អ្នកឆ្លើយតប ៩១% បានលើកឡើងថា ពួកគេ បានចូលរួមក្នុងការជ្រើសរើសក្បាលដី។ កិច្ចពិគ្រោះយោបល់ នាំឲ្យដំណើរការកាន់តែមាន

[71] មាត្រា ១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣) ចែងថា អ្នកសុំដីសម្បទានសង្គមកិច្ចគួរបំពេញលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុ ដែលកំណត់ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយផ្អែកលើយោបល់របស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ។ គោលការណ៍ណែនាំអំពីការវាយតម្លៃប្រាក់ចំណូលត្រូវពិចារណាដោយផ្អែកលើទំហំគ្រួសារ និងលក្ខខណ្ឌ អាយុ និងសុខភាពនៃសមាជិកគ្រួសារ។ គោលការណ៍ណែនាំនេះអាចប្រែប្រួលទៅតាមតំបន់ ទៅតាមពេលវេលា ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច និងជីវភាពរស់នៅ។

បរិយាប័ន្ន នាំឲ្យការបែងចែកដី និងធនធានផ្សេងទៀតកាន់តែមានសមធម៌ និងធ្វើឲ្យការរៀបចំផែនការសម្បទានដីសង្គមកិច្ចកាន់តែមានភាពល្អប្រសើរ ព្រោះបានពិចារណាលើតម្រូវការ និងសិទ្ធិរបស់គ្រួសារទទួលដី។ ចំណុចនេះត្រូវបានរកឃើញចេញពីស្ថិតិ ដែលបង្ហាញថា គ្រួសារទទួលផល ៩៨% ជឿថា ការបែងចែកដីធ្វើឡើងប្រកបដោយយុត្តិធម៌។ តួលេខនេះ គឺខ្ពស់ជាងតួលេខមធ្យម ៦៧% សម្រាប់គ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ដែលត្រូវបានជ្រើសរើសសម្រាប់ការអង្កេតនេះ។ ពុំមានអ្នកឆ្លើយតបណាលើកឡើងថា ពួកគេបានបង់លុយ ដើម្បីទទួលបានដីនោះឡើយ។ ស្ថិតិនេះ បង្ហាញថាអាជ្ញាធរមូលដ្ឋានមានការអនុវត្តបានល្អ និងមេរៀនដែលកន្លែងផ្សេងទៀត អាចរៀនសូត្រតាមជុំវិញការរៀបចំផែនការ ការពិគ្រោះយោបល់ ការចូលរួម (បរិយាប័ន្ន) និងការបែងចែកដីប្រកបដោយសមធម៌។

អាជ្ញាធរមូលដ្ឋាន បានលើកឡើងថាបានធ្វើការវាយតម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថាននៅតំបន់នេះដែរ។ ផលប៉ះពាល់តែមួយគត់ ដែលត្រូវបានរៀបរាប់ សម្រាប់គោលបំណងនៃការរៀបចំផែនការ គឺភាពចាំបាច់ ដើម្បីកាប់ឆ្ការដីសម្បទានសង្គមកិច្ច សម្រាប់ធ្វើកសិកម្ម។ ពួកគេ ក៏បានលើកឡើងផងដែរថា មានការរៀបចំកិច្ចពិគ្រោះយោបល់ជាមួយនឹងសហគមន៍ជិតខាង ដែលរស់នៅជិតទីតាំងសម្បទានដីសង្គមកិច្ចផងដែរ ហើយកិច្ចពិគ្រោះយោបល់ទាំងនេះត្រូវបានរៀបចំឡើង ដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋទាំងនោះអំពីព្រំប្រទល់សម្បទានដីសង្គមកិច្ច និងដោយសារតែពួកគេមួយចំនួនក៏ស្នើសុំដី ក្នុងសម្បទានដីសង្គមកិច្ចនេះដែរ។ អាជ្ញាធរក៏បានបញ្ជាក់ផងដែរថា ពុំមានគ្រួសារណារស់នៅក្នុងបរិវេណសម្បទានដីសង្គមកិច្ចនេះ មុនពេលចុះបញ្ជីឡើយ។

ក្នុងកំឡុងពេល ធ្វើការពិភាក្សាក្រុមគោលដៅជាមួយនឹងប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ក្បែរខាងទីតាំងសម្បទានដីសង្គមកិច្ច មានការលើកឡើងពីការមិនសប្បាយចិត្តជុំវិញការបាត់បង់ដីព្រៃមូលដ្ឋាន ដែលពួកគេពឹងអាស្រ័យ សម្រាប់ប្រមូលអនុផលព្រៃឈើ។ ពួកគេ បានលើកឡើងថា ដីព្រៃនេះគឺជាប្រភពអាហារដ៏មានតម្លៃ ដែលឥឡូវនេះ

បានទទួលរងការបំផ្លិចបំផ្លាញ ដើម្បីយកដីមកធ្វើកសិកម្ម ហើយអ្នកទទួលដីមិនមែនជាប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋាននេះ។

ការរៀបចំ និងអនុវត្តការងារអភិវឌ្ឍន៍សម្បទានដីសង្គមកិច្ច នៅថ្នាក់ឃុំ ឬថ្នាក់ខេត្តធ្វើឡើង ដោយប្រើប្រាស់ដំណើរការវិមជ្ឈការ។ ក្រៅតែពីអ្នកទទួលបានដី អ្នកដែលទទួលផលជាចម្បងពីការអនុវត្តល្អទាំងនេះគឺស្ថាប័នអនុវត្តនៅថ្នាក់ខេត្ត ស្រុក និងឃុំ ដែលជាអ្នកត្រូវបង្កើតវិធីសាស្រ្តឲ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិ សម្រាប់បង្កើតសម្បទានដីសង្គមកិច្ច និងធានាយ៉ាងណាឲ្យមានការគិតគូរពីសេចក្តីត្រូវការរបស់គ្រួសារក្រីក្រ ឬគ្រួសារគ្មានដី។

ប៉ុន្តែ មានគ្រួសារតាមផ្ទះ ៩៩% ពុំបានទទួលឯកសារពាក់ព័ន្ធនឹងការបែងចែកដីឡើយ ដែលនេះជាបញ្ហាចោទ។ នៅពេលពុំមានប័ណ្ណកម្មសិទ្ធិដី ប្រជាពលរដ្ឋ គួរមានឯកសារដើម្បីបង្ហាញភស្តុតាងពីដំណើរការរៀបចំផែនការ និងបែងចែកដី ដែលនេះជាមធ្យោបាយមួយ ដើម្បីការពារសិទ្ធិភោគៈ និងសិទ្ធិមានកម្មសិទ្ធិរបស់ពួកគេ។ គ្រួសារ ៧៦% បានចុះកិច្ចសន្យាជាមួយអាជ្ញាធរទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ចចំពោះសម្បទានដីសង្គមកិច្ចនេះ។

ពុំមានគ្រួសារណាបានលើកឡើងថា ពួកគេបានទទួលប័ណ្ណកម្មសិទ្ធិដីឡើយ។ ចំនួនខែជាមធ្យម ដែលប្រជាពលរដ្ឋរស់នៅលើដីសម្បទានសង្គមកិច្ចនេះគឺ ៣៧ ខែ គិតត្រឹមពេលសម្ភាសនេះ។ បើតាមអនុក្រឹត្យនេះ អ្នកទទួលដី ត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសម្បទានដីសង្គមកិច្ច ដោយត្រូវរស់នៅឲ្យបាន ៥ ឆ្នាំ ទើបមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិដីស្របច្បាប់។ ប៉ុន្តែ អ្នកឆ្លើយតបភាគច្រើនលើសលុប (៨៧%) ត្រូវបានប្រាប់ថាពួកគេនឹងទទួលបានប័ណ្ណកម្មសិទ្ធិ ក្រោយពេលចប់រយៈពេល ៥ ឆ្នាំ។ ប្រជាពលរដ្ឋដែលរស់នៅលើដីសម្បទានសង្គមកិច្ចភាគច្រើន (៩០%) ក៏បានទទួលឯកសារខ្លះ ពាក់ព័ន្ធជាមួយនឹងភោគៈ ឬកម្មសិទ្ធិផងដែរ (ឯកសារ ៧០% ពាក់ព័ន្ធជាមួយនឹងការចាប់ឆ្នោតយកដី ២០% ប័ណ្ណសម្គាល់អត្តសញ្ញាណដែលចេញដោយអង្គការមិនមែនរដ្ឋាភិបាល និង ១៧% កិច្ចសន្យា ឬកិច្ចព្រមព្រៀងទាក់ទងនឹងសម្បទានដីសង្គមកិច្ច) ដែលផ្តល់ឲ្យពួកគេ

នូវសិទ្ធិកាន់កាប់មិនបានជាប់លាប់ ក្នុងរយៈពេលអន្តរកាលនេះ។ នេះមិនមែនជាស្ថានភាពដែលល្អបំផុតឡើយ - ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចគួរមានឯកសារ និងកិច្ចសន្យាទាក់ទងនឹងសម្បទានដីសង្គមកិច្ចនេះ។ ប៉ុន្តែ ភាគរយនេះ គឺខ្ពស់ជាងភាគរយមធ្យមសម្រាប់គ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ (៥៣%)។

ជាការប្រៀបធៀប ក្នុងចំណោមអ្នកឆ្លើយតបទាំងអស់នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ មាន ៥៦% បានទទួលប័ណ្ណកម្មសិទ្ធិដី បើទោះបីជាចំនួនខែគិតជាមធ្យមនៃអ្នកដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ មានចំនួនខ្ពស់រហូតដល់ ៨២ ខែ ក៏ដោយ។ ប្រជាពលរដ្ឋគ្រប់គ្រួសារទាំងអស់គួរទទួលបានព័ត៌មានពីពេលដែលពួកគេត្រូវទទួលបានប័ណ្ណកម្មសិទ្ធិដី (គ្រួសារ ១៣% ដែលរស់នៅលើសម្បទានដីសង្គមកិច្ចក្នុងខេត្តកំពង់ស្ពឺ បានលើកឡើងថា ពួកគេមិនបានទទួលព័ត៌មាននេះឡើយ) ហើយប្រជាពលរដ្ឋគ្រប់គ្រួសារទាំងអស់ គួរទទួលបានឯកសារដែលបង្ហាញពីសិទ្ធិភោគៈ និងផ្តល់សិទ្ធិកាន់កាប់ដល់ពួកគេ រហូតដល់ពេលដែលរយៈពេល ៥ ឆ្នាំត្រូវបានបញ្ចប់ និងមានការចែកប័ណ្ណកម្មសិទ្ធិ។

អ្នកឆ្លើយតបប្រមាណជា ពីរភាគបី (៦៥%) <u>បានមើលផែនការសម្បទានដីសង្គមកិច្ច</u>។ ក្រុមប្រឹក្សាឃុំគួរផ្តួចផ្តើមរៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របទៅតាមលក្ខខណ្ឌ ដូចដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។ អ្នកទទួលផលសម្បទានដីសង្គមកិច្ច "ត្រូវតែបានត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចស្របតាមផែនការសម្បទានដីសង្គមកិច្ច ដែលបានយល់ព្រម។"[72] អ្នកឆ្លើយតបចំនួន ៩២% ត្រូវបានស្នើឲ្យចូលរួមកែលំអស្ថានភាព នៅលើដីសម្បទានសង្គមកិច្ចនេះ។ នេះបង្ហាញពី<u>ការជម្រុញឲ្យសហគមន៍ចូលរួមក្នុងកម្រិតខ្ពស់ពីសំណាក់អាជ្ញាធរមូលដ្ឋាន</u> ទាំងនៅកម្រិតនៃការពិគ្រោះយោបល់ ទាំងក្នុងការរៀបចំផែនការបន្តអភិវឌ្ឍន៍ទីតាំងនេះ។

---

[72] មាត្រា ១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣)។

អាជ្ញាធរមូលដ្ឋានបានលើកឡើងថា ពួកគេពុំបានជួបប្រទះនឹងបញ្ហាធ្ងន់ធ្ងរ ឬបញ្ហាប្រឈមអ្វី ក្នុងការចាត់ចែងដំណើរការសម្បទានដីសង្គមកិច្ចនោះទេ។

អ្នកឆ្លើយតបស្ទើរតែទាំងអស់ (៩៧%) លើកឡើងថា ពួកគេ បាន<u>ត្អូញត្អែរប្រាប់អាជ្ញាធរអំពីស្ថានភាពនៃការរស់នៅ</u>លើទីតាំងនេះ។ ការត្អូញត្អែរញឹកញាប់ជាងគេ គឺពាក់ព័ន្ធនឹងកង្វះទឹកស្អាតបរិភោគ (៨៤%) បន្ទាប់មកគឺកង្វះអាហារ (៨៤%) និងសម្ភារៈកសិកម្ម (២២%) ការទៅទទួលសេវានៅមណ្ឌលសុខភាព (២១%) និងកង្វះឱកាសការងារ (២០%)។ ផ្ទុយទៅវិញ កង្វះអគ្គិសនីត្រូវបានលើកឡើងដោយអ្នកចូលរួម ៦% ចំងាយផ្លូវទៅសាលារៀន ៥% និងការមានបង្គន់អនាម័យប្រើប្រាស់ ៧% ដែលជាភាគរយមួយទាបជាងនៅទីតាំងសម្បទានដីសង្គមកិច្ច ផ្សេងទៀត។ បញ្ហាផ្សេងទៀតដែលត្រូវបានលើកឡើង រួមមាន កង្វះប្រព័ន្ធធារាសាស្ត្រ ដើម្បីបង្កើភាពងាយស្រួលដល់ការធ្វើកសិកម្ម ដីគ្មានជីជាតិ កង្វះគ្រាប់ពូជ កង្វះវាលស្មៅសម្រាប់សត្វពាហៈណៈ មធ្យោបាយរកចំណូលមានមិនគ្រប់គ្រាន់ កង្វះវត្តអារាម ។ល។

ចំណុចទាំងនេះត្រូវបានលើកឡើង បើទោះបីជាមានអ្នកឆ្លើយតប ៨៦% លើកឡើងថា អាជ្ញាធរមូលដ្ឋានបានពិនិត្យតាមដានស្ថានភាពក្នុងទីតាំងនេះយ៉ាងសកម្មយ៉ាងណាក៏ដោយ។ អាជ្ញាធរមូលដ្ឋានបានដឹងយ៉ាងច្បាស់ពីស្ថានភាពទាំងនេះ បន្ទាប់ពីបានទទួលការត្អូញត្អែររបស់ប្រជាពលរដ្ឋ និងបានចូលរួមពិនិត្យតាមដាន និងចុះផ្សព្វផ្សាយព័ត៌មានរួចមក។ ពួកគេ អាចខ្វះធន្ទៈ សមត្ថភាព ឬធនធានដើម្បីដោះស្រាយបញ្ហាទាំងនេះ។ មានគ្រួសារតែ ៦៣% ប៉ុណ្ណោះ ដែលលើកឡើងថា អាជ្ញាធរមូលដ្ឋានបានឆ្លើយតបចំពោះកង្វល់របស់ពួកគេ - ចំណុចនេះអាចបកស្រាយបានថាជាការបានដោះស្រាយបញ្ហា ឬគ្រាន់តែជាការទទួលដឹងឮពីបញ្ហា។ អ្នកឆ្លើយតបបានលើកឡើងថា <u>កិច្ចប្រជុំតាមភូមិ</u> (៦១%) និងការចុះជួបតាមផ្ទះ (៤៥%) គឺជាមធ្យោបាយចម្បងសម្រាប់លើកឡើងពីទុក្ខលំបាកនានា ដែលនេះបង្ហាញពីកម្រិតនៃការចូលរួមខ្ពស់ពីសំណាក់អាជ្ញាធរមូលដ្ឋាន។ ប្រជាពលរដ្ឋដែលរស់នៅលើដីសម្បទានសង្គមកិច្ច ៤៨% បានលើកឡើងថា មានការទទួលការលើកឡើងពីទុក្ខលំបាក ឬប្រមូលភស្តុតាងផ្សេងៗជាទៀងរាល់ខែ ហើយ ៣៥% ទៀត បានទទួលការរាយ

តម្លៃ ឬពិគ្រោះយោបល់ជាមួយ រៀងរាល់ ៣ ខែម្តង។ ការចូលរួមក្នុងកម្រិតខ្ពស់បែបនេះ បង្ហាញថា អាជ្ញាធរមូលដ្ឋានបានចំណាយពេលវេលា និងកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើន ដើម្បីស្វែងយល់ពីតម្រូវការ និងបញ្ហានានារបស់សហគមន៍ បើទោះបីជា ពួកគេ ខ្វះខាតធនធានដើម្បីឆ្លើយតបចំពោះរាល់ទុក្ខលំបាកទាំងអស់ក៏ដោយ។

អាជ្ញាធរមូលដ្ឋានបានលើកឡើងថា ពួកគេបានផ្តល់ "បង្គន់ ស័ង្កសី ស៊ីម៉ងត៍ ឥដ្ឋ ចបកាំបិត ប្រាក់ចំនួន ៨០ ដុល្លារ ជួយសង់អណ្តូង" និងមានការផ្តល់គ្រាក់ទ័រជាច្រើនគ្រឿងដល់សហគមន៍។ សហគមន៍បាន<u>ផ្ដួចផ្ដើមគំនិតកែលំអស្ថានភាពនៃការរស់នៅ</u> ក្នុងតំបន់សម្បទានដីសង្គមកិច្ចនេះ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះផ្តោតការយកចិត្តទុកដាក់លើការកែលំអ ការសាងសង់ ឬការថែទាំអណ្តូង (៩៥%) និងការកែលំអប្រព័ន្ធធារាសាស្ត្រ (៥៣%)។ ទឹកគឺជាធនធានកម្រមួយ និងជាប្រភពដែលនាំឲ្យមានបញ្ហាធំៗ នៅតំបន់សម្បទានដី សង្គមកិច្ចនេះ។ ហាក់បីដូចជាមានការខិតខំប្រឹងប្រែងជាច្រើន ដើម្បីធ្វើឲ្យកន្លែងផ្តល់សេវា និងសេវានៅមូលដ្ឋាននេះកាន់តែមានភាពល្អប្រសើរ បើទោះបីជា គេ នៅមិនទាន់ដឹងច្បាស់នៅឡើយ ថាតើ អាជ្ញាធរអាចផ្តល់ជំនួយអ្វីខ្លះ ប្រសិនបើ បានផ្តល់ ដល់សកម្មភាពនេះ។

**ភាពសមស្របនៃដី៖**

ប្រជាពលរដ្ឋចំនួន ១៦២ គ្រួសារ (៩០%) បាន<u>ទទួលដីលំនៅឋានផង និងដីកសិកម្មផង</u>។ គ្រួសារ ៣ ទៀត ដែលត្រូវបានសាកសួរផងដែរនោះ បានទទួលតែដីលំនៅឋានតែប៉ុណ្ណោះ។ បើទោះបីជាចំនួននេះទាបឆ្ងាយជាងតួលេខមធ្យមក្នុងតំបន់សម្បទានដីសង្គមកិច្ចផ្សេងទៀតក៏ដោយ វាគឺជាការព្រួយបារម្ភមួយ ប្រសិនបើគ្រួសារមិនអាចទ្រទ្រង់ជីវភាពរបស់ខ្លួនបាន។ គ្រួសារទាំងនេះអាចមានមធ្យោបាយផ្សេងទៀត ដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន។ អនុក្រឹត្យនេះចែងថា ក្បាលដីអាចផ្តល់*សម្រាប់សង់លំនៅឋាន ដល់គ្រួសារក្រីក្រគ្មានផ្ទះសម្បែង ឬដល់គ្រួសារក្រីក្រ សម្រាប់ធ្វើកសិកម្ម*។ ក្នុងករណីដែលពុំមានប័ណ្ណអត្តសញ្ញាណគ្រួសារក្រីក្រ ប្រការសំខាន់គឺអាជ្ញាធរមូលដ្ឋានត្រូវតែអាចវាស់វែងកម្រិតនៃភាពក្រីក្រ និងតម្រូវការរបស់គ្រួសារទទួលដីនីមួយៗឲ្យបានត្រឹមត្រូវ។

អ្នកឆ្លើយតប ៧៥% លើកឡើងថា ដីធ្វើកសិកម្ម ដែលពួកគេបានទទួល មិនទាន់បាន "កាប់ឆ្ការសំអាត" នៅឡើយ ឬនៅមិនទាន់អាចយកមកធ្វើកសិកម្មបានឡើយ នៅពេលដែលពួកគេបានទទួលដំបូង។ គ្រួសារទាំងនេះភាគច្រើន (៦៣%) នៅមិនទាន់បានសំអាតដីនេះនៅឡើយ ដែលមានន័យថាដីនេះមិនត្រូវបានគេប្រើប្រាស់ សម្រាប់គោលបំណងដំបូង សម្រាប់ធ្វើកសិកម្មនោះឡើយ។ ប៉ុន្តែ ស្ថិតិអំពីកម្រិតចំណូលដែលបង្ហាញខាងក្រោម បង្ហាញពីសេចក្តីសន្និដ្ឋានផ្សេងៗគ្នា។ ប្រជាជនរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះជាច្រើននាក់បានលើកឡើងថា កង្វះអាហារ (៨៥%) និងសម្ភារៈកសិកម្ម (២២%) គឺជាបញ្ហា ដែលពួកគេជួបប្រទះ ចាប់តាំងពីបានផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះរួចមក ប៉ុន្តែអ្នកទទួលផលភាគច្រើននៅតែមិនអាចដាំដំណាំបាន ដោយអ្នកឆ្លើយតប ៩០% លើកឡើងថា ពួកគេមិនអាចមានលទ្ធភាពកាប់ឆ្ការសំអាតដីកសិកម្មរបស់ពួកគេបានឡើយ។ ផ្ទុយទៅវិញ អាជ្ញាធរមូលដ្ឋានដែលត្រូវបានសម្ភាស បានលើកឡើងថា គ្រួសារ ១០០% បានដាំដុះដំណាំលើដីរបស់ពួកគេប្រកបដោយជោគជ័យ។ អ្វីដែលស្តែងចេញច្បាស់គឺ ចាំបាច់ត្រូវមានការផ្តល់ជំនួយបន្ថែមទៀត ដើម្បីផ្តល់លទ្ធភាពឲ្យប្រជាពលរដ្ឋអាចចាប់ផ្តើម និងបន្តការងារកសិកម្មរបស់ពួកគេ។ គ្រួសារ ៥៥% បានលើកឡើងថា បានទទួលជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកាប់ឆ្ការសំអាតដី ខណៈពេលដែល ២៣% ទៀត ត្រូវជួលគេឲ្យជួយ។ អ្នកឆ្លើយតបភាគច្រើន (៦១%) មានបំណងធ្វើស្រែនៅពេលដែលដីនេះត្រូវបានសំអាតរួច ដោយស្រូវជាដំណាំដែលត្រូវការទឹកច្រើន។ នេះអាចធ្វើឲ្យបញ្ហាកង្វះទឹកក្នុងតំបន់នេះកាន់តែធ្ងន់ធ្ងរថែមទៀត។ អ្នកឆ្លើយតប ៥២% ទៀតគ្រោងដាំស្វាយ ៥១% ដាំដំឡូងមី ២៣% ដាំពោត និង ២២% ដាំដំណាំបន្លែចម្រុះ។ បើធៀបជាមួយនឹងទីតាំងដីសម្បទានសង្គមកិច្ចផ្សេងទៀត ប្រជាពលរដ្ឋនៅតំបន់នេះចង់ធ្វើកសិកម្ម និងដាំដុះដំណាំខុសៗគ្នាច្រើន ដែលអាចជាការឆ្លុះបញ្ចាំងពីស្ថានភាពបរិស្ថាន។ ភាពចម្រុះបែបនេះ គួរផ្តល់ប្រយោជន៍ដល់សហគមន៍ ប្រសិនបើពួកគេអាចផលិតអាហារបានច្រើនមុខផ្សេងៗគ្នា ជាពិសេស មានប្រយោជន៍ដល់សន្តិសុខស្បៀង និងការដោះស្រាយបញ្ហាអាហារូបត្ថម្ភ។

ផ្ទៃដីមធ្យមសម្រាប់សង់លំនៅឋានគឺ ១១៨១ ម៉ែត្រការ៉េ (ប្រមាណជា ០,១៧៥ ហិកតា) ជាទំហំតូចជាងក្បាលដីមធ្យម នៅតាមទីតាំងសម្បទានដីសង្គមកិច្ចដែលត្រូវបានអង្កេតនេះ (១៤២០ ម៉ែត្រការ៉េ)។ ពុំមានអ្នកឆ្លើយតបណាបានលើកឡើងថា ពួកគេបានទទួលក្បាលដីតូចជាងអ្នកជិតខាងរបស់ខ្លួននោះទេ ដែលនេះបង្ហាញពីការបែងចែកដីប្រកបដោយសមធម៌។

ទំហំផ្ទះជាមធ្យមគឺ ២២ ម៉ែត្រការ៉េ ពោលគឺតូចជាងទំហំផ្ទះគិតជាមធ្យមនៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ (២៨ ម៉ែត្រការ៉េ)។ មានផ្ទះតែ ២ ប៉ុណ្ណោះ ដែលត្រូវបានសាងសង់ឡើង មុនពេលដែលគ្រួសារទាំងនេះផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ផ្ទះផ្សេងទៀតត្រូវបានសាងសង់ដោយគ្រួសារផ្ទាល់ និងដោយអ្នកជិតខាង។ គ្រួសារអាចសាងសង់ផ្ទះបាន ជាមធ្យម ៤ ខែ ក្រោយពីបានទទួលដីនៅទីតាំងសម្បទានដីសង្គមកិច្ច។ អ្នកឆ្លើយតបភាគច្រើន (៧១%) លើកឡើងថា លំនៅឋានថ្មីរបស់ពួកគេល្អជាង ឬល្អឆ្ងាយជាង ផ្ទះមុនៗរបស់ពួកគេ។ ប្រជាពលរដ្ឋ ១១ គ្រួសារ (៦%) បានលើកឡើងថា ផ្ទះថ្មីរបស់ពួកគេអន់ជាង ឬអន់ឆ្ងាយជាង ផ្ទះមុនរបស់ពួកគេ។

អ្នកឆ្លើយតប ៥៨% លើកឡើងថា ពួកគេពុំមានអារម្មណ៍ថាខ្លួនមានសុវត្ថិភាព ក្នុងផ្ទះបច្ចុប្បន្នរបស់ខ្លួនឡើយ ដោយសារតែអាចមានការចូលលួច (១៩%) និង ៩៩% ដោយសារការខូចខាតបង្កឡើងដោយខ្យល់ /ភ្លៀង ។ គេ មិនបានដឹងច្បាស់ថាតើមានប្រជាពលរដ្ឋប៉ុន្មានគ្រួសារ ដែលបានទទួលរងគ្រោះដោយសារការលួច ឬការខូចខាតបង្កឡើងដោយសារអាកាសធាតុនោះទេ។

ក្បាលដីសម្រាប់ធ្វើកសិកម្មជាមធ្យមមានទំហំ ១,៣៤ ហិកតា ពោលគឺធំជាងទំហំមធ្យមនៅតាមទីតាំងដីសម្បទានសង្គមកិច្ច ដែលត្រូវបានអង្កេតទាំងអស់បន្តិច (១,២ ហិកតា)។ អាជ្ញាធរមូលដ្ឋានបានលើកឡើងថា ទំហំជាមធ្យមគឺ ១៥០០០ ម៉ែត្រការ៉េ ឬ ១,៥ ហិកតា។ អ្នកឆ្លើយតប ៩៩% បានលើកឡើងថា អ្នកជិតខាងរបស់ពួកគេបានទទួលក្បាលដីទំហំប៉ុនគ្នានឹងដីរបស់ពួកគេដែរ។ អ្នកឆ្លើយតប ៩៦% បានលើកឡើងថា ឥឡូវនេះ ពួកគេបានដាំដំណាំលើដីនៅជុំវិញផ្ទះរបស់ពួកគេ បើទោះបីជាពួកគេភាគច្រើន (៨២%) មិនអាច

រកចំណូលគ្រប់គ្រាន់បានពីការដាំដុះបែបនេះក៏ដោយ ពោលគឺ ភាគច្រើនដាំទុកបរិភោគជាជាងយកទៅលក់។ ចំណូលមធ្យមប្រចាំឆ្នាំ ដែលបានពីការធ្វើកសិកម្ម បានតែ ២៤២ ដុល្លារ។ តួលេខនេះ គឺទាបជាងតួលេខមធ្យមនៅតាមទីតាំងសម្បទានដីសង្គមកិច្ចផ្សេងៗ ដែលត្រូវបានអង្កេត (តួលេខមធ្យមពុំបានឆ្លុះបញ្ចាំងពីតួលេខទាំងអស់ឡើយ ដោយសារតែចំណូលខ្ពស់របស់ប្រជាពលរដ្ឋដែលរស់នៅលើ ទីតាំងសម្បទានដីសង្គមកិច្ច ក្នុងខេត្តមណ្ឌលគិរី និងត្បូងឃ្មុំ)។ អ្នកឆ្លើយតប ៧៧% ទទួលបានចំណូលច្រើនជាងមុនពេលដែលពួកគេផ្លាស់មករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ៤៨% ទទួលបានចំណូល "ច្រើនប្រសើរជាងមុន" បើទោះបីជា ១៦% បានអះអាងថា ពួកគេទទួលបានចំណូលទាបជាងមុនពេលដែលពួកគេផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះក៏ដោយ។ ជាការឆ្លើយតបចំពោះសំណួរដែលសួរថាហេតុអ្វីបានជាពួកគេ មិនអាចរកចំណូលឲ្យបានច្រើនជាងមុនពីដីកសិកម្មរបស់ពួកគេ អ្នកឆ្លើយតប ១៦% បានលើកឡើងថា ដោយសារតែដីមានគុណភាពទាប។ គ្រួសារ ៨៥% ប្រើប្រាស់ចំណូលដែលទទួលបាន ដើម្បីបរិភោគសម្រាប់គ្រួសារ/ចំណាយក្នុងផ្ទះសម្បែងរបស់ពួកគេ។ ដីមានគុណភាពទាប គឺជាការត្អូញត្អែរ ដែលតែងត្រូវបានលើកឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះទៅកាន់ទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀត (មិនមែន សម្បទានដីសង្គមកិច្ចដែលត្រូវបានអង្កេត សម្រាប់ការស្រាវជ្រាវនេះឡើយ) ហើយវាក៏ជាបញ្ហាមួយនៅទីនេះដែរ បើទោះបីវាមិនមែនជាបញ្ហាដែលកើតឡើងចំពោះគ្រួសារភាគច្រើនក៏ដោយ។

មានប្រជាពលរដ្ឋតែពីរគ្រួសារប៉ុណ្ណោះ ដែលបានលក់ដី ឬផ្តល់ដីមួយផ្នែករបស់ពួកគេជាអំណោយទាន។ អ្នករស់នៅទីនេះមួយភាគធំ បានទទួលជំនួយមួយចំនួន នៅពេលដែលពួកគេ មករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ (ឧទាហរណ៍៖ ទទួលបានសម្ភារៈ ៩៧% ប្រាក់ ៩៣% គ្រាប់ពូជ ៣៧% ជាដើម)។ ជំនួយភាគច្រើនត្រូវបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល - គ្រួសារ ៧៧% លើកឡើងថា បានទទួលការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ខណៈពេលដែលមានតែ ១១% ប៉ុណ្ណោះ ដែលបានទទួលការគាំទ្របន្ថែមដោយផ្ទាល់ពីស្ថាប័នរដ្ឋ។ ប្រជាពលរដ្ឋដែលរស់នៅលើដីសម្បទានសង្គមកិច្ចនេះភាគ

ច្រើន (៧៦%) លើកឡើងថា ពួកគេពុំមានជំនាញធ្វើកសិកម្ម មុនពេលផ្លាស់មករស់នៅលើទីតាំងនេះឡើយ ដែលបង្ហាញថាចាំបាច់ត្រូវមានផ្តល់ជាឱកាសការងារ ឬឱកាសរកចំណូលជាជម្រើសផ្សេងទៀត ហើយក៏ចាំបាច់ត្រូវមានការបណ្តុះបណ្តាល និងការគាំទ្រផ្នែក កសិកម្ម នៅតាមទីតាំងសម្បទានដីសង្គមកិច្ច ដូចជា នៅទីតាំងនេះជាដើមផងដែរ។ ប្រការនេះទាមទារឲ្យមានការវាយតម្លៃលើជំនាញ និងចំណេះដឹង ក្នុងដំណាក់កាលនៃការធ្វើផែនការសម្បទានដីសង្គមកិច្ច ដើម្បីកំណត់ពីតម្រូវការរបស់ប្រជាពលរដ្ឋ រៀបចំផែនការអន្តរាគមន៍ដែលអាចយកមកអនុវត្តបាន និងបែងចែកធនធានដែលកំពុងតែខ្សត់ឲ្យមានប្រសិទ្ធភាពបំផុត។ គ្រួសារ ៥១% បានលើកឡើងថា ជំនាញធ្វើកសិកម្មរបស់ពួកគេពុំបានល្អប្រសើរជាងមុន ពេលដែលពួកគេរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះឡើយ ដែលមានន័យថា ការគាំទ្រ និងការបណ្តុះបណ្តាលកន្លងមក នៅមិនទាន់គ្រប់គ្រាន់នៅឡើយ។

**ជម្លោះដីធ្លី៖**

ក្នុងចំណោមអ្នកឆ្លើយតបទាំង ១៨១ នាក់ ដែលត្រូវបានសម្ភាស មាន ២ នាក់ បានលើកឡើងថា បច្ចុប្បន្ននេះ ពួកគេកំពុងពាក់ព័ន្ធនឹងជម្លោះដីធ្លីទាក់ទិននឹងដីផ្ទះសម្បែងរបស់ពួកគេ។ ពុំមានជម្លោះដីធ្លីណាពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុនឯកជន ឬស្ថាប័នរដ្ឋឡើយ។ មានតែអ្នកឆ្លើយតបតែម្នាក់ប៉ុណ្ណោះ ដែលទទួលរងការទន្ទ្រានមកលើដីរបស់ពួកគេ។ មានអ្នកឆ្លើយតបម្នាក់បានអះអាងថាបានទទួលរងការគំរាមកំហែងពីក្រុមហ៊ុនឯកជនពាក់ព័ន្ធនឹងជម្លោះដីធ្លីនេះ។

ក្នុងការពិភាក្សាជាក្រុមគោលដៅ អ្នកឆ្លើយតបមកពីសហគមន៍ជិតខាងបានលើកឡើងថា ពួកគេបាត់បង់ដី ដោយសារតែកម្មវិធីសម្បទានដីសង្គមកិច្ចនេះ។ ការលើកឡើងនេះហាក់បីដូចជាសំដៅលើការបាត់បង់ការទៅប្រើប្រាស់ ដីព្រៃ ជាជាងដីលំនៅឋាន។ មន្ត្រីមូលដ្ឋានបានបដិសេធថាពុំមានអ្នកណាម្នាក់ត្រូវបានបណ្តេញចេញ ដើម្បីយកដីមកធ្វើជាសម្បទានដីសង្គមកិច្ចឡើយ។

**ការទទួលបាន ទឹក និងអនាម័យ៖**

ក្នុងចំណោមគ្រួសារដែលត្រូវបានសម្ភាសទាំងអស់ មាន ៦៥% ពុំទទួលបានទឹកស្អាតសម្រាប់បរិភោគ ឡើយ។ ប្រជាពលរដ្ឋទៅរកទឹកពីអណ្តូង ដែលអាចជាអណ្តូងសាធារណៈ (២២%) ឬអណ្តូងលើដីរបស់ពួកគេ (១៦%) មកពីតាមអន្លង់សាធារណៈ (៣២%) និង ២៧% ទិញទឹកផឹកពីគេ។ ប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ច ៨២% បានធ្វើប្រព្រឹត្តិកម្មទឹករបស់ពួកគេ មុនពេលបរិភោគ។ ៨៩% ដាំទឹកបរិភោគ ១១% ប្រើប្រាស់ប្រដាប់ចម្រោះទឹក និងនៅសល់ ១៨% ពុំបានធ្វើប្រព្រឹត្តិកម្មទឹករបស់ពួកគេសោះតែម្តង <u>ហើយពួកគេ អាចប្រឈមនឹងហានិភ័យខ្លះ</u> ។ អ្នកឆ្លើយតប ៥១% បានលើកឡើងថាទឹកបរិភោគរបស់ពួកគេមានពណ៌ រសជាតិ និង/ឬក្លិនចម្លែក។ មានគ្រួសារតែ ២% ប៉ុណ្ណោះដែលលើកឡើងថា ទឹករបស់ពួកគេត្រូវបានសំអាតដោយសារធាតុក្លរ ដោយភាគច្រើន (៥១%) មិនបានដឹងឡើយ។ អ្នកឆ្លើយតបសម្ភាសចំនួន ៤៦% បានដាក់ពិន្ទុឲ្យការទទួលបានទឹកស្អាត ថាអន់ ឬអន់ឆ្ងាយជាងកន្លែងដែលពួកគេរស់នៅពីមុន។ មានអ្នកឆ្លើយតបសម្ភាសតែ ២៨% ប៉ុណ្ណោះ ដែលបានដាក់ពិន្ទុឲ្យការទទួលបានទឹកស្អាតរបស់ពួកគេថាល្អប្រសើរជាងមុន ចាប់តាំងពីបានផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ នេះបង្ហាញថា បញ្ហាពាក់ព័ន្ធនឹងការទទួលបានទឹកស្អាត នេះគឺមានភាពស្រួចស្រាវខ្លាំង ក្នុងខេត្តកំពង់ស្ពឺ ហើយពុំមានការបែងចែកធនធាន គ្រប់គ្រាន់សម្រាប់ផ្តល់ទឹកស្អាតឡើយ។

ពុំមានប្រព័ន្ធបញ្ចេញចោលទឹកសម្អុយដាក់នៅទីតាំងសម្បទានដីសង្គមកិច្ចនេះឡើយ បើទោះបីជាមានគ្រួសារតាមផ្ទះ ៧៤% មានបរិក្ខារអនាម័យក្នុងរូបភាពខ្លះក៏ដោយ (ភាគច្រើន ជាបង្គន់ ចាក់ផេះ)។ ២៦% នៃអ្នករស់នៅទីនោះបន្ទោរបង់ក្នុងព្រៃ ឬជីករណ្តៅ។ បើទោះបីជាមានស្ថានភាពបែបនេះក៏ដោយ ក៏អ្នកឆ្លើយតប ៦០% បានដាក់ពិន្ទុឲ្យលក្ខខណ្ឌអនាម័យរបស់ខ្លួនថាល្អប្រសើរជាង បើធៀបជាមួយនឹងស្ថានភាពកាលពីមុន ហើយនិងមានតែ ៨% ប៉ុណ្ណោះ ដែលលើកឡើងថា ស្ថានភាពអន់ជាងមុន។

### សេវាសុខាភិបាលៈ

ជាមធ្យម ប្រជាពលរដ្ឋត្រូវចំណាយពេល ៦៤ នាទី ដើម្បីធ្វើដំណើរទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុត និងចំណាយពេល ៩៦ នាទី ដើម្បីធ្វើដំណើរទៅកាន់មន្ទីរពេទ្យ

ដែលនៅជិតបំផុត។ ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ៣៨% លើកឡើងថា ពួកគេមានជំងឺញឹកញាប់ជាងមុន បើធៀបជាមួយនឹងស្ថានភាពនៃការរស់នៅឯទីកន្លែងមុន។ ជំងឺគ្រុនចាញ់ គឺជាមូលហេតុដែលបង្កឲ្យមានការឈឺថ្កាត់ញឹកញាប់ ក្នុងភូមិនេះ (នេះបើតាមការលើកឡើងរបស់អ្នកឆ្លើយតប ៨៥%) "គ្រុនក្ដៅ ឬផ្ដាសាយ" (៧៦%) ឈឺក្រពះ (២៥%) និងគ្រុនពោះវៀន (៥៦%)។ អ្នកឆ្លើយតប ៣២% លើកឡើងថា ការទទួលបានសេវាសុខភាពអន់ ឬអន់ឆ្ងាយជាងមុន បើធៀបជាមួយនឹងស្ថានភាពនៅកន្លែងរស់នៅមុន។ អ្នកឆ្លើយតប ៣៥% ជឿថា ការប្រើប្រាស់សេវាសុខាភិបាលនៅមូលដ្ឋាន មានភាពល្អប្រសើរជាងមុន ហើយ ៣២% ទៀត លើកឡើងថា ស្ថានភាពប្រហាក់ប្រហែលមុនដែរ។

**ការអប់រំ**

ប្រជាពលរដ្ឋដែលរស់នៅលើទីតាំង សម្បទានដីសង្គមកិច្ចនេះ ៩១% បានលើកឡើងថា ពុំមានសាលាមធ្យមសិក្សា ក្នុងតំបន់នេះទេ។ កុមារត្រូវធ្វើដំណើរតាមម៉ូតូឌុបជាមធ្យម ៣៨ នាទី ដើម្បីទៅដល់សាលាមធ្យមសិក្សាដែលនៅជិតបំផុត។ អ្នកឆ្លើយតបទាំងអស់លើកឡើងថា មានសាលាបឋមសិក្សាមួយកន្លែង ក្នុងទីតាំងសម្បទានដី សង្គមកិច្ចនេះ។ ជាមធ្យម កុមារចំណាយពេល ៥ នាទី តាមម៉ូតូឌុប ដើម្បីធ្វើដំណើរទៅសាលាបឋមសិក្សាដែលនៅជិតជាងគេ។ អ្នកឆ្លើយតប ២០% បានលើកឡើងថា មានកុមារដល់វ័យចូលរៀនមួយចំនួន (អាយុចន្លោះពី ៦ ដល់ ១៧ ឆ្នាំ) ក្នុងផ្ទះរបស់ពួកគេ ពុំបានទៅរៀនឡើយ ដែលនេះជាចំណុចដែលធ្វើឲ្យមានការព្រួយបារម្ភខ្លាំង។ មូលហេតុអាចដោយសារកង្វះលទ្ធភាពបង់ប្រាក់ (គ្រួសារដែលកូនមិនបានទៅរៀនមាន ៩ គ្រួសារ ឬ ២៣%) ដោយសារតែត្រូវការកូនឲ្យនៅផ្ទះ (១៣%) ដោយសារតែសាលារៀននៅឆ្ងាយពេក (៨%) ឬដោយសារតែកុមារមិនចង់ទៅរៀន (២៥%)។ អ្នកឆ្លើយតបម្នាក់បានលើកឡើងថា កូនរបស់គាត់ធ្វើការនៅរោងចក្រ ហើយមានប្រជាពលរដ្ឋ ២ គ្រួសារទៀត លើកឡើងថា កូនៗរបស់ពួកគេបានទទួលការ រំខាននៅសាលា (គ្រួសារមួយលើកឡើងថា កូនទទួលរងការវាយដំពីគ្រូ ដោយសារតែមិនចូលរៀន)។ គ្រួសារ ៩% និយាយថា ចាប់តាំងពីផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះមក កូនៗរបស់ពួកគេតិចនាក់ជាងមុនបានទៅរៀន ខណៈពេល

ដែល ៨៨% អះអាងថា កូនៗរបស់ពួកគេច្រើននាក់ជាងមុនបានទៅរៀន។ នេះបង្ហាញថា ក្នុងគ្រួសារមួយចំនួនដែលរស់នៅលើទីតាំង សម្បទានដីសង្គមកិច្ចនេះ មានក្មេងៗមួយចំនួន ប៉ុន្តែមិនទាំងអស់ទេ ដែលបានទៅរៀន។ សម្គាល់ នេះមិនមែនជាការបង្ហាញថាតើមានការផ្តល់ការអប់រំជាក់ស្តែងកម្រិតណានោះទេ ច្រើនតែជាការឆ្លុះបញ្ចាំងពីបំណងរបស់គ្រួសារតាមផ្ទះទាំងនោះ និងសារៈសំខាន់ដែលទាក់ទងជាប់ទៅនឹងការអប់រំ ។

នៅពេលឲ្យដាក់ពិន្ទុលើការទទួលបានការអប់រំ នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ មានអ្នកឆ្លើយតបតែ ១១% ប៉ុណ្ណោះ ដែលបានលើកឡើងថា ការអប់រំអន់ជាងមុន ចាប់តាំងពីផ្លាស់មកនៅលើដីនេះ។ ផ្ទុយទៅវិញ ៥៨% បានលើកឡើងថា ការទទួលបានការអប់រំ មានភាពល្អប្រសើរជាងមុន។

**ហេដ្ឋារចនាសម្ព័ន្ធ និងអគ្គិសនី៖**

ប្រជាពលរដ្ឋដែលរស់នៅលើដីសម្បទានសង្គមកិច្ចនេះទាំងអស់សុទ្ធតែអាចភ្ជាប់ជាមួយនឹងបណ្តាញទូរស័ព្ទដៃ។ អ្នកឆ្លើយតប ៤២% លើកឡើងថា <u>ការប្រើប្រាស់មធ្យោបាយធ្វើដំណើរ (បណ្តាញផ្លូវថ្នល់) និងការទំនាក់ទំនង (ទូរស័ព្ទ និងអ៊ីនធឺណិត)</u> មានភាពល្អប្រសើរជាងមុន ចាប់តាំងពីពេលដែលពួកគេផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ និងមានតែ ១១% ប៉ុណ្ណោះ ដែលបាននិយាយថា ស្ថានភាពនេះអន់ជាងមុន។ គ្មានប្រជាពលរដ្ឋណា មានអគ្គិសនីប្រើប្រាស់នៅទីតាំងសម្បទានដីសង្គមកិច្ចនេះឡើយ។ សម្គាល់ថា សំណួរនៃការអង្កេតនេះសួរពីអគ្គិសនី "ដែលរដ្ឋផ្តល់ឲ្យ" តាមរយៈការភ្ជាប់បណ្តាញមេ។ វាមិនមែនមានន័យថា ពុំមានម៉ាស៊ីនភ្លើង ឬប្រភពអគ្គិសនីផ្សេងទៀតនោះឡើយ។

**សន្តិសុខស្បៀង៖**

អ្នកឆ្លើយតប ៩៧% និយាយថា កាលពីខែមុននេះ យ៉ាងហោចណាស់ក៏មានម្តងដែរ ដែលពួកគេមានការភ័យខ្លាចថាពួកគេនឹងពុំអាចផ្តល់អាហារគ្រប់គ្រាន់ដល់គ្រួសាររបស់ពួកគេ ដោយ ៦១% លើកឡើងថា នេះជាការភ័យព្រួយដែលកើតមានជាប្រចាំ។ គ្រួសារ

៨៣% លើកឡើងថា ពួកគេត្រូវកំហិតអាហារដែលត្រូវបរិភោគ (ដូចជា ពុំមានសាច់ ឬត្រី ជាដើម) នៅពេលណាមួយ ក្នុងខែមុននេះ ដោយសារតែខ្វះលុយ ហើយ ៨៨% ត្រូវបង្ខំចិត្តបរិភោគមើមរុក្ខជាតិដុះក្នុងព្រៃ ឬសាច់ដែលមានគុណភាពអន់ខ្លាំង ដោយសារតែមូលហេតុដូចគ្នានេះ។ អ្នកឆ្លើយតប ៦២% លើកឡើងថា ពួកគេធ្លាប់ដាច់បាយ កាលពីខែមុននេះ និងមានអ្នកឆ្លើយតប ៥៥% បានលើកឡើងថា មានថ្ងៃខ្លះ កាលពីខែមុននេះ ដែលពួកគេពុំមានអាហារបរិភោគតែម្តង ដោយសារតែពុំមានលុយទិញអាហារ និងពុំអាចរកអាហារបានពីដីរបស់ពួកគេ។ គ្រួសារតាមផ្ទះ ២៣% លើកឡើងថា ការទទួលបានអាហារបានថមថយជាងមុន ចាប់តាំងពីពេលដែលពួកគេផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ បើទោះបីជាសម្រាប់គ្រួសារ ៣៥% ស្ថានភាពបានល្អប្រសើរជាងមុនក៏ដោយ។ អាហារូបត្ថម្ភទំនងជាបញ្ហាធំមួយ សម្រាប់គ្រួសារតាមផ្ទះដែលតាំងនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ជាពិសេស សម្រាប់កុមារដែលខ្វះអាហារដែលមានសារជាតិប្រូតេអ៊ីន និងនៅកន្លែងដែលគ្រួសារមិនអាចកាប់ឆ្ការដីធ្វើកសិកម្មបាន។

**ការងារ និងប្រាក់ចំណូល៖**

គ្រួសារតាមផ្ទះដែលត្រូវបានសាកសួរស្ទើរតែទាំងអស់ (៩៨%) មានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់មានការងារធ្វើ ហើយខ្នងផ្ទះ ៦២% មានមនុស្សយ៉ាងហោចណាស់ ២ នាក់ មានការងារធ្វើ។ ជាការឆ្លើយតបចំពោះសំណួរដែលសួរថាតើការងារប្រភេទណាខ្លះដែលពួកគេធ្វើ ២៨% ស៊ីឈ្នួលធ្វើកសិកម្មឲ្យគេ ៧១% ធ្វើការងារប្រភេទប្រើប្រាស់កម្លាំងពលកម្មផ្សេងទៀត ហើយ ១៤% មានមុខរបរខ្លួនឯង។ ១៥% ធ្វើការងារក្នុងរោងចក្រកាត់ដេរ និង ៣% ធ្វើការងារក្នុងសេវាសាធារណៈ ឬមានតួនាទី ក្នុងរដ្ឋាភិបាល។ ចំណូលមធ្យមប្រចាំខែរបស់គ្រួសារគឺ ៥៩៦.៧៦៥ រៀល (ស្មើនឹង ៣៩០ ដុល្លារ) ក្នុងមួយខែ។ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ចំណូលមធ្យមប្រចាំខែរបស់អ្នកឆ្លើយតប គឺទាបជាងនេះបន្តិច ពោលគឺ ៥២៣.៦៦៧រៀល (២៧៦ ដុល្លារ) ក្នុងមួយគ្រួសារ។ ចំណាយមធ្យមសម្រាប់គ្រួសារបច្ចុប្បន្ននេះគឺ ៥៩៩.៨៧០រៀល (៣២៦ ដុល្លារ) ក្នុងមួយខែ កើនឡើងពី ៥០៥.៧១១ រៀល (២៥៨ ដុល្លារ) មុនពេលផ្លាស់មកនៅទីតាំង

សម្បទានដីសង្គមកិច្ចនេះ។ ចំណាយភាគច្រើន (ជាង ៨០%) គឺលើអាហារ និងការថែទាំសុខភាព។ ខណៈពេលដែលចំណូលប្រចាំខែមានការកើនឡើងតិចតួច នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ចំណាយប្រចាំថ្ងៃរបស់គ្រួសារក៏កើនឡើងទៅតាមនោះដែរ។ ចំណាយសម្រាប់ការថែទាំសុខភាពកើនឡើងខ្ពស់ជាងគេ សម្រាប់គ្រួសារដែលផ្លាស់មកនៅសម្បទានដីសង្គមកិច្ចនេះ។

គ្រួសារតិចជាងមួយភាគបីមានប្រាក់សន្សំសម្រាប់គ្រួសារ (៣០%)។ គ្រួសារ ៧៨% ជំពាក់បំណុលគេ ហើយបំណុលនេះមានការកើនឡើងខ្លាំង។ ជាមធ្យម គ្រួសារតាមផ្ទះជំពាក់បំណុលគេ ២.០២០.៧៣០ រៀល (៥០៥ ដុល្លារ) ដែលកើនឡើងយ៉ាងគំហុកពី ១៤៧.៥៨៩រៀល (៣៦ ដុល្លារ) មុនពេលផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ។ នេះមានន័យថា គ្រួសារត្រូវខ្ចីបុលគេយ៉ាងច្រើន នៅពេលផ្លាស់ ឬក្រោយពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។

ជាសូចនាករបង្ហាញពីទ្រព្យធនដែលមានគ្រួសារតែ ១២% ប៉ុណ្ណោះ មានទូរទស្សន៍ជាកម្មសិទ្ធិ បើទោះបីជា ៥០% មានម៉ូតូជាកម្មសិទ្ធិក៏ដោយ។ ៧៨% មានទូរស័ព្ទដៃជាកម្មសិទ្ធិ។

គ្រួសារតាមផ្ទះ ស្ទើរតែ ២ ភាគ ៣ (៦៧%) ដែលសមាជិកគ្រួសារទាំងអស់រស់នៅជុំគ្នាលើទីតាំងសម្បទានដីសង្គមកិច្ចនេះជាអចិន្ត្រៃយ៍។ សមាជិកគ្រួសារភាគច្រើន ដែលរស់នៅឆ្ងាយពីទីតាំងនេះ គឺកូនរបស់អ្នកឆ្លើយតបចំពោះការសម្ភាសនេះ ដែលនេះបង្ហាញថា ក្នុងចំនោមក្មេងៗជំនាន់ក្រោយភាគច្រើនជ្រើសរើសយក ការធ្វើចំណាកស្រុក ឆ្ងាយពីផ្ទះដែលគ្រួសាររបស់ពួកគេរស់នៅ ដើម្បីរកការងារធ្វើ (៧៥%) និង/ឬបន្តការសិក្សា (២២%)។

## របនាសម្ព័ន្ធផ្នែកសង្គមៈ

អ្នកឆ្លើយតប ២០% លើកឡើងថា ពួកគេមានអារម្មណ៍តានតឹង (ស្ត្រេស) ដោយ ៣១% លើកឡើងថា ដោយសារតែប្រាក់ចំណូលថយចុះ ហើយ ៤២% ទៀតលើកឡើងថា ដោយសារខ្វះអាហារបរិភោគ។

អ្នកឆ្លើយតប ៩៨% លើកឡើងថា ពួកគេដឹងថាមានការប្រើបំពានគ្រឿងស្រវឹង ក្នុងសហគមន៍នេះ។ គ្រួសារ ៥០% គិតថា ក្នុងសហគមន៍នេះ មានបទល្មើសកើតឡើងច្រើនបើធៀបជាមួយនឹងស្ថានភាព មុនពេលដែលពួកគេផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ៦៥% លើកឡើងថាបានដឹងពីករណីអំពើហិង្សាលើស្ត្រី ឬក្មេងស្រី ហើយ ៥៦% ជឿថា មានហិង្សាផ្លូវភេទកើតឡើងច្រើនជាងក្នុងសហគមន៍មុនៗរបស់ពួកគេ។ នេះគឺជាភាគរយនៃអ្នកឆ្លើយតបខ្ពស់ជាងគេ បើធៀបជាមួយនឹងទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀត មានន័យថា អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ គឺជាបញ្ហាដ៏ស្រួចស្រាវមួយ នៅទីនេះ។ ការរកឃើញទាំងនេះ មិនផ្តល់នូវការគណនាច្បាស់លាស់នៃអត្រាទូទៅនៃហិង្សាផ្លូវភេទ ឬការរំលោភបំពានដោយសារ គ្រឿងស្រវឹងនោះទេ។ ការរកឃើញទាំងនេះ ជាការឆ្លុះបញ្ចាំងពីគំនិតយោបល់របស់សហគមន៍តែប៉ុណ្ណោះ ហើយ គេត្រូវតែអានយល់ដូចនេះ ជាមួយការយល់ដឹងថា ក្រុមអង្កេតនេះ មិនបានសួរដោយផ្ទាល់ទេ ឧទាហរណ៍ ថាតើ ការរំលោភបំពានកើតឡើយដោយគ្រឿងស្រវឹងជាបញ្ហាមួយនៅក្នុងខ្នងផ្ទះមួយឬទេ។

អ្នកឆ្លើយតប ៦៩% លើកឡើងថា ពួកគេដឹងពីករណីកុមារធ្វើការងារ ដើម្បីរកចំណូលបន្ថែមឲ្យគ្រួសារ (កុមារត្រូវបានឲ្យនិយមន័យថាមានអាយុចាប់ពី១៥ ឆ្នាំចុះ)។ ការងារភាគច្រើនដែលកុមារធ្វើ គឺការងារកសិកម្ម (៩៥%) និងប្រភេទការងារប្រើកម្លាំងពលកម្មផ្សេងទៀត (៧២%)។ ខ្នងផ្ទះ ១៨% បញ្ជូនសមាជិកគ្រួសារជាកុមារទៅធ្វើការងារតាមរោងចក្រ។

ក្នុងចំណោមប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះទាំងអស់ មាន ៨០% បានចុះឈ្មោះបោះឆ្នោត។ ខណៈពេលដែលនេះជាតួលេខមួយខ្ពស់ និងខ្ពស់ជាងតួលេខមធ្យម សម្រាប់តំបន់សម្បទានដីសង្គមកិច្ចផ្សេងទៀត អាជ្ញាធរមូលដ្ឋានបានឆ្លើយថាប្រជាពលរដ្ឋសុទ្ធតែបានចុះឈ្មោះទាំងអស់គ្នា។ គ្រួសារតាមផ្ទះ ៣៥% ពុំមានឯកសារស្នាក់នៅ ដែលផ្តល់ដោយអាជ្ញាធរមូលដ្ឋាន ហើយក្នុងខ្នងផ្ទះ ១៨% យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ដែលពុំមានសំបុត្រកំណើត ហើយក្នុងខ្នងផ្ទះ ៣៣% មាន

សមាជិកគ្រួសារម្នាក់ ដែលពុំមានអត្តសញ្ញាណប័ណ្ណ។ គ្រួសារ ១៩% ពុំមានសៀវភៅគ្រួសារ។

មានគ្រួសារតែ ៥% ប៉ុណ្ណោះ បាននិយាយថា ពួកគេពិចារណាចាកចេញពីទីតាំងសម្បទានដីសង្គមកិច្ចនេះ ដែលបើតាមបញ្ហាកង្វះអាហារ និងបញ្ហាប្រឈមផ្សេងទៀតក្នុងតំបន់នេះ ជាតួលេខមួយទាបគួរឲ្យកត់សម្គាល់។ សំណូមពរជុំវិញការលើកកម្ពស់កម្រិតជីវភាពរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ផ្តោតលើការទទួលបានអាហារ និងទឹក៖ កែលំអប្រព័ន្ធធារាសាស្ត្រក្នុងមូលដ្ឋាន (៧២%) បង្កើនលទ្ធភាពទទួលបានអាហារ (៣៦%) ការទទួលបានទឹកស្អាត (៦៣%) កែលំអមូលដ្ឋានផ្តល់សេវាថែទាំសុខភាព (១៨%)។ លើសពីនេះ ក៏មានការលើកឡើងនូវសំណូមពរពាក់ព័ន្ធ នឹងបញ្ហាជាច្រើនផ្សេងទៀតផងដែរ ដូចជា លំនៅឋាន អគ្គិសនី ការងារ និងការផ្តល់បង្គន់អនាម័យជាដើម។

## ឧបសម្ព័ន្ធទី ២៖ ទិន្នន័យអង្កេតពីសម្បទានដីសង្គមកិច្ច ក្នុងឃុំបឹងប្រាំ ស្រុកបវេល ខេត្តបាត់ដំបង

*របកគំហើញសំខាន់ៗ*

- *កម្មវិធីធ្វើប័ណ្ណកម្មសិទ្ធិ និងការចែកចាយដីធ្លីពីរ (សម្បទានដីសង្គមកិច្ច និង បទបញ្ជា ០០១) ត្រូវបានអនុវត្តនៅក្នុងឃុំ បឹងប្រាំក្នុងពេលដំណាលគ្នា ហើយ វិធានរដ្ឋបាល ហាក់ដូចជា ត្រូវបានគេប្រើដោយផ្លាស់ប្តូរគ្នា។*
- *សម្បទានដីសង្គមកិច្ច ហាក់ដូចជា ត្រូវបានគេចេញលើដីដែលមានការកាន់កាប់ ដែលនៅតែមានជម្លោះនៅឡើយ។ គ្រួសារទទួលផលសម្បទានដីសង្គមកិច្ច ត្រូវបានគេផ្តល់ឲ្យនូវក្បាលដីកសិកម្ម ដែលដីនោះ មានការកាន់កាប់ និងប្រើប្រាស់រួចហើយ ដោយគ្រួសារផ្សេងៗ មានន័យថា អ្នកទទួលផលសម្បទានដីសង្គមកិច្ច រហូតដល់ពេលនេះ មិនបានទទួលការកាន់កាប់លើក្បាលដីកសិកម្មសម្បទានដីសង្គមកិច្ចទាំងនោះទេ។*
- *គ្រួសារជាង ៩០% បានទទួលដីលំនៅឋាន ប៉ុន្តែមិនបានទទួលក្បាលដីដោយឡែកសម្រាប់ផលិតកម្មកសិកម្មឡើយ។ នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀតដែលបានអង្កេត មានគ្រួសារយ៉ាងហោចណាស់ ៩០% បានទទួលដីលំនៅឋានផង និងក្បាលដីដោយឡែកសម្រាប់អភិវឌ្ឍន៍កសិកម្មផង។ នេះដោយសារ តែ ដីបានវាស់វែងសម្រាប់ក្បាលដីកសិកម្ម ត្រូវបានគេចូលកាន់កាប់រួចហើយ។*
- *បើទោះបីជាបែបនេះក៏ដោយ គ្រួសារអាចរកចំណូលតាមរយៈការអភិវឌ្ឍដីនៅជុំវិញផ្ទះរបស់ពួកគេ។ មានអ្នកឆ្លើយតបតែពាក់កណ្តាលប៉ុណ្ណោះ ដែលបាននិយាយថា ពួកគេរកចំណូលបានច្រើនជាងមុននៅទីតាំងសម្បទានដីសង្គមកិច្ចនេះ បើធៀបជាមួយនឹងចំណូលដែលពួកគេរកបាននៅកន្លែងដែលពួកគេរស់នៅមុនៗ នេះមានន័យថា <u>ការផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះមិនបានបង្កើនចំណូលសម្រាប់គ្រួសារឡើយ។</u>*

- ប្រជាពលរដ្ឋជាច្រើនគ្រួសារបានលើកឡើងថា ពួកគេត្រូវបានគេបណ្តេញចេញពីដីកសិកម្មរបស់ពួកគេ ដើម្បីយកដីសំរាប់ធ្វើសម្បទានដីសង្គមកិច្ច។ អ្នកដែលធ្លាប់រស់នៅលើដីនេះមុនៗ បានលើកឡើងថា ពួកគេមិនត្រូវបានគេប្រាប់ឲ្យដឹងពីកម្មវិធីសម្បទានដីសង្គមកិច្ចនេះឡើយ ហើយមិនបានយល់ព្រមឲ្យបង្កើតកម្មវិធីនេះទេ និងបានទទួលសំណងក្នុងចំនួនតិចតួចប៉ុណ្ណោះ។ ដីមួយភាគធំ ដែលត្រូវបានបម្លែងទៅជាសម្បទានដីសង្គមកិច្ច គឺជាអតីតដីព្រៃដែលមានន័យថា ដីនេះធ្លាប់ត្រូវបានអ្នករស់នៅពីមុនប្រើប្រាស់ ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ។ ជម្លោះដីធ្លីរវាងគ្រួសារដែលត្រូវបានបណ្តេញចេញ និងគ្រួសារទទួលផលសម្បទានដីសង្គមកិច្ច នៅតែមិនទាន់បានដោះស្រាយនៅឡើយ។
- អ្នកទទួលផលជិត ៣ ភាគ ៤ ដែលត្រូវបានសាកសួរ ក្នុងខេត្តបាត់ដំបង លើកឡើងថា ដំណើរការបែងចែកដីពុំមានភាពយុត្តិធម៌ឡើយ។ អ្នកឆ្លើយតបជាង ១ ភាគ ៥ លើកឡើងថា ពួកគេត្រូវបង់ប្រាក់សម្រាប់ដំណើរការបែងចែកដី។
- ក្នុងចំណោមអ្នកទទួលផលពីសម្បទានដីសង្គមកិច្ចទាំងអស់ដែលបានសាកសួរ មានតែ ២៦% ប៉ុណ្ណោះ ដែលបាននិយាយថា ពួកគេបានទទួលជំនួយពីអង្គការមិនមែនរដ្ឋាភិបាល។ តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានសម្ភាស បានលើកឡើងថា ពួកគេជឿថា ការជ្រើសរើស និងការបែងចែកធ្វើឡើងដោយយុត្តិធម៌។ នេះមានន័យថា ដំណើរការនេះ អាចមិនយុត្តិធម៌ មិនមានតម្លាភាព និងសមធម៌ឲ្យបានគ្រប់គ្រាន់ខ្លួនឯង ឬមានន័យថា អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលនេះ ពុំមានប្រសិទ្ធភាពក្នុងការរៀបចំកិច្ចពិគ្រោះយោបល់ និងក្នុងការពន្យល់ពីដំណើរការជ្រើសរើស និងបែងចែកដីឲ្យបានគ្រប់ជ្រុងជ្រោយ។
- អ្នកឆ្លើយតបតិចជាងពាក់កណ្តាល បានទទួលផែនការសម្បទានដីសង្គមកិច្ច។ ហាក់ដូចជា មានកិច្ចពិគ្រោះយោបល់ក្នុងកម្រិតតិចតួច បានធ្វើឡើងជាមួយនឹងគ្រួសារទទួលផលក្នុងការរៀបចំផែនការ និងក្នុងការជម្រុញឲ្យប្រជាពលរដ្ឋចូលរួមបានសកម្មក្នុងការអភិវឌ្ឍទីតាំងនេះ។

- *គ្រួសារស្ទើរតែទាំងអស់បានទទួលប័ណ្ណកម្មសិទ្ធិដី។ ប័ណ្ណកម្មសិទ្ធិទាំងនេះ ត្រូវបានចេញជាផ្នែកនៃយុទ្ធនាការធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីតាមបទបញ្ជា០០១។*
- *ការទទួលបានសេវាជាមូលដ្ឋាន ជាពិសេស ការផ្គត់ផ្គង់ទឹកស្អាត នៅតែជាបញ្ហាចោទ។ បើទោះបីជាមានសាលារៀននៅតំបន់នេះក៏ដោយ ប្រជាពលរដ្ឋជាច្រើនដាក់ពិន្ទុឲ្យការអប់រំថាអន់ជាងកន្លែងដែលពួកគេរស់នៅមុន។ សហគមន៍ ដែលរស់នៅជិតសម្បទានដីសង្គមកិច្ចបានលើកឡើងថា ការទទួលបានសេវាថែទាំសុខភាពមានភាពល្អប្រសើរជាងមុន សម្រាប់ពួកគេ ដោយសារតែការអភិវឌ្ឍសម្បទានដីសង្គមកិច្ចនេះ ដែលនេះបង្ហាញពីផលជាវិជ្ជមានមកលើអ្នកដែលទទួលផលផ្ទាល់ពីកម្មវិធីសម្បទានដីសង្គមកិច្ចនេះ។*

នៅទីតាំងសម្បទានដីសង្គមកិច្ចខេត្តបាត់ដំបង ការសម្ភាសត្រូវបានធ្វើឡើងជាមួយនឹងគ្រួសារតាមផ្ទះចំនួន២៥០រ[73] (លើប្រមាណជា ១៥៦០ គ្រួសារ នេះបើតាមទិន្នន័យរបស់ OHCHR)។ ទីតាំងសម្បទានដីសង្គមកិច្ចនេះ គ្របដណ្តប់លើផ្ទៃដីសរុបប្រមាណជា ៣.៦៣៨ ហិកតា និងបានចុះបញ្ជីជាសម្បទានដីសង្គមកិច្ច កាលពីខែ ឧសភា ឆ្នាំ ២០១០ នេះបើតាមការលើកឡើងរបស់អាជ្ញាធរមូលដ្ឋាន។ មុនពេលដែលសម្បទានដីសង្គមកិច្ចនេះត្រូវបានបង្កើតឡើងទីតាំងនេះគឺជាដីព្រៃ។

តាមរយៈដំណើរការសម្បទានដីសង្គមកិច្ច បានអនុវត្តក្នុងស្រុកបវេល ក្បាលដីទាំងនេះ ហាក់ដូចជា ត្រូវ បានគេចេញផ្តួចផ្តើមឡើងសម្រាប់ដីកសិកម្ម ជាដីដែលត្រូវបានគេចូលកាន់កាប់រួចហើយដោយ១៩២គ្រួសារ។ អ្នកទទួល ផលសម្បទានដីសង្គមកិច្ច ត្រូវបានគេបែងចែកឲ្យទាំងក្បាលដីលំនៅឋាន និងកសិកម្មក្នុងឆ្នាំ ២០១១ ទោះបីជាយ៉ាងណា ក៏ពួកគាត់នៅតែមិនទាន់បានកាន់កាប់ក្បាលដីកសិកម្មទាំងនេះទេ ដោយសារ ក្បាលដីទាំងនេះ ត្រូវបានគេចូលកាន់កាប់ រួចហើយ។ ១៩២គ្រួសារ បានអះអាងថា បានកំពុងប្រើប្រាស់ដីកសិកម្មនេះ ជាច្រើនឆ្នាំមកហើយ និងមានជម្លោះ លើការកាន់កាប់ មកដល់ពេលនេះ។

[73] ទីតាំងសម្បទានដីសង្គមកិច្ចនេះ គ្របដណ្តប់លើភូមិចំនួន ៧ (សំណាង ព្រះស្រី ជ័យជំនះ បឹងធំ បឹងប្រាំ បឹងក្រឡ យុត្តិធម៌ និងអូឫស្សី) ដែលស្ថិតក្នុងឃុំបឹងប្រាំ។

គ្រួសារទទួលផលសម្បទានដីសង្គមកិច្ច បានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីលើក្បាលដីបាន បែងចែកក្រោមសម្បទានដីសង្គមកិច្ច ក្នុងយុទ្ធនាការធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីតាមបទបញ្ជា០០១ របស់រដ្ឋាភិបាល[74]។ កម្មវិធី បទបញ្ជា ០០១ មិនមានលក្ខខ័ណ្ឌតម្រូវដូចអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ហើយមិនតម្រូវឲ្យមានការកាន់កាប់ ជាប់លាប់ ៥ឆ្នាំនោះទេ។ អ្នកទទួលផលសម្បទានដីសង្គមកិច្ច អះអាងថា បានកំពុងរស់នៅលើក្បាលដីលំនៅឋានដោយគ្មានប័ណ្ណកម្មសិទ្ធិរយៈពេលប៉ុន្មានឆ្នាំមកហើយ មុនការបង្កើតសម្បទានដីសង្គមកិច្ច និងបានស្នើរសុំសម្បទាននេះ ដើម្បីផ្តល់ឲ្យពួកគាត់មានសុវត្ថិភាពសិទ្ធិកាន់កាប់។

កម្មវិធីធ្វើប័ណ្ណកម្មសិទ្ធិ និងចែកចាយដីទាំងពីរនេះ (សម្បទានដីសង្គមកិច្ច និង បទបញ្ជា០០១) បង្ហាញឲ្យឃើញ ត្រូវបានគេអនុវត្តក្នុងឃុំ បឹងប្រាំ ក្នុងពេលជំណាលគ្នា ហើយវិធានគ្រប់គ្រងដោយនីតិវិធីរដ្ឋបាល ត្រូវបានគេប្រើប្រាស់ផ្លាស់ប្តូរគ្នា។ ១៩២គ្រួសារដែលចូលកាន់កាប់ក្បាលដីកសិកម្មសម្បទានដីសង្គមកិច្ច ក៏ទាមទារផងដែរនូវសិទ្ធិភោគៈ និងបានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមូលដ្ឋាន តវ៉ាឲ្យជួយដោះស្រាយរហូតមក។

អ្នកឆ្លើយតប ៦០% គឺជាស្ត្រី បើទោះបីជាមានអ្នកឆ្លើយតបត្រឹមតែ ២៥% ប៉ុណ្ណោះ ដែលបានប្រកាសថាមេគ្រួសារជាស្ត្រី។ ៨២% លើកឡើងថា ពួកគេរៀបការរួច ឬកំពុងរស់នៅជាមួយអ្នកដែលពួកគេមានទំនាក់ទំនងជាមួយ។ ១២% គឺជាស្ត្រីមេម៉ាយ/បុរសពោះម៉ាយ ឬលែងលះ។ អាយុមធ្យមរបស់អ្នកឆ្លើយតប គឺ ៥០ ឆ្នាំ។ គ្រួសារដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ មានចំនួនសមាជិកជាមធ្យម ៤,៨៥ នាក់ និងមានកូន ២,៤ នាក់។ មិនមែនសមាជិកគ្រួសារទាំងអស់សុទ្ធតែរស់នៅទីតាំងនេះជាអចិន្ត្រៃយ៍នោះទេ។ អ្នកឆ្លើយតបទាំងអស់លើកឡើងថា ពួកគេជាជនជាតិខ្មែរ។

នៅពេលសាកសួរពីមូលហេតុដែលពួកគេបានទទួលដីនៅទីតាំងសម្បទានដីសង្គមកិច្ច អ្នកឆ្លើយតប ៨២% បានឆ្លើយថា ដោយសារតែពួកគេគ្មានដី ហើយ ៣៦% ឆ្លើយថា

[74]ក្នុងខែឧសភាឆ្នាំ២០១២ បទបញ្ជាលេខ ០០១ ត្រូវបានចេញដោយនាយករដ្ឋមន្ត្រី ស្តីពីការប្រកាស ការបញ្ឈប់ជាបន្ទាន់ បណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងការអនុវត្តគោលនយោបាយ "ស្បែកខ្លា" ចំពោះព្រំប្រទល់ដីរបស់សហគមន៍ដែលមានស្រាប់ និងព្រំប្រទល់ដី ប័ណ្ណកម្មសិទ្ធិឯកជន បានមាននៅក្នុងដីដែលបានយល់ព្រម នឹងត្រូវបានគេវាស់វែង និងដាត់ចេញពីសម្បទាន ហើយប័ណ្ណកម្មសិទ្ធិដីនៅលើដីទាំងនោះ នឹងត្រូវបានផ្តល់ជូន។

ដោយសារតែពួកគេមានជីវភាពក្រីក្រ។ គ្រួសារ ៧% ត្រូវផ្លាស់មកទីនេះ ដោយសារតែគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ អ្នកឆ្លើយតបជាច្រើននាក់ លើកឡើងថា អ្នកទទួលផលមួយចំនួនតាមពិតបានទិញដីពីមេឃុំ និងពីអ្នករស់នៅមុនៗដែលបានកាន់កាប់ដីមុនពេលបម្លែងជាដីសម្បទានសង្គមកិច្ច ដើម្បីបានចំណេញពីការបម្លែងដីនេះ។ មានចំណុចត្រូវគ្នានៅទីនេះ ដោយអ្នកឆ្លើយតបផ្តល់ចម្លើយច្រើនយ៉ាង ដែលបង្ហាញពីហេតុផលដែលនាំឲ្យពួកគេទទួលបានដី។ នៅពេលសាកសួរពីមូលហេតុ ដែលគ្រួសារផ្សេងទៀតនៅទីតាំងសម្បទានដីសង្គមកិច្ចនេះបានទទួលដី ចម្លើយគឺត្រូវគ្នាជាមួយនឹងចម្លើយខាងលើដែរគឺការគ្មានដី និងភាពក្រីក្រ។

គ្រួសារភាគច្រើន (៨៤%) មានប័ណ្ណសម្គាល់គ្រួសារក្រីក្រ (តាមរយៈកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ)។ អ្នកទទួលផលសម្បទានដីសង្គមកិច្ចទាំងអស់ ក្រៅពីយោធិនរំសាយ ឬជនរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ គួរទទួលបានប័ណ្ណអត្តសញ្ញាណគ្រួសារក្រីក្រតាំងពីដំបូង ដោយសារតែប័ណ្ណនេះ គឺជាមធ្យោបាយចម្បងសម្រាប់វាយតម្លៃកម្រិតនៃភាពក្រីក្រ និងកំណត់អត្តសញ្ញាណអ្នកសុំដី និងអ្នកទទួលបានដីដែលបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្រប។[75] កង្វះប័ណ្ណគ្រួសារក្រីក្រសម្រាប់គ្រួសារសេសសល់ ១៦% ទៀត អាចដោយសារតែពួកគេលែងរស់នៅក្នុងភាពក្រីក្រ ឬ មានការប្រើប្រាស់មធ្យោបាយផ្សេងទៀត ដើម្បីវាយតម្លៃកម្រិតនៃភាពក្រីក្រ នៅពេលដែលសម្បទានដីសង្គមកិច្ចនេះត្រូវបានបង្កើតឡើង។

គ្រួសារតាមផ្ទះភាគច្រើន (៧៦%) បានអះអាងថាបានចូលរួមក្នុងការកំណត់ និងការរៀបចំផែនការនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ដោយប្រជាពលរដ្ឋដែលរស់នៅលើដីនេះ ៧០% បានលើកឡើងថា អាជ្ញាធរមូលដ្ឋានបានពន្យល់ពីមូលហេតុដែលពួកគេត្រូវ

[75] មាត្រា ១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣) ចែងថា អ្នកសុំដីសម្បទានសង្គមកិច្ចត្រូវបំពេញលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុ ដែលកំណត់ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយផ្អែកលើយោបល់របស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ។ គោលការណ៍ណែនាំអំពីការវាយតម្លៃប្រាក់ចំណូលត្រូវពិចារណាដោយផ្អែកលើទំហំគ្រួសារ និងលក្ខខណ្ឌ អាយុ និងសុខភាពនៃសមាជិកគ្រួសារ។ គោលការណ៍ណែនាំនេះអាចប្រែប្រួលទៅតាមតំបន់ ទៅតាមពេលវេលា ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច និងជីវភាពរស់នៅ។

បានជ្រើសរើសជាអ្នកទទួលដី។ ប៉ុន្តែ មានតែ ៣៦% ប៉ុណ្ណោះ ដែលបានលើកឡើងថា អាជ្ញាធរបានពន្យល់ពីដំណើរការជ្រើសរើស និងបែងចែកដី និងពីការប្រើប្រាស់ប្រព័ន្ធចាប់ឆ្នោតដើម្បីបែងចែកដី។ ខណៈពេលដែលអ្នកឆ្លើយតប ៩៩% បានទទួលឯកសារពាក់ព័ន្ធនឹងការបែងចែកដីក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះ មានអ្នកឆ្លើយតបតែ ៤៦% ប៉ុណ្ណោះ ដែលបានលើកឡើងថា ពួកគេបានចូលរួមយ៉ាងសកម្មក្នុងការជ្រើសរើសក្បាលដី។ លើសពីនេះ មានគ្រួសារតែ ៤៥% ប៉ុណ្ណោះ ដែលបានចុះកិច្ចព្រមព្រៀងជាមួយនឹងអាជ្ញាធរ ទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ចចំពោះសម្បទានដីសង្គមកិច្ចនេះ។ អាជ្ញាធរមូលដ្ឋានបានលើកឡើងថា ពួកគេបានរៀបចំកិច្ចពិគ្រោះ យោបល់ជាមួយនឹងសហគមន៍ ដែលរស់នៅជុំវិញសម្បទានដីសង្គមកិច្ចនេះ ដើម្បីផ្តល់ព័ត៌មានដល់ពួកគេអំពីដំណើរការសម្បទានដីសង្គមកិច្ចនេះ។

តំណាងអាជ្ញាធរមូលដ្ឋានម្នាក់ ដែលត្រូវបានសាកសួរ លើកឡើងថា មានប្រជាពលរដ្ឋ ១.០៣៧ គ្រួសាររស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ មុនពេលចុះបញ្ជី (ពុំមានអ្នកធ្លាប់រស់នៅលើដីនេះកន្លងមក ត្រូវបានលើកឡើងថាជាជនជាតិដើមភាគតិចនោះឡើយ)។ អ្នកដែលធ្លាប់រស់នៅលើដីនេះ បានលើកឡើងថា ពួកគេពុំបានទទួលព័ត៌មានពីកម្មវិធីសម្បទានដីសង្គមកិច្ចនេះឡើយ ហើយក៏មិនបានផ្តល់ការយល់ព្រមដល់ការបង្កើតកម្មវិធីនេះដែរ។ មានការ លើកឡើងផងដែរថា ពុំមានគ្រួសារណាមួយក្នុងចំនោមគ្រួសារទាំងនេះទទួលរងការបណ្តេញចេញដោយបង្ខំនោះទេ បើទោះជាអ្នកឆ្លើយតបមិនអាច ឬមិនចង់បង្ហាញព័ត៌មានបន្ថែមអំពីទីកន្លែងដែលគ្រួសារត្រូវផ្លាស់ ទៅរស់នៅ ឬថាតើពួកគេបានទទួលសំណងឬអត់នោះដែរ។

ក្នុងចំណោមអ្នកទទួលផល ដែលត្រូវបានសាកសួរក្នុងខេត្តបាត់ដំបង ជិត ៣ ភាគ ៤ (៧២%) បានលើកឡើងថា ដំណើរការបានអនុវត្តបែងចែកដីពុំមានយុត្តិធម៌ឡើយ។ តួលេខនេះគឺទាបជាងតួលេខមធ្យម ៦៧% ដែលគិតថា ដំណើរការនេះមានភាពយុត្តិធម៌ នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ដែលត្រូវបានអង្កេត។ អ្នកឆ្លើយតប ២១,២% បានលើកឡើងថា ពួកគេបានបង់ប្រាក់ សម្រាប់ដំណើរការបែងចែកដីនេះ ហើយជាមធ្យម

បានបង់ ២២៤ ដុល្លារ។ នេះគឺជាការព្រួយបារម្ភយ៉ាងខ្លាំង។ ការពិគ្រោះយោបល់មិនគ្រប់គ្រាន់ និងការយកលុយ រួមជាមួយនឹងកង្វះការចូលរួមឲ្យបានសកម្ម ក្នុងដំណើរការបែងចែកដី បង្កឲ្យមានការខឹងសម្បារ និងជំនឿក្នុងចំណោមប្រជាពលរដ្ឋភាគច្រើនថា ការបែងចែកដីធ្វើឡើងដោយមិនយុត្តិធម៌។ ប្រជាពលរដ្ឋរស់នៅលើដីនេះ ដែលពុំបានទទួលបានដីហើយដែលត្រូវបាន សម្ភាសជាផ្នែកមួយនៃការពិភាក្សាក្រុមគោលដៅនៅខាងក្រៅទីតាំងសម្បទានដីសង្គមកិច្ច ក៏បានលើកឡើងផងដែរ ថា ពួកគេត្រូវបានគេបណ្តេញចេញពីដី និងត្រូវបានផាត់ចេញពីដំណើរការបែងចែកដីសម្បទានសង្គមកិច្ចទាំងអយុត្តិធម៌។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានសម្ភាសជាផ្នែកមួយនៃការអង្កេតនេះ បានលើកឡើងថា មុនពេលមានការបង្កើតកម្មវិធីសម្បទានដីសង្គមកិច្ចនេះ ដីនេះ គឺជាដីព្រៃឫស្សី និងជាដីសាធារណៈរបស់រដ្ឋ។

បើតាមអ្នកឆ្លើយតបចំពោះការអង្កេតដែលមកពីអង្គការមិនមែនរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលមួយមានឈ្មោះថា ជីវិតថ្លៃថ្នូរ ត្រូវបានអាជ្ញាធរមូលដ្ឋានអញ្ជើញឲ្យជួយកំណត់ និងជ្រើសរើសអ្នកទទួលដី ក៏ដូចជាអនុវត្តដំណើរការកំណត់រៀបចំផែនទី និងធ្វើចំណាត់ថ្នាក់ដី។ ជំនួយពីអង្គការមិនមែនរដ្ឋាភិបាលដែលឯករាជ្យ និងមានសមត្ថភាព គួរតែបានផ្តល់ឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុង និងក្រៅទីតាំងសម្បទានដីសង្គមកិច្ចនេះនូវទំនុកចិត្តខ្ពស់ ថាការបែងចែកដីធ្វើឡើងដោយយុត្តិធម៌។ ក្នុងចំណោមអ្នកទទួលផលសពីសម្បទានដីសង្គមកិច្ចដែលបានសាកសួរ មានតែ ២៦% ប៉ុណ្ណោះ ដែលបានលើកឡើងថា ពួកគេ បានទទួលជំនួយពីអង្គការមិនមែនរដ្ឋាភិបាលមួយដែលនេះ បង្ហាញថា អង្គការជីវិតថ្លៃថ្នូរមិនអាចផ្តល់ការគាំទ្របានច្រើនឡើយ។ អ្នកឆ្លើយតបចំពោះការអង្កេតមកពីអង្គការជីវិតថ្លៃថ្នូរ បានលើកឡើងថា ពួកគេ ជឿថា ការជ្រើសរើស និងការបែងចែកដីធ្វើឡើងដោយយុត្តិធម៌។ ការយល់ឃើញបែបនេះ គឺផ្ទុយគ្នានឹងការយល់ឃើញរបស់ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ និងសមាជិកសហគមន៍មូលដ្ឋានដែលមិនត្រូវបានជ្រើសរើសឲ្យទទួលដី។ នេះមានន័យថា ដំណើរការនេះ ខ្លួនវា ពុំមានយុត្តិធម៌តម្លាភាព និងសមធម៌គ្រប់គ្រាន់ ឬអាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល ដែល

ចូលរួមរៀបចំកិច្ចពិគ្រោះយោបល់ និងពន្យល់ពីដំណើរការជ្រើសរើស និងបែងចែកដី មិនអាចពន្យល់ពីនីតិវិធី និងដំណើរការជ្រើសរើសនេះប្រកបដោយប្រសិទ្ធភាពគ្រប់គ្រាន់។

អ្នកឆ្លើយតប ៩៥% បានមើលផែនការសម្បទានដីសង្គមកិច្ច។ ក្រុមប្រឹក្សាឃុំ គួរផ្តួចផ្តើមរៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ចស្របទៅតាមលក្ខខណ្ឌ ដូចដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។ អ្នកទទួលផលសម្បទានដីសង្គមកិច្ច "ត្រូវតែបានត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ស្របតាមផែនការសម្បទានដីសង្គមកិច្ច ដែលបានយល់ព្រម។"[76] អ្នកឆ្លើយតបក្នុងភាគរយមួយខ្ពស់ (៦៦%) បានអះអាងថា ត្រូវបានស្នើឲ្យចូលរួមកែលំអយ៉ាងសកម្មនូវលក្ខខណ្ឌនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ បើទោះបីជាមិនបានទទួលផែនការសម្បទានដីសង្គមកិច្ចក៏ដោយ។ នេះបង្ហាញពីកម្រិតទាបនៃការរៀបចំផែនការ និងការជម្រុញឲ្យសហគមន៍ចូលរួមពីសំណាក់អាជ្ញាធរមូលដ្ឋានក្នុងការអភិវឌ្ឍទីតាំងនេះ។

អ្នកឆ្លើយតបស្ទើរតែទាំងអស់ (៩៧%) បានលើកឡើងថា ពួកគេបានត្អូញត្អែរប្រាប់ទៅអាជ្ញាធរពីស្ថានភាពនៃការរស់នៅលើទីតាំងនេះ។ ការត្អូញត្អែរញឹកញាប់ជាងគេ គឺពាក់ព័ន្ធនឹងកង្វះទឹកស្អាត (៥៨%) កង្វះអាហារ (៦៣%) ឱកាសការងារតិចតួច (២២%) គុណភាពផ្លូវ (៣៥%) និងកង្វះអនាម័យ (១២%)។ ប្រជាពលរដ្ឋរស់នៅទីនេះ ៧៣% ផ្តល់ចម្លើយផ្សេងៗទៀត ដូចជា កង្វះដី កសិកម្ម ដែលជាផ្នែកមួយដោយសារតែជម្លោះដីធ្លី (ជាមួយសហគមន៍ជិតខាង) ពាក់ព័ន្ធនឹងដីកសិកម្ម កង្វះខាតប្រព័ន្ធធារាសាស្រ្ត កង្វះអណ្តូង ទឹកជំនន់ ពុំមានគ្រាប់ពូជសម្រាប់ដាំដុះ ឬជីគីមី កង្វះឱសថ/ថ្នាំមានសារជាតិញៀនដែលអាចប្រើបាន និងវេជ្ជបណ្ឌិតនៅក្នុងគ្លីនិកឃុំ។ កង្វះសត្វ កង្វះឧបករណ៍សម្ភារៈសម្រាប់ធ្វើកសិកម្ម គ្មានផ្សារ កង្វះគ្រូនៅសាលារៀន វត្តអារាមនៅឆ្ងាយពីផ្ទះពេក មធ្យោបាយរកចំណូលពុំមានគ្រប់គ្រាន់ ជម្លោះជាមួយអ្នកជិតខាង និងអំពើហិង្សាពាក់ព័ន្ធនឹងជម្លោះដីធ្លី។ មានអ្នករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះតែ ២៣% ប៉ុណ្ណោះ ដែលលើកឡើងថា

[76] មាត្រា ១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣)។

អាជ្ញាធរបានឆ្លើយតបចំពោះការត្អូញត្អែររបស់ពួកគេ។ ចំណុចនេះ អាចបកស្រាយបានថា ជាការបានដោះស្រាយបញ្ហា ឬគ្រាន់តែជាការទទួលដឹងឮពីបញ្ហា។ បើទោះបីជាអត្រានៃការឆ្លើយតបក្នុងគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់មានកម្រិតទាប (៥២%) ក៏ដោយ ក៏អត្រាក្នុងខេត្តបាត់ដំបងមានកម្រិតទាបជាងតួលេខមធ្យមដ៏គួរកត់សម្គាល់។

ចំណុចទាំងនេះត្រូវបានលើកឡើង បើទោះបីជាមានអ្នកឆ្លើយតប ៥៧% បានរាយការណ៍ថា អាជ្ញាធរមូលដ្ឋានបានពិនិត្យតាមដានស្ថានភាពក្នុងទីតាំងនេះយ៉ាងសកម្មយ៉ាងណាក៏ដោយ។ អាជ្ញាធរមូលដ្ឋានបានដឹងយ៉ាងច្បាស់ពីស្ថានភាពទាំងនេះ បន្ទាប់ពីបានទទួលការត្អូញត្អែររបស់ប្រជាពលរដ្ឋ និងបានចូលរួមពិនិត្យតាមដាន និងចុះផ្សព្វផ្សាយព័ត៌មានរួចមក បើទោះបីជាការពិនិត្យតាមដាននេះមិនបានធ្វើឡើងឲ្យបានជាប់លាប់ និងធ្វើនៅគ្រប់ទីកន្លែងទាំងអស់ក្នុងទីតាំងសម្បទានដីសង្គមកិច្ចទាំងមូលក៏ដោយ។ អាជ្ញាធរអាចខ្វះឆន្ទៈ សមត្ថភាព ឬធនធានដើម្បីដោះស្រាយបញ្ហាទាំងនេះ។ អ្នកឆ្លើយតបបានលើកឡើងថា <u>កិច្ចប្រជុំតាមភូមិ</u> (៨៥%) គឺជាមធ្យោបាយចម្បងសម្រាប់លើកឡើងពីទុក្ខលំបាកនានា ដែលនេះបង្ហាញពីកម្រិតនៃការចូលរួមខ្ពស់ពីសំណាក់អាជ្ញាធរមូលដ្ឋាន តាមរយៈមធ្យោបាយនេះ។ មានគ្រួសារ ១៥% ទៀត ត្រូវបានអាជ្ញាធរមូលដ្ឋានចុះសួរសុខទុក្ខដល់ផ្ទះ។

ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចតែ ២៦% បានលើកឡើងថា មានការទទួលយកនូវការលើកឡើងពីទុក្ខលំបាក ឬប្រមូលភស្តុតាងផ្សេងៗយ៉ាងហោចណាស់រៀងរាល់ ៣ ខែម្តង។ អ្នកឆ្លើយតប ៣៩% បានលើកឡើងថា ការវាយតម្លៃ ឬកិច្ចប្រជុំនេះធ្វើឡើងតែរៀងរាល់ឆ្នាំប៉ុណ្ណោះ ហើយ ១១% ទៀត លើកឡើងថា មានការធ្វើបែបនេះតែម្តងប៉ុណ្ណោះ ចាប់តាំងពីពេលដែលពួកគេផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ដោយសារតែរយៈពេលរស់នៅជាមធ្យមលើដីនេះគឺជាង ១០ ឆ្នាំ នេះមានន័យថា មានការដាច់ទំនាក់ទំនង និងកង្វះការចូលរួមសហការក្នុងកម្រិតមួយគួរឲ្យព្រួយបារម្ភ។ ឧទាហរណ៍៖ មានអ្នកឆ្លើយតបតែ ២% ប៉ុណ្ណោះដែលលើកឡើងថា អាជ្ញាធរបានសាកសួរពីកម្រិតចំណូល និងមានតែ ៧% ប៉ុណ្ណោះ ដែលត្រូវបានសួរនាំពីសន្តិសុខស្បៀង។ គ្រួសារ

ភាគច្រើន (៦៥%) បានចាត់វិធានការដោយខ្លួនឯង ដើម្បីដោះស្រាយបញ្ហានានាដោយកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ផ្តោតលើការកែលំអប្រព័ន្ធធារាសាស្ត្រ ការទទួលបានទឹក និងអនាម័យ សាលារៀន និងផ្លូវក្នុងមូលដ្ឋាននេះ។

គ្រួសារតាមផ្ទះភាគច្រើន (៨៥%) លើកឡើងថា សហគមន៍បានផ្តួចផ្តើមគំនិតកែលំអស្ថានភាពនៃការរស់នៅក្នុងតំបន់សម្បទានដីសង្គមកិច្ចនេះ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះផ្តោតការយកចិត្តទុកដាក់លើការកែលំអ ការសាងសង់ ឬការថែទាំផ្លូវ (៣៦%) ការបង្កើនលទ្ធភាពទទួលបានសេវាថែទាំសុខភាព (៥៩%) ការទទួលបានទឹក/ការសាងសង់អណ្តូង (៦៥%) និងសាលារៀនក្នុងមូលដ្ឋាន (៩%)។

**ភាពសមស្របនៃដី៖**

មានតែប្រជាពលរដ្ឋចំនួន ១៦ គ្រួសារ (៦%) ប៉ុណ្ណោះ បានទទួលដីលំនៅឋានផង និងដីកសិកម្មផងដោយឡែកពីគ្នា។ ប្រជាពលរដ្ឋ ២៣២ គ្រួសារ (៩៣%) ទៀត ដែលត្រូវបានសាកសួរផងដែរនោះ បានទទួលតែដីលំនៅឋានតែប៉ុណ្ណោះ និងមានតែ ១ គ្រួសារប៉ុណ្ណោះដែលបានអះអាងថាបានទទួលតែដីកសិកម្ម។ អនុក្រឹត្យនេះចែងថា ក្បាលដីអាចផ្តល់*សម្រាប់សង់*លំនៅឋាន *ដល់គ្រួសារក្រីក្រគ្មានផ្ទះសម្បែង ឬដល់គ្រួសារក្រីក្រសម្រាប់ធ្វើកសិកម្ម*។

អ្នកឆ្លើយតប ៨១% បានលើកឡើងថា ដីសម្រាប់ធ្វើកសិកម្មជុំវិញផ្ទះរបស់ពួកគេមិនទាន់បាន "កាប់ឆ្ការសំអាត" និងអាចយកមកធ្វើកសិកម្មបានឡើយ នៅពេលដែលពួកគេបានទទួលដំបូងដោយអ្នកឆ្លើយតបតែ ១២% ប៉ុណ្ណោះ បាននិយាយថា ដីទាំងអស់ត្រូវបានសំអាត ហើយគ្រួសារនៅសល់ទៀត បាននិយាយថា ដីមួយចំនួនត្រូវបានសំអាត។ បច្ចុប្បន្ននេះ គ្រួសារទាំងអស់បានសំអាតដីដែលអាចដាំដុះបានរបស់ខ្លួន។ គ្រួសារតាមផ្ទះ ២៧% ជួលគេឲ្យកាប់ឆ្ការសំអាត។ ប្រជាពលរដ្ឋក្នុងភាគរយមួយខ្ពស់ (៨៧%) មានបំណងដាំស្វាយ នាពេលអនាគត ៣៩% ដាំបន្លែ និង ៣៥% ធ្វើស្រែ។ នេះគឺជាការធ្វើពិពិធកម្មប្រភេទដំណាំច្រើនមុខជាង នៅទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀត។

រយៈពេលនៃការរស់នៅជាមធ្យមលើទីតាំងសម្បទានដីសង្គមកិច្ចនេះគឺ ១៣១ ខែ មានន័យថា ប្រជាពលរដ្ឋដែលរស់នៅលើដីនេះគួរតែបានទទួលប័ណ្ណកម្មសិទ្ធិ (រយៈពេល ៦០ ខែ គឺជារយៈពេលតម្រូវ ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីផ្លូវការ ដូចដែលត្រូវបានចែងក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច)។ ប្រជាពលរដ្ឋគ្រប់គ្រួសារទាំងអស់ លើកលែងតែ ២ គ្រួសារចេញ (០,៨%) បានទទួលប័ណ្ណកម្មសិទ្ធិដី។ យោងតាមអនុក្រឹត្យនេះ អ្នកទទួលដីត្រូវតែគោរពទៅតាមលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសម្បទានដីសង្គមកិច្ច ដោយត្រូវរស់នៅឲ្យបាន ៥ ឆ្នាំ ទើបមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិដីស្របច្បាប់។ ពុំមានការដឹងច្បាស់ទេថាតើមានការអនុលោមទៅតាមរយៈពេលកំណត់ ៦០ ខែ ឬអត់នោះ ប៉ុន្តែសុវត្ថិភាពក្នុងការកាន់កាប់ ត្រូវបានផ្តល់ដល់ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះស្ទើរតែទាំងអស់។ ប្រជាពលរដ្ឋ ១ ភាគ ៤ (២៤%) ក៏បានទទួលឯកសារបន្ថែម ទាក់ទងនឹងសិទ្ធិភោគៈ ឬម្ចាស់កម្មសិទ្ធិ (កិច្ចសន្យា ឯកសារចាប់ឆ្នោត ឬឯកសាររបស់អង្គការមិនមែនរដ្ឋាភិបាល) ផងដែរ។

ផ្ទៃដីមធ្យមសម្រាប់សង់លំនៅឋានគឺ ១៧០៧ ម៉ែត្រការ៉េ ជាទំហំធំជាងក្បាលដីមធ្យម នៅតាមទីតាំងសម្បទានដីសង្គមកិច្ចដែលត្រូវបានអង្កេតនេះ (១៤២០ ម៉ែត្រការ៉េ)។ អ្នកឆ្លើយតប ៥,៦% បានលើកឡើងថា ពួកគេបានទទួលក្បាលដីតូចជាងអ្នកជិតខាងរបស់ខ្លួន។

ទំហំផ្ទះជាមធ្យមគឺ ២២ ម៉ែត្រការ៉េ ពោលគឺតូចជាងទំហំផ្ទះគិតជាមធ្យមនៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់បន្តិច (២៨ ម៉ែត្រការ៉េ)។ មានផ្ទះតែ ៩% ប៉ុណ្ណោះ ដែលត្រូវបានសាងសង់ឡើង មុនពេលដែលគ្រួសារទាំងនេះផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ផ្ទះផ្សេងទៀត ត្រូវបានសាងសង់ដោយគ្រួសារផ្ទាល់ និងដោយអ្នកជិតខាង។ គ្រួសារអាចសាងសង់ផ្ទះបាន ជាមធ្យម ១២ ខែ ក្រោយពីបានទទួលដីសម្បទានសង្គមកិច្ច។ អ្នកឆ្លើយតបភាគច្រើន (៥៩%) លើកឡើងថា លំនៅឋានថ្មីរបស់ពួកគេ*ល្អជាង ឬល្អឆ្ងាយជាង* ផ្ទះមុនៗរបស់ពួកគេ។ ប៉ុន្តែ ២២% បានលើកឡើងថា ផ្ទះថ្មីរបស់ពួកគេ*អន់ជាង* ឬ*អន់ឆ្ងាយជាង* ផ្ទះមុនរបស់ពួកគេ ហើយគ្រួសារដែលនៅសល់លើកឡើងថាស្ថានភាព

ប្រហាក់ប្រហែលគ្នា។ បើទោះបីជាចំណុចនេះមួយផ្នែកដោយសារតែការយល់ឃើញក៏ដោយ វាជាសញ្ញាសំខាន់បង្ហាញ ពីភាពជោគជ័យនៃគម្រោងសម្បទានដីសង្គមកិច្ចនេះ។ តើគ្រួសារក្រីក្រ ឬគ្មានដី បានទទួលលំនៅឋានសមរម្យ ដែលអាចបំពេញទៅតាមតម្រូវការជាមូលដ្ឋានរបស់ពួកគេដែរឬទេ? ក្នុងករណីនេះ កម្មវិធីសម្បទានដី សង្គមកិច្ចនេះហាក់បីដូចជាមិនបានកែលំអកម្រិតជីវភាពរស់នៅ សម្រាប់គ្រួសារទទួលផលមួយភាគធំឡើយ។

អ្នកឆ្លើយតប ៥៩% លើកឡើងថា ពួកគេពុំមានអារម្មណ៍ថាខ្លួនមានសុវត្ថិភាព ក្នុងផ្ទះបច្ចុប្បន្នរបស់ខ្លួនឡើយ ដោយសារតែការខូចខាតបង្កឡើងដោយខ្យល់ /ភ្លៀង (៧២%) ឬដោយសារអំពើចោរកម្ម (១៣%)។ អ្នកឆ្លើយតប ៥% ទៀត គិតថា សំណង់ផ្ទះរបស់ពួកគេមិនរឹងមាំឡើយ។ គេមិនបានដឹងច្បាស់ថាតើមានប្រជាពលរដ្ឋប៉ុន្មានគ្រួសារ ដែលបានទទួលរងគ្រោះដោយសារអំពើចោរកម្ម ឬការខូចខាតបង្កឡើងដោយសារអាកាសធាតុនោះទេ។

ក្បាលដីសម្រាប់ធ្វើកសិកម្មជាមធ្យមមានទំហំត្រឹមតែ ០,១២ ហិកតាប៉ុណ្ណោះ។ ប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ៨% លើកឡើងថា អ្នកជិតខាងរបស់ពួកគេទទួលបានដីធំជាង។ អ្នកឆ្លើយតប ៩១% បានលើកឡើងថា ឥឡូវនេះ ពួកគេបានដាំដំណាំលើដីនៅជុំវិញផ្ទះរបស់ពួកគេ បើទោះបីជា ៩០% និយាយថា ដីនេះមិនសមស្របសម្រាប់ការដាំដុះ និងមានអ្នកឆ្លើយតបជាច្រើន (៧៦%) មិនអាចរកចំណូលសម្រាប់គ្រួសារពីការដាំដុះនេះក៏ដោយ ពោលគឺភាគច្រើនដាំទុកបរិភោគ ជាជាងយកទៅលក់ ឬដាំបានតិចពេក មិនគ្រប់សម្រាប់យកទៅលក់។ បើទោះបីជាដីមានទំហំតូចៗក៏ដោយ ប្រជាពលរដ្ឋរស់នៅទីនេះ ៧៦% អាចរកចំណូលពីការធ្វើកសិកម្មបាន។ ចំណូលប្រចាំឆ្នាំជាមធ្យមដែលបានពីការធ្វើកសិកម្ម គឺ ៩៨៣ ដុល្លារ។ បើទោះបីជាបែបនេះក៏ដោយ ក៏មានអ្នកឆ្លើយតបតែ ៥៨% ប៉ុណ្ណោះ ដែលលើកឡើងថា ពួកគេរកចំណូលបានច្រើនជាងមុនពេលមករស់នៅលើទីតាំងសម្បទានដី សង្គមកិច្ចនេះ បើធៀបនឹង កន្លែងរស់នៅរបស់ពួកគេកន្លងមក (ហើយ ៩៦% រកបាន "ច្រើនជាងមុនតែបន្តិច" ប៉ុណ្ណោះ)។ ប្រជាពលរដ្ឋ ៨២% លើកឡើងថា ពួកគេទទួលបានដីនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ដោយសារ ពួកគេ

ខ្វះដី និង ៣៦% ទៀតលើកឡើងថាដោយសារភាពក្រីក្រ នេះមានន័យថា ការផ្លាស់មករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះមិនបានបង្កើនចំណូលសម្រាប់គ្រួសារ (និងទ្រព្យសម្បត្តិ ហើយទំនងជាកម្រិតជីវភាពរស់នៅ) ក្នុងចំណោមគ្រួសារ ដែលត្រូវបានចាត់ទុកថារស់នៅក្នុងភាពក្រីក្រ មុនពេលផ្លាស់មកទីនេះឡើយ។ គ្រួសារតាមផ្ទះ ២៣% រកចំណូលប្រចាំខែបានតិចជាងកម្រិតចំណូលដែលពួកគេធ្លាប់តែទទួលបាន។

អ្នកឆ្លើយតប ៩១% លើកឡើងថា ពួកគេមិនអាចរកចំណូលពីការធ្វើកសិកម្មឡើយ ដោយសារតែដំណាំដាំតែបានសម្រាប់បរិភោគក្នុងផ្ទះ ហើយ ៤៨% ទៀត លើកឡើងថា ដោយសារតែទិន្នផលបានតិចពេក។ នេះបង្ហាញថា ការផ្តល់ដីកសិកម្មទំហំតូចបែបនេះមិនបានផ្តល់ការគាំទ្រឲ្យបានគ្រប់គ្រាន់ដល់គ្រួសារដើម្បីជួយបង្កើនចំណូលឡើយ។ អាជ្ញាធរមូលដ្ឋាន អះអាងថាបានផ្តល់សម្ភារៈកសិកម្ម ក៏ដូចជាសម្ភារៈសម្រាប់សាងសង់លំនៅឋានដល់អ្នកដែលទើបនឹងទទួលបានដីថ្មីៗ។ អ្វីដែលជាការព្រួយបារម្ភខ្លាំងនោះគឺ គ្រួសារតាមផ្ទះ ១៨% លើកឡើងថា ពួកគេមិនអាចរកចំណូលបានឡើយ ដោយសារតែពួកគេកំពុងមានជម្លោះលើរឿងភោគៈ ឬកម្មសិទ្ធិដីរបស់ពួកគេ។

ប្រជាពលរដ្ឋត្រឹមតែ ២% ប៉ុណ្ណោះ បានលក់ ឬផ្តល់ផ្នែកនៃដីរបស់ពួកគេជាអំណោយ។ នេះអាចដោយសារតែចំណូលមានកម្រិតទាប ហើយបំណុលមានកម្រិតខ្ពស់ និង/ឬដោយសារតែការពុំមានលទ្ធភាពដាំដុះ និងរកចំណូលពីដីដែលពួកគេទទួលបាន។ ដោយសារតែរយៈពេលមានកម្មសិទ្ធិ (ជាមធ្យម ១៣១ ខែ) ហើយប្រជាពលរដ្ឋទាំងនេះមានសិទ្ធិស្របច្បាប់ក្នុងការលក់ដីរបស់ពួកគេ ក្រោយការកាន់កាប់បានជាង ៥ ឆ្នាំ តួលេខទាបបែបនេះបង្ហាញថា គ្រួសារភាគច្រើនអាចទ្រទ្រង់ជីវភាពគ្រួសាររបស់ខ្លួនបានគ្រប់គ្រាន់ និង/ឬមានន័យថា ជម្រើសផ្សេងទៀតអន់ជាងនេះ។ មានការផ្តល់ជំនួយច្រើនប្រភេទដល់គ្រួសារ ៤១% ដែលប្រើប្រាស់ដីសម្រាប់ធ្វើកសិកម្ម ក្នុងចំណោមប្រជាពលរដ្ឋ ៦១ គ្រួសារដែលបានទទួលជំនួយ ៨៥% បានទទួលឧបករណ៍សម្ភារៈ និង ៥៦% បានទទួលជំនួយហិរញ្ញវត្ថុ ភាគច្រើនពីអង្គការមិនមែនរដ្ឋាភិបាលជាជាងពីស្ថាប័នរដ្ឋ។

ប្រជាពលរដ្ឋភាគច្រើន (៧៧%) បានលើកឡើងថា ពួកគេពុំមានជំនាញធ្វើកសិកម្មមុនពេលផ្លាស់មករស់នៅលើទីតាំងនេះឡើយ ហើយមានតែ ៩២% ប៉ុណ្ណោះ ដែលនិយាយថា ពួកគេបានកែលំអជំនាញទាក់ទងនឹងការធ្វើកសិកម្ម ដែលនេះបង្ហាញថាមានការផ្តល់ការគាំទ្រ និងការបណ្តុះបណ្តាលដែរ ប៉ុន្តែប្រហែលជាពុំទាន់មានប្រសិទ្ធភាព។

**ជម្លោះដីធ្លី៖**

១៦ គ្រួសារតាមផ្ទះ ស្មើនឹង ៦% លើកឡើងថា បច្ចុប្បន្ននេះ ពួកគេកំពុងជាប់ពាក់ព័ន្ធនឹងជម្លោះដីធ្លី ទាក់ទិននឹងដីផ្ទះសម្បែងរបស់ពួកគេ ដែលជម្លោះនេះគឺជាមួយអ្នកដែលធ្លាប់រស់នៅលើដីនេះកន្លងមក ឬជាមួយនឹងស្ថាប័នរដ្ឋណាមួយ។ យ៉ាងណាមិញ អ្នកឆ្លើយតប ៩៦% ធ្លាប់ទទួលរងការទន្ទ្រានលើដីរបស់ពួកគេ ដែលនេះជាភាគរយខ្ពស់បំផុត ក្នុងចំណោមទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ដែលត្រូវបានអង្កេត ដែលការទន្ទ្រានបែបនេះធ្វើឡើងដោយប្រជាពលរដ្ឋដែលធ្លាប់រស់នៅកន្លងមក (៥៣%) ដោយស្ថាប័នរដ្ឋ ឬមន្ត្រីរដ្ឋាភិបាល (១៥%) ឬដោយភាគីផ្សេងទៀត។ ចំណុចដែលគួរឲ្យព្រួយបារម្ភនោះគឺមានគ្រួសាររស់នៅទីតាំងនេះ ៣២% លើកឡើងថា បានទទួលរងការយាយី ឬការគំរាមកំហែងពាក់ព័ន្ធនឹងដីរបស់ពួកគេ ពីសំណាក់ប្រជាពលរដ្ឋដែលធ្លាប់រស់នៅកន្លែងនេះ (៤០%) ពីស្ថាប័នរដ្ឋ (១៤%) ឬពីយោធា (១៤%)។ ការកើតឡើងខ្ពស់នូវករណីគំរាមកំហែង និងយាយីពីសំណាក់ស្ថាប័នរដ្ឋ និងយោធាក្នុងខេត្តបាត់ដំបង ជាង ១ ភាគ ៤ នៃគ្រួសារតាមផ្ទះទាំងអស់ កំពុងព្រួយបារម្ភជាពិសេស ដោយសារតែភាពងាយរងគ្រោះរបស់គ្រួសារក្រីក្រខ្លួន និងដោយសារតែជាទូទៅ គ្រួសារតាមផ្ទះទាំងនោះ ពឹងអាស្រ័យលើស្ថាប័នរដ្ឋឲ្យដោះស្រាយបញ្ហាឲ្យខ្លួន តែក្នុងករណីនេះស្ថាប័នរដ្ឋបែរក្លាយជាឧបសគ្គដែលអាចរារាំងដល់ការទទួលបានយុត្តិធម៌ និងការដោះស្រាយជម្លោះប្រកបដោយសមធម៌ទៅវិញ។ បញ្ហានេះនឹងរួមចំណែកយ៉ាងខ្លាំង ដល់ការកាន់កាប់ដីធ្លីដែលគ្មានសុវត្ថិភាព ដែលជាការផ្ទុយទៅនឹងគោលដៅមួយក្នុងចំណោមគោលដៅនានានៃកម្មវិធីសម្បទានដីសង្គមកិច្ច។

ក្រុមសម្ភាស បានរៀបចំការពិភាក្សាក្រុមគោលដៅជាមួយនឹងប្រជាពលរដ្ឋមួយក្រុមមកពីភូមិយុត្តិធម៌ ឃុំបឹងប្រាំ ស្រុកបវេល ដែលបានអះអាងថាត្រូវបានបណ្តេញចេញពី

ទីតាំងសម្បទានដីសង្គមកិច្ចក្នុងខេត្តបាត់ដំបង។ ក្រុមនេះ រួមមានប្រជាពលរដ្ឋដែលអះអាងថា ពួកគេធ្លាប់រស់នៅ ឬធ្លាប់ប្រើប្រាស់ទីតាំងសម្បទានដីសង្គមកិច្ចនេះរហូតដល់ ១១ ឆ្នាំកន្លងមក។ មិនមានសញ្ញាដែលបង្ហាញថា នឹងមានការផ្តល់ប័ណ្ណកម្មសិទ្ធិដីដល់សហគមន៍នេះឡើយ។ ប្រជាពលរដ្ឋអះអាងថា ពួកគេបានទទួលសំណងតិចតួចប្រមាណជា ២០.០០០ រៀល (ស្មើនឹង ៥ ដុល្លារ) ម្នាក់តែប៉ុណ្ណោះ។ ក្រុមអង្កេតមិនអាចផ្ទៀងផ្ទាត់ដឹងពីភាពពិតប្រាកដនៃការអះអាងនេះឡើយ។ អ្នកឆ្លើយតបដែលចូលរួមក្នុងការពិភាក្សាក្រុមគោលដៅនេះមិនបានដាក់ការបន្ទោសលើអ្នកទទួលផលសម្បទានដីសង្គមកិច្ចឡើយ ប៉ុន្តែបានត្អូញត្អែរពីរបៀបដែលអាជ្ញាធរមូលដ្ឋានឆ្លើយតបចំពោះបណ្តឹងតវ៉ារបស់ពួកគេ។

អាជ្ញាធរមូលដ្ឋានបានលើកឡើងថា ជម្លោះដីធ្លីជាកត្តាបន្ទុចបង្អាក់មិនឲ្យអ្នកទទួលផលធ្វើកសិកម្មលើដីរបស់ពួកគេបាន ហើយបញ្ហានេះមានផលប៉ះពាល់ធំធេងមកលើចំណូលរបស់គ្រួសារ សន្តិសុខស្បៀង និងកម្រិតជីវភាពរស់នៅ។ ពួកគេ លើកឡើងថា ពួកគេមិនអាចដោះស្រាយជម្លោះនេះបានឡើយ ហើយមានតែមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ប៉ុណ្ណោះ ដែលអាចជួយដោះស្រាយបាន។ ពួកគេក៏បានលើកឡើងផងដែរថា មានប្រជាពលរដ្ឋមកពីខេត្តផ្សេង មកទន្ទ្រានយកដីនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ដែលនេះបង្ហាញថាគ្មានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងជម្លោះដែលមិនទាន់បានដោះស្រាយអាចរួមចំណែកនាំឲ្យមានការទន្ទ្រានយកដីបន្ថែមទៀត និងធ្វើឲ្យបញ្ហាបច្ចុប្បន្ននេះកាន់តែធ្ងន់ធ្ងរឡើង។

ការទទួលបានសេវាមួយចំនួន ដូចជា មណ្ឌលសុខភាព ជាដើម មានភាពល្អប្រសើរជាងមុន ចាប់តាំងពីមានការបង្កើតសម្បទានដីសង្គមកិច្ចនេះរួចមក នេះបើតាមការលើកឡើងរបស់អ្នកចូលរួមមួយចំនួនក្នុងការពិភាក្សាក្រុមគោលដៅនេះ ដែលនេះបង្ហាញថាប្រជាពលរដ្ឋមូលដ្ឋានដែលរស់នៅខាងក្រៅតំបន់សម្បទានដីសង្គមកិច្ច ក៏អាចប្រើប្រាស់និង ទទួលបានប្រយោជន៍ពីសេវាសាធារណៈដែលកាន់តែល្អប្រសើរជាងមុន ដោយសារមានការសម្របសម្រួលរវាងអាជ្ញាធរមូលដ្ឋាន និងកម្មវិធីសម្បទានដីសង្គមកិច្ច។ ប៉ុន្តែ ការទទួលបានទឹកស្អាត និងអនាម័យមិនបានល្អប្រសើរជាងមុនឡើយ ហើយនៅតែជាបញ្ហា

ចម្បងមួយ។ ចំណុចនេះ គឺស្របគ្នាជាមួយនឹងការលើកឡើងរបស់អ្នកទទួលផលសម្បទានដីសង្គមកិច្ច។ ក្រុមដដែលនេះ ក៏បានលើកឡើងផងដែរថា សមាជិកគ្រួសារនៅតែបន្តធ្វើចំណាកស្រុកទៅកាន់ប្រទេសថៃដើម្បីស្វែងរកការងារធ្វើ ហើយឱកាសការងារនៅតែមានតិចតួច និងពុំបានកើនឡើងជាងមុនឡើយ ចាប់តាំងពីមានការបង្កើតសម្បទានដីសង្គមកិច្ចនេះរួចមក។

**ការទទួលបាន ទឹក និងអនាម័យៈ**

គ្រួសារ ៩០% ដែលត្រូវបានសម្ភាស ពុំមានលទ្ធភាពទទួលបានទឹកស្អាតសម្រាប់បរិភោគឡើយ។ ប្រជាពលរដ្ឋទៅយកទឹកពីស្រះ ទំនប់ ឬបឹង (៥៨%) ទន្លេ ឬប្រឡាយ (១០%) ឬត្រង់ទឹកភ្លៀងទុក (២២%)។ ប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ច ៨២% បានសំអាតទឹករបស់ពួកគេ មុនពេលបរិភោគ តាមរយៈការដាំ បើទោះបីជាមានតែ ៣% ប៉ុណ្ណោះ ដែលប្រើឧបករណ៍ចម្រោះទឹក។ អ្នកឆ្លើយតប ៤២% បានលើកឡើងថាទឹកបរិភោគរបស់ពួកគេមានពណ៌ រសជាតិ និង/ឬក្លិនចម្លែក និងមានគ្រួសារតែ ៣% ប៉ុណ្ណោះ ដែលលើកឡើងថាទឹករបស់ពួកគេត្រូវបានសំអាតដោយប្រើសារធាតុក្លរ។ អ្នកឆ្លើយតបសម្ភាស ៥៣% បានដាក់ពិន្ទុឲ្យការទទួលបានទឹករបស់ខ្លួនថា*អន់ ឬអន់ឆ្ងាយជាង*កន្លែងដែលពួកគេរស់នៅលើកមុន។ មានអ្នកឆ្លើយតបសម្ភាសតែ ២១% ប៉ុណ្ណោះ ដែលបានដាក់ពិន្ទុឲ្យការទទួលបានទឹកស្អាតរបស់ពួកគេថាល្អប្រសើរជាងមុន។ នេះបង្ហាញថា បញ្ហាពាក់ព័ន្ធនឹងការទទួលបានទឹកស្អាតនេះគឺមានភាពស្រួចស្រាវខ្លាំង ក្នុងខេត្តបាត់ដំបង ហើយពុំមានការបែងចែកធនធានគ្រប់គ្រាន់សម្រាប់ផ្តល់ទឹកស្អាតឡើយ។

ពុំមានប្រព័ន្ធលូបញ្ចេញចោលទឹកស្អុយ ឡើយសម្រាប់ប្រជាពលរដ្ឋ ៩៨% ដែលបានអង្កេត ហើយមានគ្រួសារ ៦២% ពុំមានបរិក្ខារអនាម័យឡើយ។ ប៉ុន្តែ ក្នុងចំណោមគ្រួសារ ៣៨% ដែលមានបរិក្ខារអនាម័យ ពួកគេអាចមានបង្គន់ចាក់ទឹកដែលភ្ជាប់ជាមួយនឹងរណ្តៅស្តុកលាមក ឬរណ្តៅស្តុកលាមកដែលចោះឲ្យមានខ្យល់ចេញចូល។ ប្រជាពលរដ្ឋផ្សេងទៀតបន្ទោរបង់ក្នុងព្រៃ ឬជីករណ្តៅ។ អ្នកឆ្លើយតប ៨៩% លើកឡើងថា ពួកគេពុំមានអារម្មណ៍ថាមានសុវត្ថិភាព នៅពេលចេញទៅបន្ទោរបង់ខាងក្រៅផ្ទះឡើយ។ អ្នក

ឆ្លើយតប ២៨% បានដាក់ពិន្ទុឲ្យស្ថានភាពអនាម័យរបស់ខ្លួនថាអន់ ឬអន់ឆ្ងាយជាងស្ថានភាពកាលពីមុន និង ៣០% លើកឡើងថាស្ថានភាពបានប្រសើរជាងមុន។ អ្នកឆ្លើយតបភាគច្រើនលើកឡើងថា ស្ថានភាពពុំមានការប្រែប្រួលឡើយ។

**សេវាសុខាភិបាល៖**

ជាមធ្យម ប្រជាពលរដ្ឋត្រូវចំណាយពេលតែ ៩ នាទីប៉ុណ្ណោះ ដើម្បីធ្វើដំណើរទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុត ប៉ុន្តែរហូតដល់ ៩៥ នាទី ដើម្បីធ្វើដំណើរទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត។ ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ៥៨% លើកឡើងថា ពួកគេមានជំងឺញឹកញាប់ជាងមុន បើធៀបជាមួយនឹងស្ថានភាពនៃការរស់នៅពីមុន។ ជំងឺគ្រុនពោះវៀនត្រូវបានរាយការណ៍ថាកើតឡើងញឹកញាប់ជាងគេដូចគ្នានឹងករណីជំងឺគ្រុនឈាមដែរ។ ជំងឺគ្រុនចាញ់ ក៏កើតមានផងដែរ។ គ្រុនក្តៅ ឬផ្តាសាយ និងឈឺពោះ ក៏កើតឡើងញឹកញាប់ផងដែរ។ មានគ្រួសារ ២% បានលើកឡើងថាក្នុងខ្នងផ្ទះមួយមានសមាជិកម្នាក់ផ្ទុកមេរោគអេដស៍។ អ្នកឆ្លើយតប ៥២% លើកឡើងថាការទទួលបានសេវាសុខភាព*អន់ឆ្ងាយជាងមុន* បើធៀបជាមួយនឹងស្ថានភាពរស់នៅកន្លែងមុន និង ៧% ទៀត លើកឡើងថាអន់ជាងមុន។ មានអ្នកឆ្លើយតបតែ ៣២% ប៉ុណ្ណោះ ដែលលើកឡើងថា សេវាសុខាភិបាលមានភាពល្អប្រសើរជាងមុន នៅទីតាំងសម្បទានដីសង្គមកិច្ចថ្មីនេះ។

**ការអប់រំ៖**

នៅតំបន់នេះ មានសាលាបឋមសិក្សាផង និងសាលាមធ្យមសិក្សាផង។ កុមារត្រូវធ្វើដំណើរតាមម៉ូតូឌុបជាមធ្យម ១៨ នាទី ដើម្បីទៅដល់សាលាមធ្យមសិក្សាដែលនៅជិតបំផុត (បើទោះបីជារយៈពេលធ្វើដំណើរគឺយូរជាងនេះ សម្រាប់ប្រជាពលរដ្ឋ ១៣% ដែលនិយាយថា ពុំមានសាលាមធ្យមសិក្សា នៅកៀកនឹងកន្លែងដេលពួកគេរស់នៅ)។ ជាមធ្យម កុមារចំណាយពេលត្រឹមតែ ៦ នាទី តាមម៉ូតូឌុប ដើម្បីធ្វើដំណើរទៅសាលាបឋមសិក្សាដែលនៅជិតជាងគេ។ អ្នកឆ្លើយតប ២០% បានលើកឡើងថា យ៉ាងហោចណាស់ មានកុមារដល់វ័យចូលរៀនមួយចំនួន (អាយុចន្លោះពី ៦ ដល់ ១៧ ឆ្នាំ) ក្នុងផ្ទះរបស់ពួកគេ <u>ពុំបានទៅរៀន</u>

ឡើយ ដែលនេះជាចំណុច ដ៏គួរព្រួយបារម្ភខ្លាំង។ ពួកគេបានលើកឡើងពីមូលហេតុច្រើនយ៉ាង ដែលក្នុងនោះរាប់បញ្ចូលទាំងលទ្ធភាពចំណាយផងដែរ។ គ្រួសារ ១៩% និយាយថា បច្ចុប្បន្ននេះ កូនៗពួកគេតិចជាងមុនបានទៅរៀន ចាប់តាំងពីផ្លាស់មករស់នៅទីតាំងសម្បទានដីសង្គមកិច្ចនេះមក ដែលនេះក៏ជាបញ្ហាចោទជាពិសេសមួយផងដែរ បើទោះបីជាអ្នកឆ្លើយតប ៤២% និយាយថា កូនៗរបស់ពួកគេច្រើននាក់ជាងមុនបានទៅរៀនក៏ដោយ។ ការថយចុះបែបនេះមិនទំនងជាកើតឡើងដោយសារតែទីតាំងនោះទេ ពីព្រោះ តែនៅតំបន់នេះមានសាលាបឋមសិក្សាផង និងសាលាមធ្យមសិក្សាផង (ខុសពីទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀត)។ មូលហេតុចម្បងគឺអាចដោយសារភាពក្រីក្រ ដែលនេះជាការបង្ហាញថា ចាំបាច់ត្រូវតែមានការផ្តល់ការគាំទ្រឲ្យបានច្រើនជាបន្ទាន់ដល់គ្រួសារក្រីក្រ ដើម្បីឲ្យពួកគេអាចបង្កើតប្រភពចំណូលបន្ថែមរបស់គ្រួសារ ទើបកូនៗទាំងអស់របស់ពួកគេអាចទៅរៀនបាន។ ជាមធ្យម មានគ្រួសារប្រមាណជា ៥៥% មានគម្រោងចង់ឲ្យកូនប្រុសទទួលបានការអប់រំ *យ៉ាងហោចណាស់* ១២ ឆ្នាំ ប៉ុន្តែតួលេខនេះថយចុះមកនៅ ៤៩% សម្រាប់កូនស្រី ដែលបង្ហាញថា <u>ការរើសអើងយេនឌ័រគឺជាបញ្ហាមួយ ក្នុងការទទួលបានការអប់រំ</u>។ សម្គាល់ នេះមិនមែនជាការបង្ហាញថាតើមានការផ្តល់ការអប់រំជាក់ស្តែងកម្រិត ណានោះទេ ច្រើនតែជាការឆ្លុះបញ្ចាំងពីបំណងរបស់គ្រួសារតាមផ្ទះទាំងនោះ និងសារៈសំខាន់ដែលទាក់ទងជាប់ទៅ នឹងការអប់រំ។

នៅពេលឲ្យដាក់ពិន្ទុលើការទទួលបានការអប់រំ នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ មានអ្នកឆ្លើយតបតែ ៤០% ប៉ុណ្ណោះ ដែលបានលើកឡើងថា ការអប់រំមានភាពល្អប្រសើរជាងមុន។ ផ្ទុយទៅវិញ ២៥% បានលើកឡើងថា ការទទួលបានការអប់រំធ្លាក់ចុះជាងមុន។

**ហេដ្ឋារចនាសម្ព័ន្ធ និងអគ្គិសនី៖**

ប្រជាពលរដ្ឋដែលរស់នៅលើដីសម្បទានសង្គមកិច្ចនេះស្ទើរតែទាំងអស់ អាចភ្ជាប់បណ្តាញទូរស័ព្ទដៃបាន ហើយអ្នកឆ្លើយតបភាគច្រើន (៨៩%) មានទូរស័ព្ទ និងអ៊ីនធឺណិតប្រើប្រាស់។ មានអ្នកឆ្លើយតបតែ ៣០% ប៉ុណ្ណោះ ដែលលើកឡើងថា <u>ការប្រើប្រាស់មធ្យោបាយធ្វើដំណើរ (បណ្តាញផ្លូវថ្នល់) និងការទំនាក់ទំនង (ទូរស័ព្ទ និងអ៊ីនធឺណិត)</u> មាន

ភាពល្អប្រសើរជាងមុន ខណៈពេលដែល ៤៩% បាននិយាយថា ស្ថានភាពនេះអន់ជាងមុន ចាប់តាំងពីពេលដែលពួកគេផ្លាស់មករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ បើទោះបីជាមានការកសាងផ្លូវថ្នល់ក្នុងតំបន់នេះក៏ដោយ។

ក្នុងចំណោមប្រជាពលរដ្ឋទាំងអស់ដែលបានសាកសួរ មានតែ ៣ នាក់ (១%) ប៉ុណ្ណោះ ដែលមានអគ្គិសនីប្រើប្រាស់នៅទីតាំងសម្បទានដីសង្គមកិច្ចនេះឡើយ។ សម្គាល់ សំណួរនៃការអង្កេតនេះសួរពីអគ្គិសនី "ដែលរដ្ឋផ្តល់ឲ្យ" តាមរយៈការភ្ជាប់បណ្តាញមេ។ វាមិនមែនន័យថា ពុំមានម៉ាស៊ីនភ្លើង ឬប្រភពអគ្គិសនីផ្សេងទៀតនោះឡើយ។

**សន្តិសុខស្បៀង៖**

អ្នកឆ្លើយតប ៩៦% និយាយថា កាលពីខែមុននេះ យ៉ាងហោចណាស់ក៏មានម្តងដែរ ដែលពួកគេមានការភ័យខ្លាចថា ពួកគេនឹងពុំអាចផ្តល់អាហារគ្រប់គ្រាន់ដល់គ្រួសាររបស់ពួកគេ ដោយ ៧៨% លើកឡើងថា នេះជាការភ័យព្រួយដែលកើតមានជាប្រចាំ។ គ្រួសារ ៨០% លើកឡើងថា ពួកគេត្រូវកំហិតអាហារដែលត្រូវបរិភោគ (ដូចជា ពុំមានសាច់ ឬត្រី ជាដើម) នៅពេលណាមួយ ក្នុងខែមុននេះ ដោយសារតែខ្វះលុយ ហើយ ៩០% ត្រូវបង្ខំចិត្តបរិភោគមើមរុក្ខជាតិដុះក្នុងព្រៃ ឬសាច់ដែលមានគុណភាពអន់ខ្លាំង ដោយសារតែមូលហេតុដូចគ្នានេះ។ អ្នកឆ្លើយតប ៥៦% លើកឡើងថា ពួកគេធ្លាប់ដាច់បាយ កាលពីខែមុននេះ និងមានអ្នកឆ្លើយតប ៣៩% បានលើកឡើងថា មានថ្ងៃខ្លះ កាលពីខែមុននេះ ដែលពួកគេពុំមានអាហារបរិភោគតែម្តង ដោយសារតែពុំមានលុយទិញអាហារ និងពុំអាចរកអាហារបានពីដីរបស់ពួកគេ។ ការទទួលបានអាហារដែលមានតម្លៃសមរម្យ និងកង្វះអាហារ គឺជាបញ្ហាស្រួចស្រាវមួយ ក្នុងខេត្តបាត់ដំបង។ បើទោះបីជាបែបនេះក៏ដោយ មានគ្រួសារតាមផ្ទះតែ ៣១% ប៉ុណ្ណោះ លើកឡើងថា ការទទួលបានអាហារបានថមថយជាងមុន ចាប់តាំងពីពេលដែលពួកគេផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ហើយសម្រាប់គ្រួសារ ២៣% ស្ថានភាពបានល្អប្រសើរជាងមុន។ អាហារូបត្ថម្ភទំនងជាបញ្ហាធំមួយសម្រាប់គ្រួសារតាមផ្ទះដែលតាំងនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ជាពិសេស សម្រាប់កុមារដែល

ខ្វះអាហារដែលមានសារជាតិប្រូតេអ៊ីន និងនៅកន្លែងដែលគ្រួសារមិនអាចកាប់ឆ្ការដីធ្វើកសិកម្មបាន។

**ការងារ៖**

គ្រួសារតាមផ្ទះដែលត្រូវបានសាកសួរស្ទើរតែទាំងអស់ (៩៨%) មានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់មានការងារធ្វើ ហើយគ្រួសារតាមផ្ទះ ៧៥% មានមនុស្សចាប់ពី ២ នាក់ឡើងទៅ មានការងារធ្វើ ដោយខ្នងផ្ទះខ្លះមានមនុស្សរហូតដល់ ៥ នាក់ មានការងារធ្វើ។ ជាការឆ្លើយតបចំពោះសំណួរដែលសួរថា តើការងារប្រភេទណាខ្លះដែលពួកគេធ្វើ ៣៣% ស៊ីឈ្នួលធ្វើកសិកម្មឲ្យគេ ៦៣% ធ្វើការងារប្រភេទប្រើប្រាស់កម្លាំងពលកម្មផ្សេងទៀត ហើយ ២២% មានមុខរបរខ្លួនឯង។ ចំណូលមធ្យមប្រចាំខែរបស់គ្រួសារគឺ ១៦៧ ដុល្លារ ក្នុងមួយខែ។ ចំណូលភាគច្រើនបានពីការងារស៊ីឈ្នួលគេ/ការងាររោងចក្រ និងបានពីមុខរបរខ្លួនឯង ដូចជា ការលក់ផលិតផលផ្ទាល់ ជាដើម។ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ចំណូលមធ្យមប្រចាំខែរបស់អ្នកឆ្លើយតបគឺទាបជាងនេះបន្តិចពោលគឺ ១៦៤ ដុល្លារ ក្នុងមួយខ្នងផ្ទះ។ ចំណាយមធ្យមសម្រាប់គ្រួសារ បច្ចុប្បន្ននេះគឺ ១៩០ ដុល្លារ ក្នុងមួយខែ កើនឡើងពី ១៥៨ ដុល្លារ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ចំណាយខ្ពស់ជាងគេ គឺលើអាហារ និងការថែទាំសុខភាព។ ចំណាយលើការរៀបចំ "ពិធីសាសនា" ក៏ខ្ពស់ផងដែរ។ ចំណូលមធ្យមប្រចាំខែមានការកើនឡើង ប៉ុន្តែមិនខ្លាំងដូចចំណាយគ្រួសារប្រចាំថ្ងៃឡើយ ដែលបច្ចុប្បន្ននេះ គិតជាមធ្យមខ្ពស់ជាងចំណូលប្រចាំខែ។

គ្រួសារតិចជាងមួយភាគប្រាំមានប្រាក់សន្សំសម្រាប់គ្រួសារ (១៧%) បើទោះបីជាជាមធ្យម ប្រាក់សន្សំនេះមានការកើនឡើង ចាប់តាំងពីផ្លាស់មករស់នៅទីតាំងសម្បទានដីសង្គមកិច្ចនេះក៏ដោយ ហើយបច្ចុប្បន្នេះ តួលេខមធ្យមគឺ ២៥៣ ដុល្លារ។ គ្រួសារ ៨២% ជាប់ជំពាក់បំណុលគេ ហើយបំណុលនេះមានការកើនឡើងខ្លាំង។ ជាមធ្យម គ្រួសារតាមផ្ទះជំពាក់បំណុលគេ ១៣៨៦ ដុល្លារ ដែលកើនឡើងពីត្រឹមតែ ២០ ដុល្លារ មុនពេលផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ។ នេះមានន័យថា គ្រួសារតាមផ្ទះ ត្រូវខ្ចីបុលគេយ៉ាងច្រើន

នៅពេលផ្លាស់ ឬក្រោយពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ការឆ្លើយតប ចំពោះការអង្កេតបង្ហាញថា ប្រាក់សន្សំរបស់គ្រួសារមានការកើនឡើង បើទោះបីជា ចំណាយមធ្យមប្រចាំខែគិតជាមធ្យមលើសពីចំណូលក៏ដោយ។ ចំណុចនេះអាចជាផល វិបាកនៃការប្រែប្រួលចំណូលតាមរដូវដែលអ្នកឆ្លើយតបមិនបានយកមកគិតបញ្ចូល ឬ បំណុលរបស់គ្រួសារត្រូវបានប្រើប្រាស់ ដើម្បីរ៉ាប់រងចំណាយប្រចាំខែដែលកើតឡើងជា បន្តបន្ទាប់ ដូចជា ថ្លៃចំណាយលើការថែទាំសុខភាពជាដើម។

ជាសូចនាករបង្ហាញពីទ្រព្យធន មានគ្រួសារ ២២% មានទូរទស្សន៍ជាកម្មសិទ្ធិ បើ ទោះបីជា ៨៤% មានម៉ូតូជាកម្មសិទ្ធិក៏ដោយ។ ៩៥% មានទូរស័ព្ទដៃជាកម្មសិទ្ធិ។

មានតែខ្នងផ្ទះប្រមាណជាពាក់កណ្តាល (៥៣%) ប៉ុណ្ណោះ ដែលសមាជិកគ្រួសារ ទាំងអស់រស់នៅជុំគ្នាលើទីតាំងសម្បទានដីសង្គមកិច្ចនេះជាអចិន្ត្រៃយ៍។ សមាជិកគ្រួសារ ភាគច្រើនដែលរស់នៅឆ្ងាយពីទីតាំងនេះ គឺកូនរបស់អ្នកឆ្លើយតបចំពោះការសម្ភាសនេះ ដែលបង្ហាញថាក្មេងៗជំនាន់ក្រោយភាគច្រើនធ្វើចំណាកស្រុកឆ្ងាយពីផ្ទះដែលគ្រួសាររបស់ ពួកគេរស់នៅដើម្បីរកការងារធ្វើ (ឧទាហរណ៍ ៩២% នៃកូនទី ១ និង ៨៩% នៃកូនទី ២ ដែល មិនរស់នៅជាអចិន្ត្រៃយ៍នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ បានចាកចេញដើម្បីទៅរក ការងារធ្វើជាដើម)។

**រចនាសម្ព័ន្ធផ្នែកសង្គម៖**

ក្នុងចំណោមខ្នងផ្ទះដែលបានសាកសួរទាំងអស់ មានតែ ២៣% ប៉ុណ្ណោះ ដែលជឿ ថា <u>ការសម្រេចចិត្តចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចនេះ</u> ធ្វើឡើង តាមរយៈដំណើរ ការប្រជាធិបតេយ្យ ដោយ ៧០% លើកឡើងថា មេភូមិគឺជាអ្នកសម្រេចចិត្ត។ អាជ្ញាធរ មូលដ្ឋានលើកឡើងថា ការសម្រេចចិត្តធ្វើឡើងជាសមូហភាព ក្រោយពីមានកិច្ចពិគ្រោះ យោបល់កម្រិតភូមិរួច។

អ្នកឆ្លើយតប ៨៦% លើកឡើងថា ពួកគេមានអារម្មណ៍តានតឹង (ស្រ្តេស) ដោយ ៥១% លើកឡើងថា នេះជាបញ្ហាស្រួចស្រាវខ្លាំង។ បញ្ហានេះកើតឡើងដោយសារការខ្វះខាតអាហារ ចំណូលថយចុះ និងកត្តាផ្សេងទៀត។

អ្នកឆ្លើយតបស្ទើរតែទាំងអស់ (៩៣%) លើកឡើងថា ពួកគេ*បានដឹង* ថាមានការរំលោភបំពានដោយសារគ្រឿងស្រវឹង កំពុងកើតឡើងក្នុងសហគមន៍នេះ និង ១០% ទៀតជឿថា មានបញ្ហាគ្រឿងញៀនក្នុងតំបន់សម្បទានដីសង្គមកិច្ចនេះ។ គ្រួសារតាមផ្ទះ ២៦% លើកឡើងថា ពួកគេកំពុងធ្វើការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលជាអ្នកផ្តល់ការគាំទ្រ (៥៧% លើកពីឈ្មោះអង្គការជីវិតថ្លៃថ្នូរ និង ៤០% ទៀត មិនចាំថាអង្គការមិនមែនរដ្ឋាភិបាលណាមួយឡើយ)។ គ្រួសារតាមផ្ទះដែល ត្រូវបានអង្កេត ៤៦% គិតថា ក្នុងសហគមន៍នេះ មានបទល្មើសឧក្រិដ្ឋកើតឡើងច្រើន បើធៀបជាមួយនឹងស្ថានភាពមុនពេលដែលពួកគេ ផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ។ អ្នកឆ្លើយតប ៦២% លើកឡើងថាបានដឹងពីករណីអំពើហិង្សាលើស្រ្តី ឬក្មេងស្រី ហើយ ៣៧% ជឿថា ជាក់ស្តែងហិង្សាផ្លូវភេទ មានអត្រាកើតឡើងច្រើនជាងក្នុងសហគមន៍មុនៗរបស់ពួកគេ។ ការរកឃើញទាំងនេះ មិនផ្តល់នូវការគណនាច្បាស់លាស់នៃអត្រាទូទៅនៃហិង្សាផ្លូវភេទ ឬការរំលោភបំពានដោយសារគ្រឿងស្រវឹងនោះទេ។ ការរកឃើញទាំងនេះ ជាការឆ្លុះបញ្ចាំងពីគំនិតយោបល់របស់សហគមន៍តែប៉ុណ្ណោះ ហើយ គេត្រូវតែអានយល់ដូចនេះ ជាមួយការយល់ដឹងថា ក្រុមអង្កេតនេះ មិនបានសួរដោយផ្ទាល់ទេ ឧទាហរណ៍៖ ថាតើ ការរំលោភបំពានកើតឡើយដោយគ្រឿងស្រវឹងជាបញ្ហាមួយនៅក្នុងខ្ទងផ្ទះមួយឬទេ។

អ្នកឆ្លើយតប ៨៩% លើកឡើងថា ពួកគេដឹងពីករណីកុមារធ្វើការងារ ដើម្បីរកចំណូលបន្ថែមឲ្យគ្រួសារ។ ការងារភាគច្រើនដែលកុមារធ្វើ គឺការងារកសិកម្ម (៤៦%) និងប្រភេទការងារប្រើកម្លាំងពលកម្មផ្សេងទៀត (៧០%)។ គ្រួសារតាមផ្ទះ ៦% បញ្ជូនសមាជិកគ្រួសារជាកុមារទៅធ្វើការងារតាមរោងចក្រ។ នេះគឺជាតួលេខមធ្យមខ្ពស់ជាងគេក្នុងចំណោមទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់។ ចំណូលទាបរបស់គ្រួសារមានផលប៉ះ

ពាល់អវិជ្ជមានយ៉ាងខ្លាំងមកលើជីវិតរស់នៅរបស់កុមារ ការទទួលបានការអប់រំ និងសុខុមាលភាពទូទៅរបស់ពួកគេ។<u>នេះជាបញ្ហាដែលចាំបាច់ត្រូវមានការឆ្លើយតបជាបន្ទាន់</u>។

ប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ២៩% ដោយចោទថា ពួកគេ *មិន* ត្រូវ<u>បានគេចុះឈ្មោះបោះឆ្នោតឲ្យឡើយ</u>។ តួលេខនេះជាតួលេខដែលមានជាប់ទាក់ទងគ្នាខ្ពស់ ដោយហេតុថា គ្រួសារតាមផ្ទះជាមធ្យម បានមកតាំងនៅទីនោះ អស់រយៈពេលជាង១០ឆ្នាំ ហើយការបោះឆ្នោតឃុំសង្កាត់កៀកនឹងមកដល់ក្នុងឆ្នាំ ២០១៧ នេះ។

គ្រួសារតាមផ្ទះ ២១% នៅមិនទាន់មានឯកសារស្នាក់នៅ ដែលផ្តល់ដោយអាជ្ញាធរមូលដ្ឋាន ហើយក្នុងខ្នងផ្ទះ១៦% យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ ដែលពុំមានសំបុត្រកំណើត ហើយក្នុងខ្នងផ្ទះ៤៦% មានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់ ដែលពុំមានអត្តសញ្ញាណប័ណ្ណ។ គ្រួសារ ២៧% ពុំមានសៀវភៅគ្រួសារ។

ប្រជាពលរដ្ឋ ៣៤ គ្រួសារ (ស្មើនឹង ១៤%) បាននិយាយថា ពួកគេ<u>ពិចារណាចាកចេញពីទីតាំងសម្បទានដីសង្គមកិច្ចនេះ</u> ដោយមូលហេតុបញ្ហាកង្វះទឹក អាហារ និងបញ្ហាប្រឈមផ្សេងៗទៀតក្នុងតំបន់នេះ តែនេះជាតួលេខមួយដ៏ទាប និងប្រហែលអាចជាការបង្ហាញឲ្យឃើញថា ជម្រើសផ្សេងល្អជាងនេះគឺពិបាកនឹងរក។ សំណូមពរជុំវិញការលើកកម្ពស់កម្រិតជីវភាពរស់នៅ នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ (៦៤%) ការទទួលបានទឹកស្អាត (៤៦%) ការផ្គត់ផ្គង់អគ្គិសនី (១៦%) ការកែលំអប្រព័ន្ធធារាសាស្ត្រក្នុងមូលដ្ឋាន (៥០%) និងការសង់បង្គន់បន្ថែម និងការកែលំអអនាម័យជាដើម លើសពីនេះ ក៏មានការលើកឡើងនូវសំណូមពរទាក់ទងនឹងបញ្ហាជាច្រើនផ្សេងទៀតផងដែរ ដូចជា ការផ្តល់ឲ្យបានល្អប្រសើរជាងមុននូវអាហារ គ្រាប់ពូជ និងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដែលនេះបង្ហាញយ៉ាងច្បាស់ពីបំណងចង់បានទិន្នផលពីការដាំដុះច្រើនជាងមុន ចំណូលរគ្រួសារនិងសន្តិសុខស្បៀងជាងមុន ដែលត្រូវបានចាត់ទុកថាជាអាទិភាពសម្រាប់គ្រួសារជាច្រើន។

## ឧបសម្ព័ន្ធទី ៣៖ ទិន្នន័យអង្កេតពីសម្បទានដីសង្គមកិច្ចក្នុងភូមិស្រែឈើ សែនជ័យ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

*របកគំហើញសំខាន់ៗ*

- *បើទោះបីជាមានការផ្តល់ការគាំទ្របន្ថែមពីដៃគូអភិវឌ្ឍន៍ តាមរយៈកម្មវិធី LASED ក៏ដោយ ក៏កម្មវិធីសម្បទានដីសង្គមកិច្ចនេះខ្វះកន្លែងផ្តល់សេវាជាមូលដ្ឋាន ស្ថានភាពនៃការរស់នៅមិនល្អ ហើយគ្រួសារទទួលដីបន្តជួបប្រទះនឹងបញ្ហាជាច្រើន ដូចជា កង្វះការទទួលបានទឹកស្អាត បញ្ហាអសន្តិសុខស្បៀង គ្មានអគ្គិសនីប្រើប្រាស់ និងឱកាសរកចំណូលបានតិចតួច។*
- *ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ត្រូវបានលើកឡើងថាបានធ្វើឡើងក្នុងឆ្នាំ ២០១១/១២ ពោលគឺ ៣ ឆ្នាំ ក្រោយពេលដែលគ្រួសារទទួលផលផ្លាស់មករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។*
- *គ្រួសារទាំងអស់ដែលបានសាកសួរសម្រាប់ការអង្កេតនេះ បានទទួលប័ណ្ណកម្មសិទ្ធិដី។*
- *ចំណូល ប្រចាំឆ្នាំជាមធ្យមដែលបានពីការធ្វើកសិកម្ម គឺលើសពីមធ្យម។ ប៉ុន្តែ បំណុលគ្រួសារក៏មានកម្រិតខ្ពស់ផងដែរ ដោយជាមធ្យមមានចំនួន ១.០៧២ ដុល្លារ ក្នុងមួយគ្រួសារ។*
- *ការកំណត់ និងការរៀបចំផែនការនៅទីតាំងសម្បទានដីសង្គមកិច្ចហាក់បីដូចជាបានធ្វើឡើង ស្របទៅតាមអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ហើយគ្រួសារទទួលផលភាគច្រើនលើសលុប ជឿថា ដំណើរការបែងចែកដីធ្វើឡើងប្រកបដោយយុត្តិធម៌។ ប៉ុន្តែតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ លើកឡើងថា ដំណើរការដាក់ពាក្យសុំដីមានពាក់ព័ន្ធនឹងអំពើពុករលួយ ហើយគ្រួសារដែលមានក្បាលដីផ្សេងទៀតរួចទៅហើយនោះ ត្រូវបានជ្រើសរើសជាអ្នក ទទួលផលដែរ។*
- *គ្រួសារ ៨៦% លើកឡើងថា កន្លែងរស់នៅថ្មីរបស់ពួកគេមានស្ថានភាពល្អប្រសើរជាងផ្ទះមុនរបស់ពួកគេ ប៉ុន្តែគ្រួសារទទួលផលទាំងអស់ត្រូវសង់ផ្ទះដោយខ្លួនឯង។ កម្មវិធី*

*សម្បទានដីសង្គមកិច្ចបានរួមចំណែកលើកកម្ពស់ស្ថានភាពលំនៅឋាន តាមរយៈការផ្តល់ដី និងការគាំទ្រផ្សេងទៀតពីដៃគូអភិវឌ្ឍន៍។*

- *ប៉ុន្តែ ជម្លោះដីធ្លីនៅតែមិនអាចដោះស្រាយបាន ហើយមានមួយករណីដែលគ្រួសារក្រីក្រមួយត្រូវបាត់បង់ដីកសិកម្ម ៤,៥ ហិកតា នៅពេលមានការបែងចែកក្បាលដីសម្បទានដីសង្គមកិច្ច និងនៅតែមិនទាន់បានទទួលយុត្តិធម៌ដដែល។*

ការសម្ភាសត្រូវបានធ្វើឡើងជាមួយនឹង ១១០គ្រួសារតាមផ្ទះ នៅទីតាំងសម្បទានដីសង្គមកិច្ចខេត្តត្បូងឃ្មុំនេះ។ ទីតាំងសម្បទានដីសង្គមកិច្ចនេះត្រូវបានចុះបញ្ជី កាលពីខែកក្កដា ឆ្នាំ ២០០៧ និងគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណជា ៨៦៣,៦៥ ហិកតា ហើយការបែងចែកដី (ដោយប្រើប្រព័ន្ធចាប់ឆ្នោត) ត្រូវបានធ្វើឡើង ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៩។ អ្នកទទួលផលត្រូវបានជ្រើសរើសចេញពីភូមិចំនួន ១៧ ក្នុងឃុំជាំក្រវៀន។ មន្ត្រីមូលដ្ឋានផ្តល់ចម្លើយផ្សេងៗគ្នាពីចំនួនសរុបនៃគ្រួសារទទួលផល (២៥០ ឬ ២៨៥ គ្រួសារ) និងពីចំនួនមនុស្សសរុប (១២៩៧ នាក់ ឬ ១៣៩៤ នាក់) ដែលរស់នៅលើទីតាំងនេះ (ដំបូងឡើយ ទីតាំងនេះត្រូវបានរៀបចំសម្រាប់ប្រជាពលរដ្ឋចំនួន ២៥០ គ្រួសារ និងបានកើន ចំនួនជាបន្តបន្ទាប់)។ មន្ត្រីទាំងនេះក៏ផ្តល់ចម្លើយខុសៗគ្នាផងដែរ នៅពេលដែលសួរថាតើកម្មវិធីសម្បទានដីសង្គមកិច្ចនេះត្រូវបានចេញនៅថ្នាក់ជាតិ ឬថ្នាក់ឃុំ ថាតើដីនេះដំបូងឡើយជាដីសាធារណៈ ឬដីឯកជនរបស់រដ្ឋ និងថាតើដីនេះបានចុះបញ្ជីជាដីសម្បទានសង្គមកិច្ចនៅថ្ងៃខែឆ្នាំណា ដែលនេះជាការបង្ហាញពីការដឹងតិចតួចពីដំណើរការរបស់កម្មវិធីសម្បទានដីសង្គមកិច្ច និងលទ្ធផលនៃកម្មវិធីនេះ។

ទីតាំងនេះគឺជាផ្នែកមួយនៃកម្មវិធី LASED ដែលទទួលបានការឧបត្ថម្ភថវិកាពីអ្នកផ្តល់ជំនួយ។ ការអនុវត្តសម្បទានដីសង្គមកិច្ច ក្រោមកម្មវិធីនេះ បានទទួលការគាំទ្របន្ថែមជាច្រើនពីអ្នកផ្តល់ជំនួយ ដូចជា GIZ ជាដើម ដែលផ្តល់ជំនួយ និងការគាំទ្រដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរបច្ចេកទេសពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំ/សង្កាត់ សម្រាប់ការអនុវត្តបច្ចេកទេស ក្នុងវិស័យនៃការកំណត់អត្តសញ្ញាណ

ដី ការជ្រើសរើសអ្នកទទួលដី និងការអភិវឌ្ឍជនបទដែលមានលក្ខណៈសមាហរណ៍កម្ម[77] ហើយនិងអ្នកផ្តល់ជំនួយមួយទៀតគឺធនាគារពិភពលោក ដែលបានផ្តល់ថវិកាគាំទ្រដល់ (ក) ការរៀបចំផែនការ សម្បទានដីសង្គមកិច្ចថ្នាក់ឃុំ និងការបែងចែកដី (ខ) សេវា និងការវិនិយោគលើការអភិវឌ្ឍជនបទ (គ) ការអភិវឌ្ឍកម្មវិធីប្រកបដោយចីរភាព និងតម្លាភាព និង (ឃ) ការគ្រប់គ្រងគម្រោង។[78] អ្នកឆ្លើយតប ៧៦% គឺជាស្ត្រី បើទោះបីជាមានអ្នកឆ្លើយតបត្រឹមតែ ៣៥% ប៉ុណ្ណោះ ដែលបានប្រកាសថាមេគ្រួសារជាស្ត្រី។ ៨៥% លើកឡើងថា ពួកគេរៀបការរួច ឬកំពុងរស់នៅជាមួយអ្នកដែលពួកគេមានទំនាក់ទំនងជាមួយ។ ១៥% គឺជាស្ត្រីមេម៉ាយ/បុរសពោះម៉ាយ ឬលែងលះ។ <u>អាយុមធ្យម</u>របស់អ្នកឆ្លើយតបគឺ ៤៦ ឆ្នាំ។ គ្រួសារតាមផ្ទះដែលតាំងនៅលើដីសម្បទានសង្គមកិច្ចនេះ មានចំនួន សមាជិកជាមធ្យម ៥,០១ នាក់នៅក្នុងផ្ទះ និងជាមធ្យមមានកូន ២,៣ នាក់ កំពុងរស់នៅក្នុងផ្ទះ (មិនមែនសមាជិកគ្រួសារទាំងអស់សុទ្ធតែរស់នៅទីតាំងនេះជាអចិន្ត្រៃយ៍នោះទេ ដូចបញ្ជាក់ខាងក្រោម)។ អ្នកឆ្លើយតបទាំងអស់លើកឡើងថា ពួកគេជា<u>ជនជាតិខ្មែរ</u>។

<u>រយៈពេលនៃការរស់នៅជាមធ្យមលើដីសម្បទានសង្គមកិច្ចនេះ</u>គឺ ៧២ ខែ - មានន័យថា ប្រជាពលរដ្ឋដែលរស់នៅលើដីនេះគួរតែបានទទួលប័ណ្ណកម្មសិទ្ធិ (រយៈពេល ៦០ ខែ គឺជារយៈពេលតម្រូវ ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីផ្លូវការ ដូចដែលត្រូវបានចែងក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច)។ ប្រជាពលរដ្ឋគ្រប់គ្រួសារទាំងអស់ ដែលបានសម្ភាសសម្រាប់ការអង្កេតនេះ <u>បានទទួលប័ណ្ណកម្មសិទ្ធិដី</u> ប៉ុន្តែវាមិនច្បាស់ទេថាតើការផ្តល់ប័ណ្ណកម្មសិទ្ធិនេះធ្វើឡើងក្រោយពេលចប់រយៈពេល ៦០ ខែនោះ។ ប្រជាពលរដ្ឋពាក់កណ្តាលក៏បានទទួលឯកសារបន្ថែម ពាក់ព័ន្ធនឹងភោគៈ ឬកម្មសិទ្ធិ (កិច្ចសន្យា ឯកសារចាប់ឆ្នោត ឬឯកសាររបស់អង្គការមិនមែនរដ្ឋាភិបាល) ផងដែរ។

---

[77] មេរៀនដែលជាបទពិសោធន៍។ បទពិសោធន៍ពីការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចក្នុងប្រទេសកម្ពុជា។ GIZ. Iris Richter ខែមករា ឆ្នាំ ២០១៦.

[78] ធនាគារពិភពលោក ឆ្នាំ២០១៥ ប្រទេសកម្ពុជា-កម្មវិធីបែងចែកដីធ្លីដើម្បីសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ច។ វ៉ាស៊ីនតោន ឌីស៊ី៖ ក្រុមធនាគារពិភពលោក

នៅពេលសាកសួរពីមូលហេតុដែលពួកគេបានទទួលដីនៅទីតាំងសម្បទានដីសង្គមកិច្ច អ្នកឆ្លើយតប ៧២% បានឆ្លើយថា ដោយសារតែពួកគេគ្មានដី ហើយ ៨៩% ឆ្លើយថាដោយសារតែពួកគេមានជីវភាពក្រីក្រ។ មានប្រជាពលរដ្ឋតែមួយគ្រួសារប៉ុណ្ណោះ ដែលអះអាងថា ត្រូវផ្លាស់មកទីនេះ ដោយសារតែគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ អ្នកឆ្លើយតប ១១% បានលើកឡើងថា ពួកគេបានផ្លាស់មកទីនេះ ដោយសារតែឱកាសការងារក្នុងចំការសម្បទានដីសេដ្ឋកិច្ច។ មានចំណុចត្រួតគ្នានៅទីនេះ ដោយអ្នកឆ្លើយតបផ្តល់ចម្លើយច្រើនយ៉ាង ដែលបង្ហាញពីហេតុផលដែលនាំឲ្យពួកគេទទួលបានដី។ នៅពេលសាកសួរពីមូលហេតុ ដែលគ្រួសារផ្សេងទៀតនៅទីតាំងសម្បទាន ដីសង្គមកិច្ចនេះបានទទួលដី ចម្លើយគឺត្រូវគ្នាជាមួយនឹងចម្លើយខាងលើដែរគឺ ការគ្មានដី និងភាពក្រីក្រ។ ឱកាសការងារអាចមិនមែនជាកត្តាជម្រុញតែមួយគត់ ដែលនាំឲ្យប្រជាពលរដ្ឋសម្រេចចិត្តដាក់ពាក្យសុំដីសម្បទានដីសង្គមកិច្ចនោះទេ ប៉ុន្តែអាចជាកត្តារួមចំណែកច្រើនដែរ។ ដរាបណាការវាយតម្លៃលើការបំពេញតាមលក្ខណៈសម្បត្តិសមស្របធ្វើឡើងដោយយុត្តិធម៌ និងតម្លាភាព ហើយការបែងចែកដីធ្វើឡើងដោយសមធម៌ ការមានកត្តាលើកទឹកចិត្តច្រើនយ៉ាងដែលនាំឲ្យប្រជាពលរដ្ឋផ្លាស់មករស់នៅទីនេះ មិនគួរជាបញ្ហាចោទនោះទេ។ ការដឹងពីឱកាសការងារស្របច្បាប់ គឺជាចំណុចសំខាន់ ប៉ុន្តែគ្រួសារដែលផ្លាស់មកនៅទីនេះដែលខកខានមិនអាចរកការងារបាន អាចត្រូវបានរុញច្រានឲ្យធ្លាក់ចូលទៅក្នុងភាពក្រីក្របន្ថែមទៀត។

គ្រួសារភាគច្រើន (៥៨%) មានប័ណ្ណសម្គាល់គ្រួសារក្រីក្រ (តាមរយៈកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ)។ អ្នកទទួលដីសម្បទានសង្គមកិច្ចទាំងអស់ ដែលបានបែងចែកដីឲ្យ ក្រោយអនុក្រឹត្យឆ្នាំ២០១១ ស្តីពី អត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ក្រៅពីយោធិនរំសាយ) គួរទទួលបានប័ណ្ណសម្គាល់គ្រួសារក្រីក្រតាំងពីដំបូង ដោយសារតែប័ណ្ណនេះគឺជាមធ្យោបាយចម្បង សម្រាប់វាយតម្លៃកម្រិតនៃភាពក្រីក្រ និងកំណត់អត្តសញ្ញាណអ្នកសុំដី

និងអ្នកទទួលបានដីដែលបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្រប។[79] កង្វះប័ណ្ណគ្រួសារក្រីក្រសម្រាប់គ្រួសារសេសសល់ ៤២% ទៀត អាចដោយសារតែពួកគេលែងរស់នៅក្នុងភាពក្រីក្រ ឬមានការប្រើប្រាស់មធ្យោបាយផ្សេងទៀត ដើម្បីវាយតម្លៃកម្រិតនៃភាពក្រីក្រនៅពេលដែលសម្បទានដីសង្គមកិច្ចនេះត្រូវបានបង្កើតឡើង។ អាជ្ញាធរមូលដ្ឋានបានលើកឡើងថា ប្រជាពលរដ្ឋមកពីស្រុកមេមត់ត្រូវបានឲ្យអាទិភាព ក្នុងដំណើរការដាក់ពាក្យសុំដីនេះ ហើយប័ណ្ណសម្គាល់គ្រួសារក្រីក្រ គឺជាមធ្យោបាយចម្បង សម្រាប់ធ្វើការវាយតម្លៃ រួមគ្នាជាមួយនឹងសៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ។ មន្ត្រីមូលដ្ឋានម្នាក់ ដែលត្រូវបានសម្ភាស បានលើកឡើងថា <u>លក្ខណៈវិនិច្ឆ័យកំណត់ពីភាពសមស្របរបស់អ្នកសុំដីមិនត្រូវបានតាំងបង្ហាញជាសាធារណៈ</u> មុនដំណើរការនៃការដាក់ពាក្យសុំដីនេះឡើយ។ ការបង្កើនការយល់ដឹង និងការជូនដំណឹងជាសាធារណៈអំពីដំណើរការ និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស គឺមានសារៈសំខាន់សម្រាប់ធានាភាពអាចជឿជាក់បាននៃដំណើរការនេះ និងធានាឲ្យមានតម្លាភាពសមស្រប ក្នុងដំណើរការទាំងមូល។ កង្វះខាតនៃការជូនដំណឹងជាសាធារណៈអាចធ្វើឲ្យគ្រួសារមួយចំនួន ដែលពុំបានដឹងពីដំណើរការ ឬ លក្ខណៈវិនិច្ឆ័យនេះបាត់បង់អត្ថប្រយោជន៍ ហើយដែលអាចធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃកម្មវិធីសម្បទានដីសង្គមកិច្ច។

គ្រួសារភាគច្រើនលើសលុប (៩៣%) បានអះអាងថាបានចូលរួមក្នុង<u>ការកំណត់ និងការរៀបចំផែនការនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ</u> ដោយប្រជាពលរដ្ឋដែលរស់នៅលើដីនេះ ៩៦% បានលើកឡើងថា អាជ្ញាធរមូលដ្ឋានបានពន្យល់ពីមូលហេតុដែលពួកគេត្រូវបានជ្រើសរើសជាអ្នកទទួលផល។ ប្រជាពលរដ្ឋក្នុងភាគរយប្រហាក់ប្រហែលនេះដែរ (៩២%) បានលើកឡើងថា អាជ្ញាធរបានពន្យល់ពីដំណើរការជ្រើសរើស និងបែងចែកដី និង

[79] មាត្រា ១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣) ចែងថា អ្នកសុំដីសម្បទានសង្គមកិច្ចគួរបំពេញលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុ ដែលកំណត់ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយផ្អែកលើយោបល់របស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ។ គោលការណ៍ណែនាំអំពីការវាយតម្លៃប្រាក់ចំណូលត្រូវពិចារណាដោយផ្អែកលើទំហំគ្រួសារ និងលក្ខខណ្ឌ អាយុ និងសុខភាពនៃសមាជិកគ្រួសារ។ គោលការណ៍ណែនាំនេះអាចប្រែប្រួលទៅតាមតំបន់ ទៅតាមពេលវេលា ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច និងជីវភាពរស់នៅ។

ពីការប្រើប្រាស់ប្រព័ន្ធចាប់ឆ្នោតដើម្បីបែងចែកដី។ អ្នកឆ្លើយតបទាំងអស់ បានទទួលឯកសារពាក់ព័ន្ធនឹងការបែងចែកដីក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះ និងមានអ្នកឆ្លើយតប ៨១% ប៉ុណ្ណោះ ដែលបានលើកឡើងថា ពួកគេបានចូលរួមយ៉ាងសកម្ម ក្នុងការជ្រើសរើសក្បាលដី។ លើសពីនេះ មានគ្រួសារ ៨៥% បានចុះកិច្ចព្រមព្រៀងជាមួយនឹងអាជ្ញាធរទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ចចំពោះសម្បទានដីសង្គមកិច្ចនេះ។

នេះបង្ហាញពីការចូលរួមសហការក្នុងកម្រិតមួយខ្ពស់ពីសំណាក់អាជ្ញាធរមូលដ្ឋានជាមួយនឹងសហគមន៍អ្នកទទួលផល ក្នុងការរៀបចំផែនការ និងការអភិវឌ្ឍទីតាំងនេះពីដំបូង។ តួលេខប្រជាពលរដ្ឋប្រហាក់ប្រហែលនេះដែរ ពោលគឺ ៩៦% ជឿថា ដំណើរការបានអនុវត្តបែងចែកដីធ្វើឡើងប្រកបដោយយុត្តិធម៌។ តួលេខនេះគឺខ្ពស់ជាងតួលេខមធ្យម ៦៧% សម្រាប់គ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ដែលត្រូវបានអង្កេត។ អ្នកឆ្លើយតបម្នាក់បានលើកឡើងថា គាត់បានបង់លុយ ដើម្បីចូលរួមក្នុងដំណើរការបែងចែកដី និងបានអះអាងថាបានបង់លុយ ១ លានរៀល (ប្រមាណជា ២៥០ ដុល្លារ)។

តំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកម្នាក់បានលើកឡើងថា ដំណើរការដាក់ពាក្យស្នើសុំដីជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ហើយគ្រួសារវណ្ណៈកណ្តាល ដែលមានដីផ្សេងទៀតទៅហើយនោះ ត្រូវបានជ្រើសរើសជាអ្នកទទួលផលពីសម្បទានដីសង្គមកិច្ច។ ពួកគេ បានចោទប្រកាន់ថា អ្នកទទួលផលទាំងនេះបានផ្តល់ប្រាក់ដល់អាជ្ញាធរមូលដ្ឋាន។ អ្នកទទួលផលដែលបានបង់ប្រាក់ ហើយបែរជាត្រូវបានចាត់ទុកថាពុំបានបំពេញតាមលក្ខណៈសមស្របទៅវិញ មិនទំនងជាលើកឡើងពីការបង់ប្រាក់ ឬការបែងចែកដីដោយមិនមានសមធម៌ ក្នុងការឆ្លើយតបចំពោះការអង្កេតនេះឡើយ។ តំណាងអង្គការមិនមែនរដ្ឋាភិបាលរូបនេះបានលើកឡើងថា ដំណើរការជ្រើសរើសអ្នកទទួលផលក៏ពុំមានយុត្តិធម៌ដែរ ហើយការបែងចែកដីនោះ មានពាក់ព័ន្ធនឹងអំពើពុករលួយ ដោយអ្នកដែលមិនចង់បង់លុយ ឬពុំមានលទ្ធភាពបង់លុយឲ្យអាជ្ញាធរមូលដ្ឋាន បានទទួលក្បាលដី ដែលមានដីជាតិតិចបំផុត និងនៅឆ្ងាយបំផុតពីទីកន្លែងផ្តល់សេវា និងហេដ្ឋារចនាសម្ព័ន្ធនានា។

អ្នកឆ្លើយតប ៨៦% បានទទួលផែនការសម្បទានដីសង្គមកិច្ច។ ក្រុមប្រឹក្សាឃុំ គួរផ្តួចផ្តើមរៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របទៅតាមលក្ខខណ្ឌ ដូចដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។ អ្នកទទួលដីសម្បទានសង្គមកិច្ច "ត្រូវតែបានត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ស្របតាមផែនការសម្បទានដីសង្គមកិច្ចដែលបានយល់ព្រម។"[80] អ្នកឆ្លើយតបភាគច្រើន (៧២%) បានអះអាងថា ត្រូវបានស្នើឲ្យចូលរួមកែលំអយ៉ាងសកម្មលើលក្ខខណ្ឌនៅលើដីសម្បទានសង្គមកិច្ចនេះ។ នេះបង្ហាញពីកម្រិតខ្ពស់នៃការរៀបចំផែនការ និងការជម្រុញឲ្យសហគមន៍ចូលរួមយ៉ាងសកម្មពីសំណាក់ អាជ្ញាធរមូលដ្ឋានក្នុងការអភិវឌ្ឍបន្ថែមលើទីតាំងនេះ។

អាជ្ញាធរមូលដ្ឋាន បានលើកឡើងថា ពួកគេបានរៀបចំកិច្ចពិគ្រោះយោបល់ជាមួយនឹងសហគមន៍ក្នុងតំបន់ជុំវិញ ប៉ុន្តែទីតាំងសម្បទានដីសង្គមកិច្ចនេះពុំមានប្រជាពលរដ្ឋរស់នៅឡើយមុនពេលដែលសម្បទានដីសង្គមកិច្ចនេះត្រូវបានបង្កើតឡើង។ បើទោះបីជាមានការអះអាងបែបនេះក៏ដោយ មន្ត្រីឃុំម្នាក់បានលើកឡើងថា មានប្រជាពលរដ្ឋចំនួន ៤ គ្រួសារ ត្រូវបានបណ្តេញចេញ ដោយសារតែដំណើរការបង្កើតទីតាំងសម្បទានដីសង្គមកិច្ចនេះ។ គ្រួសារទាំងនេះ ត្រូវបានចោទប្រកាន់ថាបានកាប់ឆ្ការព្រៃដោយខុសច្បាប់លើទីតាំងសម្បទានដីសង្គមកិច្ចនេះ ហើយពុំបានទទួលសំណងឡើយនៅពេលបណ្តេញចេញ។

អ្នកឆ្លើយតបស្ទើរតែទាំងអស់ (៩៨%) បានលើកឡើងថា ពួកគេបានត្អូញត្អែរប្រាប់ទៅអាជ្ញាធរពីស្ថានភាពនៃការរស់នៅលើទីតាំងនេះ។ ការត្អូញត្អែរញឹកញាប់ជាងគេ គឺពាក់ព័ន្ធនឹងកង្វះទឹកស្អាតបរិភោគ (៨៩%) កង្វះអាហារ (៦២%) ឱកាសការងារតិចតួច (១១%) គុណភាពផ្លូវ (១៨%) កង្វះអគ្គិសនី និងកង្វះអនាម័យ (១៩%)។ ប្រជាពលរដ្ឋរស់នៅទីនេះ ៦១% លើកឡើងថាអាជ្ញាធរបានឆ្លើយតបចំពោះការត្អូញត្អែររបស់ពួកគេ (នេះអាចបកស្រាយបានថាជាការបានដោះស្រាយបញ្ហា ឬគ្រាន់តែជាការទទួលដឹងឮពីបញ្ហា)។ បើទោះបីជាអត្រាឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋានក្នុងខេត្តត្បូងឃ្មុំ អាចពុំមានកម្រិតខ្ពស់ក៏

[80] មាត្រា ១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣)។

ដោយ កម្រិតនៃការឆ្លើយតបនេះគឺខ្ពស់ជាកម្រិតមធ្យមនៃទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ (៩២%)។ វាមិនច្បាស់ទេ ថាតើ ការឆ្លើយតបទាំងនេះគួរជាទីពេញចិត្ត និងថាតើអាជ្ញាធរមូលដ្ឋាន អាចបំពេញតម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានទាំងនេះ។ ព័ត៌មានដែលបានពីការអង្កេតនេះបង្ហាញថា អាជ្ញាធរបានឆ្លើយតបតាមរយៈការទទួលដឹងឮពីទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបន្តតាមដាន តាមរយៈការសហការចូលរួមជាមួយប្រជាពលរដ្ឋ។

អ្នកឆ្លើយតបស្ទើរតែទាំងអស់ (៩២%) លើកឡើងថា <u>អាជ្ញាធរមូលដ្ឋានបានពិនិត្យតាមដានលក្ខខណ្ឌក្នុងទីតាំងនេះយ៉ាងសកម្ម</u>។ អាជ្ញាធរមូលដ្ឋានបានដឹងយ៉ាងច្បាស់ពីលក្ខខណ្ឌទាំងនេះ បន្ទាប់ពី ទទួលការត្អូញត្អែររបស់ប្រជាពលរដ្ឋ និងបានចូលរួមពិនិត្យតាមដាន និងចុះផ្សព្វផ្សាយព័ត៌មានរួចមក បើទោះបីជាអាជ្ញាធរខ្វះសមត្ថភាព ឬធនធានដើម្បីឆ្លើយតបចំពោះបញ្ហាទាំងនេះក៏ដោយ។ អ្នកឆ្លើយតបបានលើកឡើងថា <u>កិច្ចប្រជុំតាមភូមិ</u> (៨៣%) គឺជាមធ្យោបាយចម្បងសម្រាប់លើកឡើងពីទុក្ខលំបាកនានា ហើយអ្នកឆ្លើយតប ៨៨% ទៀត ត្រូវបានអាជ្ញាធរមូលដ្ឋានចុះសួរសុខទុក្ខដល់ផ្ទះ ដែលបង្ហាញពីការចូលរួមកម្រិតខ្ពស់ពីសំណាក់អាជ្ញាធរមូលដ្ឋាន។

ប្រជាពលរដ្ឋ ៥៦% បានលើកឡើងថា <u>មានការវាយតម្លៃ</u>យ៉ាងហោចណាស់រៀងរាល់ខែ ហើយ ២៨% ទៀត និយាយថា ការវាយតម្លៃត្រូវបានធ្វើឡើងរៀងរាល់ ៣ ខែម្តង។ អ្នកឆ្លើយតប ១៧% លើកឡើងថា មានការវាយតម្លៃ ឬកិច្ចប្រជុំតែរៀងរាល់ឆ្នាំប៉ុណ្ណោះ។ អាជ្ញាធរ បានសួរនាំពីកម្រិតចំណូល សន្តិសុខស្បៀង ការធ្វើកសិកម្ម ការអប់រំ និងបញ្ហាផ្សេងទៀត។ នេះ បង្ហាញថាអាជ្ញាធរមានភាពសកម្ម ដែលសមនឹងទទួលបានការកោតសរសើរ ក្នុងការវាយតម្លៃលើកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ និងព្យាយាមកំណត់ពីកន្លែងដែលមានបញ្ហាកើតឡើង។ គ្រួសារភាគច្រើន (៨៩%) បាន<u>ផ្តួចផ្តើមកែលំអស្ថានភាពការរស់នៅ</u> ទីតាំងសម្បទានដីសង្គមកិច្ចនេះដោយខ្លួនឯង ដោយកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេផ្តោតលើការកែលំអផ្លូវ សាលារៀន វត្តអារាម ផ្សារ ។ល។

**ភាពសមស្របនៃដី៖**

គ្រួសារដែលត្រូវបានសាកសួរទាំងអស់ បានទទួលដីលំនៅឋានផង និងដីកសិកម្មផង។ អ្នកឆ្លើយតប ៥៦% បានលើកឡើងថា ដីសម្រាប់ធ្វើកសិកម្មជុំវិញផ្ទះរបស់ពួកគេមិនទាន់ត្រូវបាន "កាប់ឆ្ការសំអាត" និងអាចយកមកធ្វើកសិកម្មបានឡើយ នៅពេលដែលពួកគេបានទទួលដំបូង ដោយអ្នកឆ្លើយតបតែ ២% ប៉ុណ្ណោះ បាននិយាយថា ដីមួយចំនួនត្រូវបានកាប់ឆ្ការសំអាត។ បច្ចុប្បន្ននេះ គ្រួសារស្ទើរតែទាំងអស់ (៩៥%) បានសំអាតដីដែលអាចដាំដុះបានរបស់ខ្លួន។ គ្រួសារ ៤៩% ជួលគេឲ្យ កាប់ឆ្ការសំអាត។ ប្រជាពលរដ្ឋក្នុងភាគរយមួយខ្ពស់ (៣៥%) មានបំណងដាំដំណាំផ្លែស្វានៅពេលអនាគត ៣៤% ដាំបន្លែ និង ៥៦%ដាំដំឡូងមី។ ៨៧% គិតថា ពួកគេ មានបំណងដាំដំណាំចម្រុះ ដូចជា ស្វាយចន្ទី កៅស៊ូ សណ្តែក ម្រេច ខ្ញី ចេក សាវម៉ាវ ល្ហុង ដំឡូងឈើ ដើមចាន់គ្រឹស្នារ ឬអំពៅ។

ផ្ទៃដីមធ្យមសម្រាប់សង់លំនៅឋានគឺ ១០០០ ម៉ែត្រការ៉េ ជាទំហំតូចជាងក្បាលដីមធ្យម នៅតាមទីតាំងសម្បទានដីសង្គមកិច្ចដែលត្រូវបានអង្កេតនេះ (១៤២០ ម៉ែត្រការ៉េ)។ អ្នកឆ្លើយតបទាំងអស់ លើកលែងតែម្នាក់ចេញ បានលើកឡើងថា ពួកគេបានទទួលក្បាលដីក្នុងទំហំដូចអ្នកជិតខាងរបស់ខ្លួនដែរ ដែលនេះបង្ហាញពីការបែងចែកដីប្រកបដោយសមធម៌ក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះទាំងមូល។ អាជ្ញាធរមូលដ្ឋាន ដែលត្រូវបានសម្ភាស បានលើកឡើងថា ក្បាលដីសម្រាប់សង់លំនៅឋានក៏មានទំហំមធ្យម ១០០០ ម៉ែត្រការ៉េផងដែរ។ ការសម្ភាសដែលធ្វើឡើងដោយ OHCHR បង្ហាញថា ទំហំក្បាលដី ដែលត្រូវបានបែងចែកដំបូង មានទំហំទៅតាមទំហំរបស់គ្រួសារទទួលផល (១,៥ ហិកតា សម្រាប់គ្រួសារដែលមានសមាជិកពីរនាក់ ២ ហិកតា សម្រាប់គ្រួសារដែលមានសមាជិកបួននាក់ និង ២,៥ ហិកតា សម្រាប់គ្រួសារដែលមានសមាជិកចាប់ពី ៥ នាក់ឡើងទៅ)។ ប្រជាពលរដ្ឋក្នុងភាគរយដ៏គួរកត់សម្គាល់ (៤០%) បានលក់ ឬធ្វើអំណោយផ្នែកខ្លះនៃដីរបស់ពួកគេ ចាប់តាំងពីពេលដែលពួកគេបានទទួលក្បាលដីទាំងនេះមក ដែលធ្វើឲ្យទំហំដីចែកឲ្យពួកគេពីដំបូង និងទំហំដីបច្ចុប្បន្ននេះខុសគ្នា។

តំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលបានសាកសួរ បានលើកឡើងថា ការរៀបចំផែនការ ការកំណត់ ការរៀបចំផែនទី និងការធ្វើចំណាត់ថ្នាក់ដី មិនត្រូវបានធ្វើឡើង

ស្របតាមអនុក្រឹត្យនេះឡើយ។ នេះ គឺដោយសារតែដីកសិកម្មពុំមានទំហំធំគ្រប់គ្រាន់ដើម្បីឲ្យគ្រួសារទាំងអស់ដាំដុះដំណាំសម្រាប់បរិភោគឲ្យបានគ្រប់គ្រាន់ សម្រាប់ធានានិរន្តរភាពទីតាំងសម្បទានដីសង្គមកិច្ចនេះ។

ទំហំផ្ទះជាមធ្យមគឺ ៣៣ ម៉ែត្រការ៉េ ពោលគឺធំជាងទំហំផ្ទះគិតជាមធ្យមនៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ (២៨ ម៉ែត្រការ៉េ)។ ផ្ទះផ្សេងទៀតត្រូវបានសាងសង់ដោយគ្រួសារផ្ទាល់ និងមានផ្ទះខ្លះសង់ដោយមានជំនួយពីអ្នកជិតខាង។ គ្រួសារ អាចសាងសង់ផ្ទះបាន ជាមធ្យម ៣ ខែ ក្រោយពីបានទទួលដីនៅទីតាំងសម្បទានដីសង្គមកិច្ច។ អ្នកឆ្លើយតបភាគច្រើនលើសលុប (៨៦%) លើកឡើងថា លំនៅឋានថ្មីរបស់ពួកគេ*ល្អជាង ឬល្អឆ្ងាយជាង* ផ្ទះមុនៗរបស់ពួកគេ។ មាន គ្រួសារតែមួយប៉ុណ្ណោះ បានលើកឡើងថា ផ្ទះថ្មីរបស់ពួកគេ*អន់ជាង ឬអន់ឆ្ងាយជាង* ផ្ទះមុនរបស់ពួកគេ ហើយគ្រួសារដែលនៅសល់លើកឡើងថាស្ថានភាពប្រហាក់ប្រហែលគ្នា។ បើទោះបីជាចំណុចនេះមួយផ្នែកដោយសារតែការយល់ឃើញក៏ដោយ វាជាសញ្ញាសំខាន់បង្ហាញថាពីភាពជោគជ័យនៃគម្រោងសម្បទានដីសង្គមកិច្ចនេះ។ តើគ្រួសារក្រីក្រ ឬគ្មានដី បានទទួលលំនៅឋានសមរម្យ ដែលអាចបំពេញទៅតាមតម្រូវការជាមូលដ្ឋានរបស់ពួកគេដែរឬទេ? ក្នុងករណីនេះ ផ្ទះភាគច្រើនត្រូវបានសាងសង់ឡើងដោយគ្រួសារខ្លួនឯង ប៉ុន្តែរដ្ឋជាអ្នកផ្តល់ដីឲ្យ និងមានការគាំទ្របន្ថែមពីកម្មវិធី LASED ជាលទ្ធផល កម្មវិធីសម្បទានដីសង្គមកិច្ចនេះបានចូលរួមចំណែកកែលំអកម្រិតជីវភាពរស់នៅសម្រាប់គ្រួសារទទួលផលមួយភាគធំ។

អ្នកឆ្លើយតប ៤៨% លើកឡើងថា ពួកគេពុំមានអារម្មណ៍ថាខ្លួនមានសុវត្ថិភាពក្នុងផ្ទះបច្ចុប្បន្នរបស់ខ្លួនឡើយ ដោយសារតែការខូចខាតបង្កឡើងដោយខ្យល់ /ភ្លៀង (៧០%) ឬដោយសារអំពើចោរកម្ម (២១%)។ អ្នកឆ្លើយតប ៤% ទៀត គិតថាសំណង់ផ្ទះរបស់ពួកគមិនរឹងមាំឡើយ។ គេមិនបានដឹងច្បាស់ ថាតើ មានប្រជាពលរដ្ឋប៉ុន្មានគ្រួសារដែលបានទទួលរងគ្រោះដោយសារអំពើចោរកម្ម ឬការខូចខាតបង្កឡើងដោយសារអាកាសធាតុនោះទេ។

ក្បាលដីសម្រាប់ធ្វើកសិកម្មជាមធ្យមមានទំហំ ២,២១ ហិកតា។ ប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ១៧% លើកឡើងថា អ្នកជិតខាងរបស់ពួកគេទទួល

បានដីកសិកម្មធំជាង។ អ្នកឆ្លើយតបទាំងអស់ បានលើកឡើងថា ឥឡូវនេះ ពួកគេបានដាំដំណាំលើដីនៅជុំវិញផ្ទះរបស់ពួកគេ ហើយពួកគេភាគច្រើន (៩៧%) ទទួលបានចំណូលប្រចាំខែសម្រាប់គ្រួសារពីការដាំដុះនេះ។ អាជ្ញាធរមូលដ្ឋាន បានលើកឡើងថា ក្បាលដីធំៗត្រូវបានផ្ដល់ដល់គ្រួសារដែលមានសមាជិកច្រើន ហើយនេះគឺជាកត្តាមួយ ក្នុងការបែងចែកដី។ ពួកគេក៏បានលើកឡើងផងដែរថានេះជាបញ្ហាពិបាកដោះស្រាយមួយ ហើយពួកគេមានការពិបាកក្នុងការបង្ហាញហេតុផលពីការចែកដីក្នុងទំហំខុសៗគ្នាបែបនេះ។

ចំណូលប្រចាំឆ្នាំជាមធ្យម ដែលទទួលបានពីការធ្វើកសិកម្ម គឺ ៩៨៧ ដុល្លារ។ នេះជាចំនួនមួយខ្ពស់ជាងតួលេខមធ្យមសម្រាប់ទីតាំងសម្បទានដីសង្គមកិច្ច ដែលត្រូវបានអង្កេតផ្សេងទៀត។ សម្រាប់អ្នកឆ្លើយតប ៧៩% ចំនួននេះគឺច្រើនជាងអ្វីដែលពួកគេទទួលបានពីការធ្វើកសិកម្ម នៅកន្លែងដែលពួកគេរស់នៅមុន។ ដោយសារតែប្រជាពលរដ្ឋ ៨២% លើកឡើងថា ពួកគេទទួលបានដីនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ពីព្រោះតែពួកគេខ្វះខាតដី និងមាន ៣៦% ទៀតលើកឡើងពីភាពក្រីក្រ ស្ថិតិនេះបង្ហាញថា ការផ្លាស់មករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះបានរួមចំណែកបង្កើនចំណូលដល់គ្រួសាររបស់ពួកគេយ៉ាងច្រើន (ក៏ដូចជាទ្រព្យធន និងកម្រិតជីវភាពផងដែរ) សម្រាប់គ្រួសារដែលត្រូវបានចាត់ទុកថារស់នៅក្នុងភាពក្រីក្រ មុនពេលផ្លាស់មកនៅទីនេះ។ គ្រួសារតាមផ្ទះ ១៤% ទទួលបានចំណូលក្នុងមួយខែពីការធ្វើកសិកម្មតិចជាងចំណូលដែលពួកគេធ្លាប់ទទួលបាន។

អាជ្ញាធរមូលដ្ឋានបានលើកឡើងថា អ្នកទទួលផលបានទទួលអង្ករ សម្ភារៈកសិកម្ម (ចប កាំបិត និងស័ង្កសី) ឈើសម្រាប់សង់ផ្ទះ ហើយមានអង្គការមិនមែនរដ្ឋាភិបាលមួយបានជួយសង់អណ្ដូង និងផ្ដល់វិទ្យុ និងផ្ទាំងសូឡាពន្លឺព្រះអាទិត្យ។ ប៉ុន្តែ ពុំមានការលើកឡើងថា ជំនួយនេះត្រូវបានផ្ដល់ជាប្រចាំនោះទេ។ បុគ្គលិក OHCHR ដែលបានចុះទៅទីតាំងនេះ បានលើកឡើងថា នេះគឺជាតំបន់សម្បទានដីសង្គមកិច្ចដែលមានប្រជាពលរដ្ឋរស់នៅច្រើនជាងគេ ហើយក៏ជាតំបន់ដែលមានសកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋយ៉ាងសកម្មផងដែរ។ អ្នកទទួលផលបានប្រាប់ OHCHR ថា នៅទីនេះ ពុំមានប្រព័ន្ធធារាសាស្ត្រសម្រាប់ធ្វើកសិកម្មឡើយ ដូច្នេះ សកម្មភាពកសិកម្មនានាធ្វើឡើងភាគច្រើន

បានតែនៅរដូវវស្សា។ ពួកគេ ក៏បានលើកឡើងផងដែរថា ពួកគេពុំបានទទួលការគាំទ្រ ឬជំនួយបច្ចេកទេសឲ្យបានច្រើនពីអាជ្ញាធរមូលដ្ឋានឡើយ។ នេះបង្ហាញថា ការរកចំណូលពីការធ្វើកសិកម្មអាចបង្កើនឲ្យរឹតតែច្រើនថែមទៀតតាមរយៈការកែលំអធារាសាស្ត្រ និង បង្កើនចំណេះដឹងបច្ចេកទេស។ ប្រជាពលរដ្ឋក្នុងភាគរយដ៏គួរកត់សម្គាល់មួយ (៤០%) បានលក់ ឬផ្តល់ផ្នែកខ្លះនៃដីរបស់ពួកគេជាអំណោយ។ ដោយសារតែរយៈពេលទទួលកម្មសិទ្ធិរបស់ពួកគេ (ជាមធ្យម ប្រហែលជា ៦ ឆ្នាំ) ហើយប្រជាពលរដ្ឋទាំងនេះមានសិទ្ធិស្របច្បាប់ក្នុងការលក់ដីរបស់ពួកគេ ក្រោយការកាន់កាប់បានជាង ៥ ឆ្នាំ តួលេខទាបបែបនេះបង្ហាញថា គ្រួសារភាគច្រើនអាចទ្រទ្រង់ជីវភាពគ្រួសាររបស់ខ្លួនបានគ្រប់គ្រាន់ ខណៈដែលអាចលក់ចំណែកខ្លះនៃដីរបស់ពួកគេ។ ប៉ុន្តែ វា ក៏អាចបង្ហាញផងដែរថា គ្រួសារត្រូវបង្ខំចិត្តលក់ដីខ្លះដើម្បីទទួលបានចំណូល។ មានការផ្តល់ជំនួយច្រើនប្រភេទដល់គ្រួសារ ៨៣,៦% ដែលប្រើប្រាស់ដីសម្រាប់ធ្វើកសិកម្ម ក្នុងចំណោមគ្រួសារដែលបានទទួលជំនួយ ៩១% បានទទួលឧបករណ៍សម្ភារៈ និង ៥៦% បានទទួលគ្រាប់ពូជ ភាគច្រើនពីអង្គការមិនមែនរដ្ឋាភិបាលជាជាងពីស្ថាប័នរដ្ឋ។

ប្រជាពលរដ្ឋភាគច្រើន (៩០%) បានលើកឡើងថា ពួកគេពុំមានជំនាញធ្វើកសិកម្មមុនពេលផ្លាស់មករស់នៅលើទីតាំងនេះឡើយ បើទោះបីជាក្នុងចំណោមអ្នកទាំងនេះ ៨៨% និយាយថា ពួកគេបានកែលំអជំនាញពាក់ព័ន្ធនឹងការធ្វើកសិកម្ម ដែលនេះបង្ហាញថាមានការផ្តល់ការគាំទ្រ និងការបណ្តុះបណ្តាល ដែលមានប្រសិទ្ធភាពខ្ពស់។

**ជម្លោះដីធ្លី៖**

មានតែ២គ្រួសារតាមផ្ទះប៉ុណ្ណោះ ក្នុងចំណោមគ្រួសារតាមផ្ទះទទួលផល (២%) បានលើកឡើងថា បច្ចុប្បន្ននេះ ពួកគេកំពុងជាប់ពាក់ព័ន្ធនឹងជម្លោះដីធ្លី ទាក់ទិននឹងដីផ្ទះសម្បែងរបស់ពួកគេ ដែលករណីជម្លោះទាំងពីរនេះ គឺជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាននេះ។ ប៉ុន្តែ អ្នកឆ្លើយតប ១២% ធ្លាប់ទទួលរងការទន្ទ្រានលើដីរបស់ពួកគេ ពីប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋាននេះ។ ក្នុងចំណោមអ្នកឆ្លើយតបទាំងនេះ មាន ៥ គ្រួសារ បានអះអាង

ដោយចោទថាបានទទួលរងការឈឺចាប់ពីការឃាយឺ ឬការគំរាមកំហែង ពាក់ព័ន្ធជាមួយនឹងដីរបស់ពួកគេ ពីសំណាក់ប្រជាពលរដ្ឋផ្សេងទៀត។

អាជ្ញាធរមូលដ្ឋាន បានលើកឡើងថា ទីតាំងសម្បទានដីសង្គមកិច្ចនេះ គឺជាដីដែលគ្រួសារផ្សេងទៀតធ្វើកសិកម្ម មុនពេលដីនេះត្រូវបានធ្វើអនុបយោគ ហើយជម្លោះ គឺកើតឡើងជាមួយនឹងកសិករទាំងនេះ។ ពួកគេទាំងនេះត្រូវបានគេចាត់ទុកថាបាន "កាប់ឆ្ការដីព្រៃខុសច្បាប់"។

ក្នុងកំឡុងកិច្ចពិភាក្សាក្រុមគោលដៅ ប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋាននេះ ចំនួន ១០ គ្រួសារ រាយការណ៍ថា បានបាត់បង់ដី នៅពេលដែលសម្បទានដីសង្គមកិច្ចនេះត្រូវបានបង្កើតឡើង។ ពួកគេភាគច្រើនបានទទួលដីរបស់ពួកគេទាំងអស់ ឬដីភាគច្រើនត្រលប់មកវិញ ឬទទួលបានដីបន្ថែមទៀត ជាសំណង ប៉ុន្តែមាន ៣ គ្រួសារដែលមិនបានទទួលសំណងបែបនេះ។ ក្នុងចំណោមគ្រួសារទាំងនេះ មានមួយគ្រួសារ[81] បានលើកឡើងថា បានបាត់បង់ដី ៦ ហិកតា និងបានទទួលមកវិញត្រឹមតែ ១,៥ ហិកតាប៉ុណ្ណោះ ហើយអះអាងថា អាជ្ញាធរមូលដ្ឋានដែលយកដីនេះពីពួកគេក្នុងឆ្នាំ ២០០៥ នៅជំពាក់ដីពួកគេ ៤,៥ ហិកតាទៀត។ សមាជិកគ្រួសារម្នាក់បានប្តឹងទៅអាជ្ញាធរស្រុក និងអាជ្ញាធរខេត្ត ដែលមិនអាច ឬពុំមានឆន្ទៈជួយពួកគេបាន។ ពុំមានការផ្តល់ជំនួយផ្លូវច្បាប់ ឬពុំមានអង្គការមិនមែនរដ្ឋាភិបាលណាជួយគ្រួសារនេះ ដើម្បីដាក់ពាក្យបណ្តឹងនេះឡើយ។ ករណីនេះនៅតែមិនទាន់បានដោះស្រាយរហូតដល់ពេលនេះ។ បច្ចុប្បន្ននេះ ផ្លូវមួយខ្សែកំពុងសាងសង់កាត់ដីដែលនៅសល់ ១,៥ ហិកតានេះ ដើម្បីកែលំអហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទីតាំងសម្បទានដីសង្គមកិច្ចនេះ។ គាត់បានដាក់ពាក្យបណ្តឹងទៅកាន់មេភូមិ ប៉ុន្តែភ័យខ្លាចមិនហ៊ានធ្វើសកម្មភាពបន្ថែមទៀតឡើយ។

**ការទទួលបានទឹក និងអនាម័យ៖**

[81] ការបាត់បង់ដី និងបញ្ហាប្រឈមផ្សេងទៀត ដែលគ្រួសារនេះជួបប្រទះ ត្រូវបានកត់ត្រាដោយ OHCHR ដែលបានសម្ភាសជនរងគ្រោះទាំងនេះ សម្រាប់ចងក្រងករណីសិក្សាអំពីគ្រួសារដែលទទួលរងផលប៉ះពាល់ ដោយសារគម្រោងសម្បទានដីសង្គមកិច្ច។

ប្រជាពលរដ្ឋបានរាយការណ៍ប្រាប់ OHCHR ថា នៅពេលដែលពួកគេផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះដំបូង កាលពីឆ្នាំ ២០០៩ ពុំមានអណ្តូងទឹកឡើយ។ ក្នុងឆ្នាំ ២០១១ បុគ្គលិករបស់កម្មវិធី LASED បានចុះមកវាយតម្លៃដល់ទីតាំងនេះ និងផ្តួចផ្តើមសាងសង់អណ្តូងចំនួន ១០ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត។ ប៉ុន្តែ ក្នុងចំណោមគ្រួសារដែលត្រូវបានសម្ភាស ៩៥% នៅមិនទាន់បានចាត់ទុកខ្លួនឯងថាបានទទួលទឹកស្អាត សម្រាប់បរិភោគនោះទេ។ ក្នុងក្រុមនេះ គ្រួសារ ៨៨% ទៅយកទឹកពីអណ្តូងជីក និង ១០% ទៅយកពីអន្លង់សាធារណៈ។ ប្រជាពលរដ្ឋជាច្រើនជីកអណ្តូងរបស់ពួកគេដោយខ្លួនឯង ដោយសារមិនមានជំនួយពីអាជ្ញាធរ ដៃគូអភិវឌ្ឍន៍ ឬអង្គការមិនមែនរដ្ឋាភិបាល។ មានប្រជាពលរដ្ឋតែ ៥៦% ប៉ុណ្ណោះ ដែលធ្វើប្រព្រឹត្តិកម្មទឹកមុនបរិភោគ តាមរយៈការដាំទឹក (៦២%) ឬប្រើប្រាស់ឧបករណ៍ចម្រោះ (៣៨%)។ អ្នកឆ្លើយតប ១២% បានលើកឡើងថាទឹកបរិភោគរបស់ពួកគេមានពណ៌ រសជាតិ និង/ឬក្លិនចម្លែក និងមានគ្រួសារតែ ០,៩% ប៉ុណ្ណោះ ដែលលើកឡើងថាទឹករបស់ពួកគេត្រូវបានសំអាតដោយប្រើសារធាតុក្លរ។ អ្នកឆ្លើយតបសម្ភាស ១៦% បានដាក់ពិន្ទុឲ្យការទទួលបានទឹករបស់ខ្លួនថា*អន់ ឬអន់ឆ្ងាយជាង* កន្លែងដែលពួកគេរស់នៅលើកមុន។ ប៉ុន្តែ អ្នកឆ្លើយតបសម្ភាស ៥០% បានដាក់ពិន្ទុឲ្យការទទួលបានទឹករបស់ពួកគេថាល្អប្រសើរជាងមុន។ នេះបង្ហាញថា បញ្ហាទទួលបានទឹកស្អាត គឺនៅតែជាបញ្ហាចោទនៅឡើយក្នុងទីតាំងសម្បទានដីសង្គមកិច្ចត្បូងឃ្មុំនេះ បើទោះបីជាបញ្ហានេះ មិនសូវជាធ្ងន់ធ្ងរដូចទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀតក៏ដោយ។ អាជ្ញាធរមូលដ្ឋានចាត់ទុកកង្វះទឹក (ក៏ដូចជា ជំងឺដែលបង្កផលប៉ះពាល់ដល់ដំណាំដំឡូង) គឺជាឧបសគ្គធំបំផុតចំពោះគ្រួសារដែលចង់ដាំដុះលើដីរបស់ពួកគេ។

ពុំមានប្រព័ន្ធលូបញ្ចេញចោលទឹកស្អុយឡើយ សម្រាប់ប្រជាពលរដ្ឋ ៩៦% ដែលបានអង្កេត ហើយមានគ្រួសារតាមផ្ទះ ៦៦% ពុំមានបរិក្ខារអនាម័យឡើយ។ ប៉ុន្តែ ក្នុងចំណោមគ្រួសារ ៣៤% ដែលមានបរិក្ខារអនាម័យ ពួកគេអាចមានបង្គន់ចាក់ទឹក ដែលភ្ជាប់ជាមួយនឹងរណ្តៅស្តុកលាមក ការតភ្ជាប់បំពង់អនាម័យ ឬរណ្តៅស្តុកលាមកដែលចោះឲ្យមានខ្យល់ចេញចូល។ ប្រជាពលរដ្ឋជាច្រើននាក់បានទទួលសម្ភារៈ សម្រាប់សាងសង់បង្គន់

ដែលជាផ្នែកមួយនៃជំនួយរបស់គម្រោង LASED។ គ្រួសារមួយចំនួន ក្នុងចំណោមគ្រួសារទាំងនេះ បានសង់បង្គន់ប្រកបដោយជោគជ័យ ប៉ុន្តែគ្រួសារផ្សេងទៀតបានលើកឡើងថា ពួកគេខ្វះកម្លាំងពលកម្ម ជំនាញ និង/ឬប្រាក់កាស សម្រាប់សង់បង្គន់ ឬបានលក់សម្ភារៈទាំងនេះ ដើម្បីទិញអង្ករបរិភោគ ។ ប្រជាពលរដ្ឋផ្សេងទៀតបន្ទោរបង់ក្នុងព្រៃ (៤០%) ឬជីករណ្ដៅសម្រាប់បន្ទោរបង់ (៥៥%) នៅកន្លែងផ្សេងទៀត។ អ្នកឆ្លើយតបត្រឹមតែ ៦៧% លើកឡើងថា ពួកគេពុំមានអារម្មណ៍ថាមានសុវត្ថិភាព នៅពេលចេញទៅបន្ទោរបង់ខាងក្រៅផ្ទះឡើយ។ អ្នកឆ្លើយតបតែ ៣% ប៉ុណ្ណោះ បានដាក់ពិន្ទុឲ្យលក្ខខណ្ឌអនាម័យរបស់ខ្លួនថាអន់ ឬអន់ឆ្ងាយជាងស្ថានភាពកាលពីមុន ខណៈដែល ៥៥% លើកឡើងថាស្ថានភាពបានប្រសើរជាងមុន។ អ្នកដែលនៅសល់លើកឡើងថា ស្ថានភាពពុំមានការប្រែប្រួលឡើយ។ នេះបង្ហាញថា កត្តាអនាម័យនៅទីតាំងសម្បទានដីសង្គមកិច្ច ក្នុងខេត្តត្បូងឃ្មុំ មានស្ថានភាពល្អប្រសើរជាងទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀត និងបានជួយធ្វើឲ្យស្ថានភាពរបស់គ្រួសារភាគច្រើនបានល្អប្រសើរជាងមុន ទំនងជាដោយសារមានការគាំទ្រពីគម្រោង LASED។ តែទោះយ៉ាងណាក៏ដោយ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីធានាយ៉ាងណាឲ្យគ្រប់គ្រួសារទាំងអស់ដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ មានលទ្ធភាពទទួលបានទឹក និងអនាម័យ។

**សេវាសុខាភិបាល៖**

ជាមធ្យម ប្រជាពលរដ្ឋត្រូវចំណាយពេលតែ ៤ នាទីប៉ុណ្ណោះ ដើម្បីធ្វើដំណើរទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុត ប៉ុន្តែរហូតដល់ ៦០ នាទី ដើម្បីធ្វើដំណើរទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត។ ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ៣០% លើកឡើងថា ពួកគេមានជំងឺញឹកញាប់ជាងមុន បើធៀបជាមួយនឹងស្ថានភាពនៃការរស់នៅមុន។ ជំងឺគ្រុនពោះវៀនត្រូវបានរាយការណ៍ថាកើតឡើងញឹកញាប់ជាងគេ ដូចគ្នានឹងករណីជំងឺគ្រុនចាញ់ដែរ។ ជំងឺគ្រុនឈាម ក៏កើតមានផងដែរ។ គ្រុនក្ដៅ ឬផ្ដាសាយ និងឈឺក្រពះ ក៏កើតឡើងញឹកញាប់ផងដែរ។ អ្នកឆ្លើយតប ៥៨% លើកឡើងថា <u>ការទទួលបានសេវាសុខភាពមានភាពល្អប្រសើរ ឬល្អប្រសើរឆ្ងាយជាងមុន</u> បើធៀបជាមួយ

នឹងស្ថានភាពនៅកន្លែងរស់នៅមុន។ មានអ្នកឆ្លើយតបតែ ១៩% ប៉ុណ្ណោះ ដែលលើកឡើងថា សេវាសុខាភិបាលអន់ជាងកន្លែងដែលពួកគេរស់នៅមុន។

**ការអប់រំ៖**

មានសាលាបឋមសិក្សាមួយនៅលើទីតាំងនេះ ប៉ុន្តែពុំមានសាលាមធ្យមសិក្សានោះទេ។ ជាមធ្យម កុមារចំណាយពេលត្រឹមតែ ៤ នាទី តាមម៉ូតូឌុបប៉ុណ្ណោះទៅសាលាបឋមសិក្សា និង ៣២ នាទី ដើម្បីទៅដល់សាលាមធ្យមសិក្សាដែលនៅជិតបំផុត។ អ្នកឆ្លើយតប ២៩% បានលើកឡើងថា យ៉ាងហោចណាស់ មានកុមារដល់វ័យចូលរៀនមួយចំនួន (អាយុចន្លោះពី ៦ ដល់ ១៧ ឆ្នាំ) ក្នុងផ្ទះរបស់ពួកគេ <u>ពុំបានទៅរៀនឡើយ</u> ដែលនេះជាចំណុចដែលធ្វើឲ្យមានការព្រួយបារម្ភខ្លាំង។ ពួកគេបានលើកឡើងពីមូលហេតុច្រើនយ៉ាង ដូចជាលទ្ធភាពចំណាយ (៣៩%) ចំងាយផ្លូវ (២៨%) ដោយសារតែគេត្រូវការពួកគេឲ្យនៅផ្ទះ (១៣%) និងដោយសារតែកូនៗមិនចង់ទៅរៀន (២២%)។ គ្រួសារ ២១% និយាយថា បច្ចុប្បន្ននេះ កូនៗពួកគេតិចជាងមុនបានទៅរៀន ចាប់តាំងពីផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះមក ដែលនេះក៏ជាបញ្ហាចោទជាពិសេសមួយផងដែរ បើទោះបីជាអ្នកឆ្លើយតប ៤៩% និយាយថា កូនៗរបស់ពួកគេច្រើននាក់ជាងមុនបានទៅរៀនក៏ដោយ។ ក្នុងការសម្ភាសដោយឡែកមួយទៀតដែល OHCHR ទទួលបាន ប្រជាពលរដ្ឋលើកឡើងថា សាលារៀននេះមានគ្រូតិចពេក ដែលទំនងជានាំឲ្យឪពុកម្ដាយសម្រេចចិត្តមិនបញ្ជូនកូនទៅរៀន។ មូលហេតុមួយផ្នែក គឺភាពក្រីក្រ ដែលបង្ហាញថា ចាំបាច់ត្រូវតែមានការផ្ដល់ការគាំទ្រឲ្យបានច្រើនជាបន្ទាន់ដល់គ្រួសារក្រីក្រ ដើម្បីឲ្យពួកគេអាចបង្កើប្រភពចំណូលបន្ថែមសម្រាប់គ្រួសារ ទើបកូនៗទាំងអស់របស់ពួកគេអាចទៅរៀនបាន។ វាក៏មានន័យផងដែរថា គួរមានការផ្ដល់ព័ត៌មានបន្ថែមដល់គ្រួសារទាំងនេះអំពីមូលហេតុដែលការបញ្ជូនកូនទៅទទួលការអប់រំនៅសាលារៀន គឺជាកាតព្វកិច្ចរបស់ពួកគេ។

ជាមធ្យម មានគ្រួសារប្រមាណជា ៥៩% មានគម្រោងចង់ឲ្យកូនប្រុសទទួលបានការអប់រំ *យ៉ាងហោចណាស់* ១២ ឆ្នាំ ប៉ុន្តែតួលេខនេះថយចុះមកនៅ ៥៣% សម្រាប់កូនស្រី ដែលបង្ហាញថា <u>ការរើសអើងយេនឌ័រ គឺជាបញ្ហាមួយក្នុងការទទួលបានការអប់រំ</u>។ សម្គាល់

នេះមិនមែនជាការបង្ហាញថាតើមានការផ្តល់ការអប់រំជាក់ស្តែងកម្រិតណានោះទេ ច្រើនតែជាការឆ្លុះបញ្ចាំងពីបំណងរបស់គ្រួសារតាមផ្ទះទាំងនោះ និងសារៈសំខាន់ដែលទាក់ទងជាប់ទៅនឹងការអប់រំ។

នៅពេលឲ្យដាក់ពិន្ទុលើការទទួលបានការអប់រំនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ មានអ្នកឆ្លើយតបភាគច្រើន (៥៩%) បានលើកឡើងថា ការអប់រំមានភាពល្អប្រសើរជាងមុន។ ផ្ទុយទៅវិញ ១៧% បានលើកឡើងថា ការទទួលបានការអប់រំធ្លាក់ចុះជាងមុន។

**ហេដ្ឋារចនាសម្ព័ន្ធ និងអគ្គិសនី៖**

ពុំមានប្រជាពលរដ្ឋណាដែលត្រូវបានសម្ភាស សម្រាប់ការអង្កេតនេះ <u>មានអគ្គិសនីប្រើប្រាស់</u>នៅទីតាំងសម្បទានដីសង្គមកិច្ចនេះឡើយ។ សម្គាល់៖ សំណួរនៃការអង្កេតនេះ សួរពីអគ្គិសនី "ដែលរដ្ឋផ្តល់ឲ្យ" តាមរយៈការភ្ជាប់បណ្តាញមេ។ វាមិនមែនន័យថា ពុំមានម៉ាស៊ីនភ្លើង ឬប្រភពអគ្គិសនីផ្សេងទៀតនោះឡើយ។

ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះស្ទើរតែទាំងអស់អាចភ្ជាប់បណ្តាញទូរស័ព្ទដៃបាន (៩៩%) ហើយអ្នកឆ្លើយតបជាច្រើននាក់ (៦៩%) មានទូរស័ព្ទ និងអ៊ីនធឺណិតប្រើប្រាស់។ មានអ្នកឆ្លើយតបតែ ៤៦% ប៉ុណ្ណោះ ដែលលើកឡើងថា <u>ការប្រើប្រាស់មធ្យោបាយធ្វើដំណើរ (បណ្តាញផ្លូវថ្នល់) និងការទំនាក់ទំនង (ទូរស័ព្ទ និងអ៊ីនធឺណិត)</u> មានភាពល្អប្រសើរជាងមុន ខណៈពេលដែល ១៦% បាននិយាយថា ស្ថានភាពនេះអន់ជាងមុន ចាប់តាំងពីពេលដែលពួកគេផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ បើទោះបីជាមានការកសាងផ្លូវថ្នល់ក្នុងតំបន់នេះក៏ដោយ។ ផ្លូវទាំងនេះត្រូវបានសាងសង់ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល នេះបើតាមការលើកឡើងរបស់ប្រជាពលរដ្ឋ។

**សន្តិសុខស្បៀង៖**

អ្នកឆ្លើយតប ៨៧% និយាយថា កាលពីខែមុននេះ យ៉ាងហោចណាស់ក៏មានម្តងដែរ ដែលពួកគេមានការព្រួយបារម្ភថាពួកគេនឹងពុំអាចផ្តល់អាហារគ្រប់គ្រាន់ដល់គ្រួសាររបស់ពួកគេ ដោយ ៤៩% លើកឡើងថា នេះជាការ ព្រួយបារម្ភដែលកើតមានជាប្រចាំ។ គ្រួសារ

៦១% លើកឡើងថា ពួកគេត្រូវកំហិតអាហារដែលត្រូវបរិភោគ (ដូចជា ពុំមានសាច់ ឬត្រី ជាដើម) នៅពេលណាមួយ ក្នុងខែមុននេះ ដោយសារតែខ្វះលុយ ហើយ ៨៦% ត្រូវបង្ខំចិត្តបរិភោគមើមរុក្ខជាតិដុះក្នុងព្រៃ ឬសាច់ដែលមានគុណភាពអន់ខ្លាំង ដោយសារតែមូលហេតុដូចគ្នានេះ។ អ្នកឆ្លើយតប ៣៥% លើកឡើងថា ពួកគេធ្លាប់ដាច់បាយ កាលពីខែមុននេះ និងមានអ្នកឆ្លើយតប ៣១% បានលើកឡើងថា មានថ្ងៃខ្លះ កាលពីខែមុននេះ ដែលពួកគេពុំមានអាហារបរិភោគតែម្តង ដោយសារតែពុំមានលុយទិញអាហារ និងពុំអាចរកអាហារបានពីដីរបស់ពួកគេ។ ការទទួលបានអាហារដែលមានតម្លៃសមរម្យ និងកង្វះអាហារ គឺជាបញ្ហាស្រួចស្រាវមួយ ក្នុងខេត្តត្បូងឃ្មុំ។ បើទោះបីជាបែបនេះក៏ដោយ មានគ្រួសារតាមផ្ទះតែ ១១% ប៉ុណ្ណោះ លើកឡើងថា ការទទួលបានអាហារបានថមថយជាងមុន ចាប់តាំងពីពេលដែលពួកគេផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ហើយសម្រាប់គ្រួសារ ៦០% លើកឡើងថាមានស្ថានភាពបានល្អប្រសើរជាងមុន។ អាហារូបត្ថម្ភទំនងជាបញ្ហាធំមួយ សម្រាប់គ្រួសារតាមផ្ទះដែលតាំងនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ជាពិសេសសម្រាប់កុមារដែលខ្វះអាហារ មានជាតិប្រូតេអ៊ីន។

**ប្រាក់ចំណូល និងការងារ៖**

គ្រួសារតាមផ្ទះដែលត្រូវបានសាកសួរស្ទើរតែទាំងអស់ (៩៩%) មានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់មានការងារធ្វើ ហើយខ្នងផ្ទះប្រមាណជា ៨៦% មានមនុស្សចាប់ពី ២ នាក់ឡើងទៅ មានការងារធ្វើ ដោយខ្នងផ្ទះខ្លះមានមនុស្សរហូតដល់ ៦ នាក់ មានការងារធ្វើ។ ជាការឆ្លើយតបចំពោះសំណួរដែលសួរថា តើការងារប្រភេទណាខ្លះដែលពួកគេធ្វើ ៩៣% ស៊ីឈ្នួលធ្វើកសិកម្មឲ្យគេ ៨៥% ធ្វើការងារប្រភេទប្រើប្រាស់កម្លាំងពលកម្មផ្សេងទៀត ហើយ ២០% មានមុខរបរខ្លួនឯង។ ចំណូលមធ្យមប្រចាំខែរបស់គ្រួសារដែលបានពីការងារគឺ ៤៦០ ដុល្លារ ក្នុងមួយខែ។ ចំណូលភាគច្រើនបានពីការងារកសិកម្ម ការងារស៊ីឈ្នួលគេ/ការងាររោងចក្រ និងបានពីមុខរបរខ្លួនឯង ដូចជា ការលក់ផលិតផលផ្ទាល់ ជាដើម។ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ចំណូលមធ្យមប្រចាំខែរបស់អ្នកឆ្លើយតបគឺទាបជាងនេះបន្តិចពោលគឺ ៣៩១ ដុល្លារ ក្នុងមួយខ្នងផ្ទះ។ ចំណាយមធ្យម

សម្រាប់គ្រួសារបច្ចុប្បន្ននេះគឺ ២៤៦ ដុល្លារ ក្នុងមួយខែ កើនឡើងពី ១៦២ ដុល្លារ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ចំណាយខ្ពស់ជាងគេ គឺលើអាហារ (កើនឡើងពី ៧៧ ដុល្លារ ដល់ ៩២ ដុល្លារ) និងលើពិធីសាសនា (ពី ២១ ដុល្លារ ដល់ ៧១ ដុល្លារ) ។ ចំណាយលើការថែទាំសុខភាពមានការថយចុះតិចតួច។ ចំណូលប្រចាំខែជាមធ្យមហាក់បីដូចជាមានការកើនឡើងច្រើនជាងចំណាយប្រចាំខែជាមធ្យមរបស់គ្រួសារក្នុងខេត្តនេះ។

គ្រួសារតែ ៩១% ប៉ុណ្ណោះ ដែលមានប្រាក់សន្សំសម្រាប់គ្រួសារ បើទោះបីជាមធ្យមប្រាក់សន្សំនេះមានការកើនឡើង ចាប់តាំងពីផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះក៏ដោយ ហើយបច្ចុប្បន្នេះ តួលេខមធ្យមគឺ ១៩៤ ដុល្លារ។ គ្រួសារ ៨៩% ជាប់ជំពាក់បំណុលគេ ហើយបំណុលនេះមានការកើនឡើងខ្លាំង។ ជាមធ្យមគ្រួសារតាមផ្ទះនិមួយៗ ជំពាក់បំណុលគេ ១០៧២ ដុល្លារ ដែលកើនឡើងពីត្រឹមតែ ១៩៣ ដុល្លារ មុនពេលផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ។ នេះមានន័យថា គ្រួសារតាមផ្ទះទាំងនោះ ត្រូវខ្ចីបុលគេយ៉ាងច្រើន នៅពេលផ្លាស់ ឬក្រោយពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។

មានគ្រួសារតាមផ្ទះប្រមាណជា ២ ភាគ ៣ (៦២%) ដែលសមាជិកគ្រួសារទាំងអស់រស់នៅជុំគ្នានៅទីតាំងសម្បទានដីសង្គមកិច្ចនេះជាអចិន្ត្រៃយ៍។ សមាជិកគ្រួសារភាគច្រើនលើសលុប ដែលរស់នៅឆ្ងាយពីទីតាំងនេះ គឺកូនរបស់អ្នកឆ្លើយតបចំពោះការសម្ភាសនេះ ដែលនេះបង្ហាញថាក្មេងៗជំនាន់ក្រោយភាគច្រើនធ្វើចំណាកស្រុកឆ្ងាយពីផ្ទះដែលគ្រួសាររបស់ពួកគេរស់នៅ ដើម្បីរកការងារធ្វើ (ឧទាហរណ៍ ៨១% នៃកូនទី ១ និង ៨២% នៃកូនទី ២ ដែលមិនរស់នៅជាអចិន្ត្រៃយ៍នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ បានចាកចេញដើម្បីទៅរកការងារធ្វើជាដើម កូនផ្សេងទៀតភាគច្រើន ដើម្បីបន្តការសិក្សា)។

ជាសូចនាករបង្ហាញពីទ្រព្យធនគឺ មានគ្រួសារ ៣១% មានទូរទស្សន៍ជាកម្មសិទ្ធិ ហើយ ៨៦% មានម៉ូតូជាកម្មសិទ្ធិ។ បច្ចុប្បន្ន ៨៥% មានទូរស័ព្ទដៃជាកម្មសិទ្ធិ។

**រចនាសម្ព័ន្ធផ្នែកសង្គមៈ**

ក្នុងចំណោមគ្រួសារតាមផ្ទះដែលបានសាកសួរទាំងអស់ មានតែ ២០% ប៉ុណ្ណោះ ដែលជឿថា ការសម្រេចចិត្តរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចនេះ ធ្វើឡើង តាមរយៈ ដំណើរការប្រជាធិបតេយ្យ ដោយ ៧៤% លើកឡើងថា មេភូមិគឺជាអ្នកសម្រេចចិត្ត។

អ្នកឆ្លើយតប ៦៧% លើកឡើងថា ពួកគេមានអារម្មណ៍តានតឹង (ស្ត្រេស) ដោយ ១៧% លើកឡើងថា នេះជាបញ្ហាស្រួចស្រាវខ្លាំង។ បញ្ហានេះកើតឡើងដោយសារការខ្វះខាតអាហារ និងចំណូលថយចុះ។

អ្នកឆ្លើយតបស្ទើរតែទាំងអស់ (៩៩%) បានលើកឡើងថា ពួកគេ បានដឹងថា មានការរំលោភបំពានដោយសារគ្រឿងស្រវឹង កំពុងកើតមាន ក្នុងសហគមន៍នេះ និង ១៤% ទៀត ជឿថា មានបញ្ហាគ្រឿងញៀន នៅទី តាំងសម្បទានដីសង្គមកិច្ចនេះ។ គ្រួសារតាមផ្ទះ ២៦% លើកឡើងថា ពួកគេ បានកំពុងធ្វើការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលជាអ្នកផ្តល់ការគាំទ្រ (ភាគច្រើន - ៧៣% ទៀត មិនចាំថា អង្គការមិនមែនរដ្ឋាភិបាល ណាឡើយ)។ គ្រួសារតាមផ្ទះដែលត្រូវបានអង្កេត ២០% គិតថា ក្នុងសហគមន៍នេះ មានបទល្មើសឧក្រិដ្ឋកើតឡើងច្រើន បើធៀបជាមួយនឹងស្ថានភាព មុនពេលដែលពួកគេផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ។ អ្នកឆ្លើយតប ៤០% លើកឡើងថា បានដឹងពីករណីអំពើហិង្សាលើស្ត្រី ឬក្មេងស្រី ហើយ ២១% ជឿថា មានហិង្សាផ្លូវភេទកើតឡើងច្រើនជាងក្នុងសហគមន៍មុនៗរបស់ពួកគេ។ ការរកឃើញទាំងនេះ មិនផ្តល់នូវការ គណនាច្បាស់លាស់នៃអត្រាទូទៅនៃហិង្សាផ្លូវភេទ ឬការរំលោភបំពានដោយសារគ្រឿងស្រវឹងនោះទេ។ សូមចំណាំថា៖ នេះ ជាការឆ្លុះបញ្ចាំងពីគំនិតយោបល់របស់សហគមន៍តែប៉ុណ្ណោះ ហើយ គេត្រូវតែអានយល់ដូចនេះ ជាមួយការយល់ ដឹងថា ក្រុមអង្កេតនេះ មិនបានសួរដោយផ្ទាល់ទេ ឧទាហរណ៍៖ ថាតើ ការរំលោភបំពានកើតឡើយដោយគ្រឿងស្រវឹងជាបញ្ហាមួយនៅក្នុងខ្នងផ្ទះមួយឬទេ។

អ្នកឆ្លើយតប ៧០% លើកឡើងថា ពួកគេដឹងពីករណីកុមារធ្វើការងារដើម្បីរកចំណូលបន្ថែមឲ្យគ្រួសារ។ ការងារភាគច្រើនដែលកុមារធ្វើ គឺការងារកសិកម្ម (៧១%) និង

ប្រភេទការងារប្រើកម្លាំងពលកម្មផ្សេងទៀត (៦៩%)។ គ្រួសារតាមផ្ទះ ១២% បញ្ជូនសមាជិកគ្រួសារជាកុមារទៅធ្វើការងារតាមរោងចក្រ។

តំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ បានលើកឡើងថា កម្រិតជីវភាពរបស់គ្រួសារដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ មានភាពល្អប្រសើរជាងមុន បើទោះបីជាមានបញ្ហាទាក់ទងនឹងការទទួលបានសេវា និងមានការផ្តល់ដីក្នុងទំហំតូចដល់គ្រួសារក៏ដោយ។ អង្គការមិនមែនរដ្ឋាភិបាលនេះ មិនបានធ្វើការពិនិត្យតាមដាន និងវាយតម្លៃលើកម្រិតជីវភាពរស់នៅដើម្បីវាស់វែងពីលទ្ធផលដែលកម្មវិធីសម្បទានដីសង្គមកិច្ចនេះមានមកលើគ្រួសារទទួលផលនោះទេ។ អង្គការនេះក៏មិនដឹង ថាតើមានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះមកលើសហគមន៍មូលដ្ឋានផ្សេងទៀតនោះដែរ។

មានប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះតែ ១៣% ប៉ុណ្ណោះ ដោយចោទថាថា ពួកគេ *មិន*ត្រូវ<u>បានគេចុះឈ្មោះបោះឆ្នោតឲ្យឡើយ</u> ដែលជាតួលេខទាបជាងតួលេខមធ្យមនៅទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀត (២៩%) និងជាសញ្ញា ដែលបង្ហាញពីជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ក្នុងការជម្រុញឲ្យប្រជាពលរដ្ឋចូលរួមក្នុងការងារនយោបាយ (មិនសូវ មាននៅទីតាំងសម្បទានដីសង្គមកិច្ចដែលត្រូវបានអង្កេតផ្សេងទៀតឡើយ)។

គ្រួសារតាមផ្ទះ ២៩% នៅមិនទាន់មានឯកសារស្នាក់នៅដែលផ្តល់ដោយអាជ្ញាធរមូលដ្ឋាន។ ក្នុងខ្នង ផ្ទះ ៥៤% យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ ដែល<u>ពុំមានសំបុត្រកំណើត</u> ហើយក្នុងខ្នងផ្ទះ ៥៩% មានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់ ដែលពុំមាន<u>អត្តសញ្ញាណប័ណ្ណ</u>។ គ្រួសារ ១៥% ពុំមាន<u>សៀវភៅគ្រួសារ</u>។

ប្រជាពលរដ្ឋ ២១ គ្រួសារ (ស្មើនឹង ១៩%) បាននិយាយថា ពួកគេពិចារណាចាកចេញពីទីតាំងសម្បទានដីសង្គមកិច្ចនេះ ដោយហេតុផល កង្វះទឹក អាហារ និងបញ្ហាប្រឈមផ្សេងទៀតក្នុងតំបន់នេះ ជាតួលេខមួយទាបគួរឲ្យកត់សម្គាល់ និងប្រហែលជាបង្ហាញពីការពេញចិត្តជាទូទៅជាមួយគុណភាពជីវិត ដែលសម្រាប់គ្រួសារភាគច្រើន គឺមានភាពល្អប្រសើរជាងមុន ឬបង្ហាញថា គេពិបាកនឹងរកជម្រើសផ្សេងទៀត។ សំណូមពរជុំវិញ

ការលើកកម្ពស់កម្រិតជីវភាពរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ (៣២%) ការទទួលបានទឹកស្អាត (៣៦%) ការផ្គត់ផ្គង់អគ្គិសនី (៤២%) ទីផ្សារលក់ដូរ (៣០%) ការសាងសង់សាលាមធ្យមសិក្សា (២៦%) ការសាងសង់វត្តអារាម (៥០%) និងការសង់បង្គន់បន្ថែម និងការកែលំអអនាម័យ (២០%)។ មានការលើកឡើងនូវសំណូមពរសម្រាប់បញ្ហាជាច្រើនផ្សេងទៀតផងដែរ។

អាជ្ញាធរមូលដ្ឋាន ជឿថា លក្ខខណ្ឌការរស់នៅបានល្អប្រសើរជាងមុន សម្រាប់អ្នកទទួលផលដោយគ្រួសារខ្លះមានលទ្ធភាពទិញម៉ូតូ ឬសង់ផ្ទះធំៗ។ ពួកគេក៏លើកឡើងផងដែរ ថា គ្រួសារផ្សេងទៀតបានសម្រេចចិត្តលក់ផ្នែកខ្លះនៃដីរបស់ខ្លួន ហើយចុងក្រោយ ជួបការលំបាកក្នុងការទ្រទ្រង់ជីវភាពខ្លួនឯង។ នៅពេលសាកសួរពីបញ្ហាមួយចំនួន ពួកគេបានលើកឡើងពីបញ្ហាដីខ្សត់ជីជាតិ និងជំងឺដំណាំ ដែលនាំឲ្យចំណូល និងសន្តិសុខស្បៀងរបស់ពួកគេមានការថយចុះ។ អាជ្ញាធរមូលដ្ឋានបានលើកឡើងថា មានគ្រួសារជាច្រើនបានលក់ដីរបស់ពួកគេ និងសម្រេចចិត្តទៅធ្វើការនៅតាមចំការកៅស៊ូក្នុងសម្បទានដីសេដ្ឋកិច្ច ឬផ្លាស់ទៅរស់នៅជិតកូនៗរបស់ពួកគេដែលកំពុងធ្វើការងារ ឬបន្តការសិក្សានៅកន្លែងផ្សេងទៀត។

## ឧបសម្ព័ន្ធទី ៤៖ ទិន្នន័យអង្កេតពីសម្បទានដីសង្គមកិច្ចភូមិបឹងខ្នុរ ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ

*របកគំហើញសំខាន់ៗ*

- *ក្នុងចំណោមប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ៩៥% បានផ្លាស់មកនៅទីនេះ បន្ទាប់ពីពួកគេ បាត់បង់ផ្ទះសម្បែងដោយសារតែការបាក់ច្រាំងទន្លេមេគង្គ។ ក្នុងចំណោមទីតាំងសម្បទានដីសង្គមកិច្ចដែលត្រូវបានអង្កេតទាំងអស់ នេះគឺជាទីតាំងសម្បទានដីសង្គមកិច្ចតែមួយគត់ ដែលអ្នកទទួលផលភាគច្រើនពុំបានលើកឡើងថា ពួកគេទទួលបានដី ដោយសារតែពួកគេមានជីវភាពក្រីក្រ។*
- *OHCHR ដឹងថា ក្នុងចំណោមប្រជាពលរដ្ឋទទួលផល ២៥៣ គ្រួសារ ដែលត្រូវបានជ្រើសរើសពីដំបូងឲ្យមករស់នៅជាអចិន្ត្រៃយ៍ មានតែ ២៤ គ្រួសារប៉ុណ្ណោះ ដែលនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ នេះបង្ហាញថា ការទទួលបានសេវាជាមូលដ្ឋាន និងឱកាសរកចំណូល ឬការងារ ពុំមានគ្រប់គ្រាន់ និងមានន័យថា ទីតាំងសម្បទានដីសង្គមកិច្ចពុំមាននិរន្តរភាពឡើយ ប្រសិនបើពុំមានការវិនិយោគបន្ថែមឲ្យបានច្រើននោះ។*
- *មានគ្រួសារតាមផ្ទះតែ ៥៩% ប៉ុណ្ណោះ ដែលអះអាងថាបានចូលរួមក្នុងដំណើរការកំណត់ និងរៀបចំផែនការសម្រាប់ទីតាំងនេះ និងមានតែ ៦៨% ប៉ុណ្ណោះ បានលើកឡើងថា អាជ្ញាធរមូលដ្ឋានបានពន្យល់ពីដំណើរការជ្រើសរើស និងបែងចែកដី។ ការពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋត្រូវបានធ្វើឡើង ប៉ុន្តែហាក់បីដូចជាមានកម្រិតនៅឡើយ។ ប៉ុន្តែ អ្នកឆ្លើយតប ៨៦% ជឿថា ដំណើរការបែងចែកដីធ្វើឡើងប្រកបដោយយុត្តិធម៌។*
- *អ្នកឆ្លើយតបចំនួន ៤ នាក់ (១៨%) លើកឡើងថា ពួកគេបានបង់ប្រាក់ ដើម្បីបានចូលរួមក្នុងដំណើរការបែងចែកដីនេះ។*
- *គ្រួសារប្រជាពលរដ្ឋមួយក្រុម ក្នុងភូមិអូរព្រាំ ឃុំបឹងល្វា អះអាងថាធ្លាប់រស់នៅ និងធ្វើកសិកម្មលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ប្រមាណជា ១០ ឆ្នាំ មុនពេលដែលទីតាំងនេះត្រូវបានបង្កើតឡើយ។ ពួកគេ អះអាងថាត្រូវបានគេបណ្ដេញចេញដោយបង្ខំ*

*ដោយពុំមានការពិគ្រោះយោបល់ត្រឹមត្រូវ និងទទួលបានសំណងតិចតួច ឬពុំបានទទួលសំណងសោះ។*

- *ពុំមានគ្រួសារណា លើកឡើងថា បានទទួលប័ណ្ណកម្មសិទ្ធិដីនោះឡើយ បើទោះបីជាចំនួនខែជាមធ្យមដែលពួកគេរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះបានត្រឹមតែ ៣៥ ខែ នៅពេលសម្ភាសនេះក៏ដោយ (ក្រោមរយៈពេលកំណត់ ៥ ឆ្នាំ)។*
- *ចំណូលមធ្យមប្រចាំខែ ដែលបានពីការធ្វើកសិកម្ម មានកម្រិតទាបជាងកម្រិតមធ្យមសម្រាប់ទីតាំងសម្បទានដី សង្គមកិច្ចផ្សេងទៀតដែលត្រូវបានអង្កេត បើទោះបីជាគ្រួសារពីរភាគបីលើកឡើងថា ពួកគេបានទទួលចំណូលច្រើនជាង ឬច្រើនឆ្ងាយជាងចំណូលដែលពួកគេធ្លាប់ទទួលបាន នៅកន្លែងរស់នៅមុនៗក៏ដោយ។*
- *ក្នុងចំណោមគ្រួសារដែលត្រូវបានសម្ភាស ៩៥% បានលើកឡើងថា ពួកគេពុំមានទឹកស្អាតសម្រាប់បរិភោគឡើយ។ គ្រួសារបីភាគបួន ដែលត្រូវបានសម្ភាស បានដាក់ពិន្ទុឲ្យការទទួលបានទឹកស្អាតរបស់ពួកគេ ថាអន់ឆ្ងាយជាងកន្លែងដែលពួកគេរស់នៅមុនៗ។ នេះបង្ហាញថា បញ្ហាជុំវិញការទទួលបានទឹកស្អាត ក្នុងខេត្តកំពង់ធំ មានកម្រិតស្រួចស្រាវ ហើយមានការបែងចែកធនធានមិនគ្រប់គ្រាន់ឡើយសម្រាប់ការផ្តល់ទឹកស្អាត។ ពុំមានប្រព័ន្ធបញ្ចេញចោលទឹកស្អុយសម្រាប់ប្រជាពលរដ្ឋដែលត្រូវបានអង្កេតឡើយ ហើយក៏ពុំមានគ្រួសារតាមផ្ទះណាមានបរិក្ខារអនាម័យនោះដែរ។*
- *ការទទួលបានសេវាជាមូលដ្ឋានផ្សេងទៀត ដូចជា ការអប់រំ ជាដើម ក៏ជាបញ្ហាចោទផងដែរ។ បញ្ហាអសន្តិសុខស្បៀង គឺជាបញ្ហាមួយធំ។ ពុំមានប្រជាពលរដ្ឋដែលត្រូវបានអង្កេតណា មានអគ្គិសនីប្រើប្រាស់ឡើយ។*
- *បំណុលរបស់គ្រួសារកើនឡើងយ៉ាងគំហុក បើប្រៀបធៀបជាមួយនឹងកម្រិតមុនផ្លាស់មករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ បំណុលក្នុងខេត្តកំពង់ធំ មានកម្រិតខ្ពស់ឆ្ងាយជាងកម្រិតមធ្យមសម្រាប់ទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀត។*

នៅទីតាំងសម្បទានដីសង្គមកិច្ចខេត្តកំពង់ធំនេះ ការសម្ភាសត្រូវបានធ្វើឡើងជាមួយនឹងគ្រួសារតាមផ្ទះចំនួន ២២ ។ អាជ្ញាធរមូលដ្ឋាន បានលើកឡើងថា ប្រជាពលរដ្ឋ

សរុប ២៥៣ គ្រួសារ បានទទួលដីក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះ។ អាជ្ញាធរ ពុំមានព័ត៌មានអំពីចំនួនប្រជាពលរដ្ឋសរុបដែលរស់នៅលើទីតាំងនេះឡើយ។ តាមរយៈការសម្ភាស និងការចុះដល់ទីតាំងផ្ទាល់ OHCHR ប៉ាន់ប្រមាណថា មានប្រជាពលរដ្ឋតែ ២៤ គ្រួសារប៉ុណ្ណោះ ដែលរស់នៅលើទីតាំងនេះជាអចិន្ត្រៃយ៍។ គ្រួសារទទួលផលជាច្រើនផ្សេងទៀតហាក់បីដូចជាបានលក់ដីរបស់ពួកគេទៅឲ្យប្រជាពលរដ្ឋផ្សេងទៀតដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ឬទៅឲ្យបុគ្គលផ្សេងទៀត។ ព័ត៌មានត្រលប់ ដែលOHCHR ទទួលបាន បង្ហាញថា ហេដ្ឋារចនាសម្ព័ន្ធមិនល្អ (ផ្លូវតូចៗ) និងការពុំមានទឹកស្អាត គឺជាមូលហេតុចម្បង ដែលគ្រួសារសម្រេចចិត្តថាមិនផ្លាស់មករស់នៅតំបន់នេះ។

កម្មវិធីសម្បទានដីសង្គមកិច្ចនេះ ហាក់បីដូចជា ត្រូវបានផ្តួចផ្តើមបង្កើតឡើងដោយសារតែការបាក់ច្រាំងតាមដងទន្លេមេគង្គ ក្នុងភូមិពាមក្នុង និងភូមិពាមក្រៅ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ សមាជិកសហគមន៍ម្នាក់បានអំពាវនាវឲ្យមន្ត្រីមូលដ្ឋានជួយបង្កើតកម្មវិធីសម្បទានដីសង្គមកិច្ចសម្រាប់គ្រួសារ ដែលបានបាត់បង់ផ្ទះរបស់ពួកគេ បន្ទាប់ពីបាក់ដីច្រាំងទន្លេរួចមក។ ក្រោយពីបានទទួលការគាំទ្រពីអាជ្ញាធរខេត្ត កាលពីខែ មករា ឆ្នាំ ២០១២ សម្តេចនាយករដ្ឋមន្ត្រីបានពិនិត្យ និងសម្រេចតាមការស្នើសុំ និងបានបញ្ជាឲ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្វែងរកដំណោះស្រាយសម្រាប់គ្រួសារដែលគ្មានដី។ ក្នុងខែ វិច្ឆិកា ឆ្នាំ ២០១២ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសម្រេចយល់ព្រមលើផែនការសម្បទានដីសង្គមកិច្ចនេះ។ មានការរាយការណ៍ប្រាប់ OHCHR ថាមានគ្រួសារខ្លះ (មិនបានដឹងចំនួនពិតប្រាកដ) បានលក់ដីដែលត្រូវបានប្រគល់ឲ្យពួកគេអស់ហើយ។

អ្នកឆ្លើយតប ៧៣% គឺជាស្ត្រី បើទោះបីជាមានអ្នកឆ្លើយតបត្រឹមតែ ២៧% ប៉ុណ្ណោះដែលបានប្រកាសថាមេគ្រួសារជាស្ត្រី។ ៨២% លើកឡើងថា ពួកគេរៀបការរួច ឬកំពុងរស់នៅជាមួយអ្នកដែលពួកគេមានទំនាក់ទំនងជាមួយ។ ១៤% គឺជាស្ត្រីមេម៉ាយ/បុរសពោះម៉ាយ ឬលែងលះ។ អាយុមធ្យមរបស់អ្នកឆ្លើយតបគឺ ៤៤ ឆ្នាំ។ ខ្នងផ្ទះដែលតាំងនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ មានចំនួនសមាជិកជាមធ្យម ៣,៤១ នាក់នៅក្នុងផ្ទះ និង

មានកូន ១,១៨ នាក់ រស់នៅក្នុងផ្ទះតែមួយ។ អ្នកឆ្លើយតបទាំងអស់លើកឡើងថា ពួកគេជាជនជាតិខ្មែរ។

អាជ្ញាធរមូលដ្ឋានផ្តល់ចម្លើយផ្សេងៗគ្នា នៅពេលត្រូវបានសាកសួរថាតើទីតាំងសម្បទានដីសង្គមកិច្ចនេះគឺជាដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ និងថាតើពេលណាដែលសម្បទានដីសង្គមកិច្ចនេះត្រូវបានចុះបញ្ជី ដែលនេះបង្ហាញពីការយល់ដឹងដ៏មានកម្រិតអំពីដំណើរការ និងនីតិវិធីសម្បទានដីសង្គមកិច្ច។អាជ្ញាធរអះអាងថាទីតាំងសម្បទានដីសង្គមកិច្ចនេះពីមុនគឺជាដីព្រៃ។ អ្នកសុំដីសម្បទានសង្គមកិច្ចភាគច្រើន គឺជាប្រជាពលរដ្ឋមកពីភូមិពាមក្នុង និងភូមិពាមក្រៅ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

នៅពេលសាកសួរពីមូលហេតុដែលពួកគេបានទទួលដីសម្បទានសង្គមកិច្ច អ្នកឆ្លើយតបតែ ៤១% ប៉ុណ្ណោះ ដែលបានឆ្លើយថា ដោយសារតែពួកគេគ្មានដី ដោយមាន ៩៦% លើកឡើងថា ដោយសារតែពួកគេត្រូវផ្លាស់ប្តូរទីលំនៅ ព្រោះគ្រោះមហន្តរាយ។ មានចំណុចត្រួតគ្នានៅទីនេះ ដោយអ្នកឆ្លើយតបផ្តល់ចម្លើយច្រើនយ៉ាង ដែលបង្ហាញពីហេតុផលដែលនាំឲ្យពួកគេទទួលបានដី។ មានប្រជាពលរដ្ឋតែ ៤ គ្រួសារប៉ុណ្ណោះ ដែលលើកឡើងពីភាពក្រីក្រ។ នៅពេលសាកសួរពីមូលហេតុ ដែលគ្រួសារផ្សេងទៀតនៅទីតាំងសម្បទានដីសង្គមកិច្ចនេះបានទទួលដី ចម្លើយគឺត្រូវគ្នាជាមួយនឹងចម្លើយខាងលើដែរគឺការគ្មានដី និងគ្រោះមហន្តរាយធម្មជាតិ គឺជាមូលហេតុ។

អ្នកទទួលផលតែ ៥០% ប៉ុណ្ណោះ ដែលមានប័ណ្ណសម្គាល់គ្រួសារក្រីក្រ។ អ្នកទទួលផលភាគច្រើនផ្លាស់មកនៅទីនេះ ដោយសារតែពួកគេបាត់បង់ដី និងផ្ទះរបស់ពួកគេ បន្ទាប់ពីបាក់ដីតាមដងទន្លេមេគង្គ។ នេះពន្យល់ពីមូលហេតុ ដែលពួកគេពុំមាន ឬមិនត្រូវការប័ណ្ណសម្គាល់គ្រួសារក្រីក្រ ដើម្បីបានទទួលដី។

គ្រួសារតាមផ្ទះតែ ៥៩% ប៉ុណ្ណោះ ដែលបានអះអាងថាបានចូលរួមក្នុងការកំណត់និងការរៀបចំផែនការនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ដោយប្រជាពលរដ្ឋដែលរស់នៅលើដីនេះត្រឹមតែ ៦៨% បានលើកឡើងថា អាជ្ញាធរមូលដ្ឋានបានពន្យល់ពី ដំណើរការ

ជ្រើសរើស និងបែងចែកដី និងពីការប្រើប្រាស់ប្រព័ន្ធចាប់ឆ្នោត ដើម្បីបែងចែកដី។ មានអ្នកឆ្លើយតប ៦៤% ប៉ុណ្ណោះ ដែលបានលើកឡើងថា ពួកគេបានចូលរួមយ៉ាងសកម្ម ក្នុងការជ្រើសរើសក្បាលដី។ មានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប៉ុន្តែហាក់បីដូចជាមានកម្រិត ដោយគ្រួសារមួយភាគបីមិនបានចូលរួម។ បើទោះបីជាបែបនេះក៏ដោយ ប្រជាពលរដ្ឋ ៨៦% ជឿថា <u>ដំណើរការបានអនុវត្តដើម្បីបែងចែកដីធ្វើឡើងប្រកបដោយភាពយុត្តិធម៌។</u> ភាគរយនេះគឺខ្ពស់ជាងតួលេខមធ្យម ៦៧% នៅក្នុងគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ដែលត្រូវបានអង្កេត។ មានអ្នកឆ្លើយតប ៤ នាក់ (ស្មើនឹង ១៨%) លើកឡើងថា ពួកគេបានបង់លុយ ដើម្បីចូលរួមក្នុងដំណើរការបែងចែកដី ដោយត្រូវបង់ប្រាក់ជាមធ្យមប្រមាណជា ៣១,៨ ដុល្លារ។

គ្រួសារតាមផ្ទះ ៨៦% ដែលរស់នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ<u>ពុំបានទទួលឯកសារពាក់ព័ន្ធ</u>នឹងការបែងចែកដីឡើយ ដែលនេះជាបញ្ហាចោទមួយ។ ក្នុងករណីដែលពុំមានប័ណ្ណកម្មសិទ្ធិដី គ្រួសារគួរមានឯកសារបង្ហាញពីដំណើរការរៀបចំផែនការ និងបែងចែកដីដែលជាមធ្យោបាយមួយ ដើម្បីការពារសិទ្ធិភោគៈ និងសិទ្ធិមានកម្មសិទ្ធិរបស់ពួកគេ។ គ្រួសារ ៦៤% បានចុះកិច្ចសន្យាជាមួយអាជ្ញាធរ ទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ច ចំពោះសម្បទានដីសង្គមកិច្ចនេះ។

អ្នកឆ្លើយតប ៧៣% <u>បានមើលផែនការសម្បទានដីសង្គមកិច្ច</u>។ ក្រុមប្រឹក្សាឃុំគួរផ្តួចផ្តើមរៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ចស្របទៅតាមលក្ខខណ្ឌ ដូចដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។ អ្នកទទួលផលពីសម្បទានដីសង្គមកិច្ច "ត្រូវតែបានត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ស្របតាមផែនការសម្បទានដីសង្គមកិច្ច ដែលបានយល់ព្រម។"[82] ប៉ុន្តែ អ្នកឆ្លើយតបត្រឹមតែ ៥% ប៉ុណ្ណោះ បានអះអាងថា ត្រូវបានស្នើឲ្យចូលរួមកែលំអស្ថានភាព នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ នេះ

[82] មាត្រា ១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣)។

បង្ហាញពីកម្រិតទាបនៃការជម្រុញឲ្យសហគមន៍ចូលរួម ពីសំណាក់អាជ្ញាធរមូលដ្ឋាន ក្នុងការអភិវឌ្ឍទីតាំងនេះ។

អ្នកឆ្លើយតបទាំងអស់ បានលើកឡើងថា ពួកគេបានត្អូញត្អែរប្រាប់ទៅអាជ្ញាធរពីស្ថានភាពនៃការរស់នៅលើទីតាំងនេះ។ ការត្អូញត្អែរញឹកញាប់ជាងគេ គឺពាក់ព័ន្ធនឹងកង្វះទឹកស្អាត (៨២%) កង្វះអាហារ (២២%) ការទៅមណ្ឌលសុខភាព (៥១%) ចំងាយទៅកាន់សាលារៀន (១៨%) គុណភាពផ្លូវ (៣៦%) និងអគ្គិសនី (២៣%)។ ការត្អូញត្អែរផ្សេងទៀតមានដូចជា កង្វះគ្រូក្នុងសាលារៀនដែលស្ថិតក្នុងទីតាំងនេះ ពុំមានវត្តនៅជិតផ្ទះ និងបញ្ហាសន្តិសុខនៅតំបន់នេះ។ មានអ្នករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះតែ ២៣% ប៉ុណ្ណោះ ដែលលើកឡើងថាអាជ្ញាធរអាចឆ្លើយតបចំពោះការត្អូញត្អែររបស់ពួកគេ។ ចំណុចទាំងនេះត្រូវបានលើកឡើង បើទោះបីជាមានអ្នកឆ្លើយតប ៥០% លើកឡើងថា អាជ្ញាធរមូលដ្ឋានបានពិនិត្យតាមដានស្ថានភាពក្នុងទីតាំងនេះយ៉ាងសកម្មយ៉ាងណាក៏ដោយ។ អាជ្ញាធរមូលដ្ឋានបានដឹងយ៉ាងច្បាស់ពីស្ថានភាពទាំងនេះ បន្ទាប់ពីបានទទួលយកការត្អូញត្អែររបស់ប្រជាពលរដ្ឋ និងបានចូលរួមពិនិត្យតាមដាន និងចុះផ្សព្វផ្សាយព័ត៌មានរួចមក។ អាជ្ញាធរអាចខ្វះឆន្ទៈ សមត្ថភាព ឬធនធាន ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ អ្នកឆ្លើយតបបានលើកឡើងថា កិច្ចប្រជុំតាមភូមិ (៦៣%) គឺជាមធ្យោបាយចម្បងសម្រាប់លើកឡើងពីទុក្ខលំបាកនានា ដែលនេះបង្ហាញពីកម្រិតនៃការចូលរួមខ្ពស់ពីសំណាក់អាជ្ញាធរមូលដ្ឋាន។ ប្រជាពលរដ្ឋ ៦៨% បានលើកឡើងថា មានការទទួលយកការត្អូញត្អែរ ឬប្រមូលភស្តុតាងពីប្រជាពលរដ្ឋជារៀងរាល់ខែ ឬរៀងរាល់ ៣ ខែម្តង។

គ្រួសារតាមផ្ទះទាំងអស់ បានលើកឡើងថា សហគមន៍បានផ្តួចផ្តើមគំនិតកែលំអលក្ខខណ្ឌនៃការរស់នៅ ក្នុងទីតាំងសម្បទាន ដីសង្គមកិច្ចនេះ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះផ្តោតការយកចិត្តទុកដាក់លើការកែលំអ ការសាងសង់ ឬការថែទាំផ្លូវ (៥០%) ការបង្កើនលទ្ធភាពទទួលបានសេវាថែទាំសុខភាព (៥០%) វត្តអារាមក្នុងមូលដ្ឋាននេះ (៨០%) ការទទួលបានទឹក (៥៥%) និងសាលារៀនក្នុងមូលដ្ឋាន (៥០%)។

**ភាពសមស្របនៃដី៖**

ប្រជាពលរដ្ឋចំនួន ២០ គ្រួសារ (៩១%) ប៉ុណ្ណោះ បាន<u>ទទួលដីលំនៅឋានផង និងដីកសិកម្មផង</u>។ ប្រជាពលរដ្ឋ ២ គ្រួសារទៀត ដែលត្រូវបានសម្ភាសផងដែរនោះ បានទទួលតែដីលំនៅឋានប៉ុណ្ណោះ។ គ្រួសារទាំងពីរនេះអាចមានមធ្យោបាយផ្សេងទៀត ដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន។ អនុក្រឹត្យនេះចែងថា ក្បាលដីអាចផ្តល់*សម្រាប់សង់លំនៅឋាន ដល់គ្រួសារក្រីក្រគ្មានផ្ទះសម្បែង ឬដល់គ្រួសារក្រីក្រ សម្រាប់ធ្វើកសិកម្ម*។ ក្នុងករណីដែលពុំមានប័ណ្ណគ្រួសារក្រីក្រ ជាការសំខាន់ណាស់ ដែលអាជ្ញាធរមូលដ្ឋានត្រូវវាស់វែងកម្រិតនៃភាពក្រីក្រ និងតម្រូវការរបស់គ្រួសារទទួលដីនីមួយៗឲ្យបានត្រឹមត្រូវដោយប្រើប្រាស់មធ្យោបាយដែលអាចជឿទុកចិត្តបានផ្សេងទៀត។

អ្នកឆ្លើយតបទាំងអស់បានលើកឡើងថា <u>ដីសម្រាប់ធ្វើកសិកម្មខ្លះរបស់ពួកគេត្រូវបាន "កាប់ឆ្ការសំអាត"</u> និងអាចយកមកធ្វើកសិកម្មបាន នៅពេលដែលពួកគេបានទទួលពីដំបូង។ ៣៦% និយាយថាដីទាំងអស់របស់ពួកគេត្រូវបានកាប់ឆ្ការសំអាត និងនៅសល់ ៦៤% ទៀត និយាយថា ដីមួយចំនួនត្រូវបានសំអាត។ មានតែគ្រួសារភាគតិចក្នុងចំណោមគ្រួសារទាំងនេះតែប៉ុណ្ណោះ (២១%) ដែលនៅមិនទាន់កាប់ឆ្ការសំអាតដីរបស់ខ្លួននៅឡើយ ដោយពួកគេនិយាយថា ពួកគេពុំមានលទ្ធភាពចំណាយលើការកាប់ឆ្ការសំអាតដីនេះបាន ដែលបង្ហាញថា បច្ចុប្បន្ន ដីនេះមិនត្រូវបានប្រើប្រាស់ សម្រាប់ធ្វើកសិកម្ម ទៅតាមគោលបំណងពីដំបូងឡើយ។ ប្រជាពលរដ្ឋភាគច្រើន (៨២%) មានបំណងដាំដំឡូងមី និង ៣២% ទៀត ចង់ដាំស្វាយ។ អាជ្ញាធរមូលដ្ឋានលើកឡើងថា ពួកគេពុំមានលទ្ធភាពផ្តល់ឧបករណ៍សម្ភារៈ ឬការគាំទ្រដល់គ្រួសារទទួលដីថ្មីៗ ដូចអ្វីដែលបានធ្វើនៅទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀតឡើយ។

ពុំមានគ្រួសារណាបានលើកឡើងថា ពួកគេ <u>បានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីនោះទេ</u>។ រយៈពេលនៃការរស់នៅជាមធ្យមលើទីតាំងសម្បទានដីសង្គមកិច្ចនេះគឺ ៣៥ ខែ គិតត្រឹមពេលសម្ភាសនេះ។ យោងតាមអនុក្រឹត្យនេះ អ្នកទទួលផលត្រូវតែគោរពទៅតាមលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសម្បទានដីសង្គមកិច្ច ដោយត្រូវរស់នៅឲ្យបាន ៥ ឆ្នាំ ទើបមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិដីស្របច្បាប់។ អ្នកឆ្លើយតបភាគច្រើន (៦៤%) *មិន* ត្រូវបានប្រាប់

ថាពួកគេនឹងទទួលបានប័ណ្ណកម្មសិទ្ធិនោះទេ។ ប្រជាពលរដ្ឋភាគច្រើន (៨៦%) បានទទួលឯកសារខ្លះ ពាក់ព័ន្ធនឹងភោគៈ ឬកម្មសិទ្ធិ (៩០% ឯកសារពាក់ព័ន្ធនឹងការចាប់ឆ្នោតយកដី និងមួយគ្រួសារ (៥%) មានកិច្ចសន្យា ពាក់ព័ន្ធនឹងដីសម្បទានសង្គមកិច្ចនេះ) ដែលផ្តល់ឲ្យពួកគេនូវសុវត្ថិភាពក្នុងការកាន់កាប់ដ៏មានកម្រិតក្នុងអំឡុងអន្តរកាលនេះ។ នេះមិនមែនជាស្ថានភាពល្អប្រសើរនោះទេ។ ប្រជាពលរដ្ឋគ្រប់រូបគួរមានឯកសារ និងកិច្ចសន្យា ពាក់ព័ន្ធជាមួយនឹងដីសម្បទានសង្គមកិច្ចនេះ។ ប៉ុន្តែ តួលេខនេះគឺខ្ពស់ឆ្ងាយជាងតួលេខមធ្យមសម្រាប់គ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ (៥៣%)។

ជាការប្រៀបធៀប ៥៦% នៃអ្នកឆ្លើយតបទាំងអស់ នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ បានទទួលប័ណ្ណកម្មសិទ្ធិដី បើទោះបីជាចំនួនខែជាមធ្យមនៃការរស់នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់គឺខ្ពស់រហូតដល់ ៨២ ខែ ក៏ដោយ។ ប្រជាពលរដ្ឋគ្រប់គ្រួសារទាំងអស់ គួរទទួលបានព័ត៌មានអំពីពេលវាលាដែលពួកគេត្រូវទទួលបានប័ណ្ណកម្មសិទ្ធិដី ហើយពួកគេទាំងអស់គួរទទួលបានឯកសារដែលបង្ហាញពីសិទ្ធិភោគៈ និងទទួលបានសិទ្ធិកាន់កាប់រហូតដល់រយៈពេល ៥ ឆ្នាំ ត្រូវបានបញ្ចប់ និងមានការចែកប័ណ្ណកម្មសិទ្ធិ។

<u>ផ្ទៃដីមធ្យមសម្រាប់សង់លំនៅឋាន</u>គឺ ១១៣២ ម៉ែត្រការ៉េ ជាទំហំតូចជាងក្បាលដីមធ្យម នៅតាមទីតាំងសម្បទានដីសង្គមកិច្ចដែលត្រូវបានអង្កេតនេះ (១៤២០ ម៉ែត្រការ៉េ)។ មានអ្នកឆ្លើយតបតែ ២ នាក់ប៉ុណ្ណោះ ដែលបានលើកឡើងថា ពួកគេបានទទួលក្បាលដីតូចជាងអ្នកជិតខាងរបស់ខ្លួន។

<u>ទំហំផ្ទះជាមធ្យម</u>គឺ ២២ ម៉ែត្រការ៉េ ពោលគឺតូចជាងទំហំផ្ទះគិតជាមធ្យមនៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់បន្តិច (២៨ ម៉ែត្រការ៉េ)។ មានផ្ទះតែ ២ ប៉ុណ្ណោះ ដែលត្រូវបានសាងសង់ឡើង មុនពេលដែលគ្រួសារទាំងនេះផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ផ្ទះផ្សេងទៀតត្រូវបានសាងសង់ដោយគ្រួសារផ្ទាល់ និងដោយអ្នកជិតខាង។ គ្រួសារអាចសាងសង់ផ្ទះបាន ជាមធ្យម ៦ ខែ ក្រោយពីបានទទួលដីសម្បទានសង្គមកិច្ច។ អ្នកឆ្លើយតបភាគតិច (២៣%) លើកឡើងថា លំនៅឋានថ្មីរបស់ពួកគេ*ល្អជាង* ឬ*ល្អឆ្ងាយ*

*ជាង* ផ្ទះមុនៗរបស់ពួកគេ។ ប្រជាពលរដ្ឋ ១០ គ្រួសារ (៤៥%) បានលើកឡើងថា ផ្ទះថ្មីរបស់ពួកគេ*អន់ជាង* ឬ*អន់ឆ្ងាយជាង* ផ្ទះមុនរបស់ពួកគេ។ បើទោះបីជាចំណុចនេះមួយផ្នែកដោយសារតែការយល់ឃើញក៏ដោយ វាជាសញ្ញាសំខាន់បង្ហាញថាពីជោគជ័យនៃគម្រោងសម្បទានដីសង្គមកិច្ចនេះ។ តើគ្រួសារក្រីក្រ ឬគ្មានដី បានទទួលលំនៅឋានសមរម្យ ដែលអាចបំពេញទៅតាមតម្រូវការជាមូលដ្ឋានរបស់ពួកគេដែរឬទេ? ក្នុងករណីនេះ គម្រោងសម្បទានដីសង្គមកិច្ចនេះហាក់បីដូចជាមិនបានសម្រេចគោលដៅនេះឡើយ។

<u>អ្នកឆ្លើយតប ៥៥% លើកឡើងថា ពួកគេពុំមានអារម្មណ៍ថាខ្លួនមានសុវត្ថិភាព ក្នុងផ្ទះបច្ចុប្បន្នរបស់ខ្លួនឡើយ</u> ដោយសារតែការខូចខាតបង្កឡើងដោយសារអំពើចោរកម្ម (១៧%) ឬដោយខ្យល់ /ភ្លៀង (៤៩%)។ គេមិនបានដឹងច្បាស់ថាតើមានប្រជាពលរដ្ឋប៉ុន្មានគ្រួសារ ដែលបានទទួលរងគ្រោះដោយសារអំពើចោរកម្ម ឬការខូចខាតបង្កឡើងដោយសារអាកាសធាតុនោះទេ។

<u>ក្បាលដីសម្រាប់ធ្វើកសិកម្មជាមធ្យមមានទំហំ</u> ១,៨២ ហិកតា ដែលធំជាងទំហំមធ្យមសម្រាប់គ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ដែលត្រូវបានអង្កេត (១,១៧ ហិកតា)។ ប្រជាពលរដ្ឋចំនួន ២ នាក់ លើកឡើងថា អ្នកជិតខាងរបស់ពួកគេទទួលបានដីធំជាង ហើយអ្នកឆ្លើយតបដែលនៅសល់លើកឡើងថា ក្បាលដីរបស់ពួកគេមានទំហំស្មើគ្នា។ អ្នកឆ្លើយតប ៩១% បានលើកឡើងថា ឥឡូវនេះ ពួកគេបានដាំដំណាំលើដីនៅជុំវិញផ្ទះរបស់ពួកគេ បើទោះបីជា អ្នកឆ្លើយតបជាច្រើន (៤៨%) ពុំទាន់ទទួលចំណូលសម្រាប់គ្រួសារពីសកម្មភាពនេះក៏ដោយ។ ពួកគេភាគច្រើនដាំទុកបរិភោគ ជាជាងយកទៅលក់។ <u>ចំណូលប្រចាំឆ្នាំជាមធ្យម ដែលបានពីការធ្វើកសិកម្ម គឺ ២៧១ ដុល្លារ</u>។ នេះជាតួលេខទាបជាងតួលេខមធ្យម សម្រាប់ទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀត ដែលត្រូវបានអង្កេត។ អ្នកឆ្លើយតប ២៧% លើកឡើងថា នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ពួកគេរកចំណូលបានតិចជាងពេលដែលពួកគេរស់នៅទីតាំងមុន។ ផ្ទុយទៅវិញ ៦៤% ទទួលបានចំណូលច្រើនជាង ឬច្រើនឆ្ងាយជាងចំណូលដែលពួកគេធ្លាប់ទទួលបាន។

ពុំមានប្រជាពលរដ្ឋដែលកំពុងរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ហើយដែលត្រូវបានសាកសួរ បានលើកឡើងថា បានលក់ ឬធ្វើអំណោយផ្នែកខ្លះនៃដីរបស់ពួកគេឡើយ។ ប្រជាពលរដ្ឋមួយភាគតូចបានទទួលជំនួយខ្លះ ដើម្បីបង្កបង្កើនផលលើដីរបស់ពួកគេ ពេលដែលពួកគេមក រស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ (២៤%)។ ពុំមានប្រជាពលរដ្ឋណាអះអាងថាធ្លាប់មានជំនាញកសិកម្ម មុនពេលផ្លាស់មកនៅទីតាំងនេះឡើយ ហើយក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ ៨៣% និយាយថា ជំនាញធ្វើកសិកម្មរបស់ពួកគេពុំបានល្អប្រសើរជាងមុនឡើយ ដែលនេះបង្ហាញថា ការគាំទ្រ និងការបណ្តុះបណ្តាលនៅមិនទាន់បានគ្រប់គ្រាន់នៅឡើយ រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ។ នេះក៏បង្ហាញផងដែរថា ចាំបាច់ត្រូវមានការងារ ឬឱកាសរកចំណូលក្នុងទម្រង់ផ្សេងទៀត ហើយការបណ្តុះបណ្តាល និងការគាំទ្រខាងការធ្វើកសិកម្មក៏ចាំបាច់ត្រូវមាននៅតាមទីតាំងសម្បទានដីសង្គមកិច្ច តូយ៉ាងដូចជាទីតាំងនេះផងដែរ។ នេះក៏ទាមទារឲ្យមានការវាយតម្លៃលើជំនាញ និងចំណេះដឹង ក្នុងដំណាក់កាលរៀបចំផែនការសម្បទានដីសង្គមកិច្ចនេះ ដើម្បីកំណត់ពីតម្រូវការរបស់ប្រជាពលរដ្ឋ រៀបចំអន្តរាគមន៍ដែលមានសក្តានុពល និងធ្វើការបែងចែកធនធានដែលកំពុងតែខ្វះខាតឲ្យមានប្រសិទ្ធភាពបំផុត។

**ជម្លោះដីធ្លីៈ**

ក្នុងចំណោមអ្នកឆ្លើយតបដែលត្រូវបានសម្ភាសទាំងអស់ មានតែ ម្នាក់ ដែលបានលើកឡើងថា បច្ចុប្បន្ននេះ កំពុងជាប់ពាក់ព័ន្ធនឹងជម្លោះដីធ្លី ទាក់ទិននឹងដីផ្ទះសម្បែងរបស់ពួកគេ ជាមួយអ្នកដែលធ្លាប់រស់នៅលើដីនេះកន្លងមក។ ប៉ុន្តែ មានអ្នកឆ្លើយតបចំនួន ៣ នាក់ ជួបប្រទះនឹងការទន្ទ្រានដីពីអ្នកផ្សេងទៀត។

ការពិភាក្សាក្រុមគោលដៅខាងក្រៅមួយ ត្រូវបានធ្វើឡើងជាមួយនឹងប្រជាពលរដ្ឋចំនួន ៣៣ គ្រួសារ ក្នុងភូមិអូរប្រាំ ឃុំបឹងល្វា ដែលអះអាងថាធ្លាប់រស់នៅ និងធ្វើកសិកម្មលើទីតាំង ដែលត្រូវបានជ្រើសរើសធ្វើជាសម្បទានដីសង្គមកិច្ចនេះ រយៈពេលប្រមាណជា ១០ ឆ្នាំ មុនពេលដែលសម្បទានដីសង្គមកិច្ចនេះត្រូវបានបង្កើតឡើង។ ពួកគេអះអាងថា ត្រូវបានគេបណ្តេញចេញដោយពុំមានការពិគ្រោះយោបល់ត្រឹមត្រូវ ដើម្បីយកដីផ្តល់ដល់អ្នក

ចំណូលថ្មី។ ប្រជាពលរដ្ឋដែលធ្លាប់រស់នៅលើដីនេះមួយចំនួនអះអាងថា ពួកគេបានទទួលសំណងតិចតួច ឬទទួលបានជាដីនៅទីតាំងផ្សេង ប៉ុន្តែប្រជាពលរដ្ឋផ្សេងទៀតលើកឡើងថា ពួកគេមិនបានទទួលអ្វីទាំងអស់ ហើយពាក្យបណ្ដឹងដែលពួកគេដាក់ទៅអាជ្ញាធរមូលដ្ឋាន ក៏មិនត្រូវបានគេពិនិត្យវាយតម្លៃឲ្យបានត្រឹមត្រូវនោះដែរ។ ក្រុមអង្កេតពុំបានវាយតម្លៃលើការទាមទារដីនេះឡើយ ប៉ុន្តែបានសម្ភាសប្រជាពលរដ្ឋដែលជាអ្នកដាក់ពាក្យបណ្ដឹង និងបានកត់ត្រាទុកក្នុងឯកសារកន្លងមកថា អ្នកទាំងនេះបានអះអាងថាខ្លួនត្រូវបានផាត់ចេញពីដំណើរការរៀបចំផែនការ និងត្រូវបានបណ្ដេញចេញដោយបង្ខំពីដីរបស់ ពួកគេដោយពុំមានការអនុវត្តឲ្យបានត្រឹមត្រូវ។

អាជ្ញាធរមូលដ្ឋានបានអះអាងថាមានប្រជាពលរដ្ឋ ៦៥ គ្រួសារ រស់នៅលើដីនេះ មុនពេលដែលទីតាំងសម្បទាន ដីសង្គមកិច្ចត្រូវបានបង្កើតឡើង។ មានការជូនដំណឹងដល់ប្រជាពលរដ្ឋដែលរស់នៅលើដីនេះកន្លងមក អំពីដំណើរការបង្កើតសម្បទានដីសង្គមកិច្ចនេះ។ គ្រួសារទាំងនេះ ដោយចោទថា ពួកគេ ត្រូវបានគេបណ្ដេញចេញ ឬផ្លាស់ប្ដូរទីតាំងដោយមាន គ្រួសារមួយចំនួន ប៉ុន្តែមិនទាំងអស់នោះទេ ហាក់បីដូចជាបានទទួលដីជំនួសនៅកន្លែងផ្សេង។ វាមិនច្បាស់ទេថាតើប្រជាពលរដ្ឋដែលធ្លាប់រស់នៅលើដីនេះបានយល់ព្រម ឬមានការប្រើប្រាស់ដំណើរការអ្វី សម្រាប់រកដីនៅទីតាំងផ្សេងសម្រាប់ពួកគេនោះ។

**ការទទួលបានទឹក និងអនាម័យ៖**

គ្រួសារ ៩៦% ដែលត្រូវបានសម្ភាស ពុំមានលទ្ធភាពទទួលបានទឹកស្អាតសម្រាប់បរិភោគឡើយ។ ប្រជាពលរដ្ឋទៅរកទឹកពីអន្លង់សាធារណៈ (៥៦%) ឬ អូរ ឬប្រឡាយ (៤៦%)។ ប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ច ៨២% បានធ្វើប្រព្រឹត្តិកម្មទឹករបស់ពួកគេ មុនពេលផឹក តាមរយៈការដាំ។ ពុំមានអ្នកឆ្លើយតបណាប្រើប្រាស់ឧបករណ៍ចម្រោះឡើយ។ អ្នកឆ្លើយតប ៥០% បានលើកឡើងថាទឹកបរិភោគរបស់ពួកគេមានពណ៌រសជាតិ និង/ឬក្លិនចម្លែក។ ពុំមានគ្រួសារណាលើកឡើងថាទឹករបស់ពួកគេត្រូវបានសំអាតដោយប្រើសារធាតុក្លរឡើយ។ អ្នកឆ្លើយតបសម្ភាស ៧៧% បានដាក់ពិន្ទុឲ្យការទទួលបានទឹកស្អាតរបស់ខ្លួនថា*អន់ថយជាង*កន្លែងដែលពួកគេរស់នៅពីលើកមុន ហើយអ្នកឆ្លើយ

តបសម្ភាស ១៨% ទៀត រៀបរាប់ថាការទទួលបានទឹករបស់ខ្លួនអន់ជាងមុន។ នេះបង្ហាញថា បញ្ហាពាក់ព័ន្ធនឹងការទទួលបានទឹកស្អាតនេះគឺមានភាពស្រួចស្រាវខ្លាំង ក្នុងខេត្តកំពង់ធំ ហើយពុំមានការបែងចែកធនធានគ្រប់គ្រាន់ សម្រាប់ផ្គត់ទឹកស្អាតឡើយ។

ពុំមានប្រព័ន្ធ បញ្ចេញចោលទឹកស្អុយឡើយ សម្រាប់ប្រជាពលរដ្ឋទាំងអស់ ដែលបានអង្កេត ហើយពុំមានគ្រួសារតាមផ្ទះណាដែលមានបរិក្ខារអនាម័យឡើយ។ ប្រជាពលរដ្ឋបន្ទោរបង់ក្នុងព្រៃ ឬជីកអន្លង់។ អ្នកឆ្លើយតប ៧៧% បានដាក់ពិន្ទុឲ្យលក្ខខណ្ឌអនាម័យរបស់ខ្លួនថាអន់ ឬអន់ឆ្ងាយជាងស្ថានភាពកាលពីមុន។

ពុំមានប្រជាពលរដ្ឋដែលត្រូវបានសាកសួរណាម្នាក់ មានអគ្គិសនីប្រើប្រាស់ឡើយ នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ សម្គាល់ សំណួរនៃការអង្កេតនេះសួរពីអគ្គិសនី "ដែលរដ្ឋផ្តល់ឲ្យ" តាមរយៈការភ្ជាប់បណ្តាញមេ។ វាមិនមែនន័យថា ពុំមានម៉ាស៊ីនភ្លើង ឬប្រភពអគ្គិសនីផ្សេងទៀតនោះឡើយ។

**សេវាសុខាភិបាល៖**

ជាមធ្យម ប្រជាពលរដ្ឋត្រូវចំណាយពេល ៩៣ នាទី ដើម្បីធ្វើដំណើរទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុត និង ១០៦ នាទី ដើម្បីធ្វើដំណើរទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត។ ប្រជាពលរដ្ឋដែលរស់នៅលើដីសម្បទានសង្គមកិច្ចនេះ ៣២% លើកឡើងថា ពួកគេមានជំងឺញឹកញាប់ជាងមុន បើធៀបជាមួយនឹងស្ថានភាពនៃការរស់នៅពីមុន។ ជាពិសេស គ្រុនក្តៅ ឬផ្តាសាយ និងឈឺក្រពះកើតឡើងជាញឹកញាប់ ។ អ្នកឆ្លើយតប ៦៨% លើកឡើងថា ការទទួលបានសេវាសុខភាពអន់ឆ្ងាយជាងមុន បើធៀបជាមួយនឹងស្ថានភាពនៅកន្លែងរស់នៅមុន ហើយ ៩% លើកឡើងថាអន់ជាងមុន។

**ការអប់រំ៖**

ប្រជាពលរដ្ឋដែលរស់នៅលើដីនេះ ៩១% លើកឡើងថា ពុំមានសាលាមធ្យមសិក្សានៅតំបន់នេះឡើយ។ កុមារត្រូវធ្វើដំណើរតាមម៉ូតូឌុបជាមធ្យម ៧៦ នាទី ដើម្បីទៅដល់សាលាមធ្យមសិក្សាដែលនៅជិតបំផុត។ អ្នកឆ្លើយតបទាំងអស់លើកឡើងថា មានសាលា

បឋមសិក្សាមួយកន្លែងនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ កុមារត្រូវធ្វើដំណើរតាមម៉ូតូឌុបជាមធ្យម ៦ នាទី ដើម្បីទៅដល់សាលាបឋមសិក្សាដែលនៅជិតបំផុត។ អ្នកឆ្លើយតប ២៧% បានលើកឡើងថា យ៉ាងហោចណាស់ មានកុមារដល់វ័យចូលរៀនមួយចំនួន (អាយុចន្លោះពី ៦ ដល់ ១៧ ឆ្នាំ) ក្នុងផ្ទះរបស់ពួកគេ *ពុំបានទៅ សាលារៀន*ឡើយ ដែលនេះជាចំណុចដែលធ្វើឲ្យមានការព្រួយបារម្ភខ្លាំង។ ពួកគេបានលើកឡើងពីមូលហេតុច្រើនយ៉ាងដូចជា លទ្ធភាពចំណាយ ដោយសារតែត្រូវការកូនឲ្យនៅផ្ទះ និងដោយសារតែសាលារៀននៅឆ្ងាយពេក។ អ្នកឆ្លើយតប ៥០% លើកឡើងថា ដោយសារតែខ្វះគ្រូ នៅសាលានេះ។ គ្រួសារ ៩១% និយាយថា បច្ចុប្បន្ននេះ កូនៗពួកគេតិចជាងមុនបានទៅរៀន ចាប់តាំងពីផ្លាស់មករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះមក ដែលនេះក៏ជាបញ្ហាមួយធំផងដែរ។ សម្គាល់ នេះមិនមែនជាការបង្ហាញថាតើមានការផ្តល់ការអប់រំជាក់ស្តែងកម្រិតណានោះទេ ច្រើនតែជាការឆ្លុះបញ្ចាំងពីបំណងរបស់គ្រួសារតាមផ្ទះទាំងនោះ និងសារៈសំខាន់ដែលទាក់ទងជាប់ទៅនឹងការអប់រំ។

នៅពេលឲ្យដាក់ពិន្ទុលើការទទួលបានការអប់រំ នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ពុំមានអ្នកឆ្លើយតបណាម្នាក់លើកឡើងថា ការអប់រំមានភាពល្អប្រសើរជាងមុនឡើយ។ ផ្ទុយទៅវិញ ៧៣% បានលើកឡើងថា ការទទួលបានការអប់រំធ្លាក់ចុះជាងមុន។

**ហេដ្ឋារចនាសម្ព័ន្ធ និងអគ្គិសនី៖**

ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះទាំងអស់ អាចភ្ជាប់បណ្តាញទូរស័ព្ទដៃបាន ហើយអ្នកឆ្លើយតប ៩១% មានទូរស័ព្ទ និងអ៊ីនធឺណិតប្រើ។ ពុំមានអ្នកឆ្លើយតបណាម្នាក់លើកឡើងថា ការប្រើប្រាស់មធ្យោបាយធ្វើដំណើរ (បណ្តាញផ្លូវថ្នល់) និងការទំនាក់ទំនង (ទូរស័ព្ទ និងអ៊ីនធឺណិត) មានភាពល្អប្រសើរជាងមុនឡើយ បើទោះបីជាកំពុងតែមានការកសាងផ្លូវនៅទីតាំងសម្បទានដីសង្គមកិច្ចនេះក៏ដោយ។ អ្នកឆ្លើយតប ៩៦% និយាយថា ការប្រើប្រាស់មធ្យោបាយធ្វើដំណើរ និងទំនាក់ទំនងជារួមមានការថមថយ ចាប់តាំងពីផ្លាស់មករស់នៅទីកន្លែងនេះមក។

**សន្តិសុខស្បៀង៖**

អ្នកឆ្លើយតប ៧៣% និយាយថា កាលពីខែមុននេះ យ៉ាងហោចណាស់ក៏មានម្ដងដែរ ដែលពួកគេមានការព្រួយបារម្ភថាពួកគេនឹងពុំអាចផ្ដល់អាហារគ្រប់គ្រាន់ដល់គ្រួសាររបស់ពួកគេ ដោយ ៩៥% លើកឡើងថា នេះជាការ ព្រួយបារម្ភដែលកើតមានជាប្រចាំ។ គ្រួសារ ៣៦% លើកឡើងថា ពួកគេត្រូវកំហិតអាហារដែលត្រូវបរិភោគ (ដូចជា ពុំមានសាច់ ឬត្រី ជាដើម) នៅពេលណាមួយ ក្នុងខែមុននេះ ដោយសារតែខ្វះលុយ ហើយ ៧៣% ត្រូវបង្ខំចិត្តបរិភោគមើមរុក្ខជាតិដុះក្នុងព្រៃ ឬសាច់ដែលមានគុណភាពអន់ខ្លាំង ដោយសារតែមូលហេតុដូចគ្នានេះ។ អ្នកឆ្លើយតប ២៣% លើកឡើងថា ពួកគេធ្លាប់ដាច់បាយ កាលពីខែមុននេះ និងមានអ្នកឆ្លើយតប ១៨% បានលើកឡើងថា មានថ្ងៃខ្លះ កាលពីខែមុននេះ ដែលពួកគេពុំមានអាហារបរិភោគតែម្ដង ដោយសារតែពុំមានលុយទិញអាហារ និងពុំអាចរកអាហារ បានពីដីរបស់ពួកគេ។ គ្រួសារតាមផ្ទះ ៦៨% លើកឡើងថា ការទទួលបានអាហារបានថមថយជាងមុន ចាប់តាំងពីពេលដែលពួកគេផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ បើទោះបីជាសម្រាប់គ្រួសារ ៩% ស្ថានភាពបានល្អប្រសើរជាងមុនក៏ដោយ។ អាហារូបត្ថម្ភទំនងជាបញ្ហាធំមួយ សម្រាប់គ្រួសារតាមផ្ទះដែលតាំងនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ជាពិសេស សម្រាប់កុមារដែលខ្វះអាហារដែលមានសារជាតិប្រូតេអ៊ីន និងនៅកន្លែងដែលគ្រួសារមិនអាចកាប់ឆ្ការដី ធ្វើកសិកម្មបាន។

**ចំណូល និងការងារ**

គ្រួសារតាមផ្ទះដែលត្រូវបានសាកសួរទាំងអស់ មានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់មានការងារធ្វើ ហើយគ្រួសារ ៧៣% មានមនុស្ស ២ នាក់ មានការងារធ្វើ។ ជាការឆ្លើយតបចំពោះសំណួរដែលសួរថាតើការងារប្រភេទណាខ្លះដែលពួកគេធ្វើ ៩១% ស៊ីឈ្នួលធ្វើកសិកម្មឲ្យគេ ៧៧% ធ្វើការងារប្រភេទប្រើប្រាស់កម្លាំងពលកម្មផ្សេងទៀត ហើយ ២៧% មានមុខរបរខ្លួនឯង។ ចំណូលមធ្យមប្រចាំខែរបស់គ្រួសារគឺ ២៥៨ ដុល្លារ ក្នុងមួយខែ។ មុនពេលផ្លាស់មកនៅដីសម្បទានសង្គមកិច្ចនេះ ចំណូលមធ្យមប្រចាំខែរបស់អ្នកឆ្លើយតបមានកម្រិតខ្ពស់រហូតដល់ ៥៨៦ ដុល្លារ ក្នុងមួយខ្នងផ្ទះ។ នេះជាការឆ្លុះបញ្ចាំងពីចំណុចដែលថាអ្នកទទួលផលសម្បទាន ដីសង្គមកិច្ចនេះមិនមែនជាគ្រួសារក្រីក្រ គ្មានដីពី

ដំបូងឡើយ។ ពួកគេបានទទួលដី ដោយសារតែកន្លែងរស់នៅរបស់ពួកគេកាលពីមុនត្រូវបានបំផ្លាញ ដែលធ្វើឲ្យពួកគេគ្មានដី។ អ្នកឆ្លើយតបលើកឡើងថា កាលពីមុន ពួកគេទទួលបានចំណូលពីច្រើនប្រភព ដូចជា ពីការនេសាទ ជាដើម និងអាចរកចំណូលបានច្រើន ប៉ុន្តែក្រោយពេលដែលពួកគេបាត់បង់ផ្ទះសម្បែង ចំណូលរបស់ពួកគេមានការថយចុះយ៉ាងគំហុក។ បើទោះបីជាចំណូលប្រចាំខែរបស់គ្រួសារ មានការថយចុះក៏ដោយ ប្រជាពលរដ្ឋដែលរស់នៅទីនេះអាចរកចំណូលបានច្រើនជាងចំណូលមធ្យម សម្រាប់ទីតាំងសម្បទានដីសង្គមកិច្ច ទាំង ៦ (ប្រមាណជា ២៣០ ដុល្លារ ក្នុងមួយខែ) ហើយចំណូលប្រចាំខែរបស់ពួកគេ គឺខ្ពស់ជាងចំណាយ។ ចំណាយមធ្យមសម្រាប់គ្រួសារ បច្ចុប្បន្ននេះគឺ ២២៩ ដុល្លារក្នុងមួយខែ កើនឡើងពី ២០៤ ដុល្លារ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ចំណាយភាគច្រើន គឺលើអាហារ និងការថែទាំសុខភាព។ <u>ចំណូលមធ្យមប្រចាំខែបានថយចុះយ៉ាងគំហុក ហើយចំណាយប្រចាំថ្ងៃរបស់គ្រួសារមានការកើនឡើង។</u> នេះអាចបង្ហាញថា កម្មវិធីសម្បទានដីសង្គមកិច្ចនេះមានផលប៉ះពាល់ជាអវិជ្ជមានលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទ ទាក់ទិននឹងកម្រិតចំណូល។ ប៉ុន្តែ ដោយសារតែបរិបទជុំវិញការបង្កើតកម្មវិធីសម្បទានដីសង្គមកិច្ចនេះ គេមិនគួរវិនិច្ឆ័យលើជោគជ័យ ដោយពិនិត្យតែលើការថយចុះចំណូលប៉ុណ្ណោះនោះទេ ប៉ុន្តែពិនិត្យ ថាតើគ្រួសារទទួលផលដែលរងផលប៉ះពាល់ដោយសារការបាក់ច្រាំងទន្លេ ដែលបាន ផ្លាស់ប្តូរទីលំនៅទាំងនេះ បានទទួលកម្រិតជីវភាពសមរម្យ ដែលមាននិរន្តរភាពដែរឬទេ។

មានគ្រួសារតែមួយភាគបីប៉ុណ្ណោះ ដែលមានប្រាក់សន្សំសម្រាប់គ្រួសារ(៣៦%)។ គ្រួសារ ៦៨% ជាប់បំណុលគេ ហើយកម្រិតបំណុលមានការកើនឡើងខ្លាំង។ ជាមធ្យមគ្រួសារតាមផ្ទះជំពាក់បំណុលគេ ២.២៩៥ ដុល្លារដែលកើនឡើងពី ៨៨៧ ដុល្លារ មុនពេលផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះ។ នេះមានន័យថា <u>គ្រួសារតាមផ្ទះត្រូវខ្ចីបុលគេយ៉ាងច្រើននៅពេលផ្លាស់ ឬក្រោយពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះទោះបីជាគេមិនអាចកំណត់ដឹងពីមូលហេតុពិតប្រាកដដែលនាំឲ្យមានការខ្ចីបុលនេះឡើយ</u>។

ជាសូចនាករបង្ហាញពីទ្រព្យធន មានគ្រួសារ ៣៦% មានទូរទស្សន៍ជាកម្មសិទ្ធិ ហើយ ៨៦% មានម៉ូតូជាកម្មសិទ្ធិ។ ៨៦% មានទូរស័ព្ទដៃជាកម្មសិទ្ធិ។ ក្នុងខ្នងផ្ទះមួយភាគបី (៣៦%) សមាជិកគ្រួសារ ទាំងអស់រស់នៅជុំគ្នា លើទីតាំងសម្បទានដីសង្គមកិច្ចនេះជាអចិន្ត្រៃយ៍។ សមាជិកគ្រួសារភាគច្រើន ដែលរស់នៅឆ្ងាយពីទីតាំងនេះ គឺកូនរបស់អ្នកឆ្លើយតបចំពោះការសម្ភាសនេះ ដែលនេះបង្ហាញថា ក្មេងៗជំនាន់ថ្មីជាច្រើនធ្វើចំណាកស្រុកឆ្ងាយពីផ្ទះដែលគ្រួសាររបស់ពួកគេរស់នៅ ដើម្បីរកការងារធ្វើ (៣៦%) និង/ឬបន្តការសិក្សា (៥៧%)។

## រចនាសម្ព័ន្ធផ្នែកសង្គម៖

អ្នកឆ្លើយតប ៥៥% លើកឡើងថា ពួកគេមានអារម្មណ៍តានតឹង (ស្ត្រេស) បើទោះបីជាមានអ្នកឆ្លើយតបតែ ២ នាក់ប៉ុណ្ណោះ ដែលលើកឡើងថា បញ្ហាអារម្មណ៍តានតឹងនេះមានភាពស្រួចស្រាវ។ អ្នកឆ្លើយតប ៩៦% លើកឡើងថា ពួកគេ*បានដឹង*ថាមាន<u>ការរំលោភបំពានដោយសារគ្រឿងស្រវឹងកំពុងកើតឡើងក្នុងសហគមន៍នេះ</u>។ ពុំមានគ្រួសារតាមផ្ទះដែលត្រូវបានអង្កេតណា គិតថា មានបទល្មើសឧក្រិដ្ឋកើតឡើងច្រើនក្នុងសហគមន៍នេះ បើប្រៀបធៀបជាមួយនឹងស្ថានភាពមុនពេលដែលពួកគេផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះនោះទេ ។មានអ្នកឆ្លើយតបតែម្នាក់ប៉ុណ្ណោះ ដែលលើកឡើងថាខ្លួនបានដឹងពីករណីអំពើហិង្សាលើស្ត្រី ឬក្មេងស្រី ហើយភាគច្រើនជឿថា ហិង្សាផ្លូវភេទមានអត្រាកើតឡើងតិចជាងក្នុងសហគមន៍មុនៗរបស់ពួកគេ។ នេះជាតួលេខមួយទាបជាងគេបំផុត ក្នុងចំណោមទីតាំងសម្បទានដីសង្គមកិច្ច ទាំងអស់ ហើយគេអាចពិចារណាពិគ្រោះយោបល់ជាមួយអាជ្ញាធរបន្ថែមទៀត ដើម្បីស្វែងយល់ពីវិធីសាស្ត្រ ដែលពួកគេប្រើប្រាស់ ដើម្បីទទួលបានជោគជ័យ ក្នុងការកាត់បន្ថយហានិភ័យហិង្សាផ្លូវភេទ និង ចំណាកស្រុកសំរាប់ស្ត្រី និងក្មេងស្រី។ ការរកឃើញទាំងនេះ មិនផ្តល់នូវការគណនាច្បាស់លាស់នៃអត្រាទូទៅនៃហិង្សាផ្លូវភេទ ឬការរំលោភបំពានដោយសារគ្រឿងស្រវឹងនោះទេ។ ការរកឃើញទាំងនេះ ជាការឆ្លុះបញ្ចាំងពីគំនិតយោបល់របស់សហគមន៍តែប៉ុណ្ណោះ ហើយ គេត្រូវតែអានយល់ដូចនេះ ជាមួយការយល់ដឹងថា ក្រុមអង្កេតនេះ មិនបានសួរដោយផ្ទាល់ទេ

ឧទាហរណ៍៖ ថាតើ ការរំលោភបំពានកើតឡើងដោយគ្រឿងស្រវឹងជាបញ្ហាមួយនៅក្នុងខ្នងផ្ទះមួយឬទេ។

អ្នកឆ្លើយតប ៥០% លើកឡើងថា ពួកគេដឹងពីករណីកុមារធ្វើការងារដើម្បីរកចំណូលបន្ថែមឲ្យគ្រួសារ (កុមារត្រូវបានឲ្យនិយមន័យថាមានអាយុ ១៥ ឆ្នាំចុះក្រោម)។ ការងារភាគច្រើនដែលកុមារធ្វើ គឺការងារកសិកម្ម (៨២%) និងប្រភេទការងារប្រើកម្លាំងពលកម្មផ្សេងទៀត (៦៥%)។ មានខ្នងផ្ទះចំនួន ២ បញ្ជូនសមាជិកគ្រួសារជាកុមារទៅធ្វើការងារនៅតាមរោងចក្រ។

ប្រជាពលរដ្ឋរស់នៅលើសម្បទានដីសង្គមកិច្ចនេះ ៩៦% ដោយចោទថា ពួកគេ មិនត្រូវបានគេចុះឈ្មោះបោះឆ្នោតឲ្យទេ។ តួលេខនេះ កើនខ្ពស់ដោយគ្មានសមាមាត្រទេ ដោយសារ ចំនួនខ្នងផ្ទះជាមធ្យម បានតាំងនៅទីនោះ អស់រយៈពេលជិត៣ឆ្នាំ ហើយការបោះឆ្នោតឃុំសង្កាត់កៀកនឹងមកដល់ក្នុងឆ្នាំ ២០១៧ នេះទៀត។

គ្រួសារតាមផ្ទះ ៦៥% នៅមិនទាន់មានឯកសារស្នាក់នៅ ដែលផ្តល់ដោយអាជ្ញាធរមូលដ្ឋាន ហើយក្នុងខ្នងផ្ទះ ២៣% យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ ដែលពុំមានសំបុត្រកំណើត ហើយក្នុងខ្នងផ្ទះ ១៨% មានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់ដែលពុំមានអត្តសញ្ញាណប័ណ្ណ។ គ្រួសារ ១៥% ពុំមានសៀវភៅគ្រួសារ។

មានប្រជាពលរដ្ឋតែ ៣ គ្រួសារប៉ុណ្ណោះ (១៥%) បាននិយាយថា ពួកគេ កំពុងពិចារណាចាកចេញពីទីតាំងសម្បទានដីសង្គមកិច្ចនេះ ដោយសារតែបញ្ហាកង្វះទឹក អាហារ និងបញ្ហាប្រឈមផ្សេងទៀតក្នុងតំបន់នេះ ជាតួលេខមួយទាបគួរឲ្យកត់សម្គាល់។ សំណូមពរជុំវិញការលើកកម្ពស់កម្រិតជីវភាពរស់នៅ លើទីតាំងសម្បទាន ដីសង្គមកិច្ចនេះ ផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវ (៥០%) ការទទួលបានទឹកស្អាត (៨២%) និងការកែលំអលើការផ្តល់ សេវាថែទាំសុខភាព (៧៣%) ប៉ុន្តែក៏មានការលើកឡើងសំណូមពរទាក់ទងនឹងបញ្ហាជាច្រើនផ្សេងទៀតផងដែរ ដូចជា លំនៅឋាន អគ្គិសនី ការងារ និងការផ្តល់បង្គន់អនាម័យជាដើម។ អាជ្ញាធរមូលដ្ឋានដែលត្រូវបានសម្ភាស ជឿថា កម្មវិធីសម្បទានដីសង្គមកិច្ចនេះមានផលជាវិជ្ជមានខ្លាំងលើជីវិតរបស់ប្រជាពលរដ្ឋ ជាពិសេស ដោយសារតែអ្នក

ទទួលដីភាគច្រើន គឺជាជនរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ ហើយកម្មវិធីសម្បទានដីសង្គមកិច្ចនេះបានផ្តល់លទ្ធភាពឲ្យពួកគេកសាងជីវិតរបស់ពួកគេឡើងវិញ។

## ឧបសម្ព័ន្ធទី ៥៖ និន្នន័យអំពីសម្បទានដីសង្គមកិច្ចក្នុងភូមិពូលុ ឃុំ ម៉ីស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី

*របកគំហើញសំខាន់ៗ*

- *សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ផ្សេងទៀត ហាក់បីដូចជាត្រូវបានបណ្តេញចេញទាំងបង្ខំពីដីនៅទីតាំងនេះ ដើម្បីយកបង្កើតជាសម្បទានដីសង្គមកិច្ច។ គេមិនដឹងច្បាស់ទេថាតើមានការវាយតម្លៃហេតុប៉ះពាល់សង្គម ឬបរិស្ថានឬអត់ មុនពេលផ្តល់ដីសម្បទានសង្គមកិច្ចនេះ។ ប៉ុន្តែ សហគមន៍មូលដ្ឋានពុំបានចូលរួមក្នុងដំណើរការនេះឡើយ។ ការកំណត់ចេញជាទីតាំងសម្បទានដីសង្គមកិច្ចនេះ មិនត្រូវបានធ្វើឡើង ស្របតាមលក្ខខណ្ឌ ដែលមានចែងក្នុងអនុក្រឹត្យនេះឡើយ។*
- *គ្រួសារទទួលផល អះអាងថាបានបង់សំណូកដើម្បីទទួលបានដីក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ប្រព័ន្ធបែងចែកដីហាក់បីដូចជាមានអំពើពុករលួយ ដែលអនុញ្ញាតឲ្យប្រជាពលរដ្ឋទទួលបានក្បាលដីច្រើនកន្លែង។*
- *អ្នកឆ្លើយតបតិចជាងពាក់កណ្តាលអះអាងថា បានចូលរួមក្នុងការកំណត់ និងការរៀបចំផែនការនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។*
- *ការទទួលបានទឹកស្អាត អនាម័យ អប់រំ និងសេវាសុខភាព គឺជាបញ្ហាចោទជាពិសេស ដូចគ្នានឹងបញ្ហាអសន្តិសុខស្បៀងដែរ។ នៅទីតាំងនេះ ពុំមានសាលាបឋមសិក្សា ឬមធ្យមសិក្សា ឬមណ្ឌលសុខភាពនោះទេ។ ប្រជាពលរដ្ឋ ពុំមានអគ្គិសនីប្រើប្រាស់នោះឡើយ។*
- *គ្រួសារទទួលផលភាគច្រើនលើកឡើងថា បានទទួលចំណូលច្រើនជាងមុនពេលដែលពួកគេផ្លាស់មករស់នៅទីតាំងនេះ ហើយចំណូលមានកម្រិតខ្ពស់ជាងកម្រិតមធ្យម បើធៀបជាមួយនឹងទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀត។*
- *គ្រួសារទទួលផលហាក់បីដូចជាមានជីវភាពធូរធាជាងមុន បន្ទាប់ពីបានទទួលដីក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះរួចមក។ សហគមន៍មូលដ្ឋានហាក់បីដូចជាកាន់តែក្រជាងមុន ជាពិសេស បន្ទាប់ពីត្រូវបានបណ្តេញចេញពីដីដើម្បីយកមកធ្វើជាទីតាំង*

*សម្បទានដីសង្គមកិច្ច។ ជម្លោះដីធ្លី នៅតែបន្តកើតមានឡើង ហើយមានការលើកឡើងថា សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ផ្សេងទៀត មិនអាចប្រើប្រាស់យន្តការដោះស្រាយជម្លោះបានឡើយ ហើយក៏ពុំទទួលបានយុត្តិធម៌នោះដែរ។ ការទាមទារដីរបស់ពួកគេមិនត្រូវបានអាជ្ញាធរពាក់ព័ន្ធ ឬប្រព័ន្ធយុត្តិធម៌ធ្វើការវាយតម្លៃឲ្យបានត្រឹមត្រូវនោះដែរ។*

ជាសរុបមានមនុស្សចំនួន ៣១ នាក់ ត្រូវបានសម្ភាស ដែលធ្វើឲ្យទិន្នន័យនេះ ជាសំណុំទិន្នន័យតូចមួយនៃ ការអង្កេតលើទីតាំងសម្បទានដីសង្គមកិច្ច ។ អាជ្ញាធរមូលដ្ឋានបានលើកឡើងថា សរុបមានប្រជាពលរដ្ឋ ៥០ គ្រួសារ និងមនុស្សចំនួន ១៩០ នាក់ បានទទួលដី ក្នុងទីតាំងដីសម្បទានសង្គមកិច្ចនេះ។ កម្មវិធីសម្បទានដីសង្គមកិច្ចនេះត្រូវបានផ្តួចផ្តើមបង្កើតឡើង ដោយជនជាតិភាគតិចចាមម្នាក់មកពីខេត្តកំពង់ចាម។ OHCHR បានសម្ភាសជាមួយបុគ្គលដែលផ្តួចផ្តើមបង្កើតកម្មវិធីសម្បទានដីសង្គមកិច្ចនេះឡើង។ គាត់ (ស្ត្រី) បានលើកឡើងថា បានដាក់សំណើរទៅអាជ្ញាធរមូលដ្ឋាន ក្នុងខេត្តកំពង់ចាម កាលពីឆ្នាំ ២០០៨។ គាត់បានស្នើសុំដីទំហំ ៣០០០ ហិកតា សម្រាប់ប្រជាពលរដ្ឋ ២០០ គ្រួសារ ដែលគាត់អះអាងថាជាប្រជាពលរដ្ឋក្រីក្រ និងគ្មានដី។ គាត់បានលើកឡើងថា គាត់ត្រូវបង់ប្រាក់ទៅឲ្យអាជ្ញាធរមូលដ្ឋាន ក្នុងខេត្តកំពង់ចាម និងមណ្ឌលគិរី ឲ្យរត់ការសំណើនេះឲ្យគាត់ ដែលចុងក្រោយបានទទួលការសម្រេចយល់ព្រមក្នុងឆ្នាំ ២០១២។ គាត់បានលើកឡើងថា បច្ចុប្បន្ននេះ មានប្រជាពលរដ្ឋចំនួន ១០៧ គ្រួសារ កំពុងរស់នៅលើទីតាំងនេះ ប៉ុន្តែបុគ្គលិក OHCHR មានមន្ទិលថាតើមានគ្រួសារច្រើនប៉ុណ្ណេះរស់នៅទីនេះជាអចិន្ត្រៃយ៍ បែបនេះមែនដែរឬទេ។[83]

---

[83] នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ អាជ្ញាធរខេត្តមណ្ឌលគិរី បានចេញ លិខិតមួយទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បី ស្នើសុំ ការបែងចែកក្បាលដីសម្បទានដីសង្គមកិច្ច ទៅឲ្យ៥២១គ្រួសារ (៣២២គ្រួសារ មកពីកំពង់ចាម និងត្បូងឃ្មុំ ហើយ ១៩៩គ្រួសារ មកពីមណ្ឌលគីរី) ទូទាំង ២៨០០ហិកតា នៅក្នុងឃុំ ប៊ូស្រា ស្រុកពេជ្រាដា។ ការស្នើសុំនេះបានធ្វើឡើង បន្ទាប់ពីក្រុមការងារថ្នាក់ខេត្ត បានចុះដល់ទីតាំង ដើម្បីធ្វើការវាយតម្លៃ ចំនួនគ្រួសារជាក់ស្តែងកំពុងរស់នៅក្នុងទីតាំងបានវាស់វែងសម្រាប់សម្បទានដីសង្គមកិច្ចនេះ។ លិខិតនេះ បានកំណត់ថា អំឡុងពេល ឆ្នាំ២០១៣

លទ្ធផលនៃការអង្កេតនេះ បង្ហាញថា ហាក់បីដូចជាមានការបែងចែកស្មើគ្នានូវ<u>ជាតិពន្ធុរបស់ប្រជាពលរដ្ឋដែលរស់នៅទីនេះ</u> ដោយអ្នកឆ្លើយតបភាគច្រើន ប៉ុន្តែលើសតែបន្តិចប៉ុណ្ណោះ ជាសហគមន៍ជនជាតិភាគតិចចាម (៥២%) ហើយនៅសល់គឺជាជនជាតិខ្មែរ (៤៨%) (គេមិនគួរសន្មត់ថាតួលេខនេះជាតួលេខតំណាងឲ្យសហគមន៍ទាំងមូលឡើយ។ ខណៈពេលដែលតួលេខទាក់ទងនឹងការទទួលបានសេវាមូលដ្ឋាន ឬការបង់ប្រាក់ដល់អាជ្ញាធរមូលដ្ឋាន គួរជាភស្តុតាងអាចជឿទុកចិត្តបានដែលបង្ហាញពីលក្ខណៈដែលអាចមាន កម្រិតជីវភាពរស់នៅ ឬនិន្នាការឥរិយាបថ ។ល។ ស្ថិតិនេះបង្ហាញថា សហគមន៍នេះមានចម្រុះជនជាតិ ហើយមានជនជាតិភាគតិចចាមជាច្រើនរស់នៅ ជាជាងបង្ហាញថា ៥០% នៃសហគមន៍ដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះទាំងមូលជាជនជាតិចាម)។ មានអ្នកឆ្លើយតបតែ ៣៨% ប៉ុណ្ណោះជាបុរស។ អ្នកឆ្លើយតប ៨៧% និយាយថា បុរសគឺជា<u>មេគ្រួសារ</u> ហើយ ៨១% បានរៀបការហើយ ឬកំពុងរស់នៅជាមួយដៃគូ/មនុស្សដែលខ្លួនមានទំនាក់ទំនងជាមួយ។

អ្នកឆ្លើយតប ២ ភាគបី (៦៨%) បាននិយាយថា ពួកគេបានទទួលក្បាលដីលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ដោយសារតែពួកគេជាអ្នកគ្មានដី។ ពុំមានអ្នកឆ្លើយតបណាម្នាក់អះអាងថា ត្រូវបានបាត់បង់ទីលំនៅដោយសារតែគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនោះទេ។ អ្នកឆ្លើយតបចំនួន ៣ នាក់ លើកឡើងថា ខ្លួនទទួលបានដី ដោយសារតែពួកគេកំពុងធ្វើការក្នុងចំការសម្បទានដីសេដ្ឋកិច្ច។ អ្នកឆ្លើយតប ២៤ នាក់ (៧៧%) លើកឡើងថា ភាពក្រីក្រ គឺជាមូលហេតុ ដែលនាំឲ្យពួកគេទទួលបានដី។ អ្នកឆ្លើយតបម្នាក់បានលើកឡើងថា គ្រួសាររបស់គាត់ បានទទួលក្បាលដីដោយសារបំរើការនៅក្នុងកងកំលាំង ខណៈដែលគ្រួសារផ្សេងៗ បាន លើកឡើង ថា ពួកគេ បានផ្លាស់ទីលំនៅដោយគ្រោះមហន្តរាយធម្មជាតិ។

---

អាជ្ញាធរខេត្ត បានយល់ព្រមឲ្យ ៥២១គ្រួសារ កាប់ឆ្ការដីនៅទីតាំងនោះ សម្រាប់ការសាងសង់ផ្ទះជាបណ្ដោះអាសន្ន ហើយរង់ចាំ ដំណើរការបែងចែកដីជាផ្លូវការពីអាជ្ញាធរមានសមត្ថកិច្ច។

មានចំណុចត្រូតគ្នាច្បាស់លាស់ នៅកន្លែងដែលអ្នកឆ្លើយតប ផ្តល់ចម្លើយច្រើន យ៉ាងដែលបង្ហាញពីហេតុផលដែលនាំឲ្យពួកគេទទួលបានដី។ មូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន អាចដោយសារតែមន្ត្រីមូលដ្ឋានពន្យល់ថា គ្រួសារក្រីក្រ គ្មានដី បានទទួលអាទិភាព ក្នុងដំណើរការបែងចែកដីនេះ។ កម្រងសំណួរត្រង់ផ្នែកនេះអនុញ្ញាតឲ្យផ្តល់ចម្លើយបានច្រើន។ អាជ្ញាធរមូលដ្ឋានដែលត្រូវបានសម្ភាស បានលើកឡើងថា ដីដែលផ្តល់ឲ្យគឺមិនសមស្របសម្រាប់គ្រួសារក្រីក្រ និងគ្មានដីឡើយ។

អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចឆ្នាំ ២០០៣ ចែងថា ដីអាចត្រូវផ្តល់ ដើម្បី "ជួយសម្រួលដល់សម្បទានដីសេដ្ឋកិច្ច ដោយផ្តល់ដីឡូតិ៍ដល់កម្មករចំការធំៗ សម្រាប់សង់លំនៅឋាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ"។ ជាការឆ្លើយតបរបស់ប្រជាពលរដ្ឋរស់នៅជុំវិញទីតាំងសម្បទានដីសង្គមកិច្ចដែលផ្តល់ដល់ OHCHR មុនពេលសម្ភាសនេះ មានការអះអាងថា ការបែងចែកដីក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះគឺមានទំនោរដោយមិនសមាមាត្រ ទៅរកអ្នកដែលមានទំនាក់ទំនងជាមួយនឹងម្ចាស់គម្រោងសម្បទានដីសេដ្ឋកិច្ច ឬអ្នកដែលធ្វើការនៅសម្បទានដីសេដ្ឋកិច្ច។ អ្នកឆ្លើយតបចំនួន ៣ នាក់ (១០%) លើកឡើងថា ការបែងចែកដី គឺជាប់ពាក់ព័ន្ធជាមួយនឹងការងារក្នុងចំការសម្បទានដីសេដ្ឋកិច្ច។ ប៉ុន្តែ នៅពេលសាកសួរពីមូលហេតុដែល*គ្រួសារផ្សេងទៀត* បានទទួលដី ក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះដែរ អ្នកឆ្លើយតបលើកពីភាពគ្មានដី (៥២%) និងភាពក្រីក្រ (៧១%) ថាជាហេតុផលចម្បង ដោយមានអ្នកឆ្លើយតបតែ ម្នាក់ប៉ុណ្ណោះ ដែលអះអាងថា ការបែងចែកដីនេះមានទំនាក់ទំនងជាមួយនឹងការងារនៅក្នុងទីតាំងសម្បទានដីសេដ្ឋកិច្ច។ នេះបង្ហាញថា ក្នុងទីតាំងសម្បទានដីសង្គមកិច្ចនៅខេត្តមណ្ឌលគិរីនេះ អ្នកទទួលផលមានការសង្ស័យតិចតួចពីការបែងចែកដី មិនត្រឹមត្រូវ ដែលលំអៀងទៅរកអ្នកទទួលផលដែលផ្លាស់មកតំបន់នេះ ដើម្បីធ្វើការងារនៅលើសម្បទានដីសេដ្ឋកិច្ច។ ចំណុចនេះអាចមិនឆ្លុះបញ្ចាំងពីគំនិតយល់ឃើញរបស់ក្រុមដែលពុំបានទទួលផលឡើយ។

អ្នកទទួលផលជាង ៨០% ពុំមានប័ណ្ណសម្គាល់គ្រួសារក្រីក្រ (តាមរយៈកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ) ឡើយ។ មានអ្នកឆ្លើយតបតែ ៦ នាក់ (១៩%) ប៉ុណ្ណោះ នៅ

ប៊ូស្រានេះ ដែលមានប័ណ្ណនេះ បើប្រៀបធៀបជាមួយនឹងតួលេខ ៧២% សម្រាប់គ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ដែលត្រូវបានអង្កេត។ អ្នកទទួលដីសម្បទាន សង្គមកិច្ចទាំងអស់ (ក្រៅពីយោធិនរំសាយ) ដែលបានបែងចែកដីឲ្យក្រោយអនុក្រឹត្យឆ្នាំ២០១១ ស្តីពីអត្តសញ្ញាណកម្ម គ្រួសារក្រីក្រ គួរមានប័ណ្ណអត្តសញ្ញាណគ្រួសារក្រីក្រពីដំបូង ប័ណ្ណនេះគឺជាមធ្យោបាយស្នូលសម្រាប់វាយតម្លៃកម្រិតនៃភាពក្រីក្រ និងកំណត់អត្តសញ្ញាណអ្នកសុំដី និងអ្នកទទួលបានដីដែលបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្រប។ ដោយកង្វះប័ណ្ណគ្រួសារក្រីក្រទាំងនេះ ធ្វើឲ្យមានការស្នើរឡើងនូវមធ្យោបាយផ្សេងទៀត ត្រូវបានគេប្រើប្រាស់ដើម្បីវាយតម្លៃកម្រិតនៃភាពក្រីក្រ និងកំណត់ពីអ្នកទទួលផលដែលមានលក្ខណៈសម្បត្តិទទួលបាន។

មានអ្នកឆ្លើយតបតិចជាងពាក់កណ្តាល (៤៨%) អះអាងថាបានចូលរួមក្នុងការកំណត់ និងរៀបចំផែនការនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ខណៈ ដែលការចូលរួមក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមនៅថ្នាក់ឃុំ ត្រូវបានកំណត់ថាជាសិទ្ធិរបស់ អ្នកទទួលផលគ្រប់រូប ដូចមានចែងក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចឆ្នាំ ២០០៣ ប៉ុន្តែការចូលរួមក្នុង*ការកំណត់អត្តសញ្ញាណ*ដី មិនត្រូវបានកំណត់ជាសិទ្ធិបែបនេះឡើយ។ ការចូលរួមបែបនេះ គួរចាត់ទុកថា ជាការអនុវត្តល្អរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង និងគួរលើកទឹកចិត្តឲ្យមាន ប្រសិនបើមានការកំណត់អត្តសញ្ញាណក្រុមអ្នកទទួលផល មុនពេលបង្កើតកម្មវិធីសម្បទាន ដីសង្គមកិច្ច។ ការពិគ្រោះយោបល់នឹងនាំឲ្យដំណើរការកាន់តែមានលក្ខណៈបរិយាប័ន្ន ការបែងចែកដីនិងធនធានផ្សេងទៀតកាន់តែមានសមធម៌ ហើយការរៀបចំផែនការសម្បទានដីសង្គមកិច្ចទៀតសោតកាន់តែធ្វើបានល្អប្រសើរ ដោយមានការពិចារណាលើតម្រូវការ និងសិទ្ធិរបស់គ្រួសារដែលទទួលបានដី។

ទីតាំងសម្បទានដីសង្គមកិច្ចនេះ ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំណាំលា។[84] អាជ្ញាធរមូលដ្ឋានអះអាងថាបានធ្វើការវាយតម្លៃលើហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលបានរកឃើញថាមានសហគមន៍ពួងកំពុងរស់នៅលើទីតាំង សម្បទានដីសង្គមកិច្ចដែលត្រូវបានស្នើឡើងនេះ។ ដីកប់សពដូនតា និងដីព្រៃ ក៏ត្រូវបានរកឃើញនៅលើទីតាំងនេះផងដែរ។ ក្នុងដំណើរការកំណត់ទីតាំងដី និងធ្វើផែនការនេះ ពុំមានការពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិចនៅទីនោះឡើយ។ មានការលើកឡើងថា មានការរៀបចំកិច្ចពិគ្រោះយោបល់ ក្រោយពេលដែលសម្បទានដី សង្គមកិច្ចនេះត្រូវបានចុះបញ្ជីរួច និងក្រោយពេលដែលអ្នកទទួលផលចាប់ផ្តើមផ្លាស់មករស់នៅលើដីនេះ។ សហគមន៍ជនជាតិដើមភាគតិចហាក់បីដូចជាត្រូវបានផាត់ចេញពីកិច្ចពិគ្រោះយោបល់ និងពុំបានចូលរួមក្នុងដំណាក់កាលរៀបចំ ផែនការពីដំបូងឡើយ។

អាជ្ញាធរមូលដ្ឋានពុំបានដឹងពីពាក្យថា ការយល់ព្រមដោយសេរី និងដោយបានប្រាប់ឲ្យដឹងជាមុន ឡើយ ហើយពួកគេមានចំណេះដឹងនៅមានកម្រិតអំពីរបៀបបង្កលក្ខណៈឲ្យមានការចូលរួម ឬរបៀបធ្វើការងារជាមួយនឹងប្រជាពលរដ្ឋជនជាតិដើមភាគតិច។ មន្ត្រីមូលដ្ឋានអាចមិនធ្លាប់ទទួលបានព័ត៌មាន ឬការបណ្តុះបណ្តាលអំពីបញ្ហាទាំងនេះ។ ចំណុចដែលស្តែងចេញច្បាស់នោះគឺថា ដំណើរការរៀបចំផែនការដំបូងៗមិនត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធភាពគ្រប់គ្រាន់ និងពុំមានបរិយាប័ន្ន ឬតម្លាភាពឡើយ។ អ្នកឆ្លើយតបដែលជាអាជ្ញាធរមូលដ្ឋានបានលើកឡើងថា ដីនេះ គឺជាដីដែលកាន់កាប់ដោយ

[84] ច្បាប់ស្តីពីតំបន់ការពារ ឆ្នាំ ២០០៨ កំណត់ពីលក្ខខណ្ឌសម្រាប់បង្កើត ឬកែសម្រួលតំបន់ការពារនានា និងបានចែងថាត្រូវអនុវត្ត តាមរយៈការចេញអនុក្រឹត្យស្តីពីការធ្វើអនុបយោគដី។ បើតាមអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា សម្បទានដីសេដ្ឋកិច្ចជាច្រើនត្រូវបានផ្តល់ ស្ថិតក្នុងតំបន់ការពារ។ រដ្ឋាភិបាលបានផ្តល់សម្បទានដីដល់ក្រុមហ៊ុនយ៉ាងហោចណាស់ចំនួន ១០៥ ក្នុងតំបន់ការពារចំនួន ១៦ លើ ២៣ ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ (១៩៩៣) ស្តីពីតំបន់ការពារធម្មជាតិ ដោយអនុក្រឹត្យភាគច្រើនត្រូវបានចេញ សម្រាប់គោលបំណងអភិវឌ្ឍកសិ-ឧស្សាហកម្ម និងទេសចរណ៍ធម្មជាតិ។ ក្រសួងបរិស្ថានបានបញ្ជាក់ថា សម្បទានដីមួយចំនួនត្រូវបានផ្តល់ក្នុងតំបន់ការពារ ដែលស្ថិតក្រោមការចាត់ចែង និងគ្រប់គ្រងរបស់ក្រសួងនេះ ប៉ុន្តែមានតែនៅក្នុងតំបន់ទ្រនាប់នៃតំបន់ការពារ (ឬតំបន់ប្រើប្រាស់ប្រកបដោយចីរភាព) ប៉ុណ្ណោះ ដើម្បីបង្ការមិនឲ្យមានការបំផ្លិចបំផ្លាញព្រៃ និងធនធានធម្មជាតិបន្ថែមទៀត ក្នុងតំបន់ស្នូលក៏ដូចជាតំបន់អភិរក្ស។ សូមមើលការវិភាគផ្អែកលើសិទ្ធិមនុស្សអំពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានគោលដៅដទៃទៀតនៅព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាសិទ្ធិមនុស្ស A/HRC/21/63/Add.1. 2012។

ប្រជាពលរដ្ឋ ២៥ គ្រួសារ ស្មើនឹង ១២៥ នាក់ មុនពេលដែលទីតាំងសម្បទានដីសង្គមកិច្ចនេះត្រូវបានបង្កើតឡើង។ OHCHR បានរកឃើញជនជាតិដើមភាគតិច ២ សហគមន៍ នៅក្នុងភូមិពូលុ និងភូមិវ៉រយោម រួមនឹង សហគមន៍ចំនួន ៦ ទៀត ក្នុងឃុំប៊ូស្រា ដែលទទួលរងផលប៉ះពាល់ដោយសារកម្មវិធីសម្បទានដីសង្គមកិច្ចនេះ ដូច្នេះចំនួនពិតប្រាកដហាក់បីដូចជាខ្ពស់ជាងនេះឆ្ងាយ។ មន្ត្រីមូលដ្ឋានបានដឹងថា មានគ្រួសារជនជាតិដើមភាគតិចរស់នៅក្នុងតំបន់នេះ ហើយមន្ត្រីមូលដ្ឋានខ្លួនឯងក៏មិនត្រូវបានឲ្យចូលរួមក្នុងដំណើរការរៀបចំផែនការ ឬពុំមានលទ្ធភាពតាមឆន្ទៈដើម្បីរារាំងមិនឲ្យមានការបង្កើតទីតាំងសម្បទានដីសង្គមកិច្ចលើដីជនជាតិដើមភាគតិច។

គ្រួសារជនជាតិដើមភាគតិច ហាក់បី ដូចជាមិនត្រូវបានគេពិគ្រោះយោបល់ជាមួយ មិនបានយល់ព្រមឲ្យមានការបង្កើតទីតាំងសម្បទានដីសង្គមកិច្ចលើដីដែលពួកគេកាន់កាប់ប្រើប្រាស់ និងអាស្រ័យផល ហើយជម្លោះដីធ្លីទាំងនេះមិនទាន់បានដោះស្រាយនៅឡើយ។ មន្ត្រីមូលដ្ឋានម្នាក់បានរៀបរាប់ថា សហគមន៍ជនជាតិដើមភាគតិចនេះ បានទទួលការគាបសង្កត់។ មន្ត្រីមូលដ្ឋានដដែលនេះពុំបានដឹង ថាតើ អ្នកទទួលផលសម្បទានដីសង្គមកិច្ចមកពីទីណាខ្លះនោះទេ និង ដឹងតិចតួចអំពីថាតើ គេផ្សព្វផ្សាយព័ត៌មាន ដោយរបៀបណា ជ្រើសរើសអ្នកសុំដីដោយរបៀបណា ឬត្រូវបែងចែកដីដោយរបៀបណា។ ពួកគេហាក់បីដូចជាត្រូវបាន ផាត់ចេញពីដំណើរការនេះ។ ពួកគេបានលើកឡើងថា អ្នកទទួលផលត្រូវបានជ្រើសរើសចេញពីខេត្តកំពង់ចាម ហើយក្នុងនាមជាអាជ្ញាធរមូលដ្ឋាន ពួកគេពុំបានបំពេញតួនាទីអ្វីទាំងអស់។ ពួកគេបានសួរមកវិញថាតើមានការប្រើប្រាស់ប្រព័ន្ធចាប់ឆ្នោត ដើម្បីជ្រើសរើសអ្នកទទួលផលដែរឬទេ។

ការដាក់ពាក្យសុំ សម្បទានដីសង្គមកិច្ចដោយបុគ្គលនានា គួរផ្តើមធ្វើឡើង ជាមួយក្រុមប្រឹក្សាឃុំ ដែលទីតាំង សម្បទានដីសង្គមកិច្ចនោះតាំងនៅ ហើយត្រូវរៀបចំឡើង ស្របតាមអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។ មានលក្ខខណ្ឌតម្រូវជាច្រើន ក្នុងនោះរាប់បញ្ចូលទាំងការវាយតម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថានផងដែរ។[85] ប៉ុន្តែ អាជ្ញាធរមូលដ្ឋាន

[85]អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣) មាត្រា ៩

អះអាងថា កម្មវិធីសម្បទានដីសង្គមកិច្ចនេះបានទទួលការសម្រេចយល់ព្រមពីថ្នាក់ជាតិ ដោយពុំមានពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងពុំមានការវាយតម្លៃលើ ហេតុប៉ះពាល់សង្គម និងបរិស្ថានឡើយ។

មានអ្នកឆ្លើយតបតែពាក់កណ្តាល (៥២%) ប៉ុណ្ណោះ អះអាងថា អាជ្ញាធរមូលដ្ឋាន បានពន្យល់ពីមូលហេតុ ដែលពួកគេបានទទួលដី លើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ អ្នកឆ្លើយតបជាងមួយភាគបី (៣៩%) បានលើកឡើងថា ពួកគេពុំបានដឹងពីប្រព័ន្ធចាប់ឆ្នោត ដែលត្រូវបានប្រើប្រាស់ ដើម្បីបែងចែកក្បាលដីឡើយ ហើយអ្នកឆ្លើយតបភាគច្រើន (៥៨%) បានឆ្លើយថា ពួកគេមិនបានចូលរួមក្នុងការជ្រើសរើសក្បាលដី តាមរយៈការចាប់ឆ្នោត ឬមធ្យោបាយផ្សេងទៀតឡើយ។ នេះអាចដោយសារតែពួកគេត្រូវបានផាត់ចេញពី ដំណើរការនេះ ឬដោយសារតែកង្វះការផ្តល់ព័ត៌មានពីសំណាក់អាជ្ញាធរមូលដ្ឋាន។ សេណារីយ៉ូទាំងពីរនេះបង្ហាញបញ្ហាដែលកើតមានក្នុងដំណើរការបែងចែកដីនេះ។

មានអ្នកឆ្លើយតបតែ ៥៨% ប៉ុណ្ណោះ ជឿថា ប្រព័ន្ធបែងចែកដីមានភាពយុត្តិធម៌។ ក្នុងចំណោមអ្នកដែលត្រូវបានសម្ភាស ៦៥% បានលើកឡើងថា ពួកគេត្រូវបង់ថ្លៃសេវា/បង់ប្រាក់ដល់ដំណើរការដាក់ពាក្យសុំដីនេះ។ នេះបង្ហាញថា អាជ្ញាធរប្រហែលជាបានទារលុយ ពីគ្រួសារក្រីក្រ ឬគ្រួសារគ្មានដី ជាថ្នូរនឹងការដាក់ពាក្យសុំដី ការបែងចែកដី ឬដើម្បីអាចទទួលបានក្បាលដីណាមួយ ក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ចំនួនប្រាក់ជាមធ្យម ដែលត្រូវបានបង់ក្នុងតំបន់ប៊ូស្រានេះ គឺ ៥.៦៦០.០០០ រៀល ស្មើនឹងប្រមាណជា ១៣៨០ ដុល្លារ។

អ្នកឆ្លើយតបដែលបានលើកឡើងថា ពួកគេត្រូវបង់ប្រាក់ សម្រាប់ដំណើរការដាក់ពាក្យសុំដី មានភាគរយខ្ពស់ជាងអ្នកដែលលើកឡើងថាការបែងចែកដីធ្វើឡើងដោយយុត្តិធម៌ ពោលគឺមិនមែនអ្នកបានបង់លុយទាំងអស់សុទ្ធតែគិតថា ដំណើរការនេះធ្វើឡើងដោយអយុត្តិធម៌នោះទេ។ នេះមានន័យថា អ្នកដែលបានទារលុយពីប្រជាពលរដ្ឋ ប្រហែលជាបានពន្យល់ដល់អ្នកទទួលផលថា ការបង់លុយនេះគឺជាផ្នែកផ្លូវការមួយនៃដំណើរការ

ដាក់ពាក្យសុំដី។ ប្រជាពលរដ្ឋក៏បានអះអាងផងដែរថា មានគ្រួសារមួយចំនួនមានក្បាលដីច្រើនកន្លែង។

អ្នកឆ្លើយតប ៩៧% លើកឡើងថា ពួកគេពុំបានចុះហត្ថលេខាលើកិច្ចសន្យាអ្វីដែលចែងពីសិទ្ធិ ឬកាតព្វកិច្ច ទាក់ទងទៅនឹងការបែងចែក ឬការប្រើប្រាស់ដីនោះទេ បើទោះបីជាអ្នកទទួលដីទាំងអស់បានទទួលឯកសារ ដែលបង្ហាញពីការបែងចែកដីក៏ដោយ។ នេះមិនមែនជាប័ណ្ណកម្មសិទ្ធិដីផ្លូវការនោះទេ។

អ្នកឆ្លើយតបប្រហែលជាពាក់កណ្ដាល ពុំបានទទួលផែនការសម្បទានដីសង្គមកិច្ចឡើយ។ ក្រុមប្រឹក្សាឃុំ គួរតែផ្ដួចផ្ដើមរៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានដោយរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របទៅតាមលក្ខខណ្ឌតម្រូវដូចដែលមានកំណត់ក្នុងអនុក្រឹត្យស្ដីពីសម្បទានដីសង្គមកិច្ច។ អ្នកទទួលផលសម្បទានដីសង្គមកិច្ច "ត្រូវតែបានត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ស្របតាមផែនការសម្បទានដីសង្គមកិច្ច ដែលបានយល់ព្រម។"[86] មានអ្នកឆ្លើយតបតែ ២៦% ប៉ុណ្ណោះ ត្រូវបានស្នើឲ្យចូលរួមក្នុងការកែលំអយ៉ាងសកម្មនូវលក្ខខណ្ឌលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ នេះចង្អុលបង្ហាញពី កម្រិតទាបនៃការជម្រុញឲ្យសហគមន៍ចូលរួមពីសំណាក់អាជ្ញាធរមូលដ្ឋាន ទាំងនៅកម្រិតនៃកិច្ចពិគ្រោះយោបល់ផង និងក្នុងការរៀបចំផែនការបន្តអភិវឌ្ឍទីតាំងនេះផង។

អ្នកឆ្លើយតបទាំងអស់ បានលើកឡើងថា ពួកគេបានត្អូញត្អែរប្រាប់ទៅអាជ្ញាធរពីស្ថានភាពនៃការរស់នៅលើទីតាំងនេះ។ ការត្អូញត្អែរញឹកញាប់ជាងគេ គឺពាក់ព័ន្ធនឹងកង្វះទឹកស្អាត (៩៥%) បន្ទាប់មកគឺការមិនមានមណ្ឌលសុខភាព (៥២%) កង្វះអគ្គិសនី (៥២%) សាលារៀននៅឆ្ងាយពេក (២៣%) ផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធមិនទាន់ល្អ (២៣%) និងកង្វះអនាម័យ (១៦%)។ អ្នកឆ្លើយតប ៨០% បានលើកឡើងថា អាជ្ញាធរមូលដ្ឋានពុំបានឆ្លើយតបចំពោះការត្អូញត្អែររបស់ពួកគេឡើយ។ ចំណុចទាំងនេះត្រូវបានលើកឡើង បើទោះបីជា

[86] មាត្រា ១០ នៃអនុក្រឹត្យស្ដីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣)។

មានអ្នកឆ្លើយតប ៨៧,១% លើកឡើងថា អាជ្ញាធរមូលដ្ឋានបានពិនិត្យតាមដានស្ថានភាព ក្នុងទីតាំងនេះយ៉ាងសកម្មយ៉ាងណាក៏ដោយ។ អាជ្ញាធរមូលដ្ឋានបានដឹងយ៉ាងច្បាស់ពី ស្ថានភាពទាំងនេះ បន្ទាប់ពី ទទួលបានការត្អូញត្អែររបស់ប្រជាពលរដ្ឋ និងបានចូលរួម ពិនិត្យតាមដាន និងចុះផ្សព្វផ្សាយព័ត៌មានរួចមក។ អាជ្ញាធរអាចខ្វះឆន្ទៈ សមត្ថភាព ឬ ធនធាន ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ កង្វះការឆ្លើយតបចំពោះការត្អូញត្អែររបស់ ប្រជាពលរដ្ឋ មានន័យថា អាជ្ញាធរអាចខ្វះគ្រប់ចំណុចខាងលើ។ អ្នកឆ្លើយតបយ៉ាងច្រើន លើសលុបលើកឡើងថា <u>កិច្ចប្រជុំតាមភូមិ</u> គឺជាមធ្យោបាយចម្បងសម្រាប់លើកឡើងពីទុក្ខ លំបាកនានា។ អាជ្ញាធរមូលដ្ឋានមិនបានប្រើប្រាស់ការសួរសុខទុក្ខតាមផ្ទះ ការសម្ភាស ឬ ការអង្កេតនោះទេ។

ប្រជាពលរដ្ឋភាគច្រើនលើសលុប (៩៧%) រស់នៅក្នុងផ្ទះឈើ ដំបូលស័ង្កសី។ អាជ្ញាធរមូលដ្ឋានបានលើកឡើងថា ប្រជាពលរដ្ឋសរុប ២៥៣ គ្រួសារ បានទទួលក្បាលដី ក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះ។ អាជ្ញាធរពុំមានព័ត៌មានអំពីចំនួនមនុស្សសរុប កំពុង រស់នៅទីតាំងនេះឡើយ។

<u>កិច្ចប្រជុំភូមិ</u>ហាក់បីដូចជាត្រូវបានធ្វើឡើងជាទៀងទាត់។ អ្នកឆ្លើយតប ៤៤% បាន ចូលរួមក្នុងកិច្ចប្រជុំនេះរៀងរាល់ មួយខែ ទៅបីខែម្តង និង ២៦% ទៀតចូលរួមរៀងរាល់ ៦ ខែម្តង។ ក្នុងកិច្ចប្រជុំភូមិ អាជ្ញាធរបានសាកសួរពីស្ថានភាពនៃការរស់នៅទៅកាន់អ្នកឆ្លើយ តប ៣០% បន្ទាប់មកអំពីការរីកចម្រើនខាងកសិកម្ម (២៦%) និងការអប់រំ (១១%)។ ពួកគេ ហាក់បីដូចជាមិនបានសាកសួរពីចំណូល ឬសន្តិសុខស្បៀង ដែលមានសារៈសំខាន់ សម្រាប់ធានានូវកម្រិតជីវភាពសមរម្យនោះទេ។ នេះបង្ហាញថា <u>អាជ្ញាធរមូលដ្ឋានពុំបាន ពិនិត្យតាមដាន ឬរាយការណ៍ពីបញ្ហាសំខាន់ៗឡើយ</u>។

សហគមន៍បាន<u>ផ្តួចផ្តើមគំនិតកែលំអលក្ខខណ្ឌនៃការរស់នៅ</u> ក្នុងទីតាំងសម្បទាន ដីសង្គមកិច្ចនេះ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះផ្តោតការយកចិត្តទុកដាក់លើការកែលំអ សាលារៀនក្នុងមូលដ្ឋាននេះ (បើតាមការលើកឡើងរបស់អ្នកឆ្លើយតប ៧០%) ការកសាង ឬថែទាំអណ្តូងទឹក (៦៣%) ការថែទាំវត្តក្នុងមូលដ្ឋាននេះ (៥៩%) ការកែលំអ សេវាថែទាំ

សុខភាព (៣៣%) ការកសាងផ្លូវ (១៩%) និងការកែលំអប្រព័ន្ធធារាសាស្ត្រ នៅតំបន់ជនបទ (១៩%)។ ហាក់បីដូចជាមានកិច្ចខិតខំប្រឹងប្រែងជាច្រើន ដើម្បីធ្វើឲ្យកន្លែងផ្ដល់សេវា និងសេវានានាក្នុងមូលដ្ឋាននេះកាន់តែមានលក្ខណៈល្អប្រសើរ បើទោះបីជាពុំមានការបង្ហាញច្បាស់ថាតើអាជ្ញាធរមូលដ្ឋានផ្ដល់ជំនួយអ្វី នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះក៏ដោយ។

**ភាពសមស្របនៃដី៖**

អ្នកឆ្លើយតបចំនួន ២៨ នាក់ (៩០%) បាន<u>ទទួលដីលំនៅឋានផង និងដីកសិកម្មផងដោយឡែកពីគ្នា</u>។ ប្រជាពលរដ្ឋ ៣ គ្រួសារទៀត ដែលត្រូវបានសម្ភាសផងដែរនោះ បានទទួលតែដីលំនៅឋាន ប៉ុណ្ណោះ។ បើទោះបីជានេះជាតួលេខមួយទាបជាងតួលេខមធ្យមនៃទីតាំងសម្បទានដីសង្គមកិច្ច ដែលត្រូវបានអង្កេតផ្សេងទៀតក៏ដោយ វានៅតែជាការព្រួយបារម្ភ ប្រសិនបើគ្រួសារទាំងនេះមិនអាចទ្រទ្រង់ជីវភាពខ្លួនឯងបាន។ គ្រួសារទាំងនេះអាចមានមធ្យោបាយផ្សេងទៀត ដើម្បីទ្រទ្រង់ជីវភាពខ្លួនឯង។ អនុក្រឹត្យនេះចែងថា ក្បាលដីអាចផ្ដល់*សម្រាប់សង់លំនៅឋាន ដល់គ្រួសារក្រីក្រគ្មានផ្ទះសម្បែង ឬដល់គ្រួសារក្រីក្រសម្រាប់ធ្វើកសិកម្ម*។ ក្នុងករណីដែលពុំមានប័ណ្ណគ្រួសារក្រីក្រ ជាការសំខាន់ណាស់ ដែលអាជ្ញាធរមូលដ្ឋានអាចវាស់វែងកម្រិតនៃភាពក្រីក្រ និងតម្រូវការរបស់គ្រួសារទទួលដីឲ្យបានត្រឹមត្រូវ។

ប្រជាពលរដ្ឋ ២៦ គ្រួសារ (៨៤%) បានលើកឡើងថា <u>ដីសម្រាប់ធ្វើកសិកម្មដែលពួកគេទទួលបាន មិនត្រូវបាន "កាប់ឆ្ការសំអាត"</u> ឬសមស្រប សម្រាប់ធ្វើកសិកម្ម នៅពេលដែលពួកគេបានទទួលពីដំបូងឡើយ។ គ្រួសារទាំងនេះភាគច្រើននៅមិនទាន់បានកាប់ឆ្ការសំអាតដីរបស់ពួកគេនៅឡើយ ដែលបង្ហាញថា ដីនេះមិនត្រូវបានប្រើប្រាស់ សម្រាប់ដាំដុះដែលជាគោលបំណងដំបូងនៃកម្មវិធីនេះឡើយ។ អ្នកឆ្លើយតប ៥ នាក់ បានលើកឡើងថាពួកគេបានត្អូញត្អែរប្រាប់អាជ្ញាធរមូលដ្ឋានអំពីកង្វះអាហារ ប៉ុន្តែអ្នកទទួលផលភាគច្រើនលើសលុបនៅតែមិនអាចដាំដុះដំណាំបាន ដោយអ្នកឆ្លើយតប ៦៨% អះអាងថា ពួកគេពុំមានលទ្ធភាពចំណាយលើការកាប់ឆ្ការសំអាតដីកសិកម្មរបស់ពួកគេបានឡើយ។ ពុំមានអ្នកឆ្លើយតបណាលើកឡើងថា ដីនេះគ្មានជីជាតិរហូតដល់មិនអាចប្រើប្រាស់បាន ជាអ្វី

ដែលអ្នកឆ្លើយតបនៅទីតាំង សម្បទានដីសង្គមកិច្ចផ្សេងទៀតតែងលើកឡើងនោះទេ។ ចាំបាច់ត្រូវមានការផ្តល់ជំនួយ ដើម្បីប្រជាពលរដ្ឋទាំងនេះអាចចាប់ផ្តើម ឬបន្តអភិវឌ្ឍការងារកសិកម្មរបស់ពួកគេ។ ពុំមានគ្រួសារណាលើកឡើងថា បានទទួលជំនួយពីអាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល ឬគូអង្គខាងក្រៅផ្សេងទៀត សម្រាប់ការកាប់ឆ្ការសំអាតដីរបស់ខ្លួនឡើយ។ អ្នកដែលបានទទួលជំនួយកន្លងមក ត្រូវបានជួយដោយសមាជិកសហគមន៍ដូចគ្នាតែប៉ុណ្ណោះ។ អ្នកឆ្លើយតបភាគច្រើន (៧៥%) មានបំណងដាំដំឡូងមី នៅពេលដែលដីនេះត្រូវបានសំអាតរួច ហើយ ២៣% គ្រោងដាំស្វាយ។ ក្នុងពេលចុះដល់ទីតាំងនេះ បុគ្គលិក OHCHR បានសង្កេតឃើញថា មានចំការម្រេចជាច្រើនកំពុងអភិវឌ្ឍ។

ប្រជាពលរដ្ឋ ៣០ គ្រួសារ (៩៧%) បានលើកឡើងថា ពួកគេនៅមិនទាន់បាន<u>ទទួលប័ណ្ណកម្មសិទ្ធិដី</u>នៅឡើយ។ រយៈពេលមធ្យមនៃការរស់នៅលើទីតាំងដីសម្បទានសង្គមកិច្ចនេះគឺ ៤៧ ខែ គិតត្រឹមពេលសម្ភាសនេះ។ យោងតាមអនុក្រឹត្យនេះ អ្នកទទួលដីត្រូវតែគោរពទៅតាមលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសម្បទានដីសង្គមកិច្ច ដោយត្រូវរស់នៅឲ្យបាន ៥ ឆ្នាំ ទើបមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិដីស្របច្បាប់។ ទោះជាយ៉ាងណាក៏ដោយ អ្នកឆ្លើយតបភាគច្រើនលើសលុប (៩៣%) ពុំបានដឹងថាតើពួកគេត្រូវទទួលបានប័ណ្ណកម្មសិទ្ធិដីនៅពេលណានោះទេ ហើយពុំមានប្រជាពលរដ្ឋណាបានទទួលឯកសារ ដែលផ្តល់ឲ្យពួកគេនូវសិទ្ធិកាន់កាប់ក្នុងរយៈពេលអន្តរកាលនេះដែរ។ នេះ អាចធ្វើឲ្យប្រជាពលរដ្ឋងាយរងគ្រោះដោយសារការបណ្តេញចេញ ឬការដណ្តើមយកដីធ្លី។ ជាការប្រៀបធៀបក្នុងចំណោមអ្នកឆ្លើយតបនៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ មាន ៥៦% បានទទួលប័ណ្ណកម្មសិទ្ធិដី បើទោះបីជាចំនួនខែជាមធ្យម ដែលពួកគេរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចមានរយៈពេលវែងរហូតដល់ ៨២ ខែក៏ដោយ។ ប្រជាពលរដ្ឋគ្រប់គ្រួសារទាំងអស់គួរទទួលបានព័ត៌មានពីពេលដែលពួកគេនឹងទទួលបានប័ណ្ណកម្មសិទ្ធិដី ហើយពួកគេទាំងអស់គួរទទួលបានឯកសារ ដែលបង្ហាញពីសិទ្ធិភោគៈ និងផ្តល់សិទ្ធិកាន់កាប់ដល់ពួកគេរហូតដល់រយៈពេល ៥ ឆ្នាំត្រូវបានបញ្ចប់ ហើយមានការបែងចែកប័ណ្ណកម្មសិទ្ធិដល់

ពួកគេ។ អាជ្ញាធរមូលដ្ឋានបានលើកឡើងថា ពួកគេក៏មិនបានដឹងថាតើនៅពេលណាដែលគ្រួសារទាំងនោះ អាចទទួលបានប័ណ្ណកម្មសិទ្ធិដីនោះដែរ។

ផ្ទៃដីមធ្យមសម្រាប់សង់លំនៅឋានគឺ ១៧៥២ ម៉ែត្រការ៉េ (ប្រមាណជា ០,១៧៥ ហិកតា) ជាទំហំធំជាងក្បាលដីមធ្យម នៅតាមទីតាំងសម្បទានដីសង្គមកិច្ចដែលត្រូវបានអង្កេតនេះ។ មានអ្នកឆ្លើយតបតែម្នាក់ប៉ុណ្ណោះ ដែលអះអាងថាខ្លួនបានទទួលក្បាលដីតូចជាងអ្នកជិតខាងរបស់ខ្លួន ដោយអ្នកឆ្លើយតបផ្សេងទៀតទាំងអស់សុទ្ធតែនិយាយថាក្បាលដីមានទំហំស្មើគ្នា។

ទំហំផ្ទះជាមធ្យមគឺ ៥១ ម៉ែត្រការ៉េ។ ពុំមានផ្ទះណាត្រូវបានសាងសង់ឡើង មុនពេលដែលគ្រួសារទាំងនេះផ្លាស់មកទីតាំងដីសម្បទានសង្គមកិច្ចនេះឡើយ ហើយក៏ពុំមានការផ្តល់ផ្ទះឲ្យនោះដែរ។ ផ្ទះទាំងអស់ត្រូវបានសាងសង់ដោយគ្រួសារផ្ទាល់ និងដោយអ្នកជិតខាង។ គ្រួសារអាចសាងសង់ផ្ទះបាន ជាមធ្យម ១៧ ខែ ក្រោយពីបានទទួលដីនៅ ទីតាំងសម្បទានដីសង្គមកិច្ចនេះ។ អ្នកឆ្លើយតបភាគច្រើន (៥៨%) លើកឡើងថា លំនៅឋានថ្មីរបស់ពួកគេ*ល្អឆ្ងាយជាង* ផ្ទះមុនៗរបស់ពួកគេ។ មានប្រជាពលរដ្ឋ ៣ គ្រួសារ បានលើកឡើងថា ផ្ទះថ្មីរបស់ពួកគេ*អន់ជាង* ឬ*អន់ឆ្ងាយជាង* ផ្ទះមុនរបស់ពួកគេ។

អ្នកឆ្លើយតប ២៦% លើកឡើងថា ពួកគេ ពុំមានអារម្មណ៍ថា ខ្លួនមានសុវត្ថិភាពក្នុងផ្ទះបច្ចុប្បន្នរបស់ខ្លួនឡើយ ដោយសារតែការខូចខាតបង្កឡើងដោយសារអំពើរចោរកម្ម (៣៨%) និងដោយខ្យល់ /ភ្លៀង (៦៣%)។ គេមិនបានដឹងច្បាស់ថាតើមានប្រជាពលរដ្ឋប៉ុន្មានគ្រួសារ ដែលបានទទួលរងគ្រោះដោយសារអំពើចោរកម្ម ឬការខូចខាតបង្កឡើងដោយសារអាកាសធាតុនោះទេ។

ក្បាលដីសម្រាប់ធ្វើកសិកម្មជាមធ្យមមានទំហំ ៤,៣៦ ហិកតា។ ក្នុងចំណោមអ្នកឆ្លើយតបចំនួន ៣១ នាក់ មាន៣០ នាក់ លើកឡើងថា ឥឡូវនេះ ពួកគេកំពុងដាំដំណាំលើដីនៅជុំវិញផ្ទះរបស់ពួកគេ ហើយចំណូលមធ្យមប្រចាំឆ្នាំដែលបានពីការធ្វើកសិកម្មនេះគឺ ៥៦៦ ដុល្លារ។ តួលេខនេះគឺខ្ពស់ឆ្ងាយជាងតួលេខមធ្យម សម្រាប់ទីតាំងសម្បទាន ដីសង្គមកិច្ចផ្សេងទៀត។

មានអ្នកឆ្លើយតបតែម្នាក់ប៉ុណ្ណោះ ដែលអះអាងថា ខ្លួនរកចំណូលបានតិចជាងមុនពេលផ្លាស់មកទីតាំង សម្បទានដីសង្គមកិច្ចនេះ។ ៨៨% លើកឡើងថា ពួកគេទទួលបានចំណូល*ច្រើនជាងមុនបន្តិច* និង ៥០% លើកឡើងថា ទទួលបានចំណូល*ច្រើនជាងមុនច្រើន*។ អ្នកដែលមិនអាចរកចំណូលពីដីសម្រាប់ធ្វើកសិកម្ម បានលើកឡើងថាខ្លួនមិនទាន់បានដាំដំណាំនៅឡើយ ដែលបង្ហាញថា ចុងក្រោយ ពួកគេនៅតែអាចរកចំណូលបានដូចគេដូចឯងដែរ។ ពុំមានអ្នកឆ្លើយតបណាលើកឡើងថាដីគ្មានជីជាតិ ឬពួកគេខ្វះជំនាញដែលចាំបាច់នោះទេ។

**ជម្លោះដីធ្លី៖**

ក្នុងចំណោមអ្នកឆ្លើយតប ៣១ នាក់ មាន ៣ នាក់ (១០%) លើកឡើងថា បច្ចុប្បន្ននេះពួកគេ កំពុងជាប់ពាក់ព័ន្ធនឹងជម្លោះដីធ្លី ទាក់ទិននឹងដីផ្ទះសម្បែងពួកគេ។ ជម្លោះពីរករណីគឺជាមួយនឹងប្រជាពលរដ្ឋដែលធ្លាប់រស់នៅទីនេះកន្លងមក។ ពុំមានជម្លោះណាកើតមានជាមួយក្រុមហ៊ុនឯកជន ឬស្ថាប័នរដ្ឋនោះទេ។ អ្នកឆ្លើយតបចំនួន ៧ នាក់ (២៣%) ទទួលរងការទន្ទ្រានលើដីរបស់ខ្លួន និង ៣ នាក់ ធ្លាប់ទទួលរងការគំរាមកំហែង។

សហគមន៍ពូនង ដែលជាជនជាតិដើមភាគតិច អះអាងថា ត្រូវបានគេបណ្ដេញចេញដោយបង្ខំពី ដីដែលជាទីតាំងសម្បទានដីសង្គមកិច្ចនេះ ដោយមិនបានទទួលសំណងឡើយ។ មន្ត្រីមូលដ្ឋានលើកឡើងថាបានដឹងពីវត្តមានសហគមន៍នេះដែរ ប៉ុន្តែពុំមានលទ្ធភាពបញ្ឈប់ ឬពន្យឺតដំណើរការសម្បទានដីសង្គមកិច្ច ឬដោះស្រាយជម្លោះនេះបាន។ ក្នុងការពិភាក្សាក្រុមគោលដៅដែលត្រូវបានធ្វើឡើងជាមួយនឹងអ្នកសម្ភាស មានការលើកឡើងថា នៅពេលមានការវាស់វែងដីលើទីតាំងសម្បទានដីសង្គមកិច្ចនេះ គ្រួសារជនជាតិដើមភាគតិច និងគ្រួសារផ្សេងទៀត បានលើកឡើងនូវការព្រួយបារម្ភដែលថាដីរបស់ពួកគេកំពុងទទួលរងការទន្ទ្រាន។ គ្រួសារមួយចំនួនបានទទួលសំណងជាក្បាលដីនៅខាងក្រៅតំបន់សម្បទានដីសង្គមកិច្ចនេះ ហើយគ្រួសារផ្សេងទៀតពុំបានទទួលអ្វីទាំងអស់។ មានការលើក ឡើងថា អាជ្ញាធរបានដឹងពីវត្តមានរបស់សហគមន៍ជនជាតិដើមភាគតិច និងពីការទាមទារចង់បានដីរបស់ពួកគេ នៅទីតាំងសម្បទានដីសង្គមកិច្ច ប៉ុន្តែអាជ្ញាធរ

នៅតែបន្តអនុវត្តកម្មវិធីនេះ ដោយមិនបានទទួលការយល់ព្រម ឬបំពេញទៅតាមការទាមទារចង់បានដីរបស់ពួកគេឡើយ (ដោយបានបង្ខំគ្រួសារជនជាតិដើមភាគតិចទាំងនេះឲ្យចេញពីដី ដែលពួកគេបានប្រើប្រាស់ជាប្រពៃណី និងមានសារៈសំខាន់ផ្នែកវប្បធម៌)។ អ្នកចូលរួមក្នុងការពិភាក្សាក្រុមគោលដៅបានលើកឡើងថា គ្រួសារដែលមានទ្រព្យសម្បត្តិច្រើន (ដូចជា "មានឡានឡិចស៊ីសជិះ" ជាដើម) បានទទួលក្បាលដី ក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះ។

បន្ថែមពីលើគ្រួសារដែលបានទទួលដី ដែលធ្លាប់ប្រើប្រាស់ដោយសហគមន៍ជនជាតិដើមភាគតិចកន្លងមក មានការលើកឡើងផងដែរថា មានក្រុមហ៊ុនឯកជនមួយបានទទួលដីសម្រាប់អភិវឌ្ឍន៍ ក្នុងទីតាំងសម្បទានដីសង្គមកិច្ចនេះ។ មន្ត្រីនៅថ្នាក់ស្រុក និងខេត្ត ជាអ្នកផ្តួចផ្តើម និងគ្រប់គ្រងដំណើរការសម្បទានដីសង្គមកិច្ចនេះ ដោយពុំមានការចូលរួមពីមន្ត្រីថ្នាក់ឃុំ។

**ការទទួលបានទឹក និងអនាម័យ៖**

អ្នកឆ្លើយតបចំនួន ២៦ នាក់ (៨៤%) <u>ពុំមានលទ្ធភាពទទួលបានទឹកស្អាតសម្រាប់បរិភោគឡើយ</u>។ ពួកគេភាគច្រើន (៥២%) ទៅរកទឹកពីអូរ ឬស្ទឹង ហើយ ៣២% ពីអណ្តូងដែលជាអណ្តូងសាធារណៈ ឬអណ្តូងដែលស្ថិតនៅលើដីរបស់ពួកគេ។ អ្នកឆ្លើយតប ៨១% លើកឡើងថា ពួកគេដាំទឹកបរិភោគ ហើយអ្នកឆ្លើយតបផ្សេងទៀតពុំបានធ្វើប្រព្រឹត្តិកម្មទឹករបស់ពួកគេសោះតែម្តង។ អ្នកឆ្លើយតប ២៩% បានលើកឡើងថាទឹកបរិភោគរបស់ពួកគេមានពណ៌ រសជាតិ និង/ឬក្លិនចម្លែក។ ពុំមានអ្នកឆ្លើយតបណាសំអាតទឹក ដោយប្រើសារធាតុក្លរឡើយ។ អ្នកឆ្លើយតបសម្ភាស ៥២% បានដាក់ពិន្ទុឲ្យការទទួលបានទឹកស្អាតរបស់ខ្លួនថា អន់ឆ្ងាយជាងកន្លែងដែលពួកគេរស់នៅលើកមុន ហើយ ១៦% ទៀត ដាក់ពិន្ទុថាអន់ខ្លាំងណាស់។ មានអ្នកឆ្លើយតបសម្ភាសតែ ១៦% ប៉ុណ្ណោះ ដែលបានដាក់ពិន្ទុឲ្យការទទួលបានទឹកស្អាតរបស់ពួកគេថាល្អប្រសើរជាងមុន ចាប់តាំងពីផ្លាស់មកនៅទីនេះមក។ តួលេខនេះគឺខ្ពស់ឆ្ងាយជាងនៅតាមទីតាំងសម្បទាន ដីសង្គមកិច្ចផ្សេងទៀត ដែលបង្ហាញថា បញ្ហា

ពាក់ព័ន្ធនឹងការទទួលបានទឹកនេះគឺមានភាពស្រួចស្រាវខ្លាំង នៅតំបន់ប៊ិស្រា ហើយពុំមានការបែងចែកធនធានគ្រប់គ្រាន់សម្រាប់ផ្ដល់ទឹកស្អាតឡើយ។

គ្រួសារទាំងនេះ ពុំមានប្រព័ន្ធបញ្ចេញចោលទឹកស្អុយនៃប្រភេទណាមួយឡើយ។ អ្នកឆ្លើយតប ៨៧% ពុំមានបរិក្ខារអនាម័យ (បង្គន់) ឡើយ។ ប្រជាពលរដ្ឋផ្សេងទៀតបន្ទោរបង់ក្នុងព្រៃ ឬជីករណ្ដៅ។ អ្នកឆ្លើយតប ៨១% បានដាក់ពិន្ទុឲ្យស្ថានភាពអនាម័យរបស់ខ្លួនថាអន់ជាងកន្លែងរស់នៅមុនរបស់ពួកគេ។

## សេវាសុខាភិបាល៖

ជាមធ្យម ប្រជាពលរដ្ឋត្រូវចំណាយពេល ៩៧ នាទី ដើម្បីធ្វើដំណើរទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុត និង ១០៣ នាទី ដើម្បីធ្វើដំណើរទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត។ ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ២៩% លើកឡើងថាពួកគេមានជំងឺញឹកញាប់ជាងមុន បើប្រៀបធៀបជាមួយនឹងស្ថានភាពនៃការរស់នៅមុន។ ជំងឺគ្រុនចាញ់ គឺជាមូលហេតុដែលនាំឲ្យមនុស្សឈឺញឹកញាប់ជាងគេក្នុងភូមិនេះ (បើតាមការលើកឡើងរបស់អ្នកឆ្លើយតប ៧១%) បន្ទាប់មកគឺ "គ្រុនក្ដៅ" (៥៥%) ឈឺក្រពះ (២៩%) និងគ្រុនពោះវៀន (២៩%)។ អ្នកឆ្លើយតប ៦៧% លើកឡើងថា ការទទួលបានសេវាសុខាភិបាលគឺអន់ជាងមុន បើប្រៀបធៀបជាមួយនឹងកន្លែងដែលពួកគេរស់នៅមុន។

## ការអប់រំ៖

នៅតំបន់នេះ ពុំមានសាលាមធ្យមសិក្សានោះទេ។ កុមារត្រូវធ្វើដំណើរតាមម៉ូតូឌុបជាមធ្យម ៥០ នាទី ដើម្បីទៅដល់សាលាមធ្យមសិក្សាដែលនៅជិតបំផុត។ អ្នកឆ្លើយតប ៩០% លើកឡើងថា ពុំមានសាលាបឋមសិក្សា លើទីតាំង សម្បទានដីសង្គមកិច្ចនេះនោះទេ។ ជាមធ្យម កុមារចំណាយពេល ៣០ នាទី ដើម្បីធ្វើដំណើរទៅសាលាបឋមសិក្សាដែលនៅជិតជាងគេ។ អ្នកឆ្លើយតប ៣ នាក់ (១០%) បានលើកឡើងថា យ៉ាងហោចណាស់ មានកូន ដល់វ័យចូលរៀនមួយចំនួន (អាយុចន្លោះពី ៦ឆ្នាំ ដល់ ១៧ឆ្នាំ) របស់ពួកគេ ពុំបានទៅរៀនឡើយ ដោយពីរនាក់លើកឡើងថា ដោយសារតែសាលារៀននៅឆ្ងាយពេក។ អ្នកឆ្លើយ

តប ១១ នាក់ (៣៦%) បាននិយាយថា បច្ចុប្បន្ននេះ កូនៗពួកគេតិចជាងមុនបានទៅរៀន ចាប់តាំងពីផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះមក។ នេះបង្ហាញថា ក្នុងចំណោម គ្រួសារដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ មានគ្រួសារជាច្រើនបានបញ្ជូន កូនខ្លះទៅរៀន ប៉ុន្តែមិនបានទាំងអស់នោះទេ។ នៅពេលឲ្យដាក់ពិន្ទុលើការទទួលបានការ អប់រំ នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ មានអ្នកឆ្លើយតប ៦៧% បានលើកឡើងថា ការ ទទួលបានការអប់រំធ្លាក់ចុះជាងមុន ចាប់តាំងពីពេលដែលពួកគេផ្លាស់មករស់នៅទីនេះ។

**ហេដ្ឋារចនាសម្ព័ន្ធ និងអគ្គិសនី៖**

អ្នកឆ្លើយតប ៨៩% លើកឡើងថា ការប្រើប្រាស់មធ្យោបាយធ្វើដំណើរ (បណ្តាញផ្លូវ ថ្នល់) និងការទំនាក់ទំនង (ទូរស័ព្ទ និងអ៊ីនធឺណិត) មានការថមថយ និងអន់ជាងកន្លែង ដែលពួកគេរស់នៅមុន។ ពុំមានប្រជាពលរដ្ឋណាអាចភ្ជាប់អគ្គិសនី ទៅនឹងបណ្តាញរបស់ រដ្ឋបានឡើយ។

**សន្តិសុខស្បៀង៖**

អ្នកឆ្លើយតប ៧១% និយាយថា ថ្មីៗកន្លងទៅនេះ ពួកគេមានការព្រួយបារម្ភជាប្រចាំ ថា ពួកគេ នឹងពុំអាចផ្តល់អាហារគ្រប់គ្រាន់ដល់គ្រួសាររបស់ខ្លួនបាន។ ៧៩% ពុំមាន លទ្ធភាពបរិភោគអង្ករ ឬសាច់ដែលមានគុណភាពល្អ ក្នុងរយៈពេល ៤ សប្តាហ៍ចុងក្រោយ នេះឡើយ។ ៥៨% បានលើកឡើថា ពួកគេបរិភោគតិចជាងសព្វដងកាល ពីពេលថ្មីៗនេះ ដោយសារតែខ្វះលុយ និងខ្វះលទ្ធភាពដាំដំណាំ សម្រាប់ប្រើជាអាហារ ហើយ ១៩% លើក ឡើងថា ពួកគេត្រូវអត់អាហារ ដោយសារតែមូលហេតុស្រដៀងគ្នានេះ។ អ្នកឆ្លើយតបចំនួន ២ នាក់ និយាយថាពួកគេធ្លាប់ដាច់បាយពេញមួយថ្ងៃ កាលពីសប្តាហ៍ថ្មីៗនេះ។ ជារួម អ្នក ឆ្លើយតប ៥៨% ចាត់ទុកការមានអាហារបរិភោគត្រូវបានចាត់ទុកថាអន់ថយជាងស្ថានភាព មុនពេលផ្លាស់មកនៅទីនេះ។

**ការងារ៖**

គ្រួសារដែលត្រូវបានសាកសួរទាំងអស់ មានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់មានការងារធ្វើ។ គ្រួសារ ៥៥% មានមនុស្ស ២ នាក់ មានការងារធ្វើ។ ជាការឆ្លើយតបចំពោះសំណួរដែលសួរថាតើការងារប្រភេទណាខ្លះដែលពួកគេធ្វើ ៩០% ស៊ីឈ្នួលធ្វើកសិកម្មឲ្យគេ ៨១% ធ្វើការងារប្រភេទប្រើប្រាស់កម្លាំងពលកម្មផ្សេងទៀត ហើយ ៥២% លើកឡើងថា មានមុខរបរខ្លួនឯង។ ចំណូលមធ្យមប្រចាំខែរបស់គ្រួសារគឺ ៣៨៩,៦ ដុល្លារក្នុងមួយខែ។ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ចំណូលមធ្យមប្រចាំខែរបស់អ្នកឆ្លើយតបគឺទាបជាងនេះបន្តិចពោលគឺ ២៧៦ ដុល្លារ ក្នុងមួយគ្រួសារ។ ចំណូលមានការកើនឡើងច្រើន បើទោះបីជាគេមិនដឹងច្បាស់ទេថាតើមុនពេលផ្លាស់មកនៅទីនេះ គ្រួសារមានមនុស្សពេញវ័យដែលមានការងារធ្វើក្នុងចំនួនដូចបច្ចុប្បន្ននេះដែរនោះ។ ចំណាយមធ្យមសម្រាប់គ្រួសារ បច្ចុប្បន្ននេះគឺ ៣២៦ ដុល្លារ កើនឡើងពី ២៥៨ ដុល្លារ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ចំណាយភាគច្រើន គឺលើអាហារ បន្ទាប់មកលើការថែទាំសុខភាព និងការធ្វើដំណើរ។ កង្វះហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញផ្លូវថ្នល់ពិបាក ធ្វើឲ្យប្រជាពលរដ្ឋត្រូវចំណាយលុយអស់ច្រើន ក្នុងមួយខែៗ។ បើទោះបីជាចំណូលមានការកើនឡើងក៏ដោយ ចំណាយប្រចាំថ្ងៃរបស់គ្រួសារក៏មានការកើនឡើងផងដែរ។ ចំណាយលើការថែទាំសុខភាពមានការកើនឡើងខ្ពស់ជាងគេសម្រាប់គ្រួសារ បន្ទាប់ពីពួកគេផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ផ្ទុយទៅវិញ ចំណាយលើការរៀបចំពិធីសាសនាមានការថយចុះខ្លាំង។

គ្រួសារប្រមាណជាពាក់កណ្តាលអាចសន្សំប្រាក់បាន ចាប់តាំងពីផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ (៤៨%)។ គ្រួសារ ៦៨% ជាប់ជំពាក់បំណុលគេ បើទោះបីជាកម្រិតបំណុលនេះ ជាមធ្យម មានការថយចុះ សម្រាប់អ្នកដែលឆ្លើយតបក៏ដោយ។ អ្នកឆ្លើយតប ៣៣% លើកឡើងថា ពួកគេមានអារម្មណ៍តានតឹង (ស្ត្រេស) ដោយសារចំណូលមានការថយចុះ។ អ្នកឆ្លើយតប ៣៣% លើកឡើងថា ពួកគេដឹងពីករណីកុមារធ្វើការងារដើម្បីរកចំណូលបន្ថែមឲ្យគ្រួសារ (កុមារត្រូវបានឲ្យនិយមន័យថាជាអ្នកដែលមានអាយុ

១៥ ឆ្នាំចុះក្រោម)។ ការងារភាគច្រើនដែលកុមារធ្វើ គឺការងារកសិកម្ម (៨៥%) និងប្រភេទការងារប្រើកម្លាំងពលកម្មផ្សេងទៀត (៣១%)។

ជាសូចនាករបង្ហាញពីទ្រព្យធន គ្រួសារ ២៦% មានទូរទស្សន៍ជាកម្មសិទ្ធិ ៩០% មានម៉ូតូជាកម្មសិទ្ធិ និង ៩៧% មានទូរស័ព្ទដៃ។

**វចនាសម្ព័ន្ធផ្នែកសង្គម៖**

គ្រួសារតាមផ្ទះ ៥២% ជឿថា ការសម្រេចចិត្តជាសមូហភាពក្នុងសម្បទានដីសង្គមកិច្ច បានត្រូវអនុវត្តតាមរយៈដំណើរការប្រជាធិបតេយ្យ មាន២៣%ទៀត កំពុងលើកឡើងថា គ្មានការធ្វើសេចក្តីសម្រេចចិត្តជាសមូហភាពនោះទេ។

អ្នកឆ្លើយតប ៥២% បានលើកឡើងថា ពួកគេ មានអារម្មណ៍ ស្រ្តេស មាន២៩%ទៀត កំពុងរាយការណ៍ ស្រ្តេសនេះ កំពុងកើតមានលក្ខណៈធ្ងន់ធ្ងរជាពិសេស។ ជាដំបូង ស្រ្តេសនេះ ត្រូវបានគេសន្មតថា មកពីកង្វះអាហារ និងប្រាក់ចំណូលទាប។

អ្នកឆ្លើយតប ៨៧% បានលើកឡើងថា ពួកគេបានដឹងពីការរំលោភបំពានដោយសារគ្រឿងស្រវឹងកំពុងកើតឡើងក្នុងសហគមន៍។ គ្មានអ្នកឆ្លើយតបណាម្នាក់អះអាងថា បានដឹងពីការរំលោភបំពានដោយសារគ្រឿងស្រវឹងក្នុងសម្បទានដីសង្គមកិច្ចទេ។ គ្មានគ្រួសារតាមផ្ទះណាមួយ បានរាយការណ៍ថា ពួកគេ ធ្លាប់បានកំពុងធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលដើម្បីអភិវឌ្ឍឲ្យប្រសើរឡើងនៅទីតាំងសម្បទានដីសង្គមកិច្ចទេ។ ៧៧% នៃគ្រួសារតាមផ្ទះដែលបានអង្កេត គិតថាមានបទល្មើសឧក្រិដ្ឋតិចក្នុងសហគមន៍ បើធៀបជាមួយនឹងស្ថានភាពរបស់ពួកគេ មុនផ្លាស់ទៅទីតាំងសម្បទានដីសង្គមកិច្ច ហើយ ១៩% បន្ថែមទៀត ជឿថា ស្ថានភាពនេះស្រដៀងគ្នាទៅនឹងស្ថានភាពពីមុន។ ៣ គ្រួសារ (ប្រហែលជា១០% នៃអ្នកឆ្លើយតប) សំអាងថា ដឹងពីអំពើហិង្សាលើស្ត្រី ឬក្មេងស្រី។ ស្របពេលនោះដែរ ៦២% ជឿថា ហិង្សាផ្លូវភេទ មានអត្រាតិចជាងក្នុងសហគមន៍ពីមុន។ ការរកឃើញទាំងនេះ មិនផ្តល់នូវការគណនាច្បាស់លាស់នៃអត្រា ទូទៅនៃហិង្សា ផ្លូវភេទ ឬការរំលោភបំពានដោយសារគ្រឿងស្រវឹងនោះទេ។ ការរកឃើញទាំងនេះ ជាការឆ្លុះបញ្ចាំងពី

គំនិតយោបល់របស់សហគមន៍តែប៉ុណ្ណោះ ហើយ គេត្រូវតែអានយល់ដូចនេះ ជាមួយការយល់ដឹងថា ក្រុមអង្កេតនេះ មិនបានសួរដោយផ្ទាល់ទេ ឧទាហរណ៍៖ ថាតើ ការរំលោភបំពានកើតឡើយដោយគ្រឿងស្រវឹងជាបញ្ហាមួយនៅក្នុងខ្នងផ្ទះមួយឬទេ។

អ្នកឆ្លើយតប ៤២% បាននិយាយថា ពួកគេ បានដឹងពីកុមារធ្វើការរកចំណូលបន្ថែមសម្រាប់គ្រួសារ។ ភាគច្រើននៃការងារ នេះ គឺជាការងារនៅចំការ (៨៥%) ហើយនិងប្រភេទការងារប្រើកំលាំងផ្សេងៗទៀត (៣១%)។

អ្នករស់នៅទីនោះ ៨៤% ដោយចោទថា ពួកគេ *មិនត្រូវបានគេចុះឈ្មោះបោះឆ្នោតឡេទេ*។ តួលេខនេះ កើន ខ្ពស់ដោយគ្មានសមាមាត្រទេ ដោយហេតុថា ខ្នងផ្ទះជាមធ្យម បានតាំងនៅទីនោះអស់រយៈពេលជិត៤ឆ្នាំ ហើយការបោះឆ្នោតឃុំកៀកនឹងមកដល់ក្នុងឆ្នាំ ២០១៧ទៀត។

គ្រួសារតាមផ្ទះ ៥៨% ខ្វះឯកសារពាក់ព័ន្ធការរស់នៅ ផ្តល់ដោយអាជ្ញាធរមូលដ្ឋាន។ ក្នុង ២៩% នៃខ្នងផ្ទះ យ៉ាងហោចណាស់ សមាជិកម្នាក់ក្នុងគ្រួសារ ខ្វះសំបុត្រកំណើត ហើយក្នុង ៤៥%នៃខ្នងផ្ទះ យ៉ាងហោចណាស់ សមាជិកគ្រួសារម្នាក់ ខ្វះអត្តសញ្ញាណប័ណ្ណ។ គ្រួសារ ១៦% ខ្វះ សៀវភៅគ្រួសារ។

មានតែ ៣ គ្រួសារ (១០%) ប៉ុណ្ណោះ បាននិយាយថា ពួកគេ កំពុងគិតគូរចេញពីទីតាំងសម្បទានដីសង្គមកិច្ចនេះ ដោយ ហេតុថា ខ្វះខាតទឹក អាហារ និងការប្រឈមផ្សេងៗទៀតក្នុងតំបន់នេះ មានការសម្គាល់ឃើញថា ចំនួននេះ មាន កំរិតទាប។ សំណើរទៅលើរបៀបដើម្បីធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ បានផ្តោតទៅលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវ (៤៨%) ការទទួលបានទឹកស្អាត(៨៧%) ការកសាងសាលាមធ្យមសិក្សាក្នុងទីតាំងសម្បទានដីសង្គមកិច្ច (៦៥%) ហើយនិងការធ្វើឲ្យប្រសើរឡើងនូវការផ្តល់បរិក្ខារថែទាំសុខភាព (៨៧%) ប៉ុន្តែ ក៏មានសំណើរជាច្រើនផងដែរ ត្រូវបានលើកឡើងទៅលើបញ្ហាផ្សេងៗមួយចំនួនទៀត រួមមាន លំនៅឋាន អគ្គិសនី ការងារ និងការផ្តល់បង្គន់អនាម័យ។

## ឧបសម្ព័ន្ធទី ៦៖ ទិន្នន័យអង្កេតពីសម្បទានដីសង្គមកិច្ចនៅឃុំត្រពាំងត្នោត ស្រុកឈូក ខេត្តកំពត

*របកគំហើញសំខាន់ៗ*

- *គ្រួសារទទួលបានដី ចោទថា ពួកគេ ទទួលរងសម្ពាធ និងត្រូវបានបង្ខំឲ្យលក់ដីនៅទីតាំងសម្បទានដីសង្គមកិច្ចទៅឲ្យបុគ្គលដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភម្នាក់ក្នុងមូលដ្ឋាន។ ដោយមានសេចក្តីរាយការណ៍ថា គ្រួសារមួយចំនួន បានទទួលរងការគំរាមកំហែង ហើយបន្ទាប់មក បានចាកចេញពីទីតាំងសម្បទានដីសង្គមកិច្ចនេះ ខណៈពេលដែលគ្រួសារផ្សេងទៀតបានទទួលយកលុយជាថ្នូរនឹងការប្រគល់ដីរបស់ពួកគេ (ដោយអ្នកខ្លះនិយាយថា ជាការផ្ទុយនឹងការចង់បានរបស់ពួកគេ)។ ដោយមានសេចក្តីរាយការណ៍ថា ជនរងគ្រោះ ដែលបានដាក់ពាក្យបណ្តឹងស្របច្បាប់ ត្រូវបានគេរាំងមិនឲ្យស្វែងរកដំណោះស្រាយចំពោះពាក្យបណ្តឹងទាំងនេះ តាមរយៈប្រព័ន្ធតុលាការឡើយ។*
- *មានការលើកឡើងដោយគ្មានភស្តុតាងថា ព្រៃឈើប្រមាណជា ១០០០ ហិកតា ក្នុងតំបន់វាលឈើត្រាវ ត្រូវបានកាប់ឆ្ការដោយជនល្មើសម្នាក់ ដែលកំពុងទទួលបានដីសម្បទានដីសង្គមកិច្ចក្នុងទំហំធំៗ ដោយប្រើប្រាស់មធ្យោបាយផ្សេងៗ។*
- *គ្រួសារតាមផ្ទះភាគច្រើន (៨៧%) ក៏បានលើកឡើងផងដែរថា ពួកគេបានចូលរួមក្នុងការកំណត់អត្តសញ្ញាណ និងរៀបចំផែនការទីតាំងសម្បទានដីសង្គមកិច្ចនេះ ហើយអ្នកឆ្លើយតប ៨៣% បានលើកឡើងថា ពួកគេបានចូលរួមក្នុងការជ្រើសរើសក្បាលដី។ គ្រួសារបីភាគបួនបានទទួលផែនការសម្បទានដីសង្គមកិច្ចនេះ។ ប្រជាពលរដ្ឋជិត ៩០% ជឿថា ដំណើរការបានអនុវត្តបែងចែកដីធ្វើឡើងដោយយុត្តិធម៌។ នេះជាតួលេខខ្ពស់ជាងតួលេខមធ្យម សម្រាប់គ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ដែលត្រូវបានអង្កេត។*
- *ពុំមានគ្រួសារតាមផ្ទះណាបានទទួលប័ណ្ណកម្មសិទ្ធិដី ឬឯកសារពាក់ព័ន្ធនឹងការបែងចែកដីនោះឡើយ។*

- *អ្នកឆ្លើយតបបីភាគបួនអះអាងថា កន្លែងរស់នៅថ្មីរបស់ពួកគេល្អជាង ឬល្អឆ្ងាយជាងផ្ទះមុនរបស់ពួកគេ ខណៈពេលដែលប្រជាពលរដ្ឋ ៦ គ្រួសារ (១៣%) បានលើកឡើងថា លំនៅឋានថ្មីរបស់ពួកគេអន់ជាង ឬអន់ឆ្ងាយជាងផ្ទះមុនរបស់ពួកគេ។ ក្នុងករណីនេះ កម្មវិធីសម្បទានដីសង្គមកិច្ចនេះហាក់បីដូចជាបានបង្កលក្ខណៈឲ្យមានការលើកកម្ពស់ស្ថានភាពលំនៅឋាន សម្រាប់គ្រួសារភាគច្រើនដែលបន្តរស់នៅទីនេះ ប៉ុន្តែមិនមែនសម្រាប់គ្រប់គ្រួសារទាំងអស់នោះឡើយ។*
- *ចំណូលជាមធ្យមប្រចាំខែ ដែលបានពីការធ្វើកសិកម្ម មានកម្រិតទាបខ្លាំង បើធៀបជាមួយនឹងទីតាំងសម្បទានដីសង្គមកិច្ចផ្សេងទៀត ដែលបង្ហាញថា ចាំបាច់ត្រូវមានការផ្តល់ការគាំទ្របន្ថែមជាបន្ទាន់ ដើម្បីជួយដល់គ្រួសារទាំងនេះអាចរកចំណូលសម្រាប់គ្រួសារពីដីកសិកម្មមកទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគេ និងរ៉ាប់រងលើចំណាយប្រចាំខែរបស់គ្រួសារដែលបន្តមានការកើនឡើង។ ចំណូលសម្រាប់គ្រួសារ គិតជាមធ្យមមានការកើនឡើងសម្រាប់គ្រួសារភាគច្រើន។ នេះគឺដោយសារតែមានសមាជិកគ្រួសារទៅធ្វើការងារនៅរោងចក្រក្បែរៗនោះ។*
- *អ្នកឆ្លើយតប ៨០% បាននិយាយថា ពួកគេបានដឹងពីកុមារដែលធ្វើការងារ ដើម្បីរកចំណូលបន្ថែមឲ្យគ្រួសារ។ ការងារភាគច្រើនគឺជាការងារកសិកម្ម (និងប្រភេទការងារប្រើកម្លាំងពលកម្មផ្សេងទៀត)។ គ្រួសារតាមផ្ទះខ្លះ បញ្ជូនសមាជិកគ្រួសារជាកុមារ ឲ្យទៅធ្វើការងារក្នុងរោងចក្រជិតនោះ។*
- *ប្រជាពលរដ្ឋ បួនភាគប្រាំ ដែលត្រូវបានសម្ភាស ពុំមានទឹកស្អាតសម្រាប់បរិភោគឡើយ។ ពុំមានប្រព័ន្ធបញ្ចេញចោលទឹកស្អុយឡើយ ហើយក៏ពុំមានគ្រួសារតាមផ្ទះណាមានបរិក្ខារអនាម័យក្នុងទម្រង់ណាមួយនោះដែរ។*

នៅទីតាំងសម្បទានដីសង្គមកិច្ចខេត្តកំពតនេះ ៤៧ គ្រួសារតាមផ្ទះ ត្រូវបានសម្ភាស។ ទីតាំងសម្បទានដីសង្គមកិច្ចនេះ ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋសរុប ១០១ គ្រួសារ ក្នុងនោះ ៤០ គ្រួសារមកពីឃុំស្ទឹងកែវ និង ៦១ គ្រួសារទៀត មកពីឃុំត្រពាំងផ្លាំង។

អាជ្ញាធរមូលដ្ឋានបានលើកឡើងថា សរុបមានប្រជាពលរដ្ឋ ១០១ គ្រួសារ ស្មើនឹង ៧០៨ នាក់ កំពុងបានរស់នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ហើយដែលទីតាំងនេះត្រូវបានចុះបញ្ជីផ្លូវការ ក្នុងខែ តុលា ឆ្នាំ ២០១១។

អ្នកឆ្លើយតប ៧៦% គឺជាស្ត្រី បើទោះបីជាមានអ្នកឆ្លើយតបត្រឹមតែ ៣៧% ប៉ុណ្ណោះដែលបានប្រកាសថា ជាស្ត្រី គឺជាគ្រួសារ។ ៧២% លើកឡើងថា ពួកគេរៀបការរួច ឬកំពុងរស់នៅជាមួយអ្នកដែលពួកគេមានទំនាក់ទំនងជាមួយ។ ៥% គឺជាស្ត្រីមេម៉ាយ/បុរសពោះម៉ាយ ឬលែងលះ។ អាយុមធ្យមរបស់អ្នកឆ្លើយតបគឺ ៥៥ ឆ្នាំ។ គ្រួសារដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ មានចំនួនសមាជិកជាមធ្យម ៤,៨៥ នាក់ នៅក្នុងផ្ទះមួយ និងមានកូន ២,២ នាក់។ មិនមែនសមាជិកទាំងអស់សុទ្ធតែរស់នៅលើទីតាំងនេះជាអចិន្ត្រៃយ៍នោះទេ។ អ្នកឆ្លើយតបទាំងអស់លើកឡើងថា ពួកគេជាជនជាតិខ្មែរ។

នៅពេលសាកសួរពីមូលហេតុដែលពួកគេបានទទួលដីសម្បទានសង្គមកិច្ច អ្នកឆ្លើយតប ៧២% បានឆ្លើយថា ដោយសារតែពួកគេគ្មានដី ដោយ ៩១% លើកឡើងថា ដោយសារភាពក្រីក្រ។ ប្រជាពលរដ្ឋ ២ គ្រួសារ (៤%) បានផ្លាស់ប្តូរទីកន្លែងរស់នៅដោយសារតែគ្រោះមហន្តរាយធម្មជាតិ និងមួយគ្រួសារផ្លាស់ប្តូរទីកន្លែងរស់នៅ ដើម្បីផ្តល់ទីតាំងឲ្យគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ មានចំណុចត្រួតគ្នានៅទីនេះ ដោយអ្នកឆ្លើយតបផ្តល់ចម្លើយច្រើនយ៉ាង ដែលបង្ហាញពីហេតុផលដែលនាំឲ្យពួកគេទទួលបានដី។ នៅពេលសាកសួរពីមូលហេតុ ដែលគ្រួសារផ្សេងទៀតនៅទីតាំងសម្បទានដីសង្គមកិច្ចនេះបានទទួលដី ចម្លើយគឺត្រូវគ្នាជាមួយនឹងចម្លើយខាងលើដែរគឺ ការគ្មានដី និងភាពក្រីក្រ។

គ្រួសារភាគច្រើន (៨៧%) មានប័ណ្ណសម្គាល់គ្រួសារក្រីក្រ (តាមរយៈកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ)។ អ្នកទទួលបានដីសម្បទានសង្គមកិច្ចទាំងអស់ បានបែងចែកឲ្យក្រោយអនុក្រឹត្យឆ្នាំ២០១១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានចេញ ( ក្រៅតែពីយោធិនរំសាយ) គួរមានប័ណ្ណសម្គាល់គ្រួសារក្រីក្រពីដំបូង ដែលនេះគឺជាមធ្យោបាយស្នូលសម្រាប់វាយតម្លៃកម្រិតនៃភាពក្រីក្រ ហើយនិងដើម្បីកំណត់អត្តសញ្ញាណអ្នកទទួល

ដី និងអ្នកដាក់ពាក្យស្នើសុំដែលមានលក្ខណៈសម្បត្តិអាចទទួលបាន។[87] កង្វះប័ណ្ណគ្រួសារក្រីក្ររបស់គ្រួសារដែលនៅសល់ ១៣% ទៀត មានន័យថា មានការប្រើប្រាស់មធ្យោបាយផ្សេងទៀតដើម្បីវាយតម្លៃកម្រិតនៃភាពក្រីក្រ។

គ្រួសារតាមផ្ទះភាគច្រើន (៨៧%) ក៏បានអះអាងថាបានចូលរួមក្នុងការកំណត់ និងការរៀបចំផែនការនៅទីតាំងសម្បទានដីសង្គមកិច្ចនេះផងដែរ ដោយប្រជាពលរដ្ឋដែលរស់នៅលើដីនេះ ៩១% បានលើកឡើងថា អាជ្ញាធរមូលដ្ឋានបានពន្យល់ពី ដំណើរការជ្រើសរើស និងបែងចែកដី និងពីការប្រើប្រាស់ប្រព័ន្ធចាប់ឆ្នោតដើម្បីបែងចែកដី។ អ្នកឆ្លើយតប ៨៣% បានលើកឡើងថា ពួកគេបានចូលរួម ក្នុងការជ្រើសរើសក្បាលដី។ មានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប៉ុន្តែពុំមានការចូលរួមឲ្យបានពេញលេញនោះទេ។ ប្រជាពលរដ្ឋ ៨៩% ជឿថា ដំណើរការបានអនុវត្តបែងចែកដីធ្វើឡើងប្រកបដោយភាពយុត្តិធម៌។ ភាគរយនេះគឺខ្ពស់ជាងតួលេខមធ្យម ៦៧% នៅក្នុងគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ ដែលត្រូវបានអង្កេត។ មានអ្នកឆ្លើយតបម្នាក់ លើកឡើងថា ពួកគេបានបង់លុយ ដើម្បីចូលរួមក្នុងដំណើរការបែងចែកដី ប៉ុន្តែបង់តែ ២០០០ រៀលប៉ុណ្ណោះ (តិចជាង ១ ដុល្លារ)។

ពុំមានគ្រួសារតាមផ្ទះណា បានទទួលឯកសារពាក់ព័ន្ធនឹងការបែងចែកដីឡើយ ដែលនេះជាបញ្ហាចោទមួយ។ ក្នុងករណីដែលពុំមានប័ណ្ណកម្មសិទ្ធិដី គ្រួសារ គួរមានឯកសារបង្ហាញពីដំណើរការរៀបចំផែនការ និងបែងចែកដីដែលជាមធ្យោបាយមួយដើម្បីការពារសិទ្ធិភោគៈ និងសិទ្ធិមានកម្មសិទ្ធិរបស់ពួកគេ។ គ្រួសារ ៣៩% បានចុះកិច្ចសន្យាជាមួយអាជ្ញាធរ ទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ច ចំពោះទីតាំងសម្បទានដីសង្គមកិច្ចនេះ។

[87] មាត្រា ១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣) ចែងថា អ្នកសុំដីសម្បទានសង្គមកិច្ចគួរបំពេញលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុ ដែលកំណត់ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយផ្អែកលើយោបល់របស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ។ គោលការណ៍ណែនាំអំពីការវាយតម្លៃប្រាក់ចំណូលត្រូវពិចារណាដោយផ្អែកលើទំហំគ្រួសារ និងលក្ខខណ្ឌ អាយុ និងសុខភាពនៃសមាជិកគ្រួសារ។ គោលការណ៍ណែនាំនេះអាចប្រែប្រួលទៅតាមតំបន់ ទៅតាមពេលវេលា ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច និងជីវភាពរស់នៅ។

អ្នកឆ្លើយតប ៧៨% បានទទួលផែនការសម្បទានដីសង្គមកិច្ច។ ក្រុមប្រឹក្សាឃុំគួរផ្តួចផ្តើមរៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របទៅតាមលក្ខខណ្ឌ ដូចដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។ អ្នកទទួលដីសម្បទានសង្គមកិច្ច "ត្រូវតែបានត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចស្របតាមផែនការសម្បទានដីសង្គមកិច្ចដែលបានយល់ព្រម។"[88] អ្នកឆ្លើយតបក្នុងភាគរយខាងលើ (៧៨%) បានអះអាងថា ត្រូវបានស្នើឲ្យចូលរួមកែលំអស្ថានភាព នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ នេះបង្ហាញពីកម្រិតខ្ពស់នៃការជម្រុញឲ្យសហគមន៍ចូលរួមពីសំណាក់អាជ្ញាធរមូលដ្ឋាន ក្នុងការអភិវឌ្ឍទីតាំងនេះ។

អ្នកឆ្លើយតបទាំងអស់ បានលើកឡើងថា ពួកគេបានត្អូញត្អែរប្រាប់ទៅអាជ្ញាធរពីស្ថានភាពនៃការរស់នៅលើទីតាំងនេះ។ ការត្អូញត្អែរញឹកញាប់ជាងគេ គឺពាក់ព័ន្ធនឹងកង្វះទឹកស្អាត (៨៥%) កង្វះអាហារ (៥០%) ការទៅមណ្ឌលសុខភាព (៧៨%) ចំងាយទៅកាន់សាលារៀន (៧៨%) គុណភាពផ្លូវ (៣៥%) និងអគ្គិសនី (២០%)។ មានអ្នករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះតែ ៣៧% ប៉ុណ្ណោះ ដែលលើកឡើងថាអាជ្ញាធរអាចឆ្លើយតបចំពោះការត្អូញត្អែររបស់ពួកគេ។ ចំណុចទាំងនេះត្រូវបានលើកឡើង បើទោះបីជាមានអ្នកឆ្លើយតប ៩១% លើកឡើងថា អាជ្ញាធរមូលដ្ឋានបានពិនិត្យតាមដានស្ថានភាពក្នុងទីតាំងនេះយ៉ាងសកម្មយ៉ាងណាក៏ដោយ។ អាជ្ញាធរមូលដ្ឋានបានដឹងយ៉ាងច្បាស់ពីស្ថានភាពទាំងនេះ បន្ទាប់ពីបានទទួលការត្អូញត្អែររបស់ប្រជាពលរដ្ឋ និងបានចូលរួមពិនិត្យតាមដាន និងចុះផ្សព្វផ្សាយព័ត៌មានរួចមក ប៉ុន្តែការពិនិត្យតាមដានពុំត្រូវបានធ្វើឲ្យបានជាប់លាប់ និងមិនត្រូវបានធ្វើនៅទីតាំងសម្បទានដីសង្គមកិច្ចទាំងមូលឡើយ។ អាជ្ញាធរអាចខ្វះឆន្ទៈ សមត្ថភាព ឬធនធាន ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ អ្នកឆ្លើយតបបានលើកឡើងថា កិច្ចប្រជុំតាមភូមិ (៦៨%) គឺជាមធ្យោបាយចម្បងសម្រាប់លើកឡើងពីទុក្ខលំបាកនានា ដែលនេះបង្ហាញពីកម្រិតនៃការចូលរួមខ្ពស់ពីសំណាក់អាជ្ញាធរមូលដ្ឋាន។ ប្រជាពលរដ្ឋ

[88] មាត្រា ១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣)។

៣២% ទៀត បានលើកឡើងថា មានការទទួលការត្អូញត្អែរ ឬប្រមូលភស្តុតាងពីប្រជាពលរដ្ឋជារៀងរាល់ខែ ឬរៀងរាល់ ៣ ខែម្តង។ អ្នកឆ្លើយតប ៣២% បានលើកឡើងថា ការវាយតម្លៃ ឬកិច្ចប្រជុំត្រូវបានរៀបចំឡើងតែប្រចាំឆ្នាំប៉ុណ្ណោះ ដោយ ២១% ទៀតលើកឡើងថា ការវាយតម្លៃ ឬកិច្ចប្រជុំនេះបានធ្វើឡើងតែ ១ លើកប៉ុណ្ណោះ ចាប់តាំងពីពេលដែលពួកគេផ្លាស់មករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ គ្រួសារភាគច្រើន (៨៥%) បានអនុវត្តសកម្មភាពដោយខ្លួនឯង ដើម្បីដោះស្រាយបញ្ហានានារបស់ខ្លួន ដោយកិច្ចខិតខំប្រឹងប្រែងផ្តោតជាសំខាន់លើសាលារៀន មណ្ឌលសុខភាព និងផ្លូវ។

គ្រួសារតាមផ្ទះភាគច្រើន (៨៥%) លើកឡើងថា សហគមន៍បានផ្តួចផ្តើមគំនិតកែលំអលក្ខខណ្ឌនៃការរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះផ្តោតការយកចិត្តទុកដាក់លើការកែលំអ ការសាងសង់ ឬការថែទាំផ្លូវ (៣៦%) ការបង្កើនលទ្ធភាពទទួលបានសេវាថែទាំសុខភាព (៥៩%) ការទទួលបានទឹក/ការកសាងអណ្តូងទឹក (៦៨%) និងសាលារៀនក្នុងមូលដ្ឋាន (៩០%)។

**ភាពសមស្របនៃដី៖**

ប្រជាពលរដ្ឋចំនួន ៩១ គ្រួសារ (៨៩%) បានទទួលដីលំនៅឋានផង និងដីកសិកម្មផង។ ប្រជាពលរដ្ឋ ៨ គ្រួសារទៀត ដែលត្រូវបានសម្ភាសផងដែរនោះ បានទទួលតែដីលំនៅឋានប៉ុណ្ណោះ ហើយមួយគ្រួសារទៀតអះអាងថាបានទទួលតែដីកសិកម្មតែប៉ុណ្ណោះ។ គ្រួសារទាំង ៨ នេះអាចមានមធ្យោបាយផ្សេងទៀត ដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន។ អនុក្រឹត្យនេះចែងថា ក្បាលដីអាចផ្តល់*សម្រាប់សង់លំនៅឋាន ដល់គ្រួសារក្រីក្រគ្មានផ្ទះសម្បែង ឬដល់គ្រួសារក្រីក្រ សម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ*។ ក្នុងករណីដែលពុំមានប័ណ្ណគ្រួសារក្រីក្រ ជាការសំខាន់ណាស់ ដែលអាជ្ញាធរមូលដ្ឋានត្រូវវាស់វែងកម្រិតនៃភាពក្រីក្រ និងតម្រូវការរបស់គ្រួសារទទួលដីនីមួយៗឲ្យបានត្រឹមត្រូវ ។

អ្នកឆ្លើយតបភាគច្រើនលើកឡើងថា ដីសម្រាប់ធ្វើកសិកម្មរបស់ពួកគេមិនទាន់បាន "កាប់ឆ្ការសំអាត" និងអាចយកមកធ្វើកសិកម្មបានឡើយ នៅពេលដែលពួកគេបានទទួលដំបូង ដោយមានតែមួយគ្រួសារ (២%) ប៉ុណ្ណោះ និយាយថាដីទាំងអស់របស់ពួកគេត្រូវបាន

កាប់ឆ្ការសំអាត និងនៅសល់ ១១% ទៀត និយាយថា ដីមួយចំនួនត្រូវបានសំអាត។ គ្រួសារភាគច្រើនក្នុងចំណោមគ្រួសារទាំងនេះ (៥១%) នៅមិនទាន់កាប់ឆ្ការសំអាតដីរបស់ខ្លួននៅឡើយ ដោយពួកគេនិយាយថា ពួកគេពុំមានលទ្ធភាពចំណាយលើការកាប់ឆ្ការសំអាតដីនេះ និងពុំមានពេលវាលា ដែលបង្ហាញថា បច្ចុប្បន្ន ដីនេះមិនត្រូវបានកំពុងប្រើប្រាស់សម្រាប់ធ្វើកសិកម្មទៅតាមគោលបំណងពីដំបូងឡើយ។ ប្រជាពលរដ្ឋភាគច្រើន (៧២%) មានបំណងដាំដំឡូងមី និង ៥២% ទៀត ចង់ដាំស្វាយ។

ពុំមានគ្រួសារណាបានលើកឡើងថា ពួកគេ <u>បានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីនោះទេ</u>។ រយៈពេលនៃការរស់នៅជាមធ្យមលើដីសម្បទានសង្គមកិច្ចនេះគឺ ៥៧ ខែ គិតត្រឹមពេលសម្ភាសនេះ។ យោងតាមអនុក្រឹត្យនេះ អ្នកទទួលដីត្រូវតែគោរពទៅតាមលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសម្បទានដីសង្គមកិច្ច ដោយត្រូវរស់នៅឲ្យបាន ៥ ឆ្នាំ ទើបមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិដីស្របច្បាប់។ អ្នកឆ្លើយតបភាគច្រើន (៨៣%) *មិន* ត្រូវបានប្រាប់ថាពួកគេនឹងទទួលបានប័ណ្ណកម្មសិទ្ធិនោះទេ។ ប្រជាពលរដ្ឋភាគច្រើន (៨០%) បានទទួលឯកសារខ្លះពាក់ព័ន្ធនឹងភោគៈ ឬកម្មសិទ្ធិ (ពួកគេ ១០០% បានទទួលឯកសារពាក់ព័ន្ធនឹងការចាប់ឆ្នោតយកដី និងមួយគ្រួសារបានទទួលកិច្ចសន្យាទាក់ទងនឹងសម្បទានដីសង្គមកិច្ចនេះ) ដែលផ្តល់ឲ្យពួកគេនូវសុវត្ថិភាពក្នុងការកាន់កាប់ដីដ៏មានកម្រិតក្នុងអំឡុងអន្តកាលនេះ។ នេះមិនមែនជាស្ថានភាពល្អប្រសើរនោះទេ។ ប្រជាពលរដ្ឋគ្រប់រូបគួរមានឯកសារ និងកិច្ចសន្យាទាក់ទងនឹងសម្បទានដីសង្គមកិច្ចនេះ។ ប៉ុន្តែ តួលេខនេះគឺខ្ពស់ឆ្ងាយជាងតួលេខមធ្យម សម្រាប់គ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ (៥៣%)។

ជាការប្រៀបធៀប ៥៦% នៃអ្នកឆ្លើយតបទាំងអស់ នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ បានទទួលប័ណ្ណកម្មសិទ្ធិដី បើទោះបីជាចំនួនខែជាមធ្យមនៃការរស់នៅគ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់គឺខ្ពស់រហូតដល់ ៨២ ខែ ក៏ដោយ។ ប្រជាពលរដ្ឋគ្រប់គ្រួសារទាំងអស់គួរទទួលបានព័តិមានពីពេលដែលពួកគេ ត្រូវទទួលបានប័ណ្ណកម្មសិទ្ធិដី ហើយពួកគេទាំងអស់គួរទទួលបានឯកសារ ដែលបង្ហាញពីសិទ្ធិភោគៈ និងទទួលបានសិទ្ធិកាន់កាប់រហូតដល់រយៈពេល ៥ ឆ្នាំត្រូវបានបញ្ចប់ និងមានការចែកប័ណ្ណកម្មសិទ្ធិ។

ផ្ទៃដីមធ្យមសម្រាប់សង់លំនៅឋានគឺ ១៧៤០ ម៉ែត្រការ៉េ ជាទំហំតូចជាងក្បាលដីមធ្យម នៅតាមទីតាំងដីសម្បទានសង្គមកិច្ចដែលត្រូវបានអង្កេតនេះ (១៩២០ ម៉ែត្រការ៉េ)។ មានអ្នកឆ្លើយតបតែ ២ នាក់ប៉ុណ្ណោះ ដែលបានលើកឡើងថា ពួកគេបានទទួលក្បាលដីតូចជាងអ្នកជិតខាងរបស់ខ្លួន។

ទំហំផ្ទះជាមធ្យមគឺ ២០ ម៉ែត្រការ៉េ ពោលគឺតូចជាងទំហំផ្ទះគិតជាមធ្យមនៅតាមទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ (២៨ ម៉ែត្រការ៉េ)។ ពុំមានផ្ទះណាត្រូវបានសាងសង់ឡើង មុនពេលដែលគ្រួសារទាំងនេះផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះឡើយ។ ផ្ទះទាំងអស់ត្រូវបានសាងសង់ដោយគ្រួសារផ្ទាល់ និងដោយអ្នកជិតខាង។ គ្រួសារអាចសាងសង់ផ្ទះបានជាមធ្យម ២ ខែ ក្រោយពីបានទទួលដីសម្បទានសង្គមកិច្ច។ អ្នកឆ្លើយតបភាគច្រើន (៦៧%) លើកឡើងថា លំនៅឋានថ្មីរបស់ពួកគេ*ល្អជាង* ឬ*ល្អឆ្ងាយជាង* ផ្ទះមុនៗរបស់ពួកគេ។ ប្រជាពលរដ្ឋ ៦ គ្រួសារ (១៣%) បានលើកឡើងថា ផ្ទះថ្មីរបស់ពួកគេ*អន់ជាង* ឬ*អន់ឆ្ងាយជាង* ផ្ទះមុនរបស់ពួកគេ។ បើទោះបីជាចំណុចនេះមួយផ្នែកដោយសារតែការយល់ឃើញក៏ដោយ វាជាសញ្ញាសំខាន់បង្ហាញពីភាពជោគជ័យនៃគម្រោងសម្បទានដីសង្គមកិច្ចនេះ។ តើគ្រួសារក្រីក្រ ឬគ្មានដី បានទទួលលំនៅឋានសមរម្យ ដែលអាចបំពេញទៅតាមតម្រូវការជាមូលដ្ឋានរបស់ពួកគេដែរឬទេ? ក្នុងករណីនេះ គម្រោងសម្បទានដីសង្គមកិច្ចនេះ ហាក់បីដូចជាមិនបានលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់គ្រួសារជាច្រើនឡើយ។

អ្នកឆ្លើយតប ៥៩% លើកឡើងថា ពួកគេពុំមានអារម្មណ៍ថាខ្លួនមិនមានសុវត្ថិភាពក្នុងផ្ទះបច្ចុប្បន្នរបស់ខ្លួនឡើយ ដោយសារតែការខូចខាតបង្កឡើងដោយខ្យល់/ភ្លៀង (៧៩%)។ គេមិនបានដឹងច្បាស់ថាតើមានប្រជាពលរដ្ឋប៉ុន្មានគ្រួសារ ដែលបានទទួលរងគ្រោះដោយសារអំពើចោរកម្ម ឬការខូចខាតបង្កឡើងដោយសារអាកាសធាតុនោះទេ។

ក្បាលដីសម្រាប់ធ្វើកសិកម្មជាមធ្យមមានទំហំ ១,២៤ ហិកតា ដែលធំជាងទំហំមធ្យមសម្រាប់គ្រប់ទីតាំងសម្បទានដីសង្គមកិច្ចទាំងអស់ដែលត្រូវបានអង្កេតបន្តិច (១,១៧ ហិកតា)។ ប្រជាពលរដ្ឋចំនួន ៦ នាក់ លើកឡើងថា អ្នកជិតខាងរបស់ពួកគេទទួលបានដីធំជាង ហើយអ្នកឆ្លើយតបដែលនៅសល់លើកឡើងថា ក្បាលដីរបស់ពួកគេមានទំហំស្មើគ្នា។

អ្នកឆ្លើយតប ៧០% បានលើកឡើងថា ឥឡូវនេះ ពួកគេបានដាំដំណាំលើដីនៅជុំវិញផ្ទះរបស់ពួកគេ បើទោះបីជា អ្នកឆ្លើយតបជាច្រើន (៥១%) ពុំទាន់ទទួលចំណូលសម្រាប់គ្រួសារពីសកម្មភាពនេះក៏ដោយ ពោលគឺពួកគេភាគច្រើនដាំទុកបរិភោគ ជាជាងយកទៅលក់ (មានប្រជាពលរដ្ឋតែមួយគ្រួសារប៉ុណ្ណោះ ដែលមិនបានដាំដុះលើដីជុំវិញផ្ទះរបស់ពួកគេទាល់តែសោះ។ ចំណូលប្រចាំឆ្នាំជាមធ្យម ដែលបានពីការធ្វើកសិកម្ម គឺត្រឹមតែ ៨៩ ដុល្លារប៉ុណ្ណោះ។ នេះជាតួលេខទាបជាងគេ សម្រាប់ទីតាំងដីសម្បទានសង្គមកិច្ចទាំងអស់ដែលត្រូវបានអង្កេត និងទាបឆ្ងាយជាងចំណូលមធ្យម ក្នុងប្រទេសកម្ពុជា។ កម្រិតចំណូលសម្រាប់គ្រួសារនេះ គឺមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ ដោយពុំមានចំណូលបន្ថែមឡើយ។ អ្នកទទួលផលធ្វើការងារក្នុងទម្រង់ផ្សេងទៀត ដូចបរិយាយខាងក្រោម។ បើទោះបីជាមានការទទួលបានចំណូលទាបពីការធ្វើកសិកម្មក៏ដោយ មានអ្នកឆ្លើយតបតែ ៣២% ប៉ុណ្ណោះដែលលើកឡើងថា នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ពួកគេរកចំណូលបានតិចជាងពេលដែលពួកគេរស់នៅទីតាំងមុន។ ផ្ទុយទៅវិញ ៦៨% ទទួលបានចំណូលច្រើនជាង ឬច្រើនឆ្ងាយជាងចំណូលដែលពួកគេធ្លាប់ទទួលបាន។ ប្រជាពលរដ្ឋ ៥៧% បាននិយាយថា ពួកគេកំពុងរង់ចាំឲ្យដំណាំរបស់ពួកគេដុះ មានន័យថា ចំណូលសម្រាប់គ្រួសារដែលបានពីការដាំដុះគួរមានការកើនឡើងទៅតាមនេះដែរ។

ប្រជាពលរដ្ឋ ១៦% បានលក់ ឬធ្វើអំណោយផ្នែកខ្លះនៃដីរបស់ពួកគេ។ នេះអាចដោយសារតែពួកគេរកចំណូលបានទាប និងជាប់បំណុលគេច្រើន និង/ឬដោយសារតែពួកគេមិនអាចបង្កបង្កើនផល និងរកចំណូលពីដីដែលពួកគេបានទទួល។ មានតែ ២ គ្រួសារតាមផ្ទះប៉ុណ្ណោះ ដែលបានសម្ភាស បានទទួលជំនួយក្នុងការប្រើប្រាស់ដីរបស់ពួកគេអំឡុងពេលដែលពួកគេមករស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។

ប្រជាពលរដ្ឋភាគច្រើនលើសលុប (៩២%) លើកឡើងថា ពួកគេមិនធ្លាប់មានជំនាញកសិកម្មមុនពេលផ្លាស់មកនៅទីតាំងនេះឡើយ ហើយក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ ៦២% និយាយថា ជំនាញធ្វើកសិកម្មរបស់ ពួកគេពុំបានល្អប្រសើរជាងមុនឡើយ ដែលនេះបង្ហាញថា ការគាំទ្រ និងការបណ្តុះបណ្តាលនៅមិនទាន់បានគ្រប់គ្រាន់នៅឡើយ រហូតមក

ទល់នឹងពេលបច្ចុប្បន្ននេះ។ នេះក៏បង្ហាញផងដែរថា ចាំបាច់ត្រូវមានការងារ ឬឱកាសរកចំណូលក្នុងទម្រង់ផ្សេងទៀត ហើយការបណ្តុះបណ្តាល និងការគាំទ្រខាងការធ្វើកសិកម្មក៏ចាំបាច់ត្រូវមាននៅតាមទីតាំងសម្បទានដីសង្គមកិច្ច តួយ៉ាងដូចជាទីតាំងនេះផងដែរ។ នេះក៏ទាមទារឲ្យមានការវាយតម្លៃលើជំនាញ និងចំណេះដឹង ក្នុងដំណាក់កាលរៀបចំផែនការទីតាំងសម្បទានដីសង្គមកិច្ចនេះ ដើម្បីកំណត់ពីតម្រូវការរបស់ប្រជាពលរដ្ឋ រៀបចំអន្តរាគមន៍ដែលមានសក្តានុពល និងធ្វើការបែងចែកធនធានដែលកំពុងតែខ្វះខាតឲ្យមានប្រសិទ្ធភាពបំផុត។

**ជម្លោះដីធ្លី៖**

ក្នុងចំណោមអ្នកឆ្លើយតបដែលត្រូវបានសម្ភាសទាំងអស់ មាន ២ នាក់ បានលើកឡើងថា បច្ចុប្បន្ននេះ កំពុងជាប់ពាក់ព័ន្ធនឹងជម្លោះដីធ្លីទាក់ទិននឹងដីគ្រួសាររបស់ពួកគេជាមួយក្រុមហ៊ុនឯកជនមួយ។ ប៉ុន្តែ មានអ្នកឆ្លើយតប ២៩% ជួបប្រទះនឹងការទន្ទ្រានដីពីក្រុមហ៊ុនឯកជន ឬពីបុគ្គលដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ ក្នុងចំណោមប្រជាពលរដ្ឋ ១១ គ្រួសារ មាន ១០ គ្រួសារអះអាងថា បានទទួលរងការយាយី ឬការគំរាមកំហែងពាក់ព័ន្ធជាមួយនឹងដីរបស់ពួកគេ។

កាលពីខែ មេសា ឆ្នាំ ២០១៤ ដោយចោទថា បុគ្គលដែលមានខ្នងបង្អែកខ្លាំងម្នាក់បានទៅជួបនឹងគ្រួសារទទួលផលមួយចំនួន និងដាក់សម្ពាធឲ្យពួកគេលក់ដីនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ និងបានចាប់ផ្តើមសាងសង់អគារលើដីនេះ។ អ្នកទទួលបានដីសម្បទានសង្គមកិច្ចបានលើកឡើងថា ពួកគេត្រូវបានប្រាប់ថានឹងទទួលបាន ៣០០ ដុល្លារម្នាក់ និងត្រូវបានគំរាមថានឹងទទួលរងការបណ្តេញចេញដោយបង្ខំ ប្រសិនបើពួកគេមិនទទួលយក។ មានការដាក់ពាក្យបណ្តឹងទៅអភិបាលខេត្ត ប៉ុន្តែប្រជាពលរដ្ឋទាំងនេះបានលើកឡើងថា អភិបាលខេត្តពុំមានឆន្ទៈ ឬមិនអាចចាត់វិធានការអ្វីបានឡើយ។ អ្នកទទួលដីក៏បានលើកឡើងផងដែរថា ពួកគេបានទទួលរងការគំរាមកំហែង ប្រសិនបើពួកគេរៀបចំធ្វើការតវ៉ា ឬដាក់ពាក្យបណ្តឹង។ ដីព្រៃក្នុងតំបន់វាលឈើគ្រារនេះប្រមាណជា ១០០០ ហិកតាដោយចោទថា ត្រូវបានកាប់ឆ្ការដោយបុគ្គលនេះ ដើម្បីយកដីមកអភិវឌ្ឍ។

ការស្រាវជ្រាវមួយដែលធ្វើឡើងដោយ OHCHR បានរកឃើញថា ក្នុងចំណោមប្រជាពលរដ្ឋ ៥០គ្រួសារ មកពីឃុំស្ទឹងកែវ មាន ៣០ គ្រួសារ បានចាកចេញពីទីតាំងសម្បទានដីសង្គមកិច្ចនេះ ក្រោយពីបដិសេធមិនព្រមទទួលសំណង និងក្រោយពីបានទទួលរងការគំរាមកំហែង ខណៈដែល ១០ គ្រួសារទៀត មកពីឃុំនេះដែរ បានទទួលយកសំណាង និងចុងក្រោយធ្វើការងារឲ្យក្រុមហ៊ុនដែលជារបស់ជនដែលទទួលរងការចោទប្រកាន់នេះ ដែលជាការងារកាប់ឆ្ការសំអាតព្រៃ។ ក្នុងចំណោមប្រជាពលរដ្ឋ ៦១ គ្រួសារមកពីឃុំត្រពាំងភ្លាំង មាន ៤១ គ្រួសារ បដិសេធមិនព្រមទទួលសំណង និងបានចាកចេញពីទីតាំងសម្បទានដីសង្គមកិច្ចនេះ ក្រោយពីបានទទួលការគំរាមកំហែង ខណៈពេលដែល ២០ គ្រួសារ បានទទួលយកសំណង និងចុងក្រោយ ធ្វើការងារឲ្យក្រុមហ៊ុនដែលជារបស់ជនឧក្រិដ្ឋដែលទទួលរងការចោទប្រកាន់នេះ ដែលជាការងារកាប់ឆ្ការសំអាតព្រៃ។

លោក ហេង សឿន តំណាងគ្រួសាររងផលប៉ះពាល់ ដោយចោទថា គាត់បានទទួលរងការវាយដំពីសន្តិសុខ ពេលដើរប្រមូលស្នាមមេដៃដើម្បីដាក់ញត្តិ។ ដោយសារតែការគំរាមកំហែងដល់អាយុជីវិតរបស់គាត់ គាត់បានចាកចេញពីទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ក្រោយពីបានទទួលសំណើរគាំទ្រពីសមាជិកសហគមន៍ដែលត្រូវបានបណ្តេញចេញ និងទទួលរងការគំរាមកំហែង អង្គការ ADHOC បានដាក់ពាក្យបណ្តឹងប្តឹងជនឧក្រិដ្ឋដែលរងការចោទប្រកាន់នេះ ទៅកាន់ព្រះរាជអាជ្ញានៃតុលាការខេត្តកំពតពីបទរំលោភបំពានសិទ្ធិដីធ្លី (ការកាប់ដីព្រៃខុសច្បាប់) និងបង្ករបួសស្នាមដល់អ្នកដទៃ។ ព្រះរាជអាជ្ញាបានកោះហៅ ហេង សឿន កាលពីថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥។ អ្នកភូមិ ១០ នាក់ផ្សេងទៀត ត្រូវបានកោះហៅមកសាកសួរផងដែរ ប៉ុន្តែមិនមាននរណាម្នាក់ត្រូវបានឃាត់ខ្លួនឡើយ។

ក្នុងចំណោមគ្រួសារទទួលដីទាំង ១០១ គ្រួសារ មានភាគច្រើនលើសលុបត្រូវបានរារាំងមិនឲ្យប្រើប្រាស់ផ្នែកខ្លះ ឬផ្នែកទាំងអស់នៃដីសម្រាប់ធ្វើកសិកម្មរបស់ពួកគេ។ ប្រជាពលរដ្ឋដែលរស់នៅជាប់នឹងទីតាំងសម្បទានដីសង្គមកិច្ចនេះ ក៏ត្រូវបានបណ្តេញចេញផងដែរ។ អាជ្ញាធរខេត្តខានមិនបានការពារប្រជាពលរដ្ឋទាំងនេះ មិនបានធ្វើការស៊ើបអង្កេតលើការចោទប្រកាន់នានា ឬពុំបានផ្តល់ដំណោះស្រាយអ្វីឡើយ។ កាលពីឆ្នាំ ២០១៦

មានការរាយការណ៍ប្រាប់ OHCHR ថា មានការវាយដំ ការចោទប្រកាន់ពីការបណ្តេញចេញដោយបង្ខំ និងការដុតផ្ទះជាច្រើនករណីថែមទៀតផងដែរ។

**ការទទួលបានទឹក និងអនាម័យ៖**

គ្រួសារ ៨០% ដែលត្រូវបានសម្ភាស ពុំមានលទ្ធភាពទទួលបានទឹកស្អាតសម្រាប់បរិភោគឡើយ។ ប្រជាពលរដ្ឋទៅរកទឹកពីអណ្តូងដៃ (៤៨%) អន្លង់សាធារណៈ (១១%) ឬស្ទឹង ឬប្រឡាយ (៣៩%)។ ប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ៨៥% បានសំអាតទឹករបស់ពួកគេ មុនពេលបរិភោគ តាមរយៈការដាំ។ ពុំមានអ្នកឆ្លើយតបណាម្នាក់ប្រើប្រាស់ឧបករណ៍ចម្រោះទឹកឡើយ។ អ្នកឆ្លើយតប ៣០,៥% បានលើកឡើងថា ទឹកបរិភោគរបស់ពួកគេមានពណ៌ រសជាតិ និង/ឬក្លិនចម្លែក។ ពុំមានគ្រួសារណាលើកឡើងថាទឹករបស់ពួកគេត្រូវបានសំអាតដោយប្រើសារធាតុក្លរឡើយ។ អ្នកឆ្លើយតបសម្ភាស ៥៥% បានដាក់ពិន្ទុឲ្យការទទួលបានទឹកស្អាតរបស់ខ្លួនថា*អន់ជាង ឬអន់ឆ្ងាយជាង*កន្លែងដែលពួកគេរស់នៅលើកមុន។ មានតែ ២២% ប៉ុណ្ណោះ បានលើកឡើងថា ការទទួលបានទឹកស្អាតរបស់ខ្លួនបានប្រសើរជាងមុន។ នេះបង្ហាញថា បញ្ហាពាក់ព័ន្ធនឹងការទទួលបាន ទឹកនេះគឺ មានភាពស្រួចស្រាវខ្លាំង ក្នុងខេត្តកំពត ហើយពុំមានការបែងចែកធនធានគ្រប់គ្រាន់សម្រាប់ផ្តល់ទឹកស្អាតឡើយ។

<u>ពុំមានប្រព័ន្ធបញ្ចេញចោលទឹកស្អុយឡើយ</u>សម្រាប់ប្រជាពលរដ្ឋទាំងអស់ដែលបានអង្កេត ហើយពុំមានគ្រួសារតាមផ្ទះណាដែលមាន<u>បរិក្ខារអនាម័យ</u>នោះដែរ។ ប្រជាពលរដ្ឋបន្ទោរបង់ក្នុងព្រៃ ឬដីករណ្តៅ។ អ្នកឆ្លើយតប ៧២% លើកឡើងថា ពួកគេពុំមានអារម្មណ៍ថាមានសុវត្ថិភាព នៅពេលចេញទៅបន្ទោរបង់ខាងក្រៅផ្ទះឡើយ។ អ្នកឆ្លើយតប ២២% បានដាក់ពិន្ទុឲ្យស្ថានភាពអនាម័យរបស់ខ្លួនថាអន់ ឬអន់ឆ្ងាយជាងស្ថានភាពកាលពីមុន ខណៈពេល ១១% លើកឡើងថាស្ថានភាពបានប្រសើរជាងមុន។ អ្នកឆ្លើយតបដែលនៅសល់បានលើកឡើងថា ស្ថានភាពពុំមានការប្រែប្រួលឡើយ។

**ហេដ្ឋារចនាសម្ព័ន្ធ និងអគ្គិសនី៖**

ពុំមានប្រជាពលរដ្ឋដែលត្រូវបានសាកសួរណា <u>មានអគ្គិសនីប្រើប្រាស់</u>ឡើយនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ សម្គាល់៖ សំណួរនៃការអង្កេតនេះសួរពីអគ្គិសនី "ដែលរដ្ឋផ្តល់ឲ្យ" តាមរយៈការភ្ជាប់បណ្តាញមេ។ វាមិនមែនន័យថា ពុំមានម៉ាស៊ីនភ្លើង ឬប្រភពអគ្គិសនីផ្សេងទៀតនោះឡើយ។

ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះទាំងអស់ អាចភ្ជាប់បណ្តាញទូរស័ព្ទដៃបាន ហើយអ្នកឆ្លើយតប ២៦% ភ្ជាប់ទូរស័ព្ទ និងអ៊ីនធឺណិតប្រើប្រាស់។ មានអ្នកឆ្លើយតបតែ ២១% ប៉ុណ្ណោះ ដែលលើកឡើងថា <u>ការប្រើប្រាស់មធ្យោបាយធ្វើដំណើរ (បណ្តាញផ្លូវថ្នល់) និងការទំនាក់ទំនង (ទូរស័ព្ទ និងអ៊ីនធឺណិត) មានភាពល្អប្រសើរជាងមុន</u> បើប្រៀបធៀបជាមួយនឹងកន្លែងរស់នៅមុន បើទោះបីជាកំពុងតែមានការកសាងផ្លូវ នៅទីតាំងសម្បទានដីសង្គមកិច្ចនេះក៏ដោយ។ អ្នកឆ្លើយតប ៣១% និយាយថា ការប្រើប្រាស់មធ្យោបាយធ្វើដំណើរ និងទំនាក់ទំនងជារួមមានការថមថយ ចាប់តាំងពីផ្លាស់មករស់នៅកន្លែងនេះមក។

### សេវាសុខាភិបាល៖

ជាមធ្យម ប្រជាពលរដ្ឋត្រូវចំណាយពេល ៦២ នាទី ដើម្បីធ្វើដំណើរទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុត និង ១១១ នាទី ដើម្បីធ្វើដំណើរទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត។ ប្រជាពលរដ្ឋដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ៣៧% លើកឡើងថា ពួកគេមានជំងឺញឹកញាប់ជាងមុន បើប្រៀបធៀបជាមួយនឹងស្ថានភាពនៃការរស់នៅមុន។ ជំងឺគ្រុនចាញ់ ឧស្សាហ៍កើតឡើង ដូចនឹងករណីជំងឺគ្រុនឈាម និងគ្រុនពោះវៀនដែរ។ ជាពិសេស គ្រុនក្តៅ ឬផ្តាសាយ និងឈឺពោះ កើតឡើងញឹកញាប់ ។ អ្នកឆ្លើយតប ៣៧% លើកឡើងថា ការទទួលបានសេវាសុខភាព*អន់ថយ*ជាងមុន បើប្រៀបធៀបជាមួយនឹងស្ថានភាពនៅកន្លែងរស់នៅមុន ហើយ ៧% លើកឡើងថាអន់ជាងមុន។ មានអ្នកឆ្លើយតបតែ ២០% ប៉ុណ្ណោះ ដែលបាននិយាយថា ស្ថានភាពនៅទីតាំងសម្បទាន ដីសង្គមកិច្ចថ្មីនេះបានល្អប្រសើរជាងមុន។

### ការអប់រំ៖

ពុំមានសាលាមធ្យមសិក្សានៅតំបន់នេះឡើយ។ កុមារត្រូវធ្វើដំណើរតាមម៉ូតូឌុបជាមធ្យម ៦៤ នាទី ដើម្បីទៅដល់សាលាមធ្យមសិក្សាដែលនៅជិតបំផុត។ អ្នកឆ្លើយតប ៧៥% លើកឡើងថា មានសាលាបឋមសិក្សាមួយកន្លែងនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ។ កុមារត្រូវធ្វើដំណើរតាមម៉ូតូឌុបជាមធ្យម ១៥ នាទី ដើម្បីទៅដល់សាលាបឋមសិក្សាដែលនៅជិតបំផុត។ អ្នកឆ្លើយតប ៣៥% បានលើកឡើងថា យ៉ាងហោចណាស់ មានកុមារដល់វ័យចូលរៀនមួយចំនួន (អាយុចន្លោះពី ៦ឆ្នាំ ដល់ ១៧ ឆ្នាំ) ក្នុងផ្ទះរបស់ពួកគេ *ពុំបានទៅរៀន* នៅសាលាឡើយ ដែលនេះជាចំណុចដែលធ្វើឲ្យមានការព្រួយបារម្ភខ្លាំង។ ពួកគេបានលើកឡើងពីមូលហេតុច្រើនយ៉ាង ដូចជា លទ្ធភាពចំណាយ ដោយសារតែត្រូវការ ឲ្យកូននៅផ្ទះ និងដោយសារតែសាលារៀននៅឆ្ងាយពេក។ អ្នកឆ្លើយតប ៩១% និយាយថា បច្ចុប្បន្ននេះ កូនៗពួកគេតិចជាងមុនបានទៅរៀន ចាប់តាំងពីផ្លាស់មកទីតាំងសម្បទានដីសង្គមកិច្ចនេះមក ដែលនេះក៏ជាបញ្ហាមួយធំ និងជាបរាជ័យធំដ៏មួយនៃការរៀបចំផែនការកម្មវិធីសម្បទានដីសង្គមកិច្ច។ ជាមធ្យម មានគ្រួសារប្រមាណជា ៥៤% មានគម្រោងចង់ឲ្យកូនប្រុសទទួលបានការអប់រំ*យ៉ាងហោចណាស់* ១២ ឆ្នាំ ប៉ុន្តែតួលេខនេះថយចុះមកនៅ ៣៧% សម្រាប់កូនស្រី ដែលបង្ហាញថា <u>ការរើសអើងយេនឌ័រគឺជាបញ្ហាមួយ ក្នុងការទទួលបានការអប់រំ</u>។ ជាសម្គាល់ នេះមិនមែនជាការបង្ហាញថាតើមានការផ្តល់ការអប់រំជាក់ស្តែងកម្រិតណានោះទេ ច្រើនតែជាការឆ្លុះបញ្ចាំងពីបំណងរបស់គ្រួសារតាមផ្ទះទាំងនោះ និងសារៈសំខាន់ដែលទាក់ទងជាប់ទៅនឹងការអប់រំ។

នៅពេលឲ្យដាក់ពិន្ទុលើការទទួលបានការអប់រំនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ មានអ្នកឆ្លើយតបតែ ១៧% ប៉ុណ្ណោះ ដែលលើកឡើងថា ការអប់រំមានភាពល្អប្រសើរជាងមុន។ ផ្ទុយទៅវិញ ៥២% បានលើកឡើងថា ការទទួលបានការអប់រំធ្លាក់ចុះជាងមុន។

## សន្តិសុខស្បៀង៖

អ្នកឆ្លើយតប ៩៦% និយាយថា កាលពីខែមុននេះ យ៉ាងហោចណាស់ក៏មានម្តងដែរ ដែលពួកគេមានការព្រួយបារម្ភថា ពួកគេនឹងពុំអាចផ្តល់អាហារគ្រប់គ្រាន់ដល់គ្រួសារខ្លួន ដោយ ៥៥% លើកឡើងថា នេះជាការភ័យព្រួយដែលកើតមានជាប្រចាំ។ គ្រួសារ ៥៤%

លើកឡើងថា ពួកគេត្រូវកំហិតអាហារដែលត្រូវញុំា (ដូចជា ពុំមានសាច់ ឬត្រី ជាដើម) នៅពេលណាមួយ ក្នុងខែមុននេះ ដោយសារតែខ្វះលុយ ហើយ ៨៥% ត្រូវបង្ខំចិត្តបរិភោគមើមរុក្ខជាតិដុះក្នុងព្រៃ ឬសាច់ដែលមានគុណភាពអន់ខ្លាំង ដោយសារតែមូលហេតុដូចគ្នានេះ។ អ្នកឆ្លើយតប ៤៨% លើកឡើងថា ពួកគេធ្លាប់ដាច់បាយ កាលពីខែមុននេះ និងមានអ្នកឆ្លើយតប ៤១% បានលើកឡើងថា <u>មានថ្ងៃខ្លះ កាលពីខែមុននេះ ដែលពួកគេពុំមានអាហារបរិភោគតែម្តង</u> ដោយសារតែពុំមានលុយទិញអាហារ និងពុំអាចរកអាហារបានពីដីរបស់ពួកគេ។ ការទទួលបានអាហារក្នុងតម្លៃសមរម្យ និងបញ្ហាខ្វះអាហារ មានភាពស្រួចស្រាវជាពិសេស ក្នុងខេត្តកំពត។ បើទោះបីជាមានបញ្ហាបែបនេះក៏ដោយ មានគ្រួសារតាមផ្ទះតែ ៣១% លើកឡើងថា ការទទួលបានអាហារបានថមថយជាងមុន ចាប់តាំងពីពេលដែលពួកគេផ្លាស់មកនៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ហើយសម្រាប់គ្រួសារ ៤១% ស្ថានភាពបានល្អប្រសើរជាងមុន។ អាហារូបត្ថម្ភទំនងជាបញ្ហាធំមួយ សម្រាប់គ្រួសារតាមផ្ទះដែលរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ជាពិសេស សម្រាប់កុមារដែលខ្វះអាហារសារជាតិប្រូតេអ៊ីន និងនៅកន្លែងដែលគ្រួសារមិនអាចកាប់ឆ្ការដីធ្វើកសិកម្មបាន។

**ការងារៈ**

គ្រួសារតាមផ្ទះដែលត្រូវបានសាកសួរស្ទើរតែទាំងអស់(៩៩%) មានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់មានការងារធ្វើ ហើយខ្នងផ្ទះ ៥៨% មានមនុស្ស ២ ឬ ៣ នាក់ មានការងារធ្វើ ដោយខ្នងផ្ទះខ្លះមានសមាជិករហូតដល់ ៥ នាក់ មានការងារធ្វើ។ ជាការឆ្លើយតបចំពោះសំណួរដែលសួរថាតើការងារប្រភេទណាខ្លះដែលពួកគេធ្វើ ៥៦% ស៊ីឈ្នួលធ្វើកសិកម្មឲ្យគេ ៧៩% ធ្វើការងារប្រភេទប្រើប្រាស់កម្លាំងពលកម្មផ្សេងទៀត ហើយ ៤០% មានមុខរបរខ្លួនឯង។ ចំណូលមធ្យមប្រចាំខែរបស់គ្រួសារ ដែលបានពីការងារផ្សេងៗគឺ ៣៩២ ដុល្លារ ក្នុងមួយខែ។ ចំណូលភាគច្រើនបានមកពីការងារស៊ីឈ្នួលគេ/ការងារតាមរោងចក្រ និងមុខរបរខ្លួនឯង តាមរយៈការលក់ផលិតផលដោយផ្ទាល់។ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ចំណូលមធ្យមប្រចាំខែរបស់អ្នកឆ្លើយតបគឺទាបជាង ២០៤ ដុល្លារ ក្នុងមួយខ្នងផ្ទះ។ ចំណាយគិតជាមធ្យមបច្ចុប្បន្នរបស់គ្រួសារតាមផ្ទះគឺ ២៦២

ដុល្លារ ក្នុងមួយខែ កើនឡើងពី ១៥៧ ដុល្លារ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ ចំណាយភាគច្រើន គឺលើអាហារ និងការថែទាំសុខភាព។ ចំណូលមធ្យមប្រចាំខែមានការកើនឡើង ដូចគ្នានឹងចំណាយប្រចាំថ្ងៃរបស់គ្រួសារដែរ។

គ្រួសារតិចជាងមួយភាគបីមានប្រាក់សន្សំសម្រាប់គ្រួសារ (២៤%) បើទោះបីជា ជាមធ្យម ប្រាក់សន្សំមានការកើនឡើង ចាប់តាំងពីពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ ហើយតួលេខជាមធ្យមបច្ចុប្បន្នគឺ ៨៤ដុល្លារ។ គ្រួសារ ៨៧% ជាប់បំណុលគេ ហើយកម្រិតបំណុលមានការកើនឡើងខ្លាំង។ ជាមធ្យមគ្រួសារតាម ផ្ទះជំពាក់បំណុលគេ ៤៥០ ដុល្លារ ដែលកើនឡើងពី ៥៧ ដុល្លារ មុនពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។ នេះមានន័យថា គ្រួសារតាមផ្ទះទាំងនេះ ត្រូវខ្ចីបុលគេយ៉ាងច្រើន នៅពេលកំពុងផ្លាស់ ឬក្រោយពេលផ្លាស់មកនៅទីតាំងសម្បទានដីសង្គមកិច្ចនេះ។

ជាសូចនាករបង្ហាញពីទ្រព្យធន មានគ្រួសារតែ ១៣% ប៉ុណ្ណោះ ដែលមានទូរទស្សន៍ជាកម្មសិទ្ធិ ហើយ ៤១% មានម៉ូតូជាកម្មសិទ្ធិ។ ៧៨% មានទូរស័ព្ទដៃជាកម្មសិទ្ធិ។

ក្នុងគ្រួសារតាមផ្ទះប្រមាណជាពាក់កណ្តាល (៥៧%) សមាជិកគ្រួសារទាំងអស់រស់នៅជុំគ្នាលើទីតាំងសម្បទានដីសង្គមកិច្ចនេះជាអចិន្ត្រៃយ៍។ សមាជិកគ្រួសារភាគច្រើនដែលរស់នៅឆ្ងាយពីទីតាំងនេះ គឺកូន (៦០%) របស់អ្នកឆ្លើយតបចំពោះការអង្កេតនេះ ដែលនេះបង្ហាញថាក្មេងៗជំនាន់ថ្មីជាច្រើន ធ្វើចំណាកស្រុកឆ្ងាយពីផ្ទះដែលគ្រួសាររបស់ពួកគេរស់នៅដើម្បីរកការងារធ្វើ (៨៥%)។

**រចនាសម្ព័ន្ធផ្នែកសង្គម៖**

ក្នុងចំណោមគ្រួសារតាមផ្ទះដែលបានសម្ភាសទាំងអស់ មានតែ ២% ប៉ុណ្ណោះ ដែលជឿថា <u>ការសម្រេចចិត្តរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចនេះ</u>ធ្វើឡើងតាមរយៈដំណើរការប្រជាធិបតេយ្យ ដោយ ៦១% លើកឡើងថា មេភូមិគឺជាអ្នកសម្រេចចិត្ត។

អ្នកឆ្លើយតប ៦៥% លើកឡើងថា ពួកគេមានអារម្មណ៍តានតឹង (ស្ត្រេស) ដោយ ២៩% រាយការណ៍ថា បញ្ហាអារម្មណ៍តានតឹងនេះមានភាពស្រួចស្រាវ។ បញ្ហានេះកើតឡើង ដោយសារការខ្វះខាតអាហារ និងចំណូលទាប។

អ្នកឆ្លើយតបទាំងអស់លើកឡើងថា ពួកគេដឹងថាមានការប្រើបំពានគ្រឿងស្រវឹង ក្នុងសហគមន៍នេះ និង ៩% ទៀត ជឿថាមានបញ្ហាគ្រឿងញៀន នៅទីតាំងសម្បទានដី សង្គមកិច្ចនេះ។ មានគ្រួសារតាមផ្ទះចំនួនតែ ១ប៉ុណ្ណោះ ដែលរាយការណ៍ថា ពួកគេ បាន កំពុងធ្វើការងារជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងចំណោមគ្រួសារតាមផ្ទះដែល ត្រូវបានអង្កេត មាន ៣៧% គិតថា មានបទល្មើសឧក្រិដ្ឋកើតឡើងច្រើនក្នុងសហគមន៍នេះ ទេ បើប្រៀបធៀបជាមួយនឹងស្ថានភាពមុនពេលដែលពួកគេផ្លាស់មកទីតាំងសម្បទានដី សង្គមកិច្ចនេះ។ មានអ្នកឆ្លើយតប ៤៥% អះអាង ថាខ្លួនបានដឹងពីករណីអំពើហិង្សាលើស្ត្រី ឬក្មេងស្រី ហើយ ២៨% ជឿថា ហិង្សាផ្លូវភេទមានអត្រាកើតឡើងច្រើនជាងនៅសហគមន៍ មុនៗរបស់ពួកគេ។ ការរក ឃើញទាំងនេះ មិនផ្តល់នូវការគណនាច្បាស់លាស់នៃអត្រា ទូទៅនៃហិង្សាផ្លូវភេទ ឬការរំលោភបំពានដោយសារគ្រឿង ស្រវឹងនោះទេ។ ការរកឃើញ ទាំងនេះ ជាការឆ្លុះបញ្ចាំងពីគំនិតយោបល់របស់សហគមន៍តែប៉ុណ្ណោះ ហើយ គេត្រូវតែ អានយល់ដូចនេះ ជាមួយការយល់ដឹងថា ក្រុមអង្កេតនេះ មិនបានសួរដោយផ្ទាល់ទេ ឧទាហរណ៍៖ ថាតើ ការរំលោភបំពានកើតឡើយដោយគ្រឿងស្រវឹងជាបញ្ហាមួយនៅក្នុង ខ្នងផ្ទះមួយឬទេ។

អ្នកឆ្លើយតប ៨០% បាននិយាយថា ពួកគេដឹងពីករណីកុមារធ្វើការងារ ដើម្បីរក ចំណូលបន្ថែមឲ្យគ្រួសារ។ ការងារភាគច្រើនដែលកុមារធ្វើ គឺការងារកសិកម្ម (៧០%) និង ប្រភេទការងារប្រើកម្លាំងពលកម្មផ្សេងទៀត (៦២%)។ មានគ្រួសារតាមផ្ទះចំនួន ៥ បញ្ជូន សមាជិកគ្រួសារជាកុមារទៅធ្វើការងារតាមរោងចក្រ។

ប្រជាពលរដ្ឋរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចនេះ ៥៥% ដោយចោទថា ពួកគេ *មិន*ត្រូវបាន គេចុះឈ្មោះបោះឆ្នោតឲ្យឡើយ។ តួលេខនេះកើនខ្ពស់ ដោយគ្មាន

សមាមាត្រទេ ដោយហេតុថា គ្រួសារតាមផ្ទះ ជាមធ្យម បានតាំងនៅទីនោះអស់រយៈពេលជិត ៥ឆ្នាំ ហើយការបោះឆ្នោតឃុំខិតជិតនឹងមកដល់ក្នុងឆ្នាំ ២០១៧ នេះហើយ។

គ្រួសារតាមផ្ទះ ៦១% នៅខ្វះឯកសារស្នាក់នៅដែលពាក់ព័ន្ធ ផ្តល់ដោយអាជ្ញាធរមូលដ្ឋាន ហើយក្នុងចំនោមខ្នងផ្ទះ ៧៦% យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ដែលពុំមានសំបុត្រកំណើត ហើយក្នុងខ្នងផ្ទះ ៥២% មានសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់ ដែលពុំមានអត្តសញ្ញាណប័ណ្ណ។ គ្រួសារ ១៧% ពុំមានសៀវភៅគ្រួសារ។

មានប្រជាពលរដ្ឋតែ ២ គ្រួសារប៉ុណ្ណោះ (៤%) បាននិយាយថា ពួកគេពិចារណាចាកចេញពីទីតាំងសម្បទានដីសង្គមកិច្ចនេះ ដោយសារតែបញ្ហាកង្វះទឹក អាហារ និងបញ្ហាប្រឈមផ្សេងទៀតក្នុងតំបន់នេះ ជាតួលេខមួយ ទាបគួរឲ្យកត់សម្គាល់។ សំណូមពរជុំវិញការលើកកម្ពស់កម្រិតជីវភាពរស់នៅ នៅទីតាំងសម្បទានដីសង្គមកិច្ចនេះ បានផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវ (៥៦%) ការទទួលបានទឹកស្អាត (៨០%) ការសាងសង់សាលាមធ្យមសិក្សាលើទីតាំងសម្បទានដីសង្គមកិច្ចនេះ (៧៦%) និងការកែលំអការផ្តល់បរិក្ខារថែទាំសុខភាព (៨០%) ប៉ុន្តែក៏មានការលើកឡើងសំណូមពរទាក់ទងនឹងបញ្ហាជាច្រើនផ្សេងទៀតផងដែរ ដូចជាលំនៅឋាន អគ្គិសនី ការងារ និងការផ្តល់បង្គន់អនាម័យជាដើមផងដែរ។